# ព្រះរាជាណាចក្រកម្ពុជា

## ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

GREEN
CLIMATE
FUND



ខែធ្នូ ឆ្នាំ២០២០

# សៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិ

## របស់ស្ថាប័នជាតិទទួលបន្ទុកនៃប្រទេសកម្ពុជា
## សម្រាប់មូលនិធិអាកាសធាតុបៃតង

## មាតិកា

បុព្វកថា ......03

បញ្ជីអក្សរកាត់......05

បញ្ជីរូបភាព......08

បញ្ជីតារាង......08

ជំពូកទី១ ៖ សេចក្តីផ្តើម......14

ជំពូកទី២ ៖ ទិសដៅអភិវឌ្ឍន៍ជាតិ ......22

ជំពូកទី៣ ៖ ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ......30

ជំពូកទី៤ ៖ ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ ......37

ជំពូកទី៥ ៖ ក្របខ័ណ្ឌស្ថាប័ននិងក្របខ័ណ្ឌហិរញ្ញវត្ថុជាតិ ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ ......60

ជំពូកទី៦ ៖ ស្ថាប័នជាតិទទួលបន្ទុក (NDA)......72

ជំពូកទី៧ ៖ និតិវិធីផ្តល់សេចក្តីទុកចិត្ត និងការឧទ្ទេសនាមស្ថាប័នទទួលមូលនិធិផ្ទាល់......83

ជំពូកទី៨៖ ស្ថាប័នប្រតិបត្តិ......97

ជំពូកទី ៩៖ ដំណើរការអនុម័តសំណើគម្រោងរបស់ GCF និងការរៀបចំឯកសារទស្សនទាន និងសំណើថវិកាប្រកបដោយគុណភាពខ្ពស់ ......99

ជំពូកទី ១០: នីតិវិធីចេញលិខិតគាំទ្រក្នុងការវាយតម្លៃនិងអនុម័តឯកសារទស្សនទាន និងសំណើថវិកា ......117

ជំពូកទី ១១៖ ការតាមដាន និងការវាយតំលៃការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានអាកាសធាតុ......137

ឧបសម្ព័ន្ធ......140

ឧបសម្ព័ន្ធ១៖ សទ្ទានុក្រម......140

ឧបសម្ព័ន្ធ ២ ៖ វិធានការមានសក្តានុពលសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើផែនទីបង្ហាញផ្លូវ NDC, ព្រមទាំងគម្រោង CDM និង JCM....145

ឧបសម្ព័ន្ធ ៣ ៖ គោលការណ៍ណែនាំរបស់ GCF ស្តីពីវិធីសាស្រ្តវាយតម្លៃផ្តល់សេចក្តីទុកចិត្តសម្រាប់គោលបំណងជាក់លាក់ (Fit-For-Purpose Accreditation Approach) ..151

**ឧបសម្ព័ន្ធទី ៤៖ លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់កម្មវិធី / គម្រោងដែលត្រូវបានផ្តល់មូលនិធិ និងលក្ខណៈវិនិច្ឆ័យនៃការសម្រេចចិត្តសកម្មភាពជាក់លាក់របស់មូលនិធិ** ........ 164
**ឧបសម្ព័ន្ធទី ៥៖ សុវត្ថិភាពបរិស្ថាន និងសង្គមរបស់មូលនិធិអាកាសធាតុបៃតង និងគម្រូវការយេនឌ័រ** ........ 174
**ឧបសម្ព័ន្ធ ៦៖ គោលនយោបាយយេនឌ័ររបស់មូលនិធិអាកាសធាតុបៃតង** ........ 177
**ឧបសម្ព័ន្ធ ៧៖ ឯកសារយោង និងតំណភ្ជាប់សំខាន់ៗ** ........ 179

..........................................................................................

## បុព្វកថា

ប្រទេសកម្ពុជាជាប្រទេសដែលងាយរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ហើយងាយប្រឈមនឹងគ្រោះទឹកជំនន់ញឹកញាប់ និងភ្លៀងធ្លាក់ដែលមិនអាចទាយទុកជាមុនបាន ក៏ដូចជាព្យុះត្រូពិច និងការកើនឡើងកម្ពស់ទឹកសមុទ្រ

ព្រមទាំងមានសមត្ថភាពបន្សាំទាប។ លើសពីនេះទៀត មួយភាគ ធំនៃប្រជាជនកម្ពុជារស់នៅពឹងផ្អែកលើវិស័យកសិកម្ម និងធនធានធម្មជាតិសម្រាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគេ ហើយមានប្រភពចំណូលផ្សេងតិចតួច ។

ការឆ្លើយតបរបស់រាជរដ្ឋាភិបាលចំពោះការប្រែប្រួលអាកាសធាតុមានដូចជា ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ យុទ្ធសាស្ត្រតាមវិស័យត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ រីឯក្របខ័ណ្ឌរួមរបស់ផែនការទាំងនេះ គឺមានផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ ២០១៤-២០២៣ ដែលមានគោលបំណងយុទ្ធសាស្ត្រចំនួន៨ និងយុទ្ធសាស្ត្រចំនួន៦១។ គោលបំណងចំនួនបីក្នុងចំណោមគោលបំណងទាំងអស់ គឺផ្តោតលើការលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ គោលបំណងចំនួនមួយផ្តោតលើការលើកកម្ពស់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ហើយគោលបំណងចំនួនបួន ផ្តោតលើការពង្រឹងស្ថាប័ន តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព ការចូលរួម និងការសហការជាដើម។

ការគាំទ្រដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និងហិរញ្ញវត្ថុ គឺពិតជាមានសារៈសំខាន់និងចាំបាច់បំផុត ដើម្បីអនុញ្ញាតឱ្យប្រទេសកំពុងអភិវឌ្ឍន៍អនុវត្តការចូលរួមចំណែកជាតិ (NDC) ប្រកបដោយប្រសិទ្ធភាព។ ក្នុងនាមជាអង្គភាពអនុវត្តសំខាន់មួយនៅក្រោមអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (UNFCCC) មូលនិធិអាកាសធាតុបៃតង (GCF) ត្រូវបានព្យាករណ៍ថានឹងទទួលបានថវិកាប្រមាណ ១០០ ពាន់លានដុល្លារក្នុងមួយឆ្នាំ។ មូលនិធិនេះត្រូវបានចាត់ទុកជាយន្តការសំខាន់សម្រាប់ការអនុវត្តផែនការសកម្មភាពអាកាសធាតុជាតិ និងជាយន្តការដើម្បីសម្រេចគោលដៅរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (UNFCCC) និងកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថាមូលនិធិនេះ ជាប្រភពនៃការគាំទ្រថវិកា និងបានចាប់ផ្តើមជំរុញភាគីពាក់ព័ន្ធថ្នាក់ជាតិ ឱ្យបង្កើនសមត្ថភាពរបស់ស្ថាប័ន។ ការគាំទ្រដែលត្រូវការចាំបាច់រួមមានការកសាង សមត្ថភាព ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា និងធនធានហិរញ្ញវត្ថុ ដើម្បីអនុវត្តសកម្មភាពបន្សាំ និងសកម្មភាពកាត់បន្ថយ ដើម្បីឈានទៅរកមាគ៌ាអភិវឌ្ឍដែលមានភាពធន់នឹងអាកាសធាតុ បញ្ចេញកាបូនតិច និងសមធម៌។ ប្រទេសកម្ពុជាសូមស្វាគមន៍ចំពោះការគាំទ្រពីសហគមន៍អន្តរជាតិដើម្បីលើកកម្ពស់ភាពធន់របស់ប្រជាជន និងដើម្បីកាត់បន្ថយភាពងាយរងគ្រោះខ្ពស់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ក្នុងនាមជាសមាជិកក្នុងវេទិកាភាពងាយរងគ្រោះនៃអាកាសធាតុ កម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងខ្លាំងដើម្បីសម្រេចគោលដៅរបស់ខ្លួន ហើយគួបផ្សំជាមួយនឹងការទទួលបានការគាំទ្រចាំបាច់នានា កម្ពុជានឹងអាចសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពទី១៣ ស្តីពីការប្រែប្រួលអាកាសធាតុ។ យើងត្រូវធ្វើការរួមគ្នា

ដើម្បីបញ្ចៀសការខូចខាត និងការបំផ្លិចបំផ្លាញដែលមិនអាចវិលវិញបាននៃភពផែនដីរបស់យើង ហើយ យើងត្រូវខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីជៀសវាងការឈានដល់ចំណុចគ្រោះថ្នាក់បំផុតទៅលើភពផែនដី។

សៀវភៅណែនាំនេះត្រូវបានបង្កើតឡើងដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិ របស់មូលនិធិអាកាសធាតុបៃតង។ សៀវភៅនេះ បានដាក់បញ្ចូលមតិយោបល់នានាពីកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាជាច្រើនលើកទាំងកម្រិតបច្ចេកទេសនិងកម្រិតថ្នាក់ដឹកនាំ ជាមួយក្រសួងពាក់ព័ន្ធ ក៏ដូចជាដៃគូអភិវឌ្ឍន៍ វិទ្យាស្ថានស្រាវជ្រាវ គ្រឹះស្ថានសិក្សា និងស្ថាប័នពាក់ព័ន្ធទាំងអស់។ ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធទាំងអស់ដែលបានចូលរួមចំណែកសហការផ្តល់មតិយោបល់ដើម្បីធ្វើឱ្យសៀវភៅណែនាំនេះលេចចេញរូបរាងឡើងប្រកបដោយជោគជ័យ។

**ឯកឧត្តម សាយ សំអាល់**
រដ្ឋមន្រ្តីក្រសួងបរិស្ថាន
ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## បញ្ជីពាក្យកាត់

| | |
|---|---|
| AE | ស្ថាប័នទទួលសេចក្តីទុកចិត្ត |
| AFD | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| BaU | ការប្រព្រឹត្តទៅតាមទម្លាប់ |
| BUR | របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង |
| CB | ការកសាងសមត្ថភាព |
| CBO | អង្គការមានមូលដ្ឋានក្នុងសហគមន៍ |
| CC | ការប្រែប្រួលអាកាសធាតុ |
| CCAP | ផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុ |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| CCFF | ក្របខ័ណ្ឌហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDM | យន្តការអភិវឌ្ឍន៍ស្អាត |
| CF | ហិរញ្ញប្បទានអាកាសធាតុ |
| CN | ឯកសារទស្សនទាន |
| COP | សន្និសីទបណ្តាភាគី |
| CPEIR | របាយការណ៍ត្រួតពិនិត្យការចំណាយសាធារណៈលើការប្រែប្រួលអាកាសធាតុ |
| CSO | អង្គការសង្គមស៊ីវិល |
| DAE | ស្ថាប័នទទួលមូលនិធិផ្ទាល់ |
| DCC | នាយកដ្ឋានប្រែប្រួលអាកាសធាតុ |
| EE | ស្ថាប័នប្រតិបត្តិ |
| ESS | សុវត្ថិភាពបរិស្ថាន និងសង្គម |
| FAO | អង្គការស្បៀង និងកសិកម្ម |
| FP | សំណើថវិកា |
| GCF | មូលនិធិអាកាសធាតុបៃតង |
| GCFAP | ក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង |
| GCFRP | គម្រោងត្រៀមរបស់មូលនិធិអាកាសធាតុបៃតង |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GSSD | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| IAE | ស្ថាប័នទទួលសេចក្តីទុកចិត្តអន្តរជាតិ |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| INC | របាយការណ៍ជាតិលើកទី១ |
| IP | ជនជាតិដើម |

| | |
|---|---|
| JCM | យន្តការផលទានកាបូនរួមគ្នា |
| LDC | ប្រទេសអភិវឌ្ឍន៍តិចតួច |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MME | ក្រសួងរ៉ែ និងថាមពល |
| MOE | ក្រសួងបរិស្ថាន |
| MOH | ក្រសួងសុខាភិបាល |
| MOT | ក្រសួងទេសចរណ៍ |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MRV | វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ |
| MWAs | ក្រសួងកិច្ចការនារី |
| MSME | សហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម |
| NAMAs | សកម្មភាពជាតិកាត់បន្ថយសមស្រប |
| NAP | ផែនការជាតិបន្សាំ |
| NAPAs | កម្មវិធីសកម្មភាពជាតិបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ |
| NCCC | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NDA | ស្ថាប័នជាតិទទួលបន្ទុក |
| NDC | របាយការណ៍ស្តីពីការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NOL | លិខិតគាំទ្រ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OM | សៀវភៅណែនាំ |
| PMU | អង្គភាពគ្រប់គ្រងគម្រោង |
| PPF | កម្មវិធីគាំទ្រការរៀបចំគម្រោង |
| PSF | កម្មវិធីគាំទ្ររបស់ GCF ដល់វិស័យឯកជន |
| REDD | ការកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ |

| | |
|---|---|
| R and D | ស្រាវជ្រាវ និងអភិវឌ្ឍ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RS | យុទ្ធសាស្ត្រចតុកោណ |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SDGs | គោលដៅអភិវឌ្ឍន៍ដោយចីរភាព |
| SIDS | រដ្ឋកោះតូចៗកំពុងអភិវឌ្ឍន៍ |
| SNC | របាយការណ៍ជាតិលើកទី២ |
| SOP | នីតិវិធីប្រតិបត្តិ |
| SPCR | កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ |
| TC | គណៈកម្មាធិការបច្ចេកទេស |
| ToRs | លក្ខខណ្ឌយោងការងារ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNFCCC | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| USD | ដុល្លារសហរដ្ឋអាមេរិក |
| WB | ធនាគារពិភពលោក |

## បញ្ជីរូបភាព

រូបភាពទី 1៖ សំណើក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌហិរញ្ញវត្ថុរបស់កម្ពុជា ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុទ្វេភាគី តំបន់ និងអន្តរជាតិ (ឧទាហរណ៍៖ មូលនិធិអាកាធាតុបៃតង) ដើម្បីពង្រីកវិសាលភាពនៃសកម្មភាពបន្សុំ និងការកាត់បន្ថយ ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអាកាសធាតុជាតិ។ ..... 19
រូបភាពទី 2 ៖ តារាងព្រឹត្តិការណ៍នៅកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩១ ..... 22
រូបភាពទី 3៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ..... 23
រូបភាពទី 4៖ វិស័យអាទិភាពទាំង ៨ របស់មូលនិធិអាកាសធាតុបៃតងស្តីពីការបន្សុំនិងការកាត់បន្ថយ ..... 34
រូបភាពទី 5៖ ទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ ..... 35
រូបភាពទី 6៖ ទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ និងបរិមាណថវិកា ..... 36
រូបភាពទី 7៖ ដំណើរការអភិវឌ្ឍន៍កម្មវិធីប្រចាំប្រទេស ដែលស្នើសុំថវិកាពីមូលនិធិGCF ..... 56
រូបភាពទី 8៖ នីតិវិធីបច្ចុប្បន្នដើម្បីវាយតម្លៃ និងអនុម័តលើឯកសារទស្សនទាន និងសំណើថវិកា ..... 64
រូបភាពទី 9៖ ប្រកចូលសម្រាប់ NDA ដើម្បីចូលរួមជាមួយ GCF និងភាគីពាក់ព័ន្ធសំខាន់ៗ ..... 66
រូបភាពទី 10៖ ក្របខ័ណ្ឌស្ថាប័ន និងហិរញ្ញវត្ថុដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញវត្ថុអាកាសធាតុទ្វេភាគី និងអន្តរជាតិ (ដូចជា *GCF)* ដើម្បីបង្កើនដំណោះស្រាយអាកាសធាតុនៅកម្ពុជាដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ និងគោលដៅអាកាសធាតុ។67
រូបភាពទី 11៖ និតិវិធីចេញលិខិតឧទ្ទេសនាម និងផ្តល់សេចក្តីទុកចិត្តដល់ស្ថាប័នទទួលមូលនិធិផ្ទាល់ ..... 90
រូបភាពទី 12៖ ដំណើរការអនុម័តសំណើគម្រោងរបស់ GCF ..... 100
រូបភាពទី 13: លក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់ GCF ..... 104
រូបភាពទី 14: និតិវិធីចេញលិខិតគាំទ្រលើការវាយតម្លៃ និងអនុម័តឯកសារទស្សនទាន ..... 121
រូបភាពទី 15៖ និតិវិធីចេញលិខិតគាំទ្រសម្រាប់ការវាយតម្លៃ និងអនុម័តសំណើថវិកា ..... 123
រូបភាពទី 16: សេចក្តីសង្ខេបនៃនីតិវិធីចេញលិខិតគាំទ្រ និងវដ្តគម្រោង GCF សម្រាប់ប្រទេសកម្ពុជាជាមួយនឹងរយៈពេលដែលត្រូវស្នើសុំ ..... 126
រូបភាពទី 17: ក្របខ័ណ្ឌសម្រាប់ធ្វើការត្រួតពិនិត្យពាក់កណ្តាលគម្រោង និងបញ្ចប់គម្រោង ..... 139

.....................................................................................................

## បញ្ជីតារាង

តារាងទី 1៖ ស្ថាប័នពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុជាតិនៅកម្ពុជា ..... 41
តារាងទី 2៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការ GCF ..... 48
តារាងទី 3៖ សង្ខេបអំពីតួនាទី និងភារកិច្ចរបស់ស្ថាប័នសំខាន់ៗ ..... 62
តារាងទី 4៖ សមាជិក GCFAP ដែលនឹងមានជំនាញស្របតាមវិស័យអាទិភាពទាំង៨ របស់ GCF ..... 69
តារាងទី 5៖ តួនាទីនិងទំនួលខុសត្រូវរបស់អាជ្ញាធរជាតិ *NDA* ដោយផ្អែកលើសៀវភៅណែនាំរបស់មូលនិធិ *GCF* ..... 73
តារាងទី 6៖ ស្ថានភាពរបស់ស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ព្រមទាំងទំនាក់ទំនងជាមួយ បណ្តាដៃគូសាធារណៈ ឯកជន និងសង្គមស៊ីវិល ..... 84
តារាងទី 7៖ និតិវិធីចេញលិខិតគាំទ្រ សម្រាប់ការវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា។ ដំណាក់កាលនីមួយៗត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៤ និង ១៥ ។ ..... 123
តារាងទី 8៖លក្ខណៈវិនិច្ឆ័យសក្តានុពលសម្រាប់ជ្រើសរើសសំណើគម្រោង ..... 127
តារាងទី 9៖ ក្របខ័ណ្ឌលទ្ធផលគម្រោង ..... 138
តារាងទី 10៖សក្តានុពលនៃការកាត់បន្ថយ ស្របជាមួយនឹងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (CCAPs) និងវឌ្ឍនភាពការងារ ..... 145

តារាងទី  11៖ បញ្ជីគម្រោង CDM នៅក្នុងប្រទេសកម្ពុជា....................................................................................147
តារាងទី 12៖បញ្ជីគម្រោងឥណទានកាបូនរួមគ្នា..............................................................................................149

## សេចក្តីសង្ខេប

ការដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុត្រូវការធនធានហិរញ្ញវត្ថុយ៉ាងក្រាស់ក្រែល។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលការគាំទ្រដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង (GCF) ដើម្បីបង្កើតនីតិវិធី និងបង្កើនសមត្ថភាពមនុស្សដែលត្រូវមានជាចាំបាច់ សម្រាប់គ្រប់គ្រងអោយបានគ្រប់ជ្រុងជ្រោយនូវភាពជាដៃគូជាមួយមូលនិធិអាកាសធាតុបៃតង និងសម្របសម្រួលជាតុចូលពីភាគីពាក់ព័ន្ធនានា។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) កំពុងគាំទ្រដល់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង (NDA) នៅប្រទេសកម្ពុជា ក្នុងការសម្របសម្រួល និងអនុម័តគម្រោង/កម្មវិធីនានារបស់មូលនិធិអាកាសធាតុបៃតងនៅក្នុងប្រទេស។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព កំពុងសម្របសម្រួល លើការអនុវត្តសកម្មភាពគម្រោងត្រៀម ដែលនឹងជួយដល់រាជរដ្ឋាភិបាល គ្រប់គ្រងតម្រូវការទាំងអស់នេះ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងការបន្សុីជាមួយផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ឧទាហរណ៍៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និង គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការប្រែប្រួលអាកាសធាតុ (ដូចជា CCCSP) ព្រមទាំងមានភាពសមស្របជាមួយលក្ខខណ្ឌតម្រូវនៃវិធានប្រតិបត្តិ និងក្របខ័ណ្ឌវិនិយោគរបស់មូលនិធិអាកាសធាតុបៃតង។

ដើម្បីទទួលបាន(រៀបចំ វាយតម្លៃ និងអនុម័ត) និងប្រើប្រាស់នូវ (អនុវត្ត តាមដាន វាយតម្លៃ និងបញ្ចប់គម្រោង) ធនធានរបស់មូលនិធិអាកាសធាតុបៃតង និងអនុញ្ញាតឱ្យស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានជាមន្ត្រីបង្គោល បំពេញភារកិច្ចរបស់ខ្លួនដោយរលូន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នាយកដ្ឋានប្រែប្រួលអាកាសធាតុ កំពុងរៀបរៀងសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិ ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញវត្ថុរបស់មូលនិធិអាកាសធាតុបៃតង។

គោលបំណងសំខាន់ៗនៃសៀវភៅណែនាំមានដូចខាងក្រោម៖

- ដើម្បីយល់អំពីយន្តការហិរញ្ញប្បទានអាកាសធាតុទ្វេភាគី ក្នុងតំបន់ និងអន្តរជាតិ ពោលគឺការទទួលបាន ការកៀរគរ ការអនុវត្ត ការតាមដាន ការវាយតម្លៃ ការពង្រីក និងការអនុវត្តគម្រូល្អៗនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ឧទាហរណ៍៖ នៅក្នុងកម្មវិធីប្រចាំប្រទេសមូលធិនិអាកាសធាតុបៃតង) ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ និងគោលដៅអាកាសធាតុ ដូចមានបង្ហាញក្នុងរូបភាពទី ១
- ដើម្បីកំណត់ឱ្យច្បាស់លាស់នូវតួនាទី និងភារកិច្ចរបស់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង និងស្ថាប័នពាក់ព័ន្ធ (ស្ថាប័នប្រតិបត្តិជាតិ និងអន្តរជាតិដែលទទួលបានសេចក្តីទុកចិត្តអង្គភាពសាធារណៈ ឯកជន និងដៃគូសង្គមស៊ីវិល) នៅក្នុងដំណើរការអភិវឌ្ឍជាតិ និងដំណើរការរបស់ហិរញ្ញប្បទានអាកាសធាតុ (ឧទាហរណ៍៖ មូលនិធិអាកាសធាតុបៃតង)
- ដើម្បីបង្កើតយន្តការ សម្របសម្រួល និងទំនាក់ទំនង ដែលជួយស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង ក្នុងលើកទឹកចិត្តឱ្យមានការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងមូលនិធិអាកាសធាតុ

- ដើម្បីយល់ពីវិធីក្នុងការកំណត់ និងបំប្លែងគំនិតគម្រោងទៅជា ឯកសារទស្សនៈទាន និងសំណើរថវិកាដែលមានគុណភាព និងការប្រកួតប្រជែងខ្ពស់ ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់មូលនិធិអាកាសាធាតុបៃតង
- ដើម្បីបញ្ជាក់ឱ្យកាន់តែលម្អិតពីវិធីវាយតម្លៃ និងអនុម័ត ឯកសារទស្សនៈទាន និងសំណើរថវិកាប្រកបដោយសមភាព និងតម្លាភាព ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងបរិធានធ្វើសេចក្តីសម្រេចចិត្ត (ពហុលក្ខណៈវិនិច្ឆ័យ និងវិភាគថ្លៃដើម និងចំណេញ) ក្នុងដំណើរការផ្តល់លិខិតយល់ព្រម
- ស្វែងយល់ពីវិធីវាយតម្លៃ និងអនុម័តលើ អង្គភាពសាធារណៈ ឯកជន និងសង្គមស៊ីវិលដែលចង់បានការទទួលស្គាល់ជាអង្គភាពដែលអាចទទួលបានមូលនិធិដោយផ្ទាល់ពីមូលនិធិអាកាសជាតុបៃតង តាមរយៈនីតិវិធីឧទ្ទេសនាម និងនីតិវិធីផ្តល់សេចក្តីទុកចិត្ត
- ដើម្បីបញ្ជាក់លម្អិតអំពីវិធីត្រួតពិនិត្យ ផ្តល់សុពលភាព រាយការណ៍ ផ្ទៀងផ្ទាត់ តាមដាន និងកត់ត្រាព័ត៌មានមូលនិធិអាកាសជាតុ។

នីតិវិធីប្រតិបត្តិស្តង់ដារ (SOP) សម្រាប់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសជាតុបៃតង គឺជាវិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ និងស្តង់ដារដើម្បីប្រតិបត្តិនូវភារកិច្ច ដែលធានានូវលទ្ធផលសមស្រប និងអាចជឿទុកចិត្តបាន។ ឧទាហរណ៍៖ ដំណើរការដែលមានលក្ខណៈស្តង់ដារ ដើម្បីកំណត់ ចាត់អាទិភាព រចនា បង្កើត អនុវត្ត តាមដាន វាយតម្លៃ ធ្វើទីផ្សារ ពង្រីក និងបំប្លែង និងបញ្ចប់គម្រោង/កម្មវិធីបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសជាតុ ដោយប្រើមូលនិធិអាកាសជាតុបៃតងជាឧទាហរណ៍។

សៀវភៅណែនាំនេះនឹងប្រើប្រាស់ជាឯកសារយោង និងជាឯកសារសម្រាប់ការបណ្តុះបណ្តាល ហើយខ្លឹមសារនៅក្នុងសៀវភៅនេះ អាចប្រើប្រាស់សម្រាប់ការលើកកម្ពស់ចំណេះដឹង ទំនាក់ទំនង និងផ្សព្វផ្សាយ (នៅលើគេហទំព័រ)។ ជំពូកនីមួយៗ អាចត្រូវបានបង្កើតជាសៀវភៅណែនាំបណ្តុះបណ្តាលដាច់ដោយឡែក ឬខិត្តប័ណ្ណផ្សព្វផ្សាយ។ សៀវភៅណែនាំនេះជាឯកសាររស់ ដែលនឹងកែលម្អរៀងរាល់បីឆ្នាំម្តង នៅពេលដែលបានទទួលបទពិសោធន៍ថ្មីៗ និងពេលដែលមាននីតិវិធី និងលក្ខខណ្ឌតម្រូវថ្មីៗពីមូលនិធិអាកាសជាតុបៃតង។

គោលបំណងចំបងរបស់សៀវភៅណែនាំនេះ គឺដើម្បីពន្យល់មន្ត្រីរបស់ស្ថាប័នជាតិទទួលបន្ទុកអង្គភាពពាក់ព័ន្ធទាំងសាធារណៈ ឯកជន និងសង្គមស៊ីវិល អំពីវិធីដើម្បីទទួលបាន និងប្រើប្រាស់ធនធានរបស់មូលនិធិអាកាសជាតុបៃតងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីពង្រីក និងអនុវត្តគម្រូល្អៗនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសជាតុ ដើម្បីសម្រេចតាមគោលដៅជាតិអភិវឌ្ឍន៍ដោយចីរភាព និងគោលដៅអាកាសជាតុ។

សៀវភៅណែនាំនេះបានបែងចែកជាជំពូកដូចខាងក្រោម៖

- ជំពូក១ ៖ **សេចក្តីផ្តើម** តើអ្វីជាបរិបទ សនិទាន គោលបំណង នីតិវិធីប្រតិបត្តិស្តង់ដារ និងក្រុមគោលដៅរបស់សៀវភៅណែនាំនេះ។
- ជំពូក២ ៖ **ទិសដៅអភិវឌ្ឍន៍ជាតិ** តើទិសដៅអភិវឌ្ឍន៍ជាតិមានអ្វីខ្លះ? ឧទាហរណ៍៖ ផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតង (២០១៣-២០៣០) និងតើហិរញ្ញប្បទានអាកាសធាតុអាចត្រូវបានប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណង និងការអភិវឌ្ឍដែលធន់នឹងអាកាសធាតុក្នុងប្រទេសកម្ពុជាដោយរបៀបណា?

- ជំពូក៣ ៖ **ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុជាតិ និងការទទួលបានហិរញ្ញវត្ថុ** តើគោលដៅអាកាសធាតុជាតិជាអ្វី (ឧទាហរណ៍ INCR, NDC, NAP) ហើយតើហិរញ្ញប្បទានអាកាសធាតុអាចត្រូវបានកៀរគរយ៉ាងណា ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ នៅថ្នាក់ជាតិ និងខេត្ត ជាពិសេសភាពធន់របស់ប្រជាជន និងសហគមន៍មូលដ្ឋាន ដើម្បីកាត់បន្ថយ និងបន្សុាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ព្រមទាំងកាត់បន្ថយការបំពុលក្នុងតំបន់ និងការបំភាយឧស្ម័នផ្ទះកញ្ចក់ ស្របពេលដែលត្រូវការពារទ្រព្យសម្បត្តិ (ដីធ្លី ទន្លេ ដី ព្រៃ ជីវចម្រុះ) ដើម្បីផ្តល់សេវាកម្មអេកូឡូស៊ីដោយរបៀបណា? បរិបទមូលនិធិអាកាសធាតុអន្តរជាតិ ក្នុងនោះរួមមាន មូលនិធិអាកាសធាតុបៃតងជាដើម។ តើមានប្រភពហិរញ្ញប្បទានអាកាសធាតុទ្វេភាគី ថ្នាក់តំបន់ និងអន្តរជាតិអ្វីខ្លះ? ហើយតើអាចទទួលបាន ច្របាច់បញ្ចូលគ្នា និងរៀបចំធនធានទាំងនេះយ៉ាងដូចម្តេច? សៀវភៅណែនាំនេះនឹងប្រើប្រាស់មូលនិធិអាកាសធាតុបៃតង ជាឧទាហរណ៍ ដើម្បីបង្ហាញពីរបៀបទាញយក និងប្រើប្រាស់មូលនិធិអាកាសធាតុ។
- ជំពូក៤ ៖ **ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ** តើអ្នកណាជាអ្នកពាក់ព័ន្ធសំខាន់ៗ ហើយតើអ្វីជាតួនាទី និងទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងនោះ ហើយតើស្ថាប័នជាតិទទួលបន្ទុកនឹងចូលរួមជាមួយអ្នកពាក់ព័ន្ធទាំងនេះ ក្នុងការរៀបចំឡើងនូវកម្មវិធីប្រចាំប្រទេសសម្រាប់មូលនិធិអាកាសធាតុ យ៉ាងដូចម្តេច? តើមានសំណើគម្រោងបឋមសំខាន់ៗណាខ្លះទាក់ទងនឹងការបន្សុាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលអាចដាក់បញ្ចូលនៅក្នុងកម្មវិធីប្រចាំប្រទេសសម្រាប់មូលនិធិអាកាសធាតុបៃតង?
- ជំពូក៥ ៖ **ក្របខ័ណ្ឌស្ថាប័នជាតិ និងហិរញ្ញវត្ថុ** ដើម្បីទទួលបាន និងប្រើប្រាស់មូលនិធិអាកាសធាតុ តើនីតិវិធីនៃការសម្រេចចិត្តដែលបានរៀបចំរួចមានអ្វីខ្លះ ហើយតើនីតិវិធីទាំងនេះអាចត្រូវបានកែសម្រួល និងអនុម័តដើម្បីអាចទទួល និងប្រើប្រាស់មូលនិធិអាកាសធាតុបានយ៉ាងដូចម្តេច?
- ជំពូកទី៦៖ ស្ថា**ប័នជាតិទទួលបន្ទុក (NDA)** តើ NDA ជាអ្វី និងជានរណា ហើយអាជ្ញាធរនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ? តើ NDA ត្រូវការការគាំទ្រអ្វីខ្លះ? តើអ្វីទៅជាសមាជិកភាព និងលក្ខន្តិកៈការងារសម្រាប់ក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុ (GCFAP)? តើធ្វើដូចម្តេចដើម្បីរៀបចំលេខាធិការដ្ឋាន NDA ដែលអាចដំណើរការបានដោយរលូនប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងមានលក្ខណៈឌីជីថល ដើម្បីទាក់ទង និងសម្របសម្រួលសកម្មភាពអាកាសធាតុជាមួយអ្នកពាក់ព័ន្ធក្នុងខ្សែចង្វាក់ហិរញ្ញប្បទានអាកាសធាតុ?
- ជំពូកទី៧៖ **នីតិវិធីនៃការផ្តល់សេចក្តីទុកចិត្ត និងឧទ្ទេសនាមដល់ស្ថាប័នទទួលមូលនិធិផ្ទាល់** តើនរណាជាអង្គភាពអន្តរជាតិ និងជាតិដែលបានទទួលសេចក្តីទុកចិត្ត ហើយតើអង្គភាពទាំងនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ? ហើយតើ NDA មាននីតិវិធីឧទ្ទេសនាមសម្រាប់ផ្តល់សេចក្តីទុកចិត្តសមស្របតាមគោលបំណងដាក់លាក់យ៉ាងដូចម្តេចដែរ?សំណួរដែលត្រូវបានសួរជាញឹកញាប់ និង

ចម្លើយមានបង្ហាញនៅក្នុងជំពូកនេះ។

- ជំពូកទី៨៖ **អង្គភាពប្រតិបត្តិ** តើអ្នកណាជាអង្គភាពប្រតិបត្តិ ហើយអង្គភាពនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ ? តើមានអ្នកណាទៀតអាចអនុវត្តគម្រោង/កម្មវិធីមូលនិធិអាកាសធាតុបៃតង ?
- ជំពូកទី៩៖ **ការរៀបចំឯកសារទស្សនៈទាន និង សំណើគម្រោង** តើ ឯកសារទស្សនៈទាន និងសំណើគម្រោងប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់ ដែលបំពេញលក្ខខណ្ឌតម្រូវ របស់ហិរញ្ញប្បទានអាកាសធាតុ (ឧទាហរណ៍ លក្ខខណ្ឌវិនិយោគរបស់មូលនិធិអាកាសធាតុបៃតង) ត្រូវរៀបចំដោយរបៀបណា ? តើមានការគាំទ្រអ្វីខ្លះសម្រាប់ការរៀបចំឯកសារគម្រោងទាំងនេះ ហើយតើអាចទទួលបានការគាំទ្រទាំងនេះបានដោយរបៀបណា ?
- ជំពូកទី១០៖ **នីតិវិធីចេញលិខិតគាំទ្រ** តើធ្វើដូចម្តេចដើម្បីប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល (ឧទាហរណ៍៖ នីតិវិធីចេញលិខិតគាំទ្រសម្រាប់មូលនិធិអាកាសធាតុបៃតង) ? ឧទាហរណ៍ខ្លះត្រូវបានផ្តល់នៅក្នុងជំពូកនេះ។
- ជំពូកទី១១៖ **ប្រព័ន្ធតាមដាន និងវាយតម្លៃ** តើត្រូវតាមដាន និងវាយតម្លៃគម្រោង / កម្មវិធី ហិរញ្ញប្បទានអាកាសធាតុដោយរបៀបណា ? តើធ្វើដូចម្តេចដើម្បីទាញយកបទពិសោធន៍ ដែលទទួលបាន និងបម្លែងទៅជាចំណេះដឹង និងជំនាញសម្រាប់ចែករំលែកនៅមូលដ្ឋាន ថ្នាក់ខេត្ត ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ ?

## ជំពូកទី១ ៖ សេចក្តីផ្តើម

### ១.១ បរិបទ និងសនិទានភាពនៃមូលនិធិអាកាសធាតុបៃតង

ការដោះស្រាយបញ្ហាប្រឈមនានាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុត្រូវការធនធានហិរញ្ញវត្ថុយ៉ាងក្រាស់ក្រែល។ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ហិរញ្ញប្បទានអាកាសធាតុ សំដៅទៅលើលំហូរមូលធនសម្រាប់សកម្មភាពនានា ដែលកាត់បន្ថយ ឬលុបបំបាត់ការបំភាយឧស្ម័នផ្ទះកញ្ចក់ (ការកាត់បន្ថយ) ឬបង្កើនភាពធន់នឹងអាកាសធាតុដែលកំពុងតែប្រែប្រួល ឱ្យកាន់តែប្រសើរឡើង (ការបន្សាំ)។ ហិរញ្ញប្បទានអាកាសធាតុមានភាពស្មុគស្មាញដោយសារតែប្រភពមូលនិធិច្រើនរួមបញ្ចូលគ្នា (សាធារណៈ ឯកជន អន្តរជាតិ ជាតិ និងថ្នាក់ក្រោមជាតិ) និងជំហានដើម្បីទទួលបានមូលនិធិនេះ មានភាពចម្រុះ។

មូលនិធិអាកាសធាតុបៃតង (GCF) ត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ ២០១០ ក្នុងគោលបំណងចូលរួមវិភាគទានយ៉ាងធំធេង និងប្រកបដោយមហិច្ឆិតាខ្ពស់ ទៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដែលសហគមន៍អន្តរជាតិបានកំណត់។ នៅក្នុងបរិបទនៃការអភិវឌ្ឍដោយចីរភាព មូលនិធិអាកាសធាតុបៃតងនឹងលើកកម្ពស់ការផ្លាស់ប្តូរដ៏សំខាន់ឆ្ពោះទៅរកការបញ្ចេញកាបូនទាប និងមាគ៌ាអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុ ដោយផ្តល់ការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីកម្រិត ឬកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

មូលនិធិអាកាសធាតុបៃតងត្រូវបានជ្រើសតាំងជាអង្គភាពប្រតិបត្តិនៃយន្តការហិរញ្ញប្បទានរបស់អនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ មូលនិធិនេះគ្រប់គ្រង និងត្រួតពិនិត្យដោយក្រុមប្រឹក្សាភិបាលមួយ ដែលទទួលខុសត្រូវក្នុងការសម្រេចចិត្តផ្តល់មូលនិធិដោយអនុលោមទៅតាមបរិធានគ្រប់គ្រងរបស់មូលនិធិអាកាសធាតុបៃតង។ មូលនិធិនេះគាំទ្រដោយលេខាធិការដ្ឋានឯករាជ្យមួយ ដែលទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល ហើយមានសមត្ថភាពគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់មូលនិធិអាកាសធាតុ ព្រមទាំងផ្តល់ការគាំទ្រលើការងាររដ្ឋបាល ច្បាប់ និងហិរញ្ញវត្ថុ។ ទីស្នាក់ការកណ្តាលរបស់មូលនិធិអាកាសធាតុបៃតង (លេខាធិការដ្ឋាន) មានទីតាំងនៅសុងដូ ទីក្រុងអ៊ីនឈុន សាធារណរដ្ឋកូរ៉េ។

បណ្តាប្រទេសអភិវឌ្ឍន៍បានប្តេជ្ញាក្នុងការកៀរគរហិរញ្ញប្បទានអាកាសធាតុថ្មី និងហិរញ្ញប្បទានបន្ថែមទៀត ក្នុងនោះរំពឹងថានឹងប្រមូលបានទឹកប្រាក់ចំនួន ១០០ ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗនៅឆ្នាំ ២០២០ ដើម្បីជួយដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការចំណាយលើការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ យ៉ាងណាក៏ដោយ ថវិកាសរុបដែលត្រូវការដើម្បីបញ្ចៀសមិនឱ្យសីតុណ្ហភាពមធ្យមរបស់ពិភពលោក កើនឡើងលើស ២ អង្សាសេសែលស្យុស លើកម្រិតឧស្សាហកម្មចាស់ និងដើម្បីបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ គឺលើសពី ១០០ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗទៅទៀត។

ភាពមិនប្រាកដប្រជាជាច្រើន នៅតែកើតមាន ពោលគឺ តើមូលនិធិនឹងកៀរគរ គ្រប់គ្រង និងបែងចែកដោយរបៀបណា។ យន្តការមួយក្នុងចំណោមយន្តការគ្រប់គ្រង និងបែងចែកហិរញ្ញប្បទានអាកាសធាតុអន្តរជាតិ គឺមូលនិធិអាកាសធាតុបៃតង។ មូលនិធិអាកាសធាតុបៃតង គាំទ្រដល់បណ្តាគម្រោង កម្មវិធី គោលនយោបាយ និងគម្រោងត្រៀមនានា និងសកម្មភាពផ្សេងៗទៀតទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ គោលបំណងរបស់មូលនិធិអាកាសធាតុបៃតង គឺដើម្បីចូលរួមចំណែកយ៉ាងធំធេង និងប្រកបដោយមហិច្ឆតាខ្ពស់ទៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ឆ្ពោះទៅរកការសម្រេចឱ្យបាននូវគោលដៅទប់ទល់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការផ្លាស់ប្តូរសំខាន់ៗឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍បញ្ចេញកាបូនទាប និងមានភាពធន់នឹងអាកាសធាតុ។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលការគាំទ្រដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង (GCF) ដើម្បីបង្កើតនីតិវិធី និងបង្កើនសមត្ថភាពមនុស្សដែលត្រូវមានជាចាំបាច់ សម្រាប់គ្រប់គ្រងអោយបានគ្រប់ជ្រុងជ្រោយនូវភាពជាដៃគូជាមួយមូលនិធិអាកាសធាតុបៃតង និងសម្របសម្រួលធាតុចូលពីភាគីពាក់ព័ន្ធនានា។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) កំពុងគាំទ្រដល់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង (NDA) នៅប្រទេសកម្ពុជា ក្នុងការសម្របសម្រួល និងអនុម័តគម្រោង/កម្មវិធីនានារបស់មូលនិធិអាកាសធាតុបៃតងនៅក្នុងប្រទេស។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព កំពុងសម្របសម្រួល លើការអនុវត្តសកម្មភាពនានា ដែលបានស្នើឡើង ក្រោមគម្រោង ការត្រៀមខ្លួន ដែលនាយកដ្ឋាននេះនឹងជួយដល់រាជរដ្ឋាភិបាល គ្រប់គ្រងតម្រូវការទាំងអស់នេះ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងដោយស្រុះស្រួលគ្នា ស្របជាមួយយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ឧទាហរណ៍ ដូចជា យុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលនយោបាយ ផែនការ យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ (ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣) ស្របពេលជាមួយនេះផងដែរគម្រោងនេះនឹងសម្រេចបាននូវតម្រូវការតាមបែបបទប្រតិបត្តិការ និងក្របខ័ណ្ឌវិនិយោគនៃមូលនិធិអាកាសធាតុបៃតង។

ដើម្បីទទួលបាន(រៀបចំ វាយតម្លៃ និងអនុម័ត) និងប្រើប្រាស់នូវ (អនុវត្ត តាមដាន វាយតម្លៃ និងបញ្ចប់គម្រោង) ធនធានរបស់មូលនិធិអាកាសធាតុបៃតង និងអនុញ្ញាតឱ្យស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានជាមន្ត្រីបង្គោល បំពេញភារកិច្ចរបស់ខ្លួនដោយរលូន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នាយកដ្ឋានប្រែប្រួលអាកាសធាតុ កំពុងអនុវត្តគម្រោងត្រៀមរបស់មូលនិធិអាកាសធាតុបៃតង ដែលមានគោលបំណងធំៗ ចំនួន២គឺ ទី១ ការពង្រឹងសមត្ថភាពរបស់ស្ថាប័នជាតិទទួលបន្ទុក ដោយយោងទៅតាមគោលការណ៍ណែនាំ និងបែបបទប្រតិបត្តិរបស់មូលនិធិអាកាសធាតុបៃតង និងទី២ ការបង្កើតនូវក្របខ័ណ្ឌចូលរួមរបស់អ្នកពាក់ព័ន្ធដើម្បីរៀបចំកម្មវិធីមូលនិធិអាកាសធាតុបៃតងប្រចាំប្រទេស ដែលមានបរិយាប័ន្ន និងគិតគូរពីយេនឌ័រ ព្រមទាំងបញ្ជីសំណើគម្រោងអាទិភាព។

## ១.២ គោលបំណងរួមនៃការងារ

គោលបំណងរួមនៃការងារគឺដើម្បី៖

- ពង្រឹងសមត្ថភាពរបស់អាជ្ញាធរជាតិទទួលបន្ទុក និងភាគីពាក់ព័ន្ធសំខាន់ៗដើម្បី បំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ទៅតាមគោលការណ៍ណែនាំប្រតិបត្តិ និងលក្ខខណ្ឌតម្រូវរបស់មូលនិធិ

អាកាសធាតុបៃតង (ឧទាហរណ៍ នីតិវិធីចេញលិខិតគាំទ្រ និងនីតិវិធីឧទ្ទេសនាមស្ថាប័នដើម្បីទទួលបានសេចក្តីទុកចិត្ត ជាដើម)

- គាំទ្រដល់ការអភិវឌ្ឍនូវក្របខ័ណ្ឌជាតិនៃការចូលរួម ដែលមានភាពបើកទូលាយ សមភាព តម្លាភាព និងបរិយាប័ន្ន ក្នុងការធ្វើការរួមគ្នាជាមួយមូលនិធិអាកាសធាតុបៃតង និងអ្នកពាក់ព័ន្ធសំខាន់ៗ ព្រមទាំងគាំទ្រដល់ការបង្កើតយុទ្ធសាស្ត្រទំនាក់ទំនង និងសម្របសម្រួលជាក់លាក់ ដើម្បីចម្រាញ់យក និងចាត់អាទិភាពលើឯកសារទស្សនទាន និងសំណើថវិកា ដែលមានគុណភាពខ្ពស់សម្រាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីមូលនិធិអាកាសធាតុប្រចាំប្រទេសរបស់កម្ពុជា។

លទ្ធផលរំពឹងទុកជាក់លាក់មានដូចខាងក្រោម៖

១. បង្កើតនីតិវិធីដែលច្បាស់លាស់ និងងាយស្រួលប្រើប្រាស់ ដើម្បីឱ្យស្ថាប័នជាតិទទួលបន្ទុក បំពេញមុខងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដូចជា នីតិវិធីវាយតម្លៃ និងអនុម័តឯកសារទស្សនៈទាន និងសំណើថវិកា សម្រាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីមូលនិធិអាកាសធាតុប្រចាំប្រទេស។

២. បណ្តុះបណ្តាលដល់មន្ត្រីរបស់ស្ថាប័នជាតិទទួលបន្ទុក និងភាគីពាក់ព័ន្ធសំខាន់ៗ (ឧទាហរណ៍៖ បណ្តាអង្គភាពដែលអាចស្នើសុំជាអង្គភាពទទួលមូលនិធិផ្ទាល់ និងអង្គភាពប្រតិបត្តិគម្រោង) ដើម្បីស្វែងយល់ពីតួនាទី និងភារកិច្ចរបស់ពួកគេ ព្រមទាំងនីតិវិធីផ្សេងៗ។

៣. បង្កើតគោលការណ៍ណែនាំដែលច្បាស់លាស់ និងងាយស្រួលប្រើប្រាស់សម្រាប់ការឧទ្ទេសនាមអង្គភាពសាធារណៈ ឯកជន និងសង្គមស៊ីវិល ជាអង្គភាពទទួលមូលនិធិផ្ទាល់ ដើម្បីរៀបចំអនុវត្តតាមដាន និងត្រួតពិនិត្យ គម្រោងមូលនិធិអាកាសធាតុបៃតង

៤. រៀបចំក្របខ័ណ្ឌជាតិនៃការចូលរួម ដែលមានយន្តការសម្រេចចិត្តច្បាស់លាស់ និងសម្របសម្រួលការពិគ្រោះយោបល់

៥. គាំទ្រស្ថាប័នជាតិទទួលបន្ទុក ក្នុងការសំយោគមតិយោបល់ ដែលទទួលបានពីភាគីពាក់ព័ន្ធ នៅក្នុងសិក្ខាសាលាផ្តល់សុពលភាព និងកិច្ចប្រជុំនានា ព្រមទាំងបញ្ចប់ការរៀបរៀងក្របខ័ណ្ឌនៃការចូលរួម។

## ១.២ គោលបំណង និតិវិធីប្រតិបត្តិការស្តង់ដា និងក្រុមគោលដៅ

**គោលបំណង៖** គោលបំណងសំខាន់ៗនៃសៀវភៅណែនាំមានដូចខាងក្រោម៖

- ដើម្បីយល់អំពីយន្តការហិរញ្ញប្បទានអាកាសធាតុទ្វេភាគី ក្នុងតំបន់ និងអន្តរជាតិ ពោលគឺការទទួលបាន ការកៀរគរ ការអនុវត្ត ការតាមដាន ការវាយតម្លៃ ការពង្រីក និងការអនុវត្តគម្រូល្អៗនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ឧទាហរណ៍៖ នៅក្នុងកម្មវិធីប្រចាំប្រទេសមូលធិនិអាកាសធាតុបៃតង) ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ និងគោលដៅអាកាសធាតុ ដូចមានបង្ហាញក្នុងរូបភាពទី ១
- ដើម្បីកំណត់ឱ្យច្បាស់លាស់នូវតួនាទី និងភារកិច្ចរបស់ស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង និងស្ថាប័នពាក់ព័ន្ធ (ស្ថាប័នប្រតិបត្តិជាតិ និងអន្តរជាតិដែលទទួលបានសេចក្តីទុកចិត្ត

អង្គភាពសាធារណៈ ឯកជន និងដៃគូសង្គមស៊ីវិល) នៅក្នុងដំណើរការអភិវឌ្ឍជាតិ និងដំណើរការរបស់ហិរញ្ញប្បទានអាកាសធាតុ (ឧទាហរណ៍៖ មូលនិធិអាកាសធាតុបៃតង)

- ដើម្បីបង្កើតយន្តការ សម្របសម្រួល និងទំនាក់ទំនង ដែលជួយស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង ក្នុងលើកទឹកចិត្តឱ្យមានការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងមូលនិធិអាកាសធាតុ
- ដើម្បីយល់ពីវិធីក្នុងការកំណត់ និងបំប្លែងគំនិតគម្រោងទៅជា ឯកសារទស្សនៈទាន និងសំណើរថវិកាដែលមានគុណភាព និងការប្រកួតប្រជែងខ្ពស់ ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់មូលនិធិអាកាសាជាតុបៃតង
- ដើម្បីបញ្ជាក់ឱ្យកាន់តែលម្អិតពីវិធីវាយតម្លៃ និងអនុម័ត ឯកសារទស្សនៈទាន និងសំណើរថវិកាប្រកបដោយស្មើភាព និងតម្លាភាព ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងឧបករណ៍ធ្វើសេចក្តីសម្រេចចិត្ត (ពហុលក្ខណៈវិនិច្ឆ័យ និងវិភាគថ្លៃដើម និងចំណេញ) ក្នុងដំណើរការផ្តល់លិខិតយល់ព្រម
- ស្វែងយល់ពីវិធីវាយតម្លៃ និងអនុម័តលើ អង្គភាពសាធារណៈ ឯកជន និងសង្គមស៊ីវិលដែលចង់បានការទទួលស្គាល់ជាអង្គភាពដែលអាចទទួលបានមូលនិធិដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតងតាមរយៈនីតិវិធីឧទ្ទេសនាម និងនីតិវិធីផ្តល់សេចក្តីទុកចិត្ត
- ដើម្បីបញ្ជាក់លម្អិតអំពីវិធីត្រួតពិនិត្យ ផ្តល់សុពលភាព រាយការណ៍ ផ្ទៀងផ្ទាត់ តាមដាន និងកត់ត្រាព័ត៌មានមូលនិធិអាកាសធាតុ។

**និតិវិធីប្រតិបត្តិការស្តង់ដា** សម្រាប់អាជ្ញាធរជាតិទទួលបន្ទុក រួមមាន៖

- វិធីសាស្ត្រដែលមានលក្ខណៈជាប្រព័ន្ធ និងស្តង់ដារដើម្បីប្រតិបត្តិនូវភារកិច្ច ដែលធានានូវលទ្ធផលសមស្រប និងអាចជឿទុកចិត្តបាន។
- វិធីស្តង់ដារ ដើម្បីកំណត់ ចាត់អាទិភាព រចនា បង្កើត អនុវត្ត តាមដាន វាយតម្លៃ ធ្វើទីផ្សារ ពង្រីក និងបំប្លែង និងបញ្ចប់គម្រោង/កម្មវិធីបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយប្រើមូលនិធិអាកាសធាតុបៃតងជាឧទាហរណ៍
- ស្វែងយល់អំពីដំណើរការដើម្បី៖

○ បង្កើតលេខាធិការដ្ឋាន NDA ដែលអាចដំណើរការបានដោយរលូនប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងមានលក្ខណៈឌីជីថល

○ កំណត់ និងបំប្លែងគំនិតគម្រោងទៅជា ឯកសារទស្សនៈទាន និងសំណើរថវិកាដែលមានគុណភាព និងការប្រកួតប្រជែងខ្ពស់ ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ របស់មូលនិធិអាកាសធាតុបៃតង (ឧទាហរណ៍៖ លក្ខណៈវិនិច្ឆ័យវិនិយោគរបស់មូលនិធិអាកាសធាតុ លទ្ធផល ក្របខណ្ឌលទ្ធផលគម្រោង (results logical framework) ការធ្វើផែនការថវិកា និងការវាយតំលៃហានិភ័យ)

○ ស្វែងយល់ពីប្រភេទគម្រូឯកសារទស្សនៈទាន និងសំណើថវិកា ដែលសមស្របបំផុតសម្រាប់យកមកប្រើប្រាស់

○ វាយតម្លៃ និងអនុម័ត លើឯកសារទស្សនៈទាន និងសំណើថវិកា ដោយសមភាព និងតម្លាភាព ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងបរិធានធ្វើសេចក្តីសម្រេចចិត្ត (ពហុលក្ខណៈវិនិច្ឆ័យ និងវិភាគខាត និងចំណេញ) ក្នុងដំណើរការផ្តល់លិខិតយល់ព្រម ដោយផ្អែកលើតារាង វាយតំលៃ

- ○ តាមដាន ផ្តល់សុពលភាព រាយការណ៍ ព្រមទាំងផ្ទៀងផ្ទាត់លទ្ធផល និងគោលដៅរបស់គម្រោង ដោយផ្អែកលើក្របខណ្ឌលទ្ធផលគម្រោង
- ○ តាមដាន និងកត់ត្រាព័ត៌មានហិរញ្ញប្បទានអាកាសធាតុទ្វេភាគី ក្នុងតំបន់ និងអន្តរជាតិ ទៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិ និងប្រព័ន្ធថវិកាជាតិប្រចាំឆ្នាំ
- ○ វាយតម្លៃ និងអនុម័ត លើអង្គភាពសាធារណៈ ឯកជន និងសង្គមស៊ីវិលដែលចង់បានការទទួលស្គាល់ជាអង្គភាពដែលអាចទទួលបានមូលនិធិដោយផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង តាមរយៈនីតិវិធីឧទ្ទេសនាម និងនីតិវិធីវាយតម្លៃផ្តល់សេចក្តីទុកចិត្ត តាមគោលបំណងជាក់លាក់
- ○ គ្រប់គ្រង និងដោះស្រាយបណ្តឹងសារទុក្ខនានា ព្រមទាំងផ្តល់នូវមតិត្រឡប់ទៅវិញ
- ○ ដោះស្រាយទំនាស់ផលប្រយោជន៍-ពិធីស្បថ និងក្រមប្រតិបត្តិ

**ក្រុមគោលដៅ៖** សៀវភៅណែនាំ និងនិតិវិធីប្រតិបត្តិស្តង់ដានេះ ត្រូវបានរៀបចំសម្រាប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែសង្វាក់ហិរញ្ញប្បទានអាកាសធាតុរួមមានដូចខាងក្រោម៖

- មន្ត្រីបម្រើការឱ្យស្ថាប័នជាតិទទួលបន្ទុក ទាំងនាពេលបច្ចុប្បន្ន និងអនាគត
- ស្ថាប័នសាធារណៈ៖ ក្រសួង នាយកដ្ឋាន ទីភ្នាក់ងារ អាជ្ញាធរ និងអាជ្ញាធរមូលដ្ឋានផ្នែកហិរញ្ញវត្ថុ ផែនការ ធនធានទឹក កសិកម្ម ថាមពល និងធនធានធម្មជាតិ កិច្ចការនារី និងយុវជន និងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត
- ឯកជន៖ ធនាគារ វិនិយោគិន ក្រុមហ៊ុនមិនរកប្រាក់ចំណេញ អ្នកផ្តល់សេវាកម្មលើបច្ចេកវិទ្យា និងធុរកិច្ច
- ដៃគូសង្គមស៊ីវិល៖ អ្នកប្រើប្រាស់ អង្គការតំណាងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ និងអភិវឌ្ឍន៍ និងអ្នកសិក្សាទូទៅ។

**ការប្រើប្រាស់៖** សៀវភៅណែនាំនេះនឹងប្រើប្រាស់ជាឯកសារយោង និងជាឯកសារសម្រាប់ការបណ្តុះបណ្តាល ហើយខ្លឹមសារនៅក្នុងសៀវភៅនេះ អាចប្រើប្រាស់សម្រាប់ការលើកកម្ពស់ចំណេះដឹង ទំនាក់ទំនង និងផ្សព្វផ្សាយ (នៅលើគេហទំព័រ)។ ជំពូកនីមួយៗ អាចត្រូវបានបង្កើតជាសៀវភៅណែនាំបណ្តុះបណ្តាលដាច់ដោយឡែក ឬខិត្តប័ណ្ណផ្សព្វផ្សាយ។ សៀវភៅណែនាំនេះជាឯកសាររស់ ដែលនឹងកែលម្អរៀងរាល់បីឆ្នាំម្តង នៅពេលដែលបានទទួលបទពិសោធន៍ថ្មីៗ និងពេលដែលមាននីតិវិធី និងលក្ខខណ្ឌតម្រូវថ្មីៗពីមូលនិធិអាកាសធាតុបៃតង។

## ១.៣ មាតិកាសៀវភៅណែនាំ

ប្រធានបទនៅក្នុងសៀវភៅណែនាំនេះត្រូវបានរៀបចំដោយយោងទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ ដែលបានបង្ហាញនៅក្នុងរូបទី១ ដូចខាងក្រោម




រូបភាពទី 1៖ សំណើក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌហិរញ្ញវត្ថុរបស់កម្ពុជា ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុទ្វេភាគី តំបន់ និងអន្តរជាតិ (ឧទាហរណ៍៖ មូលនិធិអាកាធាតុបៃតង) ដើម្បីពង្រីកវិសាលភាពនៃសកម្មភាពបន្ស៊ាំ និងការកាត់បន្ថយ ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅអាកាសធាតុជាតិ។

គោលបំណងចំបងរបស់សៀវភៅណែនាំនេះ គឺដើម្បីពន្យល់មន្ត្រីរបស់ស្ថាប័នជាតិទទួលបន្ទុក អង្គភាពពាក់ព័ន្ធទាំងសាធារណៈ ឯកជន និងសង្គមស៊ីវិល អំពីវិធីដើម្បីទទួលបាន និងប្រើប្រាស់ធនធានរបស់មូលនិធិអាកាសធាតុបៃតងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីពង្រីក និងអនុវត្តគម្រូល្អៗនៃការបន្ស៊ាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដើម្បីសម្រេចតាមគោលដៅជាតិអភិវឌ្ឍន៍ដោយចីរភាព និងគោលដៅអាកាសធាតុ។ សៀវភៅណែនាំនេះបានបែងចែកជាជំពូកដូចខាងក្រោម៖

- ជំពូក១៖ **សេចក្តីផ្តើម** តើអ្វីជាបរិបទ សនិទាន គោលបំណង នីតិវិធីប្រតិបត្តិស្តង់ដារ និងក្រុមគោលដៅរបស់សៀវភៅណែនាំនេះ។
- ជំពូក២៖ **ទិសដៅអភិវឌ្ឍន៍ជាតិ** តើទិសដៅអភិវឌ្ឍន៍ជាតិមានអ្វីខ្លះ? ឧទាហរណ៍៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍបៃតង (២០១៣-២០៣០) និងតើហិរញ្ញប្បទានអាកាសធាតុអាចត្រូវបានប្រើប្រាស់ដើម្បីសម្រេចឱ្យបាននូវគោលបំណង និងការអភិវឌ្ឍដែលធន់នឹងអាកាសធាតុក្នុងប្រទេសកម្ពុជាដោយរបៀបណា?
- ជំពូក ៣៖ **ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុជាតិ និងការទទួលបានហិរញ្ញវត្ថុ** តើគោលដៅអាកាសធាតុជាតិជាអ្វី (ឧទាហរណ៍ INCR, NDC, NAP) ហើយតើហិរញ្ញប្បទានអាកាសធាតុ

អាចត្រូវបានកៀរគរយ៉ាងណា ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុ នៅថ្នាក់ជាតិ និងខេត្ត ជាពិសេសភាពធន់របស់ប្រជាជន និងសហគមន៍មូលដ្ឋាន ដើម្បីកាត់បន្ថយ និងបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ព្រមទាំងកាត់បន្ថយការបំពុលក្នុងតំបន់ និងការបំភាយឧស្ម័នផ្ទះកញ្ចក់ ស្របពេលដែលត្រូវការពារទ្រព្យសម្បត្តិ (ដីធ្លី ទន្លេ ដី ព្រៃ ជីវចម្រុះ) ដើម្បីផ្តល់សេវាកម្មអេកូឡូស៊ីដោយរបៀបណា? បរិបទមូលនិធិអាកាសធាតុអន្តរជាតិ ក្នុងនោះរួមមាន មូលនិធិអាកាសធាតុបៃតងជាដើម។ តើមានប្រភពហិរញ្ញប្បទានអាកាសធាតុទ្វេភាគី ថ្នាក់តំបន់ និងអន្តរជាតិអ្វីខ្លះ? ហើយតើអាចទទួលបាន ច្របាច់បញ្ចូលគ្នា និងរៀបចំធនធានទាំងនេះយ៉ាងដូចម្តេច? សៀវភៅណែនាំនេះនឹងប្រើប្រាស់មូលនិធិអាកាសធាតុបៃតង ជាឧទាហរណ៍ ដើម្បីបង្ហាញពីរបៀបទាញយក និងប្រើប្រាស់មូលនិធិអាកាសធាតុ។

- ជំពូក ៤៖ **ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ** តើអ្នកណាជាអ្នកពាក់ព័ន្ធសំខាន់ៗ ហើយតើអ្វីជាតួនាទី និងទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធទាំងនោះ ហើយតើស្ថាប័នជាតិទទួលបន្ទុកនឹងចូលរួមជាមួយអ្នកពាក់ព័ន្ធទាំងនេះ ក្នុងការរៀបចំឡើងនូវកម្មវិធីប្រចាំប្រទេសសម្រាប់មូលនិធិអាកាសធាតុ យ៉ាងដូចម្តេច? តើមានសំណើគម្រោងបឋមសំខាន់ៗណាខ្លះទាក់ទងនឹងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលអាចដាក់បញ្ចូលនៅក្នុងកម្មវិធីប្រចាំប្រទេសសម្រាប់មូលនិធិអាកាសធាតុបៃតង?
- ជំពូក៥៖ **ក្របខ័ណ្ឌស្ថាប័នជាតិ និងហិរញ្ញវត្ថុ ដើម្បីទទួលបាន និងប្រើប្រាស់មូលនិធិអាកាសធាតុ** តើនីតិវិធីនៃការសម្រេចចិត្តដែលបានរៀបចំរួចមានអ្វីខ្លះ ហើយតើនីតិវិធីទាំងនេះអាចត្រូវបានកែសម្រួល និងអនុម័តដើម្បីអាចទទួល និងប្រើប្រាស់មូលនិធិអាកាសធាតុបានយ៉ាងដូចម្តេច?
- ជំពូកទី ៦៖ **ស្ថាប័នជាតិទទួលបន្ទុក (NDA)** តើ NDA ជាអ្វី និងជានរណា ហើយអាជ្ញាធរនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ? តើ NDA ត្រូវការការគាំទ្រអ្វីខ្លះ? តើអ្វីទៅជាសមាជិកភាព និងលក្ខន្តិកៈការងារសម្រាប់ក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុ (GCFAP)? តើធ្វើដូចម្តេចដើម្បីរៀបចំលេខាធិការដ្ឋាន NDA ដែលប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល អាចដំណើរការបាន និងមានលក្ខណៈឌីជីថល ដើម្បីទាក់ទង និងសម្របសម្រួលសកម្មភាពអាកាសធាតុជាមួយអ្នកពាក់ព័ន្ធក្នុងខ្សែចង្វាក់ហិរញ្ញប្បទានអាកាសធាតុ?
- ជំពូកទី ៧៖ **នីតិវិធីនៃការផ្តល់សេចក្តីទុកចិត្ត និងឧទ្ទេសនាមដល់ស្ថាប័នទទួលមូលនិធិផ្ទាល់** តើនរណាជាអង្គភាពអន្តរជាតិ និងជាតិដែលបានទទួលសេចក្តីទុកចិត្ត ហើយតើអង្គភាពទាំងនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ? ហើយតើ NDA មាននីតិវិធីឧទ្ទេសនាមសម្រាប់ផ្តល់សេចក្តីទុកចិត្តសមស្របតាមគោលបំណងជាក់លាក់យ៉ាងដូចម្តេចដែរ?សំណួរដែលត្រូវបានសួរជាញឹកញាប់ និងចម្លើយមានបង្ហាញនៅក្នុងជំពូកនេះ។
- ជំពូកទី ៨៖ **អង្គភាពប្រតិបត្តិ** តើអ្នកណាជាអង្គភាពប្រតិបត្តិ ហើយអង្គភាពនេះមានតួនាទី និងភារកិច្ចអ្វីខ្លះ? តើមានអ្នកណាទៀតអាចអនុវត្តគម្រោង/កម្មវិធីមូលនិធិអាកាសធាតុបៃតង?
- ជំពូកទី ៩៖ **ការរៀបចំឯកសារទស្សនៈទាន និងសំណើគម្រោង** តើឯកសារទស្សនៈទាន និងសំណើគម្រោងប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់ ដែលបំពេញលក្ខខណ្ឌតម្រូវរបស់ហិរញ្ញប្បទានអាកាសធាតុ (ឧទាហរណ៍ លក្ខខណ្ឌវិនិយោគរបស់មូលនិធិអាកាសធាតុ

បៃតង) ត្រូវរៀបចំដោយរបៀបណា? តើមានការគាំទ្រអ្វីខ្លះសម្រាប់ការរៀបចំឯកសារគម្រោងទាំងនេះ ហើយតើអាចទទួលបានការគាំទ្រទាំងនេះបានដោយរបៀបណា?

- ជំពូកទី ១០៖ **នីតិវិធីចេញលិខិតគាំទ្រ** តើធ្វើដូចម្ដេចដើម្បីប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល (ឧទាហរណ៍៖ នីតិវិធីចេញលិខិតគាំទ្រសម្រាប់មូលនិធិអាកាសធាតុបៃតង)? ឧទាហរណ៍ខ្លះត្រូវបានផ្ដល់នៅក្នុងជំពូកនេះ។
- ជំពូកទី ១១៖ **ប្រព័ន្ធតាមដាន និងវាយតម្លៃ** តើត្រូវតាមដាន និងវាយតម្លៃគម្រោង/កម្មវិធី ហិរញ្ញប្បទានអាកាសធាតុដោយរបៀបណា? តើធ្វើដូចម្ដេចដើម្បីទាញយកបទពិសោធន៍ ដែលទទួលបាន និងបម្លែងទៅជាចំណេះដឹង និងជំនាញសម្រាប់ចែករំលែកនៅមូលដ្ឋាន ថ្នាក់ខេត្ត ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ?

# ជំពូកទី២ ៖ ទិសដៅអភិវឌ្ឍន៍ជាតិ

ជំពូកនេះផ្តល់សេចក្តីសង្ខេបអំពីគោលនយោបាយ គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងវិធីក្នុងការស្នើសុំថវិកា ដើម្បីសម្រេចផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ។ ការយល់ដឹងអំពីទិសដៅអភិវឌ្ឍន៍ជាតិរបស់ប្រទេសកម្ពុជា នឹងជួយធានាថាឯកសារទស្សនទាន និងសំណើថវិកាគឺ ស្របទៅនឹងទិសដៅអភិវឌ្ឍន៍ជាតិ ហើយជាពិសេសផ្តោះទៅរកការអភិវឌ្ឍដែលបញ្ចេញកាបូនតិច និងមានភាពធន់នឹងអាកាសធាតុនៅកម្ពុជា។

## ២.១ គោលនយោបាយ គោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ




រូបភាពទី 2 ៖ តារាងព្រឹត្តិការណ៍នៅកម្ពុជាចាប់តាំងពីឆ្នាំ ១៩៩១[1]

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣)៖** ប្រទេសកម្ពុជាត្រូវបានចាត់ចូលជាប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ដោយអង្គការសហប្រជាជាតិ។ ប្រាក់ចំណូលរបស់ប្រជាជនម្នាក់ៗបានកើនលើសពី ១០០០ ដុល្លារអាមេរិកជាលើកដំបូងនៅឆ្នាំ ២០១២ ពេលគឺមានការកើនឡើងជិត ៥ ដងនៃប្រាក់ចំណូលសម្រាប់មនុស្សម្នាក់ក្នុងមួយទសវត្សចុងក្រោយនេះ ដែលជាសមិទ្ធិផលគួរឱ្យកត់សម្គាល់ផងដែរ។ ក្នុងន័យនេះ កម្ពុជាអាចនឹងចាកផុតពីប្រទេសអភិវឌ្ឍន៍តិចតួចនាពេលអនាគតដ៏ខ្លីខាងមុខ។ រូបភាពទី ២ បង្ហាញពីតារាងព្រឹត្តិការណ៍នៅកម្ពុជា និងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ចាប់តាំងពីឆ្នាំ ១៩៩១ ។

**យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖** រាជរដ្ឋាភិបាលកម្ពុជាបានវិវត្តទៅរក "យុទ្ធសាស្ត្រចតុកោណ" ដែលជាយុទ្ធសាស្ត្រគន្លឹះក្នុងការអភិវឌ្ឍប្រទេសចាប់តាំងពីឆ្នាំ ២០០៤ មក។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៦-២០១០) បានដាក់បញ្ចូលរបៀបវារៈ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រចតុកោណដំបូង។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០០៩-២០១៣) បានធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ចំណែកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) បានធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) អនុវត្តរបៀបវារៈដែលមាននៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាល

[1] *https://www.ifad.org/documents/38714182/39973201/Cambodia+CSPE+final+draft.pdf/963662a4-168d-4822-a0b7-730d6c66ee46*

ទី ៤ ដែលប្រកាសនៅខែកញ្ញាឆ្នាំ ២០១៨។ យុទ្ធសាស្ត្រចតុកោណផ្តល់នូវក្របខ័ណ្ឌអភិវឌ្ឍន៍ ដែលនឹងត្រូវអនុវត្តក្នុងរយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៣។

យុទ្ធសាស្ត្រចតុកោណ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងរយៈពេល ៥ ឆ្នាំខាងមុខ។ យុទ្ធសាស្ត្រចតុកោណ បានធ្វើបច្ចុប្បន្នភាពចំនួនបួនដងនៅក្នុងទសវត្សចុងក្រោយនេះ ដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែង។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ (រូបភាពទី ៣) មានគោលបំណង ពង្រឹងអភិបាលកិច្ចល្អ នីតិរដ្ឋ និងការកសាងស្ថាប័ន ដែលជាធាតុសំខាន់របស់សង្គមមួយ រួមជាមួយការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងមនុស្ស និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។




រូបភាពទី 3៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ទាំងបីដំណាក់កាលចុងក្រោយ ដែលនាំមកនូវមោទនភាពបំផុតដល់ប្រទេសកម្ពុជា ។ ជារួម យុទ្ធសាស្ត្រចតុកោណ ទាំងបីដំណាក់កាលចុងក្រោយ បានក្លាយជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដ៏ចម្បងរបស់កម្ពុជា។ ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាល ធ្វើឱ្យខឿនសេដ្ឋកិច្ចរីកចម្រើនឡើង ហើយជីវភាពរស់នៅរបស់ប្រជាជនកាន់តែល្អប្រសើរឡើង ទាំងផ្នែកសម្ភារៈ និងផ្លូវចិត្ត ដោយសារកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ការបង្កើតការងារ សមធម៌សង្គម និងការពង្រឹងអភិបាលកិច្ចនៅក្នុងជួរស្ថាប័នរដ្ឋាភិបាល។ នៅក្នុងរយៈពេលមធ្យមខាងមុខ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជានឹងឈានដល់ដំណាក់កាល “ផ្លាស់ប្តូរថ្មី” ដែលមានឈ្មោះជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។

ការពង្រឹងបន្ថែមនៅក្នុងស្ថាប័នសាធារណៈដែលចាំបាច់មានដូចជា ការពង្រឹងរចនាសម្ព័ន្ធស្ថាប័ននីតិរដ្ឋ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ នៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម ដែលកត្តាទាំង

នេះមានសារសំខាន់នៅក្នុងដំណើរការប្រជាធិបតេយ្យ សំដៅជំរុញឱ្យមានកំណើនសេដ្ឋកិច្ចខ្ពស់ កែប្រែរចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច បង្កើតការងារល្អៗជូនយុវជន បំពេញតម្រូវការរបស់ប្រជាជនដែលកំពុងកើនឡើងជាលំដាប់។ ការទទួលបានសេវាសាធារណៈប្រកបដោយគុណភាព ដូចជា ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការអប់រំ ការថែទាំសុខភាព ឬសេវាកម្មមូលដ្ឋានផ្សេងទៀត។ ធានាសន្តិសុខសង្គមនិងសុខមាលភាពរបស់ប្រជាជន ធានានូវសន្តិសុខប្រាក់ចំណូលជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ។ ធានាបាននូវគម្លាតអភិវឌ្ឍន៍ប្រកបដោយតុល្យភាព រវាងតំបន់ទីក្រុងនិងជនបទ។ មានការប្រុងប្រយ័ត្នខ្ពស់ និងភាពបត់បែនទៅតាមការអភិវឌ្ឍក្នុងតំបន់ និងពិភពលោក។ ទាញយកអត្ថប្រយោជន៍ពេញលេញពីការអភិវឌ្ឍបច្ចេកវិទ្យា និងឌីជីថលជាពិសេសនៅក្នុងបដិវត្តឧស្សាហកម្មទី៤ ។ ហើយចុងក្រោយ បង្កើនប្រសិទ្ធភាពនៃការការពារ និងអភិរក្សបរិស្ថាន ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជីវចម្រុះ ព្រៃឈើ និងជម្រកសត្វព្រៃក៏ដូចជាការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ផ្អែកលើសមិទ្ធិផលលេចធ្លោដែលសម្រេចបានតាមរយៈ ការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាលចុងក្រោយ ក៏ដូចជាតម្រូវការដើម្បីអភិវឌ្ឍប្រទេសកម្ពុជាបន្ថែមទៀតដូចដែលបានបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវ " វេទិកានយោបាយ" ដែលទទួលបានការគាំទ្រជាច្រើនពីប្រជាពលរដ្ឋ។ ជាក់ស្តែង ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌នាពេលថ្មីៗនេះបានបង្ហាញថា អត្រាអ្នកទៅបោះឆ្នោតមានចំនួនរហូតដល់ ៨៣,០៣% ។

វេទិកានយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាក្របខ័ណ្ឌគោលនយោបាយគន្លឹះសម្រាប់បង្កើត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដែលបានកំណត់សូចនាករ និងរយៈពេលសម្រាប់ការអនុវត្ត ដែលត្រូវស្របនឹងគោលនយោបាយតាមវិស័យរបស់រដ្ឋាភិបាល។ ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នឹងក្លាយជាផែនការមេដើម្បីណែនាំសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ឱ្យស្ថិតនៅក្នុងប្រព័ន្ធរស់រវើកមួយ ដែលនឹងជំរុញការអភិវឌ្ឍក្នុងរយៈពេលមធ្យម និងវែង ប្រកបដោយចីរភាព ដោយធានាប្រសិទ្ធភាពនៃការគ្រប់គ្រងស្ថាប័នសាធារណៈ និងធនធានទាំងអស់។

ក្នុងបរិបទនេះ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចសង្គម របស់រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា ក្រោមឆ័ត្រនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងម្លប់ដ៏ត្រជាក់របស់ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

## បញ្ហាប្រឈម និងឱកាសរបស់ប្រទេសកម្ពុជា

**បញ្ហាប្រឈមនៅក្នុងរយៈពេលមធ្យម៖** ប្រទេសកម្ពុជានឹងក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងមានការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងការផ្លាស់ប្តូរប្រជាសាស្ត្រ ដែលនឹងប្រឈមបញ្ហាមួយចំនួនដូចខាងក្រោម៖

១. សេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោកនឹងនៅតែមិនបិតថេរដោយសារតែ "សង្គ្រាមពាណិជ្ជកម្ម" ដែលបណ្តាលមកពីគោលនយោបាយគាំពារនិយម ការរក្សាលំនឹងរូបិយវត្ថុនៅក្នុងប្រទេសអភិវឌ្ឍន៍ កំណើនឥណទានយ៉ាងឆាប់រហ័សនៅក្នុងប្រទេសចិន ដូចជាការកើនឡើងតម្លៃប្រេង និងបញ្ហាផ្សេងៗទៀតដែលទាក់ទងនឹងភូមិសាស្ត្រនយោបាយ ភេរវកម្ម និងសន្តិសុខពិភពលោកជាដើម។

ស្ថានភាពទាំងនេះអាចជះឥទ្ធិពលអាក្រក់ដល់សេដ្ឋកិច្ចកម្ពុជាដែលពឹងផ្អែកលើពាណិជ្ជកម្មអន្តរជាតិ ដើម្បីពន្លឿនការអភិវឌ្ឍប្រទេស។

២. ការធានានូវសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមនឹងនៅតែជាបញ្ហាប្រឈមធំ ដោយសារតែភាពផុយស្រួយកើតមានឡើងទាំងក្នុងនិងក្រៅប្រទេស។ ដូច្នេះការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងផលិតភាពដែលឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជាកត្តាដ៏សំខាន់បំផុតក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែងរបស់ប្រទេសនាពេលបច្ចុប្បន្ន និងក្នុងរយៈពេលវែង។ ទោះបីគោលដៅជំរុញការបញ្ចប់ថ្នាក់បឋមសិក្សាបានសំរេចដោយជោគជ័យក៏ដោយ បញ្ហាប្រឈមនៅតែមានពាក់ព័ន្ធនឹងការបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំខ្ពស់ទៀត ដើម្បីទទួលបានអត្ថប្រយោជន៍ពីបច្ចេកទេសជឿនលឿន និងនវានុវត្តន៍ឧស្សាហកម្ម នាពេលបច្ចុប្បន្ន។

៣. ការធ្វើពិពិធកម្ម និងការបង្កើតតម្លៃបន្ថែមនៅក្នុងវិស័យឧស្សាហកម្មនិងសេវាកម្ម។ បញ្ហាប្រឈមរួមមានសម្ពាធកំណើនប្រាក់ឈ្នួល ទំនាក់ទំនងការងារ ថ្លៃដើមដឹកជញ្ជូនខ្ពស់ ការបង្កើនប្រសិទ្ធភាពប្រព័ន្ធដឹកជញ្ជូន ថ្លៃអគ្គិសនីខ្ពស់បើប្រៀបធៀបនឹងប្រទេសជិតខាង ចំណាយក្រៅផ្លូវការ និងបរិយាកាសធុរកិច្ចស្មុគស្មាញ។

៤. ការជំរុញការធ្វើពិពិធកម្ម និងផលិតភាពនៃវិស័យកសិកម្មនៅតែជាបញ្ហាប្រឈមដែលត្រូវដោះស្រាយជាបន្ទាន់ ពីព្រោះកសិកម្មនៅតែដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិជាពិសេសការចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ការកែលម្អជីវភាពរស់នៅ និងការបង្កើតការងារដល់ប្រជាជនជាដើម។ លើសពីនេះទៅទៀត កសិកម្មជួយទប់ស្កាត់ប្រជាជនធ្លាក់ក្នុងភាពក្រីក្រ និងកាត់បន្ថយគម្លាតប្រាក់ចំណូលរបស់ប្រជាជន ក៏ដូចជាគម្លាតអភិវឌ្ឍន៍រវាងទីក្រុងនិងជនបទ។ សំខាន់ជាងនេះទៀតការវិនិយោគលើវិស័យកសិកម្មនឹងចូលរួមចំណែកក្នុងការធានាសន្តិសុខស្បៀងក្នុងរយៈពេលវែង ក៏ដូចជារក្សាតម្លៃស្បៀងក្នុងកម្រិតទាប ដើម្បីធានាបាននូវស្ថេរភាពនៃចំណូលរបស់ប្រជាជន។

៥. ការផ្តល់សេវាសាធារណៈ និងសេវាយុត្តិធម៌មិនទទួលបានការទុកចិត្តគ្រប់គ្រាន់នៅឡើយទេពីសាធារណជន។ ក្របខណ្ឌស្ថាប័ន និងគតិយុត្តិ ព្រមទាំងការយល់ដឹង និងសមត្ថភាពរបស់មន្ត្រីដើម្បីអនុវត្តច្បាប់គឺនៅមានកម្រិតនៅឡើយ។ ទន្ទឹមនឹងនេះការរៀបចំរចនាសម្ព័ន្ធ ក៏ដូចជាការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ មិនបានឆ្លើយតបពេញលេញចំពោះតម្រូវការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅឡើយទេ។

៦. គុណភាពនៃសេវាថែទាំសុខភាពនៅតែជាបញ្ហាប្រឈម ទោះបីជាមានការរីកចម្រើនខ្លាំងនៅក្នុងសេវាថែទាំសុខភាពសាធារណៈក៏ដោយ។ ខណៈពេលដែលជីវភាពរស់នៅរបស់ប្រជាជនមានការផ្លាស់ប្តូរ គោលនយោបាយសុខាភិបាលត្រូវតែពិនិត្យឡើងវិញលើគ្រប់វិស័យទាំងអស់ដូចជាការផ្គត់ផ្គង់ ការផ្តល់សេវា គុណភាពសេវាកម្ម ហិរញ្ញប្បទាន និងវិសាលភាពរបស់សេវាសុខាភិបាលជាដើម។

៧. បញ្ហាប្រឈមនៅក្នុងវិស័យហិរញ្ញវត្ថុរួមមាន អត្រាការប្រាក់ខ្ពស់ ប្រាក់សន្សំក្នុងស្រុកទាប និងបំណុលគ្រួសារកើនឡើង។ ខណៈពេលដែលវិស័យធនាគារ និងហិរញ្ញវត្ថុមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ប៉ុន្តែយើងឃើញថាកំណើនឥណទាន និងអត្រាការប្រាក់នៅតែខ្ពស់ដដែល ទោះបីជាមានការធ្លាក់ចុះបន្តិចម្តងៗក៏ដោយ។ លើសពីនេះការសន្សំក្នុងស្រុកមានកម្រិតទាបបានធ្វើឱ្យកម្ពុជាពឹងផ្អែកលើប្រភពដើមទុនខាងក្រៅដើម្បីវិនិយោគ។ ខណៈពេលដែលប្រទេសកម្ពុជាកំពុងបាត់បង់លទ្ធភាពក្នុងការទទួលបានប្រាក់កម្ចីសម្បទានជាបណ្តើរៗ ប្រាក់សន្សំក្នុងស្រុកនឹងក្លាយជាប្រភពដើមទុនដ៏សំខាន់សម្រាប់ការវិនិយោគសាធារណៈ និងឯកជន។

៨. ទោះបីជាការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិមានភាពល្អប្រសើរឡើងតាមរយៈការពង្រឹងការគ្រប់គ្រងធនធានរ៉ែក៏ដោយ ក៏ការអនុវត្តកំណែទម្រង់ព្រៃឈើ និងជលផលរួមទាំងការអភិរក្សជលផលក៏ដូចជាការកែទម្រង់ដីធ្លីក៏តម្រូវឱ្យមានការយកចិត្តទុកដាក់ដូចគ្នា។ ការកែលម្អការគ្រប់គ្រងធនធានទឹករួមទាំងប្រព័ន្ធអេកូឡូស៊ីរបស់បឹងទន្លេសាប និងទន្លេមេគង្គនៅតែមានបញ្ហាប្រឈមដែលទាមទារនូវការខិតខំប្រឹងប្រែង និងគំនិតផ្តួចផ្តើមបន្ថែមទៀតដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។ **លើសពីនេះ ការប្រែប្រួលអាកាសធាតុបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា។**

៩. ប្រទេសកម្ពុជានឹងលែងជាប្រទេសអភិវឌ្ឍន៍តិចតួចក្នុងពេលខាងមុខនេះ ដែលអាចនាំឱ្យមានការកាត់បន្ថយការអនុគ្រោះពីដៃគូអភិវឌ្ឍន៍សំខាន់ៗ។ ដូច្នេះកម្ពុជាចាំបាច់ត្រូវទាញយកផលប្រយោជន៍ជាច្រើនពីឱកាសនាពេលបច្ចុប្បន្ន ដើម្បីធានានិរន្តរភាពទីផ្សារ ក៏ដូចជាបង្កើនភាពប្រកួតប្រជែងដើម្បីលើកកម្ពស់ការធ្វើពិពិធកម្មផលិតផលសម្រាប់ការនាំចេញបន្ថែមទៀត។

**ឱកាស៖** បរិបទពិភពលោក និងក្នុងស្រុកបច្ចុប្បន្នផ្តល់ឱ្យកម្ពុជានូវឱកាសដូចខាងក្រោមៈ

១. នៅក្នុងបរិបទនៃការស្តារសេដ្ឋកិច្ចពិភពលោកដែលត្រូវបានគេរំពឹងថានឹងមានភាពប្រសើរជាងឆ្នាំមុនៗ ជាពិសេសជាមួយដៃគូពាណិជ្ជកម្មសំខាន់ៗ។ ប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងអាចរក្សានូវសន្ទុះកំណើនជាក់ស្តែងក្នុងរយៈពេលមធ្យម ដែលឆ្លុះបញ្ចាំងតាមរយៈសកម្មភាពអាជីវកម្មរីកចម្រើន និងបន្តការវិនិយោគផ្ទាល់ពីបរទេស ការកើនឡើងនូវតម្រូវការក្នុងស្រុក និងការកែលម្អពាណិជ្ជកម្មអន្តរជាតិជាដើម។

២. ការផ្លាស់ប្តូរមជ្ឈមណ្ឌលសេដ្ឋកិច្ចទៅតំបន់អាស៊ី ជាពិសេសអាស៊ីបូព៌ានៅតែជា «ឱកាសមាស» សម្រាប់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍ និងធ្វើទំនើបកម្មឧស្សាហកម្មផលិតកម្ម និងសេវាកម្មរួមជាមួយបណ្តាប្រទេសក្នុងតំបន់។ នៅពេលដែលប្រទេសកម្ពុជាស្ថិតនៅចំកណ្តាលនៃតំបន់នោះ កម្ពុជានឹងមានកំណើនសេដ្ឋកិច្ចដ៏រស់រវើកហើយអាចក្លាយជាផ្នែកសំខាន់មួយនៃខ្សែចង្វាក់ផលិតកម្ម នៅអាស៊ីបូព៌ា។

៣. ការប្រកួតប្រជែងគ្នាកាន់តែខ្លាំងរវាងតំបន់ពាណិជ្ជកម្មនៅអាស៊ីប៉ាស៊ីហ្វិកដូចជា ភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់គ្រប់ជ្រុងជ្រោយ ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក ក៏ដូចជាគំនិតផ្តួចផ្តើមនៃកិច្ចសហប្រតិបត្តិការដទៃទៀត នឹងនាំឱ្យមានការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញសេវាកម្ម និង

ការវិនិយោគយ៉ាងច្រើននៅក្នុងតំបន់។ និន្នាការនេះនឹងផ្តល់នូវឱកាសដល់ប្រទេសកម្ពុជាដែលជាសមាជិកអាស៊ាន ដើម្បីទទួលយកការវិនិយោគ និងពង្រីកទីផ្សារនាំចេញរបស់កម្ពុជា។ ទាំងនេះជាឱកាសដែលកម្ពុជាទទួលបានតាមរយៈការលើកកម្ពស់ឧស្សាហកម្ម និងទំនាក់ទំនងពាណិជ្ជកម្ម ការតភ្ជាប់រូបវន្តនិងស្ថាប័ន ជាមួយនឹងការធ្វើសមាហរណកម្មទៅក្នុងផលិតកម្ម និងអន្តរតំបន់ជាដើម។

៤. ប្រទេសកម្ពុជាមានសក្តានុពលដ៏ធំធេងសម្រាប់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុបន្ថែមទៀត រួមទាំងការធ្វើប្រតិបត្តិការអន្តរការីហិរញ្ញវត្ថុ ការលើកកម្ពស់ឧស្សាហកម្មធានារ៉ាប់រង និងការអភិវឌ្ឍទីផ្សារសុវត្ថិភាព។ អត្រាប្រជាជនដែលត្រូវការទំនុកបម្រុងមានទាប រួមជាមួយនឹងការកើនឡើងចំនួនប្រជាជនដែលមានចំណូលមធ្យម នឹងបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ប្រទេសកម្ពុជាដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល ៣ ទសវត្សខាងមុខទៀត។ ការជឿនលឿនផ្នែកបច្ចេកវិទ្យានៅក្នុងដំណាក់កាលបច្ចុប្បន្ននៃបដិវត្តឧស្សាហកម្ម ៤.០ នឹងនាំឱ្យមានការកើនឡើងនូវការងារ និងមុខជំនួញថ្មីៗ។ សេដ្ឋកិច្ចឌីជីថលដែលកំពុងជឿនលឿនយ៉ាងឆាប់រហ័សនឹងផ្តល់នូវឱកាសដ៏ល្អសម្រាប់ប្រទេសកម្ពុជាក្នុងការកែលម្អរចនាសម្ព័ន្ធសេដ្ឋកិច្ចដោយសារអត្រាអ្នកប្រើប្រាស់ទូរស័ព្ទ និងអ៊ីនធឺណេតហក់ឡើងខ្ពស់។

ទោះយ៉ាងណាភាពទន់ខ្សោយគឺស្ថិតនៅលើប្រសិទ្ធភាពនៃការអនុវត្តដែលទាក់ទងនឹងសមត្ថភាពស្ថាប័ន និងប្រសិទ្ធភាពនៃការសម្របសម្រួលអន្តរស្ថាប័នក្នុងការដាក់ចេញ និងអនុវត្តវិធានការគោលនយោបាយជាក់ស្តែង។ លើសពីនេះទៅទៀតវានៅតែមានចន្លោះប្រហោងក្នុងសកម្មភាពប្រចាំថ្ងៃដែលមិនត្រូវបានបន្សុីជាមួយនឹងគោលដៅ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នក្រសួងនានា។ ក្នុងន័យនេះតម្រូវការដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទិដ្ឋភាពដូចតទៅ៖

១. ការពង្រឹងនិងពង្រីកសមិទ្ធិផលរបស់រាជរដ្ឋាភិបាលជាការចាំបាច់ណាស់ក្នុងនីតិកាលទី ៥ ក៏ដូចជាដើម្បីបំពេញភារកិច្ចដែលនៅសេសសល់ក្នុងដំណាក់កាលទាំងបីនៃយុទ្ធសាស្ត្រចតុកោណកន្លងមកតាមរយៈ ការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជាដើម។ លើកកម្ពស់ ច្បាប់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរប្រជាធិបតេយ្យសេរីពហុបក្ស និងអនុវត្តវិធានការជាក់ស្តែងដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាជនជាពិសេសការដោះស្រាយបញ្ហា «ប្រសិទ្ធភាព» ក្នុងអភិបាលកិច្ច និងយុត្តិធម៌សង្គមក៏ដូចជាការលើកកម្ពស់គុណភាពសេវាកម្មសាធារណៈផងដែរ។

២. តម្រូវការក្នុងការស្វែងរកប្រភពកំណើនថ្មីដើម្បីធានាកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយនិរន្តរភាពដោយចាប់យកប្រយោជន៍ពីឱកាសក្នុងតំបន់ ដើម្បីបង្កើតតម្លៃបន្ថែមនៅក្នុងសសរស្តម្ភសេដ្ឋកិច្ចដែលមានស្រាប់ និងអនុវិស័យពាក់ព័ន្ធ ជំរុញការវិនិយោគលើវិស័យកសិកម្ម ត្រៀមខ្លួនក្នុងការទទួលយកបច្ចេកវិទ្យាថ្មីៗក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល ក៏ដូចជាការចាប់យកឱកាសដោះស្រាយឧបសគ្គផ្សេងៗក្នុងបរិបទបដិវត្តឧស្សាហកម្ម ៤.០។ លើកកម្ពស់សមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាឆ្លើយតបទៅនឹងកង្វល់ និងតម្រូវការរបស់ប្រជាជនក្នុងដំណាក់កាលអភិវឌ្ឍន៍ថ្មី

ព្រមទាំងគោលដៅរបស់យើងដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមនៅឆ្នាំ ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។

លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបានកំណត់យក «គោលដៅយុទ្ធសាស្ត្រចំនួន៤» និង «វិស័យអាទិភាព ៤» ជាការប្តេជ្ញាចិត្តក្នុងការបន្តអនុវត្ត «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤» នេះ។

**គោលដៅយុទ្ធសាស្ត្រទាំង ៤ មានដូចជា៖**

១. ធានាឱ្យបានកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចថ្មីៗ ដោយទូលំទូលាយ និងមានភាពប្រកួតប្រជែងជាមួយនឹងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការគ្រប់គ្រងអត្រាអតិផរណាឱ្យនៅទាប ការធានាស្ថិរភាពអត្រាប្តូរប្រាក់ និងការខិតខំបង្កើនទុនបម្រុងជាប្រចាំ និងការគ្រប់គ្រងបំណុលសាធារណៈយ៉ាងប្រុងប្រយ័ត្ន។

២. បង្កើនការងារឱ្យបានកាន់តែច្រើន ទាំងគុណភាព និងបរិមាណ ជូនដល់ប្រជាជនកម្ពុជាជាពិសេសយុវជន តាមរយៈការបណ្តុះបណ្តាលជំនាញ ការផ្តល់ព័ត៌មានទីផ្សារការងារ ការកែលម្អលក្ខខ័ណ្ឌការងារ និងការលើកកម្ពស់សកម្មភាពធុរកិច្ច និងការវិនិយោគទាំងក្នុង និងក្រៅប្រទេស។

៣. សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០% ការពារមិនឱ្យភាពក្រីក្រវិលត្រឡប់មកវិញ ដោយផ្តោតលើការលើកកម្ពស់ការចូលរួមក្នុងយន្តការទីផ្សារ ការអនុវត្តគោលនយោបាយគាំពារសង្គម កាត់បន្ថយបន្ទុកជីវភាពរស់នៅ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងការកាត់បន្ថយគម្លាតសង្គម។

៤. បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ ក៏ដូចជាកែលម្អបរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។ ក្នុងនីតិកាលកន្លងមករាជរដ្ឋាភិបាលបានកំណត់វិស័យអាទិភាពចំនួន ៤ គឺ វិស័យហេដ្ឋារចនាសម្ព័ន្ធ ទឹក អគ្គិសនី និងប្រជាជន ដើម្បីកំណត់គោលដៅសម្រាប់ការអភិវឌ្ឍ ខណៈដែលវិស័យអាទិភាពទាំង ៤នេះត្រូវបានកែប្រែយោងតាមដំណាក់កាលនៃការអភិវឌ្ឍ។ នៅក្នុងនីតិកាលពីរដំបូង យុទ្ធសាស្ត្រចតុកោណផ្តល់អាទិភាពខ្ពស់ដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ បន្ទាប់មកវិស័យទឹក អគ្គិសនី និងប្រជាជន។

នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៣ ប្រជាជនបានក្លាយជាអាទិភាពទីមួយបន្ទាប់មកគឺ ផ្លូវអគ្គិសនី និងទឹក។ សម្រាប់នីតិកាលទី ៦ នេះយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ នឹងបន្តផ្តោតលើ វិស័យអាទិភាពទាំងបួនដដែល ប៉ុន្តែផ្តល់អាទិភាពដល់ប្រជាជនមុនគេ។ ក្នុងន័យនេះ ចតុកោណយុទ្ធសាស្ត្រ ទាំងបួននៃយុទ្ធសាស្ត្រចតុកោណនឹងត្រូវបានកែលម្អដើម្បីឆ្លុះបញ្ចាំងពីវិស័យអាទិភាពទាំងបួន និងកិច្ចការផ្សេងៗទៀតដែលឆ្លើយតបទៅនឹងដំណាក់កាលអភិវឌ្ឍន៍ថ្មីរបស់ប្រទេសកម្ពុជាដូចតទៅ៖

- **ចតុកោណទី ១. ការអភិវឌ្ឍន៍ធនធានមនុស្ស** រួមមាន ១) ការលើកកម្ពស់គុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្តុះបណ្តាលវិជ្ជាជីវៈ ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង ៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។

- **ចតុកោណទី ២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច** រួមមាន ១) កែលម្អនូវប្រព័ន្ធដឹកជញ្ជូន ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល ២) ការអភិវឌ្ឍប្រភពនៃកំណើនសេដ្ឋកិច្ចគន្លឹះ ៣) ការត្រៀមខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងបដិវត្តឧស្សាហកម្ម ៤.០ និង ៤) ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ។
- **ចតុកោណទី ៣. ការលើកស្ទួយវិស័យឯកជន និងការងារ** រួមមាន ១) ការអភិវឌ្ឍទីផ្សារការងារ ២) ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម និងសហគ្រិនភាព ៣) ការរៀបចំ និងអនុវត្តភាពជាដៃគូវិស័យសាធារណៈ និងឯកជន និង ៤) ការពង្រឹងការប្រកួតប្រជែង។
- **ចតុកោណទី ៤. ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន** រួមមាន ១) ការលើកស្ទួយវិស័យកសិកម្ម និងការអភិវឌ្ឍជនបទ ២) ការពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ និងវប្បធម៌ប្រកបដោយចីរភាព ៣) ការកាត់បន្ថយភាពក្រីក្រតាមរយៈការអនុវត្តយន្តការការពារសង្គមនិងការទប់ស្កាត់ភាពក្រីក្រឡើងវិញ តាមរយៈការលើកកម្ពស់ការចូលរួមរបស់ប្រជាជនក្នុងការទទួលបានអត្ថប្រយោជន៍ពីទីផ្សារដោយមិនពឹងផ្អែកលើការគាំទ្រពីរដ្ឋាភិបាល ដោយពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម និង ៤) ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

**សេចក្តីសង្ខេប**

- វេទិកានយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភានិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាក្របខ័ណ្ឌគោលនយោបាយគន្លឹះសម្រាប់បង្កើត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ ដែលបានកំណត់សូចនាករ និងរយៈពេលសម្រាប់ការអនុវត្ត ដែលត្រូវស្របនឹងគោលនយោបាយតាមវិស័យរបស់រដ្ឋាភិបាល។
- **កម្មវិធីមូលនិធិអាកាសធាតុបៃតងប្រចាំប្រទេស ដែលបង្ហាញពីសំណើគម្រោងអាទិភាព អាចចូលរួមចំណែកតូចមួយក្នុងការធ្វើឱ្យយុទ្ធសាស្ត្រចតុកោណទទួលបានជោគជ័យ។**

## ជំពូកទី៣ ៖ ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ និងទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ

ជំពូកនេះបង្ហាញសេចក្តីសង្ខេបអំពីព័ត៌មានការប្រែប្រួលអាកាសធាតុ ការឆ្លើយតប និងទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ និងបង្ហាញអំពីឱកាសដែលប្រទេសកម្ពុជាមាន។ នេះគឺជាការរំលឹកមួយ ដើម្បីជានាថាឯកសារទស្សនទាន និង សំណើថវិកា ដែលរៀបចំឡើងត្រូវបានបន្សុីជាមួយនឹងគោលនយោបាយអាកាសធាតុនៅប្រទេសកម្ពុជា។

### ៣.១ ការឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជារងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ ដែលបង្កឱ្យមានបញ្ហាកង្វះខាតធនធានទឹក អសន្តិសុខស្បៀង ការរេចរិលដីធ្លី និងគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាសហគមន៍កម្ពុជាផងដែរ។ ការគំរាមកំហែងទាំងនេះកាន់តែធ្ងន់ធ្ងរដោយសារព្រឹត្តិការណ៍ធាតុអាកាស ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ទឹកភ្លៀង ខ្យល់ព្យុះរដូវវស្សា និងរលកកំដៅ មានការកើតឡើងកាន់តែញឹកញាប់ និងកាន់តែខ្លាំងក្លាជាងមុន។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ប្រទេសកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រងអភិបាលកិច្ចអាកាសធាតុដូចមានបង្ហាញក្នុងសកម្មភាពដូចខាងក្រោម៖

១. ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៩៥។ អនុសញ្ញានេះចូលជាធរមានសម្រាប់ប្រទេសកម្ពុជានៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៩៩៦។ ប្រទេសកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយក្លាយជារដ្ឋភាគីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

២. ការិយាល័យប្រែប្រួលអាកាសធាតុបានបង្កើតក្នុងឆ្នាំ ២០០៣ ហើយតាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ១៧៥ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៩ ត្រូវបានតំឡើងទៅជានាយកដ្ឋានប្រែប្រួលអាកាសធាតុ នៅក្រោមអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ដែលមានបេសកកម្មចូលរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

៣. នៅក្នុងខែឧសភា ឆ្នាំ ២០១៥ ដើម្បីឆ្លើយតបទៅនឹងការកែទម្រង់រចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថាន នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) ត្រូវបានផ្លាស់ប្តូរទៅនៅក្រោមអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD) ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព ដើម្បីធានាតុល្យភាព សេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. រដ្ឋាភិបាលកម្ពុជាបានតែងតាំងរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាតំណាងស្ថាប័នជាតិទទួលបន្ទុកមូលនិធិអាកាសធាតុបៃតង ដែលមាននាយកដ្ឋានប្រែប្រួលអាកាសធាតុ ជាអង្គភាពបង្គោលសម្រាប់ទំនាក់ទំនងការងារផ្សេងៗ។

៥. បានបញ្ជូនរបាយការណ៍ជាតិលើកទី ២ (SNC, ២០១៥)[2] ផែនការជាតិបន្សាំ (NAP) ការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញា UNFCCC (NDC) នៅខែសីហា ឆ្នាំ ២០១៥ និងរបាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង(BUR) រួមជាមួយឧបសម្ព័ន្ធបច្ចេកទេសនៅខែកញ្ញា ឆ្នាំ ២០២០ ដល់ UNFCCC។

**ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣)៖** ចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ត្រូវបានរៀបចំឡើងដោយផ្អែកលើការវិភាគសមត្ថភាពស្ថាប័ន សង្កេតឃើញពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការព្យាករណ៍អាកាសធាតុផងដែរ។

**ចក្ខុវិស័យ៖** ប្រទេសកម្ពុជាមានការអភិវឌ្ឍឆ្ពោះទៅរកសង្គមបៃតង ការបញ្ចេញកាបូនតិច មានភាពធន់នឹងអាកាសធាតុ សមភាព និរន្តរភាព និងសង្គមផ្អែកលើចំណេះដឹង។

**បេសកកម្ម៖** បង្កើតក្របខ័ណ្ឌជាតិសម្រាប់ការចូលរួមរបស់វិស័យសាធារណៈ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នៅក្នុងដំណើរការចូលរួម ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

**គោលដៅ៖**

- កាត់បន្ថយភាពងាយរងគ្រោះលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុរបស់ប្រជាជន ជាពិសេសក្រុមងាយរងគ្រោះ និងប្រព័ន្ធសង្គម និងធម្មជាតិ
- ផ្លាស់ប្តូរឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍បៃតង ដោយលើកកម្ពស់ការអភិវឌ្ឍ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមក្នុងសកម្មភាពឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចឱ្យបានចក្ខុវិស័យ បេសកកម្ម និងគោលដៅ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលបំណង យុទ្ធសាស្ត្រចំនួន ៨ ដូចខាងក្រោម៖

១. លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល

២. កាត់បន្ថយហានិភ័យតាមវិស័យ តាមតំបន់ ភាពងាយរងគ្រោះយេនឌ័រ និងសុខភាព ចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ

៣. ធានាឱ្យមានភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ តំបន់ខ្ពង់រាប ។ ល ។) ជីវចម្រុះ តំបន់ការពារ និងតំបន់បេតិកភណ្ឌវប្បធម៌ ជាដើម

៤. ជំរុញការធ្វើផែនការ និងការប្រើប្រាស់បច្ចេកវិទ្យាកាបូនតិចដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព

[2] *https://unfccc.int/resource/docs/natc/khmnc2.pdf*

៥. លើកកម្ពស់សមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៦. ជំរុញការគាំពារសង្គមឱ្យមានការបន្សាំ និងជំរុញវិធីសាស្ត្រចូលរួមក្នុងការកាត់បន្ថយការបាត់បង់ និងការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ។

៧. ពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសម្របសម្រួលសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

៨. ពង្រឹងកិច្ចសហប្រតិបត្តិការ និងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការប្រែប្រួលកាសធាតុទាំងក្នុងតំបន់ និងពិភពលោកផងដែរ។

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣) បានដាក់ចេញនូវសកម្មភាពមួយចំនួនដែលត្រូវបានរៀបចំអនុវត្តជាបីដំណាក់កាលដូចខាងក្រោម៖

**ក្នុងរយៈពេលខ្លី (២០១៣ - ២០១៤)៖** ដំណាក់កាលនេះផ្តោតសំខាន់លើការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុសម្រាប់ការអនុវត្ត ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ការអភិវឌ្ឍក្របខ័ណ្ឌនិងសូចនាករត្រួតពិនិត្យនិងវាយតម្លៃជាតិ (M&E) និងការអភិវឌ្ឍផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (២០១៤ - ២០១៨) ដោយក្រសួងពាក់ព័ន្ធនានា។

**ក្នុងរយៈពេលមធ្យម (២០១៤ - ២០១៨)៖** ដំណាក់កាលនេះនឹងបន្តគាំទ្រដល់ការអនុវត្តនូវអ្វីដែលបានគ្រោងទុកនៅដំណាក់កាលទី ១ ដោយការបង្កើនលើសកម្មភាពផ្សេងៗ ដូចជាការទទួលស្គាល់ដោយមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង។ ការស្រាវជ្រាវ និងការគ្រប់គ្រងចំណេះដឹង ការអភិវឌ្ឍសមត្ថភាព ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅតាមវិស័យនានាក្នុងកម្រិតខុសៗគ្នា ប្រតិបត្តិការតាមដាន និងវាយតម្លៃ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងដាក់ឱ្យដំណើរការគម្រោង / កម្មវិធីអាទិភាពខ្ពស់មួយចំនួននៅក្នុងវិស័យសំខាន់ៗដែលបានកំណត់នៅក្នុងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ។ សកម្មភាពបន្សាំគឺជាអាទិភាពដំបូងដែលបានផ្តល់ឱ្យ ប៉ុន្តែសកម្មភាពកាត់បន្ថយនឹងត្រូវបានដាក់បញ្ចូលបន្ទាប់។ រដ្ឋាភិបាលអាចនឹងធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤ - ២០២៣ ឈរលើមេរៀនដែលទទួលបានពីការអនុវត្តនៅដំណាក់កាលទី ១ និងទី ២។

**រយៈពេលវែង (២០១៩ - ២០២៣)៖** ដំណាក់កាលនេះគឺផ្តោតលើការសិក្សាស្រាវជ្រាវ ប៉ុន្តែគោលបំណងសំខាន់បំផុតគឺដើម្បីពង្រីកភាពជោគជ័យ និងបន្តការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្រៅពីនេះ ក៏មានការផ្តល់ថវិកាជាតិបន្ថែម ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ។ **GCF ផ្តល់នូវឱកាសដើម្បីកែប្រែគោលនយោបាយទៅជាដំណោះស្រាយអាកាសធាតុជាក់ស្តែង ដែលជាអាជីវកម្មរួមបញ្ចូលគ្នា ដើម្បីផ្តល់ផលប្រយោជន៍ដល់សហគមន៍។**

## ៣.២ ទិដ្ឋភាពហិរញ្ញប្បទានអន្តរជាតិ និងមូលនិធិអាកាសធាតុបៃតង

ផ្នែកនេះពន្យល់ពីទិដ្ឋភាពទូទៅនៃប្រភពហិរញ្ញប្បទានទ្វេភាគី និងពហុភាគីសំខាន់ៗ ដើម្បីពង្រីកភាពជោគជ័យលើការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ រួមមាន មូលនិធិអាកាសធាតុបៃតង (GCF) មូលនិធិបន្សាំ (AF) មូលនិធិបរិស្ថានពិភពលោក (GEF) និងមូលនិធិពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុ ជាពិសេសមជ្ឈមណ្ឌលបណ្តាញ បច្ចេកវិទ្យាអាកាសធាតុ (រូបភាពទី ៤ និងទី ៥) GCF អាច

នឹងក្លាយជាប្រភពហិរញ្ញវត្ថុពហុភាគីដ៏សំខាន់ ដែលផ្តល់មូលនិធិដល់សកម្មភាពអាកាសធាតុនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (រួមទាំងប្រទេសកម្ពុជា) តាមរយៈការសហការពីមូលនិធិផ្សេងទៀតៗផងដែរ ដូចជា មូលនិធិបន្សុំា ដើម្បីសម្រេចឱ្យបាននូវកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

មូលនិធិអាកាសធាតុបៃតង ផ្តល់ឱកាសច្រើនជាងគេដល់ប្រទេសកម្ពុជា ហើយកម្ពុជានឹងបន្តបង្កើនសមត្ថភាពក្នុងការត្រៀមខ្លួនទទួលបានមូលនិធិនេះ តាមរយៈ ការទទួលបានមូលនិធិដោយផ្ទាល់ (Direct Access) ការទទួលបានមូលនិធិតាមដំណើរការងាយស្រួល (Simplified Approval Process) និងការគាំទ្រដល់វិស័យឯកជន។** ការធានារ៉ាប់រងអាកាសធាតុ ផ្តល់ឱកាសដ៏ល្អសម្រាប់ការប្រើប្រាស់ធនធានរបស់មូលនិធិអាកាសធាតុបៃតងក្នុងការបង្កើនការធានារ៉ាប់រងសន្ទស្សន៍អាកាសធាតុនៅកម្រិតកសិដ្ឋាន។

## ៣.៣ តើមូលនិធិអាកាសធាតុបៃតង គឺជាអ្វី? តើត្រូវធ្វើដូចម្តេចខ្លះដើម្បីទទួលបានមូលនិធិ?

### ក. លក្ខខណ្ឌតម្រូវ និងវិស័យអាទិភាពរបស់មូលនិធិអាកាសធាតុបៃតង៖

- ប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ដែលជាហត្ថលេខី UNFCCC មានសិទ្ធិដាក់ពាក្យស្នើសុំធនធានពីមូលនិធិអាកាសធាតុបៃតងបាន

- ធនធានរបស់មូលនិធិអាកាសធាតុបៃតងនឹងប្រើដើម្បីរ៉ាប់រងលើចំណាយបន្ថែមលើសកម្មភាពបន្សុំាសកម្មភាពកាត់បន្ថយ (រួមទាំងរេដបូក) ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា (រាប់បញ្ចូលទាំងការចាប់យកនិងផ្ទុកកាបូន) ការកសាងសមត្ថភាព និងការរៀបចំរបាយការណ៍ជាតិដោយប្រទេសកំពុងអភិវឌ្ឍន៍ ព្រមទាំងគម្រោង/កម្មវិធី ផ្សេងៗ

- មូលនិធិអាកាសធាតុបៃតងផ្តោតសំខាន់លើវិស័យអាទិភាពចំនួន ៨ និងលើកទឹកចិត្តឱ្យបែងចែកធនធាន ៥០ ភាគរយដល់គម្រោង/កម្មវិធីសម្រាប់ការបន្សុំា និង ៥០ ភាគរយដល់គម្រោង/កម្មវិធីសម្រាប់ការកាត់បន្ថយ ព្រមទាំងគម្រោង/កម្មវិធីពហុវិស័យ (រូបភាព ៦)។

### ខ. ការបែងចែកធនធាន ៖

- គោលការណ៍ណែនាំរបស់ មូលនិធិអាកាសធាតុបៃតង គឺផ្តោតលើសំណើគម្រោង ដែលមានចរិតពហុវិស័យ ផ្អែកលើលទ្ធផល ផ្អែកលើអាទិភាពរបស់ប្រទេស និងមានតុល្យភាពភូមិសាស្ត្រ ព្រមទាំងមានសកម្មភាពកាត់បន្ថយនិងបន្សុំាក្នុងវិស័យឯកជននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ ធនធាន៥០ភាគរយត្រូវបានបម្រុងទុកសម្រាប់សកម្មភាពបន្សុំា នៅក្នុងប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ដែនកោះកំពុងអភិវឌ្ឍន៍ (SIDS) និងតំបន់អាហ្វ្រិក។

### គ. ប្រភេទជំនួយ និងរចនាសម្ព័ន្ធមូលនិធិ៖

- ប្រភេទជំនួយ ក្នុងក្របខ័ណ្ឌគម្រោងត្រៀម មូលនិធិអាកាសធាតុបៃតង គឺជាជំនួយបច្ចេកទេសក្នុងការរៀបចំឬពង្រឹងយុទ្ធសាស្ត្រ ឬផែនការអភិវឌ្ឍន៍ដែលបញ្ចេញឧស្ម័នតិច NAMAs NAPs NAPAs ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់សម្របសម្រួលក្នុងប្រទេស និងដើម្បីបំពេញតាមគោលការណ៍ធានានិងបទដ្ឋានការពារបរិស្ថាន និងសង្គម ដើម្បីឱ្យប្រទេសនានាអាចទទួលបានមូលនិធិដោយផ្ទាល់

• ប្រភេទជំនួយសម្រាប់វិស័យឯកជន អាចផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ និងដោយប្រយោល ដល់សកម្មភាពបន្សាំ/ការកាត់បន្ថយដែលជាអាទិភាពរបស់ប្រទេស ដើម្បីអនុវត្តនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ តាមរយៈការគាំទ្រ និងលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធនានា (សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម អ្នកផ្តល់សេវាកម្មអាជីវកម្ម ភ្នាក់ងារអន្តរការីហិរញ្ញវត្ថុក្នុងស្រុក) នៅក្នុងដែនកោះកំពុងអភិវឌ្ឍន៍ ប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍។




**រូបភាពទី 4៖ វិស័យអាទិភាពទាំង ៨ របស់មូលនិធិអាកាសធាតុបៃតងស្តីពីការបន្សាំនិងការកាត់បន្ថយ**




រូបភាពទី 5៖ ទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ




រូបភាពទី ៦៖ ទិដ្ឋភាពហិរញ្ញប្បទានអាកាសធាតុ និងបរិមាណថវិកា

## ជំពូកទី៤ ៖ ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ

នៅក្នុងជំពូកនេះនឹងពន្យល់ពីតួនាទី និងភារកិច្ចរបស់ភាគីសំខាន់ៗនានា ដែលពាក់ព័ន្ធនឹងផ្នែកហិរញ្ញប្បទានអាកាសធាតុនៅក្នុងប្រទេសកម្ពុជា ហើយតើស្ថាប័នជាតិទទួលបន្ទុក (NDA) និងនាយកដ្ឋានប្រែប្រួលអាកាសធាតុនឹងធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធដោយវិធីណា ដើម្បីទទួលបានហិរញ្ញប្បទានទាំងនោះមកប្រើប្រាស់ ដូចជា មូលនិធិអាកាសធាតុបៃតងជាដើម។ ប្រទេសកម្ពុជាត្រូវតែធានាឱ្យភាគីពាក់ព័ន្ធមានភាពជាម្ចាស់លើកម្មវិធីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការជំរុញឱ្យមានដំណើរការពិគ្រោះយោបល់ប្រកបដោយបរិយាប័ន្ន យុត្តិធម៌ តម្លាភាព និងបើកចំហ។ នៅក្នុងបរិបទនេះ ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEF) តម្រូវឱ្យមានការចូលរួមជាលក្ខណៈប្រព័ន្ធជាមួយនឹង ភាគីពាក់ព័ន្ធថ្នាក់ជាតិដែលពាក់ព័ន្ធនៅក្នុងដំណើរការ មូលនិធិអាកាសធាតុបៃតង នេះនៅក្នុងប្រទេសកម្ពុជា ព្រមទាំងការកំណត់យ៉ាងច្បាស់លាស់អំពីតួនាទី និងដំណើរការនៃការចូលរួម។

### ៤.១ គោលការណ៍ណែនាំរបស់ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ (SEF)

ក្របខ័ណ្ឌ និងដំណើរការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ[3][4]គោរពតាមគោលការណ៍ណែនាំដូចខាងក្រោម៖

#### i. វិធីសាស្រ្តពហុភាគី និងមានការចូលរួម

- ការបង្កើតភាពជាម្ចាស់ការដ៏រឹងមាំ ដោយមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធសំខាន់ៗគ្រប់វិស័យ នឹងជួយឱ្យទទួលបានភាពជោគជ័យក្នុងដំណើរការ GCF នៅក្នុងប្រទេសកម្ពុជា ដែលលើកស្ទួយការចូលរួមរបស់ពហុភាគី និងការពិគ្រោះយោបល់ប្រកបដោយបរិយាប័ន្ន តម្លាភាព យុទ្ធធម៌ និងបើកចំហ។ វិធីសាស្រ្តនេះនឹងជួយបំពេញបន្ថែមដល់តួនាទីរបស់ភាគីពាក់ព័ន្ធផ្សេងៗ និងលើកកម្ពស់ការសហការគ្នា និងលុបបំបាត់ឧបសគ្គនានា។
- ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ លើកកម្ពស់វប្បធម៌នៃការចែករំលែក ការទទួលខុសត្រូវក៏ដូចជាបំពេញចន្លោះឱ្យគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការ GCF ដោយផ្អែកលើតួនាទី ភារកិច្ច និងការទទួលខុសត្រូវដែលបានកំណត់យ៉ាងច្បាស់លាស់។

#### ii. ការរៀបចំកម្មវិធីប្រទាក់ក្រឡា

- ការរៀបចំកម្មវិធីប្រទាក់ក្រឡា ជាជាងការរៀបចំគម្រោងដាច់ដោយឡែក និងអនុវត្តនៅក្នុងដំណើរការនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ សម្រាប់ប្រទេសកម្ពុជា។ វិធីសាស្រ្តនេះនឹងធានាឱ្យមាននិរន្តរភាព ដោយកាត់បន្ថយការខិតខំប្រឹងប្រែងដូចគ្នា និងការងារជាន់គ្នា ព្រមទាំងលើក

---

[3] *Engaging with the Green Climate Fund: A resource guide for national designated authorities and focal points of recipient countries* *https://www.greenclimate.fund/documents/20182/194568/GCF_ELEMENTS_01.pdf/542c1610-81b4-40df-be62-025cef3d26d8*

[4] *United Nations Development Programme (2018). Engaging the Green Climate Fund – GCF Readiness Programme Report. New York, UNDP. http://www.gcfreadinessprogramme.org/sites/default/files/Lessons%20learnt-%20October10.pdf*

កម្ពស់កិច្ចសហប្រតិបត្តិការ និងការតាមដានការងារពាក់ព័ន្ធនឹង GCF ។ ភាគីពាក់ព័ន្ធថ្នាក់ជាតិនឹងដឹកនាំនិងគ្រប់គ្រងដំណើរការ GCF ដើម្បីធានាឱ្យបាននូវភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលដៅអភិវឌ្ឍ និងគោលដៅអាកាសធាតុជាតិ ព្រមទាំងអាទិភាព និងតម្រូវការ។

- ការចូលរួមរបស់ភាគីពាក់ព័ន្ធ ជាសកម្មភាពដែលមានជាបន្តបន្ទាប់មានការតាមដានជាចាំបាច់ធ្វើបច្ចុប្បន្នភាព និងធ្វើការវាយតម្លៃជាទៀងទាត់ជាជាងចាត់ទុកថាជាព្រឹត្តិការណ៍កើតឡើងតែម្តងហើយចប់។ ការអនុវត្តនិងរៀនសូត្របន្ថែមជាអាទិភាពរបស់ប្រទេសកម្ពុជា ខណៈដែលការកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធ និងការចូលរួមនៅក្នុងដំណើរការ GCF (មានការពន្យល់បន្ថែមនៅក្នុងជំពូកទី៥)។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលគាំទ្រដោយម្ចាស់ជំនួយមួយចំនួន បានផ្តល់នូវបទពិសោធន៍ និងមេរៀនដ៏មានតម្លៃរួចទៅហើយក្នុងការវាយតម្លៃ និងការអនុម័តលើជំនួយដល់គម្រោងផ្សេងៗ។ ការប្រឈមនឹងបញ្ហាទាំងនេះហើយនឹងផ្តល់ដំណឹងដល់ការរៀបចំក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ **ប៉ុន្តែបញ្ហាប្រឈមដែលនៅសេសល់ទាំងនេះ គឺជាវិធីដើម្បីជំរុញការចូលរួមយ៉ាងសកម្មពីសំណាក់ស្ថាប័នរដ្ឋ ស្ថាប័នឯកជន គ្រឹះស្ថានសិក្សា និងអង្គការសង្គមស៊ីវិល (ដែលមានបន្ទុកការងារប្រចាំថ្ងៃ និងអាទិភាពផ្ទាល់ខ្លួន) ដែលអាចគាំទ្រ NDA / DCC ដើម្បីចូលរួមចំណែកយ៉ាងឆាប់រហ័ស និងប្រកបដោយស្ថាបនាក្នុងការវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា (FP) និងការឧទ្ទេសនាមអង្គភាពដែលអាចក្លាយជាស្ថាប័នទទួលមូលនិធិដោយផ្ទាល់ (DAE)។**

### iii. ការលើកកម្ពស់យេនឌ័រ និងសង្គមនៅក្នុងវិស័យហិរញ្ញប្បទានអាកាសធាតុ

- ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ លើកកម្ពស់និងធានានូវដំណើរការពិគ្រោះយោបល់ដោយបើកចំហរ យុត្តិធម៌ តម្លាភាព បរិយាប័ន្ន និងឆ្លើយតបនឹងយេនឌ័រ (ឧទាហរណ៍ នីតិវិធីចេញលិខិតគាំទ្រ និងនីតិវិធីឧទ្ទេសនាមអង្គភាពដែលអាចទទួលមូលនិធិដោយផ្ទាល់)។ បញ្ហាយេនឌ័រនឹងត្រូវបានបញ្ជ្រាបទៅក្នុងយន្តការនៃការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការពិគ្រោះយោបល់ពហុភាគី និងពហុវិស័យ។ ការលើកកម្ពស់សុវត្ថិភាពសង្គម និងបរិស្ថាននៅក្នុងដំណើរការ GCF នៅក្នុងប្រទេសកម្ពុជា គឺជាលក្ខខណ្ឌតម្រូវ មួយក្នុងចំណោមលក្ខខណ្ឌតម្រូវសំខាន់ៗក្នុងការទទួលបានធនធានពី GCF ។

### iv. គ្មានទំនាស់ផលប្រយោជន៍របស់ស្ថាប័នពាក់ព័ន្ធចូលរួមក្នុងដំណើរការ GCF ឡើយ

ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ ធានាថាមិនមានទំនាស់ផលប្រយោជន៍របស់ស្ថាប័នពាក់ព័ន្ធដែលចូលរួមក្នុងដំណើរការ GCF ឡើយ។ ឧទាហរណ៍ នៅក្នុងជំពូកទី ៥ សមាជិកនៃក្រុមការងារប្រឹក្សាយោបល់របស់ GCF នឹងត្រូវចុះហត្ថលេខាលើក្រមសីលធម៌។

## ៤.២ ហេតុអ្វីបានជាភាគីពាក់ព័ន្ធត្រូវចូលរួមក្នុងដំណើរការ GCF ?

ភាពជាម្ចាស់នៃភាគីពាក់ព័ន្ធថ្នាក់ជាតិទាំងអស់នៅក្នុងដំណើរការរបស់មូលនិធិ GCF មានដូចជាស្ថាប័នជាតិទទួលបន្ទុក (NDA) នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) មន្ត្រីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD) ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង

ផែនការ និងក្រសួង-ស្ថាប័នរដ្ឋាភិបាលនានា គណៈកម្មការវាយតំលៃ GCF ស្ថាប័នទទួលមូលនិធិដោយផ្ទាល់ (DAE) និងអង្គភាពអន្តរជាតិទទួលបានសេចក្តីទុកចិត្ត (IAEs) ពិតជាមានសារៈសំខាន់ណាស់ក្នុងដំណើរការ GCF នៅប្រទេសកម្ពុជា។ ភាពជាម្ចាស់បែបនេះអាចធ្វើទៅបានលុះត្រាតែមានការចូលរួមពីស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការហិរញ្ញប្បទានអាកាសធាតុ / ដំណើរការ GCF ដោយផ្អែកលើតួនាទីចំណាប់អារម្មណ៍ និងសមត្ថភាពរបស់ស្ថាប័ននីមួយៗ។ ការចែករំលែកការទទួលខុសត្រូវក៏ដូចជាទំនួលខុសត្រូវ របស់ស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការ GCF គឺមានសារៈសំខាន់ដូចៗគ្នាដើម្បីធ្វើឱ្យដំណើរការ GCF កាន់តែមានតម្លាភាព និងគណនេយ្យភាព។ លើសពីនេះទៅទៀត ការចូលរួមប្រកបដោយអត្ថន័យ និងការសម្របសម្រួលមុខងាររបស់ស្ថាប័នពាក់ព័ន្ធនៅក្នុងដំណើរការ GCF នឹងនាំមកនូវភាពស៊ីសង្វាក់គ្នាក្នុងការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា និងជៀសវាងការធ្វើការងារជាន់គ្នា។

កិច្ចខិតខំប្រឹងប្រែងរួមគ្នា និងការសម្របសម្រួលរបស់ស្ថាប័នពាក់ព័ន្ធនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃដំណើរការ GCF នឹងឆ្ពោះទៅរកភាពជោគជ័យក្នុងការសម្រេចបាននូវលទ្ធផលដែលបានគ្រោងទុក។ ភាពជាម្ចាស់នឹងកើតមាននៅពេលផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល គ្រឹះស្ថានសិក្សា និងស្ថាប័នពាក់ព័ន្ធដទៃទៀតនៅក្នុងដំណើរការ GCF ទៅតាមតួនាទី និងភាពខ្លាំងរបស់អង្គភាពនីមួយៗ។

លើសពីនេះទៀត ភាពច្បាស់លាស់លើតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធដែលត្រូវចូលរួមក្នុងដំណើរការ GCF គឺតម្រូវឱ្យចៀសវាងការភាន់ច្រលំដែលអាចកើតមានក្នុងចំណោមស្ថាប័នពាក់ព័ន្ធដែលរួមចំណែកនៅក្នុងដំណើរការ GCF នេះផងដែរ។ ក្របខ័ណ្ឌនៃការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធត្រូវបានគេរំពឹងថានឹងនាំមកនូវភាពច្បាស់លាស់លើតួនាទីរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការ GCF នេះ។

ដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធជំរុញអោយមានការរួមបញ្ចូលគ្នា។ គោលនយោបាយការពារបរិស្ថាន និងសង្គមរបស់ GCF តម្រូវឱ្យរាល់សំណើថវិការៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថាននិងសង្គម ដែលមានការចូលរួមពីភាគីពាក់ព័ន្ធ និងស្របទៅនឹងបទប្បញ្ញត្តិរបស់ក្នុងមូលនិធិនេះ។

## ៤.៣ ភាគីពាក់ព័ន្ធសំខាន់ៗ និងអាទិភាពរបស់ភាគីពាក់ព័ន្ធនៅក្នុងវិស័យប្រែប្រួលអាកាសធាតុ និងដំណើរការ GCF នៅកម្ពុជា

ក្នុងរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះឃើញថាមានការកើនឡើងនៃស្ថាប័នជាតិ និងអន្តរជាតិដែលជា រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានសិក្សា និងវិស័យឯកជនបានចូលរួមក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ភាគីពាក់ព័ន្ធទាំងនេះបានធ្វើការសាកល្បងជម្រើសបន្សាំ និងការកាត់បន្ថយផ្សេងៗគ្នា និងបង្កើតបានជាប្រភពចំណេះដឹង និងព័ត៌មានជាច្រើនដើម្បីគាំទ្រដល់ការបង្កើតវិធានការ ផែនការ ក្របខ័ណ្ឌ និងគោលនយោបាយ ដែលមានភាពធន់នឹងអាកាសធាតុ ព្រមទាំងបញ្ចេញកាបូនតិចនៅកម្ពុជា។ ប្រទេសកម្ពុជាចាំបាច់ត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែងទាំងនេះ និងកំណត់ភាគីពាក់ព័ន្ធសំខាន់ៗ និងតួនាទីរបស់ពួកគេនៅក្នុងដំណើរការ GCF ដើម្បីទទួលបានការគាំទ្រសម្រាប់ការបង្កើនសកម្មភាពអាកាសធាតុ និងចូលរួមចំណែកដល់អាទិភាពនៃការប្រែប្រួលអាកាសធាតុជាតិ។ ជំហានដំបូងដែលស្ថាប័នជាតិទទួលបន្ទុក (NDA) ត្រូវធ្វើនោះ គឺការប្រមូលព័ត៌មានផ្សេងៗជាច្រើន និងការចូលរួមជាមួយភាគីពាក់ព័ន្ធជាលក្ខណៈប្រព័ន្ធ នៅក្នុងដំណើរការរបស់ GCF ។

ចំណុចសក្តានុពលនៃការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការ GCF និងគម្រោង / កម្មវិធី ដែលផ្តល់ដោយមូលនិធិ GCF នឹងមានភាពខុសគ្នាអាស្រ័យលើតួនាទី បច្ចេកទេស អាណត្តិការងារ និងសមត្ថភាពរបស់អង្គភាពនីមួយៗ។ នៅក្នុងការចូលរួមជាមួយភាគីពាក់ព័ន្ធទាំងនេះ ស្ថាប័នជាតិទទួលបន្ទុក (NDA) នឹងជានាថាតំណាងរបស់ភាគីនីមួយៗគឺនឹងចូលរួមក្នុងការប្រជុំ ការធ្វើផែនការជាតិ និងកិច្ចពិភាក្សា ជាទៀងទាត់។

តារាងទី ១ បង្ហាញពីភាគីពាក់ព័ន្ធសំខាន់ៗដែលចូលរួមក្នុងការងារប្រែប្រួលអាកាសធាតុ និងតារាងទី ២ បង្ហាញពីឈ្មោះអង្គភាព និងការចូលរួមនៅក្នុងដំណើរការ GCF នេះ។

| តារាងទី 1៖ ស្ថាប័នពាក់ព័ន្ធនៃការប្រែប្រួលអាកាសធាតុជាតិនៅកម្ពុជា | | |
|---|---|---|
| **ក្រុមនៃស្ថាប័ន** | **ស្ថាប័ន** | **ចំណុចសំខាន់ៗនៃសកម្មភាព** |
| ស្ថាប័នរដ្ឋាភិបាល | ក្រសួងបរិស្ថាន | • សម្របសម្រួល គោលនយោបាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តិ ដើម្បីកៀរគរធនធាន និងអនុវត្តកម្មវិធី/គម្រោងទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេសការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>• លើកកម្ពស់ភាពធន់នឹងអាកាសធាតុ និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យ និងអនុវិស័យ នានា<br>• លើកស្ទួយបច្ចេកវិទ្យាបញ្ចេញកាបូនតិច<br>• បង្កើនសមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ<br>• ពង្រឹងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌសម្របសម្រួល<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | • អង្គភាពសម្របសម្រួលសម្រាប់បញ្ហាអន្តរវិស័យ និងគាំទ្រអន្តរក្រសួងដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រនិង ផែនការ<br>• ជំរុញការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ<br>• រៀបចំ ដឹកនាំ បញ្ជ្រាប និងវាយតម្លៃគោលនយោបាយ ផែនការយុទ្ធសាស្ត្រផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តិ ព្រមទាំងកៀរគរធនធាន និងអនុវត្តកម្មវិធី/គម្រោងទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព<br>• បង្កើតនិងថែរក្សាភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន គ្រឹះស្ថានសិក្សា និងភាគីពាក់ព័ន្ធដទៃទៀតក្នុងគោលបំណងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព<br>• លើកទឹកចិត្ត និងលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍគោលនយោបាយការអភិវឌ្ឍសមត្ថភាព បច្ចេកវិទ្យាថ្មីៗ និងការផ្សព្វផ្សាយព័ត៌មានអំពី ការប្រែប្រួលអាកាសធាតុ |

| | | |
|---|---|---|
| | | • ជាប្រធាន និងជាអនុប្រធានក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងផែនការ | • សម្របសម្រួលអន្តរក្រសួងដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ<br>• សម្របសម្រួលនិងគាំទ្រការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្ពុជា (CSDG) ដែលរួមបញ្ចូលសូចនាករការប្រែប្រួលអាកាសធាតុ (គោលដៅទី ១៣)<br>• សមាជិកនៃក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG)<br>• ដាក់បញ្ចូល និងតាមដានទិន្នន័យការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធី វិនិយោគសាធារណៈ<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | • ដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងហិរញ្ញវត្ថុសាធារណៈ ដូចជា ផែនការយុទ្ធសាស្ត្រថវិការយៈពេល៣ឆ្នាំរំកិល និងសារាចរស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ<br>• គាំទ្រដល់ក្រសួង-ស្ថាប័នដាក់បញ្ចូលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅក្នុងសំណើថវិកា និងផែនការយុទ្ធសាស្ត្រថវិកា<br>• រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីចំណាយសាធារណៈលើការងារអាកាសធាតុ(CPER)<br>• ធ្វើការស្រាវជ្រាវគោលនយោបាយ ស្តីពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើគំរូកំណើនសេដ្ឋកិច្ចដែលជាការព្យាករណ៍សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងមហាផ្ទៃ (លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ) | • រៀបចំនិងអនុវត្តកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>• មុនពេលផ្ទេរមុខងារនិងការទទួលខុសត្រូវទៅក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ NCDD ត្រូវបង្កើតនីតិវិធី និងទម្រង់បែបបទ សម្រាប់ការធ្វើ សមាហរណកម្មផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួងស្ថាប័ននៅថ្នាក់ក្រោមជាតិទៅក្នុងផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រុមប្រឹក្សានីមួយៗ។ |

| | | |
|---|---|---|
| | | • បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប) គឺជាស្ថាប័នរដ្ឋាភិបាលដំបូងគេដែលបានក្លាយជា អង្គភាពទទួលបានសេចក្ដីទុកចិត្តពី GCF<br>• ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅ ថ្នាក់ក្រោមជាតិជាពិសេសផែនការឃុំសង្កាត់ (CIP / CDP)<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងធនធានទឹកនិងឧតុនិយម | • រៀបចំផែនការនិងគ្រប់គ្រងជលសាស្ត្រ និងប្រព័ន្ធប្រកាសអាសន្នដំបូង<br>• គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត<br>• ស្តារ/ជួសជុល និងសាងសង់ប្រព័ន្ធធារាសាស្ត្រនិងទំនប់ទឹកថ្មី<br>• បង្កើនសមត្ថភាពលើការគ្រប់គ្រងទឹកនិងឧតុនិយម<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងព័ត៌មាន | • អង្កេត តម្លាភាព គណនេយ្យភាព និងការលើកកម្ពស់ការយល់ដឹង<br>• ការផ្សាយព័ត៌មានទាន់ហេតុការណ៍ទាក់ទងនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបញ្ហាផ្សេងៗ<br>• កម្មវិធីជជែកពិភាក្សា និងតស៊ូមតិស្ដីពី ការប្រែប្រួលអាកាសធាតុ |
| | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | • ការឆ្លើយតបគ្រោះមហន្តរាយបន្ទាន់ (ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះ ជំងឺរាតត្បាត និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ)<br>• វិធានការបន្ទាន់ ការផ្តល់ជំនួយនិងស្តារនីតិសម្បទាមុន និងក្រោយគ្រោះមហន្តរាយ និងសន្តិសុខស្បៀងជាដើម<br>• ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) |
| | ក្រសួងអប់រំយុវជននិងកីឡា | • ការលើកទឹកចិត្ត ការលើកកម្ពស់ ការយល់ដឹង និងការបណ្តុះបណ្តាល<br>• ដាក់បញ្ចូលការអប់រំអំពីការប្រែប្រួលអាកាសធាតុនៅក្នុងកម្មវិធីសិក្សាជាតិកម្រិតវិទ្យាល័យចាប់ពីថ្នាក់ទី ១០-១២<br>• ភាពធន់នឹងការប្រែប្រួលអាកាសធាតុរបស់សាលារៀន សាកលវិទ្យាល័យនិងគ្រឹះស្ថានសិក្សាផ្សេងៗ |

| | | |
|---|---|---|
| | ក្រសួងសុខាភិបាល | • កាត់បន្ថយកង្វះខាតអាហារូបត្ថម្ភ និងពង្រឹងសុវត្ថិភាពចំណីអាហារ<br>• ប្រយុទ្ធប្រឆាំងនឹងកង្វះខាតទឹក ជំងឺដោយភ្នាក់ងារបង្កពោគ/ឆ្លងតាមទឹក<br>• ការកសាងសមត្ថភាពលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើសុខភាពសាធារណៈ<br>• ការការពារ និងទប់ស្កាត់ពីជំងឺដែលឆ្លងតាមរយៈភ្នាក់ងារបង្កពោគ/ទឹក |
| | ក្រសួងអភិវឌ្ឍន៍ជនបទ | • ហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ (ផ្លូវជនបទ ស្ពាន អាគារ)<br>• ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាដាក់សំណើថវិកាប្រចាំឆ្នាំ ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ការយល់ដឹងនៅក្នុងតំបន់ដែលងាយរងគ្រោះ<br>• បង្កើតគោលការណ៍ណែនាំស្តីពីការបញ្ជ្រាប ការប្រែប្រួលអាកាសធាតុទៅក្នុងការកសាងផ្លូវជនបទ និងរៀបចំផែនទីងាយរងគ្រោះស្តីពីការប្រែប្រួល អាកាសធាតុ<br>• ការកសាងសមត្ថភាពដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| | ក្រសួងសាធារណការនិងដឹកជញ្ជូន | • លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ (ផ្លូវថ្នល់ជាតិ ស្ពាន)<br>• ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ក៏ដូចជាដាក់សំណើថវិកាប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>• ជំរុញការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ |
| | ក្រសួងរ៉ែនិងថាមពល | • ការគ្រប់គ្រងទិន្នន័យថាមពល ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ |
| | ក្រសួងវិទ្យាសាស្ត្រ ឧស្សាហកម្ម បច្ចេកវិទ្យា និងនវានុវត្តន៍ | • ការគ្រប់គ្រងទិន្នន័យឧស្សាហកម្ម និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• លើកកម្ពស់ឧស្សាហកម្មបៃតងសម្រាប់ភាពធន់នឹងអាកាសធាតុ និងបច្ចេកវិទ្យា បញ្ចេញកាបូនតិច |

| | | |
|---|---|---|
| | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | • បង្កើនភាពធន់នឹងអាកាសធាតុទៅក្នុងវិស័យកសិកម្ម<br>• កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យកសិកម្ម<br>• ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ សម្រាប់ ពូជដើមកៅស៊ូ ផលិតកម្មដំណាំ ផលិតកម្មសត្វ និងនេសាទ និងភាពធន់នឹងអាកាសធាតុ ដំងឺរាត្បាត និងសត្វល្អិត<br>• ចូលរួមក្នុងកម្មវិធីរេដបូក |
| | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | • ការគ្រប់គ្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA)<br>• តាមដានលំហូរហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ នៅក្នុងប្រព័ន្ធទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ<br>• កសាងសមត្ថភាពដល់ដៃគូអភិវឌ្ឍន៍ និងបុគ្គលិកក្រុមប្រឹក្សាអំពីការបញ្ចូលទិន្នន័យហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ<br>• រៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពជំនួយ រួមមានហិរញ្ញប្បទានសម្រាប់ ការប្រែប្រួលអាកាសធាតុផងដែរ |
| | ក្រសួងទេសចរណ៍ | • ជំរុញការបញ្ចេញកាបូនតិច និងភាពធន់នឹងអាកាសធាតុនៅតំបន់ បេតិកភណ្ឌវប្បធម៌ និងប្រព័ន្ធអេកូឡូស៊ី<br>• ការកសាងសមត្ថភាពដល់សហគមន៍ទេសចរណ៍ធម្មជាតិ អំពីការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• លើកកម្ពស់បទដ្ឋានសណ្ឋាគារបៃតង |
| | ក្រសួងកិច្ចការនារី | • គិតគូរពីភាពងាយរងគ្រោះរបស់ស្ត្រី និងក្រុមងាយរងគ្រោះក្នុងការពិភាក្សាគោលនយោបាយ ភាពជាអ្នកដឹកនាំ និងរបរចិញ្ចឹមជីវិត<br>• បង្កើនភាពធន់របស់សហគមន៍<br>• បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ផែនការមេ និងយុទ្ធសាស្ត្ររបស់ក្រសួងកិច្ចការនារី<br>• លើកកម្ពស់យេនឌ័រ និងការប្រែប្រួលអាកាសធាតុ |

| | | |
|---|---|---|
| | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | • រៀបចំផែនការអភិវឌ្ឍន៍ទីក្រុងដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ<br>• រៀបចំផែនការប្រើប្រាស់ដី ដើម្បីចាត់ជាអាទិភាពដល់វិធានការបន្សុំ<br>• បង្កើតកូដសម្រាប់អគារ និងសាងសង់លំនៅឋានដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ<br>• ការរៀបចំផែនការ និងបច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច |
| គ្រឹះស្ថានសិក្សា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | • ការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុសម្រាប់ការអភិវឌ្ឍ<br>• ការអភិវឌ្ឍសមត្ថភាពសម្រាប់និស្សិតសាកលវិទ្យាល័យ<br>• ការដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យនានា<br>• គាំទ្រការស្រាវជ្រាវនិក្ខេបបទរបស់និស្សិតទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
| | សាកលវិទ្យាល័យភូមិន្ទកសិកម្ម | |
| | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | |
| | សាកលវិទ្យាល័យមានជ័យ | |
| | សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា | |
| ដៃគូអភិវឌ្ឍន៍ | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ) | • ភាពជាដៃគូក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា តាមរយៈការផ្តល់ថវិកា និង ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋាភិបាល និង ការចូលរួមក្នុងសកម្មភាពនានា<br>• ការលើកទឹកចិត្តសង្គម-នយោបាយ បណ្តាញ ការតស៊ូមតិ ការទាក់ទាញ ការទទួលខុសត្រូវ ការកសាងសមត្ថភាព និងការលើកកម្ពស់ការយល់ដឹងផ្សេងៗ |
| | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) | |
| | អង្គការស្បៀងនិងកសិកម្ម(FAO) | |
| | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO) | |
| | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) | |

| | | |
|---|---|---|
| | អង្គការផ្លែនអន្តរជាតិ | |
| | សមាគមធនាគារកម្ពុជា (ABC)<br>ធនាគារអភិវឌ្ឍអាស៊ី(ADB) | • ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុប្រកួតប្រជែង ឥណទានខ្នាតតូច / ប្រាក់កម្ចីពីធនាគារ |

| តារាងទី 2៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងដំណើរការ GCF | | |
|---|---|---|
| **ភាគីពាក់ព័ន្ធសំខាន់ៗ** | **តួនាទី និងភារកិច្ច** | **វិស័យអាទិភាព** |
| រាជរដ្ឋាភិបាល | | |
| ស្ថាប័នជាតិទទួលបន្ទុកធ្វើការរួមជាមួយក្រសួងពាក់ព័ន្ធទាំងអស់ មន្ទីរខេត្ត និងអាជ្ញាធរមូលដ្ឋាន ដោយផ្តោតលើ គោលដៅលទ្ធផល និងអាទិភាពវិនិយោគ របស់GCF | • ដឹកនាំនិងគ្រប់គ្រងដំណើរការវិនិយោគ របស់ GCF នៅកម្ពុជាពាក់ព័ន្ធនឹងវិស័យលទ្ធផលចំនួនប្រាំបីរបស់ GCF និង អាទិភាពវិនិយោគកាត់ចំនួន ៥<br>• ចូលរួមក្នុងដំណើរការគោលនយោបាយជាតិ GCF ការណែនាំផ្នែកបច្ចេកទេសនិងការធ្វើសេចក្តីសម្រេចចិត្តនៅក្នុង GSSD ក្រុមការងារប្រឹក្សាយោបល់របស់ GCF និងរចនាសម្ព័ន្ធ ស្ថាប័នការប្រែប្រួលអាកាសធាតុ។<br>• រៀបចំផែនការសកម្មភាពអាទិភាពស្តីពីការប្រែប្រួលអាកាសធាតុជាតិសម្រាប់ប្រទេសកម្ពុជា ស្របជាមួយលទ្ធផល ទាំងប្រាំបីរបស់ GCF និងអាទិភាពវិនិយោគចំនួន ៥ (cross cutting) សម្រាប់មូលនិធិ។<br>• តាមដានការខិតខំរបស់ជាតិលើការអភិវឌ្ឍន៍ដែលបញ្ចេញកាបូន តិច និងភាពធន់ និងបង្កើតគោលនយោបាយ និងវិធានការណ៍កែទម្រង់សមស្រប | • ទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យចំនួនប្រាំបីត្រូវចូលរួមដោះស្រាយ បញ្ហានេះជាទៀងទាត់នៅថ្នាក់ជាតិ តាមលទ្ធភាពសមស្រប ៖<br>i. ការផលិត និងទទួលបានថាមពល<br>ii. ការដឹកជញ្ជូន<br>iii. អគារ ទីក្រុង ឧស្សាហកម្ម និងឧបករណ៍ប្រើប្រាស់<br>iv. ការប្រើប្រាស់ដីព្រៃ និងការរេចរិលព្រៃឈើ<br>v. លើកកម្ពស់ជីវភាពរស់នៅរបស់ ប្រជាជន និងសហគមន៍ដែលងាយរងគ្រោះ<br>vi. សន្តិសុខស្បៀង ទឹក និងសុខភាព<br>vii. ហេដ្ឋារចនាសម្ព័ន្ធនិង<br>viii.ប្រព័ន្ធអេកូឡូស៊ី និងសេវាអេកូឡូស៊ី |

| | | |
|---|---|---|
| | លើគោលនយោបាយជាតិ គោលនយោបាយសហព័ន្ធ និងយុទ្ធសាស្ត្រដើម្បីរួមបញ្ចូលសកម្មភាពអាកាសធាតុ។<br>• បង្កើតគំនិតផ្តួចផ្តើមធន់នឹងអាកាសធាតុការបញ្ចេញកាបូនតិច និងចូលរួមជា មួយសហហិរញ្ញប្បទានជាមួយប្រភពថវិកាផ្សេងទៀត<br>• ត្រួតពិនិត្យការអនុវត្តគម្រោង និងកម្មវិធីដែលផ្តល់មូលនិធិដោយ GCF ក្នុងវិស័យរៀងៗខ្លួនដើម្បីធានាការផ្លាស់ប្តូរគំរូអាកាសធាតុក្នុងសកម្មភាពអាកាសធាតុដែលកំពុងប្រើធនធាន GCF<br>• ធានាឱ្យបាននូវការធ្វើសមាហរណកម្មពេញលេញនៃបញ្ហាប្រឈមអាកាសធាតុនៅក្នុងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន និងថ្នាក់ខេត្ត។ | • ការចូលរួមទៀងទាត់របស់ស្ថាប័ន ពាក់ព័ន្ធរបស់រដ្ឋាភិបាលក្នុងដំណើរការ GCF និងគម្រោង / កម្មវិធី ដែល ផ្តល់មូលនិធិដោយ GCF |
| **វិស័យឯកជននិងស្ថាប័នហិរញ្ញវត្ថុ** | | |
| ស្ថាប័នហិរញ្ញវត្ថុដូចជា ធនាគារពាណិជ្ជ និង អភិវឌ្ឍន៍ សមាគមពាណិជ្ជកម្មនៃ វិស័យឯកជន សហគ្រិនឯកជន ក្រុមហ៊ុនធានារ៉ាប់រង សហគ្រាសខ្នាតតូចបំផុត តូចនិងមធ្យម | • manភាពសកម្មនៅក្នុងដំណើរការជាតិដើម្បីទាញយកធនធាន GCF សម្រាប់ការគាំទ្រដល់គម្រោងថាមពលស្អាត ប្រសិទ្ធភាពថាមពល ភាពធន់នឹងអាកាសធាតុ និងសហគមន៍ប្រកបដោយនិរន្តរភាព | • GCF លើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជនដើម្បីរួមចំណែកដល់ការសម្រេចបានលើវិស័យអាទិភាពទាំង៨ និងអាទិភាពនៃការវិនិយោគចំនួន៥ ដើម្បីបង្ហាញពី ការប្រើប្រាស់មូលនិធិ GCF ប្រកបដោយនិរន្តរភាពនិងប្រកបដោយផលិតភាព |

| | | |
|---|---|---|
| | • អាចប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុចម្រុះរបស់ GCF (ដូចជា បំណុល មូលធន និងការធានា)<br>• អាចទទួលបានជំនួយខាងផ្នែកវិស័យឯកជនពី GCF សម្រាប់គម្រោង និងកម្មវិធីថ្នាក់ជាតិដែលជំរុញការបញ្ចេញកាបូនតិច និងកសាងភាពធន់នឹងអាកាសធាតុ<br>• ចូលរួមចំណែកក្នុងការប្រជុំ ឬការរៀបចំផែនការជាតិជាទៀងទាត់<br>• គាំទ្រដល់ការកសាងសមត្ថភាពរបស់វិស័យ ឯកជនដទៃទៀត និងស្ថាប័ននានាក្នុងស្រុក<br>• ផ្តល់យោបល់ដល់វិស័យឯកជនអំពីឱកាស និងបញ្ហាប្រឈមក្នុងការចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ GCF និងយន្តការស្ថាប័ន ប្រែប្រួលអាកាសធាតុដែលមានស្រាប់<br><br>បញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការថ្នាក់មូលដ្ឋាន | • វិស័យឯកជនគួរតែចូលរួមជាទៀងទាត់ជាមួយស្ថាប័នរដ្ឋាភិបាលដើម្បីបង្ហាញពីសក្តានុពលរបស់ពួកគេនៅក្នុងដំណើរការ GCF និងគម្រោង / កម្មវិធី ដែលផ្តល់មូលនិធិដោយ GCF<br>• ភាគីនីមួយៗមិនគួរផ្តោតតែលើវិស័យ ដែលខ្លួនមានជំនាញឡើយ |
| **អង្គការសង្គមស៊ីវិល** | | |
| អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក | • ការចូលរួមយ៉ាងសកម្មដើម្បីឈានទៅរកសង្គមដែលមានការបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ | • អង្គការសង្គមស៊ីវិលចូលរួមទៀងទាត់ដើម្បីបញ្ចេញមតិជាមួយស្ថាប័ន រាជរដ្ឋាភិបាលនៅក្នុងដំណើរការរបស់ GCF និងគម្រោង / កម្មវិធីដែលផ្តល់មូលនិធិដោយ GCF |

| | | |
|---|---|---|
| អង្គការមិនមែនរដ្ឋាភិបាល អន្តរជាតិ<br><br>បណ្តាញអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការខាងប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសកម្ពុជា | • គាំទ្រលើដំណើរការចូលរួមរបស់ GCF តាមរយៈការលើកកម្ពស់សំឡេងសង្គមស៊ីវិលនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្រ្តរបស់ប្រទេសនិងអាទិភាពនៃការប្រែប្រួលអាកាសធាតុដើម្បីធានានូវតម្រូវការរបស់អ្នកទទួលធនធាន<br>• តស៊ូមតិដើម្បីបញ្ជ្រាបបញ្ហាយេនឌ័រនិងបរិយាប័ន្នសង្គមទៅក្នុងដំណើរការហិរញ្ញប្បទាន អាកាសធាតុ<br>• ទាមទារឱ្យមានគណនេយ្យភាពគម្រោង | |
| អង្គការសង្គមស៊ីវិល | • ផ្តល់នូវធាតុចូលយ៉ាងច្រើនលើបទដ្ឋាននៃ ការអនុវត្តការងារដោយផ្អែកលើក្របខ័ណ្ឌ បរិស្ថាននិងក្របខ័ណ្ឌគាំពារសង្គម និងការបង្កើតផែនការសកម្មភាពយេនឌ័ររបស់គម្រោង<br>• គាំទ្រនិងធានានិរន្តរភាពនៃគម្រោង / កម្មវិធីដែលផ្តល់មូលនិធិដោយ GCF ដែលជាផ្នែកមួយនៃយុទ្ធសាស្រ្តបញ្ចប់គម្រោង/កម្មវិធី<br>• គាំទ្រលើទស្សនវិស័យរបស់សង្គមស៊ីវិលក្នុងអំឡុងពេលធ្វើគោលនយោបាយ GCF តាមរយៈ GSSD និង GCF ATF និងរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់ | • ជម្រាបជូនរដ្ឋាភិបាលអំពីជម្រើស បញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុ ព្រមទាំងមេរៀនដោយផ្តោតលើវិស័យអាទិភាពចំនួន ៨ និងអាទិភាពវិនិយោគចំនួន ៥ របស់ GCF<br>• ការចែករំលែកមេរៀន និងការអនុវត្តល្អៗនៅតាមវេទិកាផ្សេងៗ |

| | | |
|---|---|---|
| | • ចែករំលែកការអនុវត្តល្អៗ ការរៀនសូត្រនិងបញ្ហាប្រឈមនានានៅក្នុងវេទិកាជាតិនិងអន្តរជាតិ<br>• ចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិជាទៀងទាត់<br>• ជំរុញឱ្យអង្គការសង្គមស៊ីវិលចូលរួមក្នុងការរៀបចំនិងអនុវត្ត វិស័យអាទិភាពទាំង ៨ របស់ GCF និងគម្រោងវិនិយោគអាទិភាព ដូចខាងក្រោម៖<br>១. ការពង្រឹងសមត្ថភាពនិងការលើកកម្ពស់ ការយល់ដឹងរបស់សហគមន៍ក្រីក្រ និងក្រុមងាយរងគ្រោះ និង CBOs ស្តីពីបញ្ហាការប្រែប្រួលអាកាសធាតុនិងមូលនិធិ GCF<br>២. លើកកម្ពស់បច្ចេកវិទ្យាកាបូនតិចនិងរបរចិញ្ចឹមជីវិតដែលធន់នឹងអាកាសធាតុដល់សង្គម<br>៣. កសាងសមត្ថភាពសហគមន៍ដើម្បីគ្រប់គ្រងហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយ<br>• ៤. សាកល្បង និងបង្ហាញពីវិធានការគាំពារសង្គមក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ | |
| **គ្រឹះស្ថានសិក្សា** | | |

| | | |
|---|---|---|
| •សាកលវិទ្យាល័យជាតិ<br>•មជ្ឈមណ្ឌលស្រាវជ្រាវ / ស្ថាប័ន<br>•មជ្ឈមណ្ឌលចំណេះដឹង | • ចូលរួមក្នុងការប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិជាទៀងទាត់<br>• ជំរុញអ្នកស្រាវជ្រាវ ឱ្យសិក្សាប្រមូលព័ត៌មានអំពី វិស័យអាទិភាពទាំងប្រាំបី និងអាទិភាពវិនិយោគ របស់ GCF ។ គម្រោង/កម្មវិធីមួយចំនួនដែលគួរផ្តោតមានដូចខាងក្រោម៖<br>• ស្រាវជ្រាវប្រធានបទអំពីការកាត់បន្ថយនិង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ<br>• ការគ្រប់គ្រងចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ៖ ឯកសារនិងការផ្សព្វផ្សាយ<br>• ស្ថាប័នស្រាវជ្រាវ៖ ផ្តល់ជាតុចូលដល់ គោលនយោបាយ និងការអនុវត្ត<br>• អភិវឌ្ឍនិងដាក់បញ្ចូលការអភិវឌ្ឍការបញ្ចេញ កាបូនតិច និងភាពធន់នឹងអាកាសធាតុនៅក្នុងកម្មវិធីសិក្សាកម្រិតឧត្តមសិក្សា<br>• ជំរុញនវានុវត្តន៍ដើម្បីប្រយុទ្ធប្រឆាំងនឹង ការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងបង្កើនចំណេះដឹងដើម្បីអនុម័តលើមាគ៌ាអភិវឌ្ឍន៍ដែលធន់នឹងអាកាស | • ស្ថាប័នអប់រំចូលរួមជាទៀងទាត់ជាមួយ រាជ រដ្ឋាភិបាលកម្ពុជាក្នុងដំណើរការ GCF និងគម្រោង / កម្មវិធីដែលផ្តល់មូលនិធិដោយ GCF ដោយបង្ហាញភស្តុតាង ដែលផ្អែកលើវិទ្យាសាស្ត្រនៅក្នុងវិស័យអាទិភាពចំនួន ៨ និងអាទិភាពវិនិយោគ |

| | | |
|---|---|---|
| | ធាតុ និងបញ្ចេញកាបូនតិចស្របតាមវិស័យអាទិភាព GCF។ | |
| **សហគ្រាសសាធារណៈ** | | |
| សហគ្រាសសាធារណៈ ពាក់កណ្ដាលស្វយ័ត និងសហគ្រាសគ្រប់គ្រងដោយរដ្ឋ៖<br>១. ទូរគមនាគមន៍កម្ពុជា<br>២. កំពង់ផែស្វយ័តភ្នំពេញ<br>៣. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ<br>៤. កំពង់ផែស្វយ័តក្រុងព្រះសីហនុ<br>៥. អគ្គិសនីកម្ពុជា<br>៦. ប្រៃសណីយ៍កម្ពុជា។ ល។ | • អាចក្លាយជាស្ថាប័នទទួល មូលនិធិដោយផ្ទាល់ (DAEs)<br>• ជំរុញគោលដៅរបស់ GCF<br>• ជំរុញនិងកៀរគររដ្ឋាភិបាលសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីអភិវឌ្ឍសំណើថវិកាដែលមានសក្ដានុពលដើម្បីឆ្លើយតបទៅនឹងវិស័យអាទិភាពរបស់ GCF<br>• ការគ្រប់គ្រង និងការអនុវត្តគម្រោង/កម្មវិធី<br>• ធានាឱ្យបាននូវសុវត្ថិភាព បរិស្ថាននិងការគាំពារសង្គម | • ស្ថាប័នដែលអាចទទួលមូលនិធិ ដោយផ្ទាល់ គួរដឹកនាំការអនុវត្តគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍការបញ្ចេញកាបូនតិច និងធន់នឹងអាកាសធាតុហើយចូលរួមទៀងទាត់ជាមួយស្ថាប័នពាក់ព័ន្ធ ទាំងអស់នៅក្នុងដំណើរការ GCF និងគម្រោង / កម្មវិធី ដែលផ្តល់មូលនិធិដោយ GCF<br>• ការចូលរួមជាមួយស្ថាប័នជាតិទទួលបន្ទុក |

ទោះបីជាប្រសិទ្ធភាពការងារខុសគ្នាក៏ដោយ ក៏យន្តការ និងរចនាសម្ព័ន្ធមួយចំនួនបានគិតគូរួច ទៅហើយអំពី ការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ជៀសជាងការបង្កើតរចនាសម្ព័ន្ធថ្មីសម្រាប់ GCF លទ្ធភាព ប្រើប្រាស់យន្តការដែលមានស្រាប់ក្នុងការទទួល និងប្រើប្រាស់ធនធានរបស់ GCF នឹងពន្យល់យ៉ាងច្បាស់ នៅក្នុងជំពូកទី ៥ ខណៈតួនាទី និងភារកិច្ចរបស់ NDA ទាក់ទងនឹង GCF និងភាគីពាក់ព័ន្ធសំខាន់ៗក៏នឹង ត្រូវបង្ហាញនៅក្នុងជំពូកទី ៦ ផងដែរ។

## ៤.៤ ការចាត់អាទិភាពដំបូង នៃវិធានការបន្សាំនិងការកាត់បន្ថយ សម្រាប់ដាក់បញ្ចូលក្នុងកម្មវិធី GCF ប្រចាំប្រទេសកម្ពុជា

ក្របខ័ណ្ឌនៃការចូលរួមរបស់ភាគីពាក់ព័ន្ធនឹងផ្តល់ការណែនាំមួយចំនួនសម្រាប់ដំណើរការ អភិវឌ្ឍកម្មវិធី GCF ប្រចាំប្រទេសកម្ពុជា នឹងបង្ហាញនៅក្នុងរូបភាពទី ៧ និងក្នុងប្រអប់ទី ១ ដូចខាងក្រោម។ យុទ្ធសាស្ត្រផែនការ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុ គឺជាក្របខ័ណ្ឌយុទ្ធសាស្ត្រដែលបានផ្តល់ជូន នៅក្នុងកម្មវិធីប្រចាំប្រទេសកម្ពុជា ដូច្នេះហើយវាជាមូលដ្ឋានសម្រាប់ការរៀបចំ និងអនុវត្តសំណើថវិកា។ ប្រទេសកម្ពុជានឹងកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ខ្លួនដោយផ្អែកលើមូលដ្ឋានគ្រឹះនៃផែនការ និង យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុជាតិដែលមានស្រាប់ រួមមានការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញា ក្របខ័ណ្ឌសហប្រជាជាតិស្តីពី ការប្រែប្រួលអាកាសធាតុ (NDC) សកម្មភាពជាតិកាត់បន្ថយសមស្រប (NAMAs) ផែនការជាតិបន្សាំ (NAPs) និងកម្មវិធីសកម្មភាពជាតិបន្សាំ (NAPAs)។ ឬក៏ជ្រើសរើសដើម្បី បង្កើតមូលនិធិក្របខ័ណ្ឌយុទ្ធសាស្ត្រជាក់លាក់ ដែលដើរតាមផែនការនិងយុទ្ធសាស្ត្រជាតិដែលមានស្រាប់។



**រូបភាពទី 7៖ ដំណើរការអភិវឌ្ឍន៍កម្មវិធីប្រចាំប្រទេស ដែលស្នើសុំថវិកាពីមូលនិធិGCF**

របាយការណ៍ជាតិលើកទី២ (SNC) ត្រូវបានយកមកប្រើប្រាស់ក្នុងរយៈពេលបីឆ្នាំចុងក្រោយ ដើម្បីជួយណែនាំគំនិតផ្តួចផ្តើមជាច្រើន ដើម្បីដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងផែនការរដ្ឋាភិបាល។ កម្មវិធីសកម្មភាពជាតិបន្សាំ (NAPAs) ត្រូវបានរៀបចំចងក្រងក្នុងឆ្នាំ ២០០៦ ហើយមានសកម្មភាពចំនួន ៣៩។ ក្នុងចំណោមសកម្មភាពទាំងនោះមាននៅក្នុងវិស័យកសិកម្ម និងធនធានទឹកចំនួន ២០ នៅតំបន់ឆ្នេរចំនួន ៨ សកម្មភាព វិស័យសុខាភិបាលមាន ៦ សកម្មភាព និងអន្តរវិស័យ ចំនួន៥ សកម្មភាពទៀត។ ហើយក្នុងចំណោមសកម្មភាពទាំង ៣៩ នៃ NAPAs បានជ្រើសរើសសកម្មភាពចំនួន ២០ ជាសកម្មភាពអាទិភាពខ្ពស់។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (២០០៩-២០១៣) បានកំណត់ចំណុចអាទិភាពចំនួន ១០ ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ក្រសួងពាក់ព័ន្ធជាច្រើនបានដាក់បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការថវិកា និងកម្មវិធី/គម្រោងការងារប្រចាំឆ្នាំផងដែរ។ ក្រសួងពាក់ព័ន្ធចំនួនប្រាំបួនហើយដែលបានរៀបចំផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ខ្លួន។ ទាំងនេះត្រូវបានចងក្រងទៅក្នុងផែនការយុទ្ធសាស្រ្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជា (CCCSP) ដែលកំណត់គោលបំណងចំនួន ៨ និងគាំទ្រដោយយុទ្ធសាស្រ្តចំនួន ៦១ដូចខាងក្រោម៖

- លើកកម្ពស់ភាពធន់នឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង ទឹក និងថាមពល
- កាត់បន្ថយហានិភ័យតាមវិស័យ តាមតំបន់ ភាពងាយរងគ្រោះយែនឌ័រ និងសុខភាពចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ
- ធានាឱ្យមានភាពធន់នឹងអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (បឹងទន្លេសាប ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រ តំបន់ខ្ពង់រាប ។ល។) ជីវចម្រុះ តំបន់ការពារ និងតំបន់បេតិកភណ្ឌវប្បធម៌ជាដើម
- ជំរុញការធ្វើផែនការ និងការប្រើប្រាស់បច្ចេកវិទ្យាកាបូនតិចដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព
- លើកកម្ពស់សមត្ថភាព ចំណេះដឹង និងការយល់ដឹងសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ជំរុញការគាំពារសង្គមឱ្យមានការបន្សាំ និងជំរុញវិធីសាស្រ្តចូលរួមក្នុងការកាត់បន្ថយការបាត់បង់ និងការខូចខាតដោយសារការប្រែប្រួលអាកាសធាតុ។
- ពង្រឹងក្របខ័ណ្ឌស្ថាប័ន និងសម្របសម្រួលសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

**ប្រអប់ទី ១៖ ជម្រើសនៃការអនុវត្តល្អបំផុតដំបូងបង្អស់សម្រាប់ការសម្របសម្រួលថ្នាក់ជាតិនិងការចូលរួមរបស់ភាគីពាក់ព័ន្ធជាច្រើន**

ប្រភព:https://www.greenclimate.fund/documents/20182/194568/GCF_ELEMENTS_01.pdf/542c1610-81b4-40df-be62-025cef3d26d8

- មូលនិធិនេះនឹងមានវិសាលភាពទូលំទូលាយក្នុងការផ្តល់មូលនិធិ ទាំងសកម្មភាពកាត់បន្ថយ និងបន្សាំតាមរយៈ ដំណើរការជាច្រើនរួមមាន តាមរយៈវិស័យឯកជននិងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ ដូច្នេះនៅក្នុងកម្រិតអនុវត្តនឹងមានការចូលរួម ពីវិស័យផ្សេងៗគ្នា។
- បណ្តាប្រទេសនានាគួរមានការពិចារណាលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមសម្រាប់អនុវត្តការសម្របសម្រួលរបស់ប្រទេស និងការចូលរួមរបស់ភាគីពាក់ព័ន្ធជាច្រើននៅកម្រិតអាទិភាពនិងយុទ្ធសាស្ត្រជាតិ ឬក្នុងការអភិវឌ្ឍសំណើថវិកាដែលសមស្រប និងទទួលមេរៀន បទពិសោធន៍ពីប្រទេសដទៃផងដែរ។

## ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ប្រទេស

- ផែនការយុទ្ធសាស្ត្រ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុគឺជា ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់កម្មវិធីប្រទេស ដែលនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំ និងអនុវត្តសំណើថវិកានេះ។ ដូច្នេះបណ្តាប្រទេសដែលទទួលថវិកានេះអាចកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ពួកគេដោយផ្អែកលើផែនការ និងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុជាតិដែលមានស្រាប់ ដូចជា ការរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញា UNFCCC (NDC) សកម្មភាពជាតិកាត់បន្ថយសមស្រប (NAMAs) ផែនការជាតិបន្សាំ (NAPs) និងកម្មវិធីសកម្មភាពជាតិបន្សាំ (NAPAs) ជាដើម ឬ ក៏អាចបង្កើតក្របខ័ណ្ឌយុទ្ធសាស្ត្រជាក់លាក់ដែលផ្តោតលើមូលនិធិអាកាសធាតុបៃតង ដែលឈរលើផែនការនិងយុទ្ធសាស្ត្រជាតិដែលមានស្រាប់។ មូលនិធិអាកាសធាតុបៃតង នឹងផ្តល់ជំនួយជាគម្រោងត្រៀម សម្រាប់ការកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រថ្នាក់ជាតិទាំងនេះ ។
- ដើម្បីធានាឱ្យមានការសម្របសម្រួល និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធជាប្រព័ន្ធ ប្រទេសនានាត្រូវបានលើកទឹកចិត្តឱ្យរៀបចំដំណើរការពិគ្រោះយោបល់មួយសម្រាប់កំណត់យុទ្ធសាស្ត្រ និងអាទិភាពជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ ។
- ដំណើរការពិគ្រោះយោបល់នេះ គួរតែមានទំនាក់ទំនងគ្នារវាងសកម្មភាពនីមួយៗ ជាជាងសកម្មភាពដាច់ៗពីគ្នាដែលធ្វើឱ្យមិនមានលទ្ធភាពតាមដានបន្ត ដើម្បីធ្វើបច្ចុប្បន្នភាព និងវាយតម្លៃពីវឌ្ឍនភាពទៀងទាត់។
- ដំណើរការពិគ្រោះយោបល់ទាំងនេះគួរតែត្រូវបានដាក់បញ្ចូល និងស្វែងរកការចូលរួមពីសំណាក់អង្គភាពពាក់ព័ន្ធទាំងអស់នៅក្នុងស្ថាប័នរដ្ឋ វិស័យឯកជន គ្រឹះស្ថានសិក្សា សង្គមស៊ីវិល និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។
- លក្ខណៈវិនិច្ឆ័យ និងជម្រើសសម្រាប់ការសម្របសម្រួលប្រទេសតាមរយៈដំណើរការពិគ្រោះយោបល់នេះមានដូចជា៖
  i. ការប្រជុំប្រចាំប្រទេសដែលមានស្រាប់ ការរៀបចំផែនការ ឬការសន្ទនាថ្នាក់ជាតិ ដែលទទួលបានការគាំទ្រពីប្រភពមូលនិធិផ្សេងទៀតសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុ ការចែករំលែកមេរៀន និងការប្រមូលផ្តុំជាតុចូល និងទស្សនៈ។
  ii. ប្រសិនបើកាលៈទេសៈប្រទេសផ្តល់ឱ្យ បង្កើតឱ្យមានយន្តការសម្របសម្រួលក្នុងប្រទេសសម្រាប់កំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រក្នុងដំណើរការរបស់មូលនិធិអាកាសធាតុបៃតង។
  iii. ដាក់បញ្ចូលនៅក្នុងដំណើរការពិគ្រោះយោបល់ថ្នាក់ជាតិពាក់ព័ន្ធផ្សេងៗទៀត ដែលអាចធ្វើការរួមគ្នា និងផ្លាស់ប្តូរព័ត៌មានគ្នា និង
  iv. អភិវឌ្ឍបន្ថែមពីលើបទពិសោធន៍មុនៗរបស់ប្រទេសក្នុងការសម្របសម្រួលគំនិតផ្តួចផ្តើម និងការវិនិយោគអន្តរវិស័យ និងការចូលរួមជាមួយប្រភពហិរញ្ញវត្ថុផ្សេងទៀត។

**អាទិភាពនៃកាត់បន្ថយ៖** NCSD នឹងសម្របសម្រួលសកម្មភាពកាត់បន្ថយនៅគ្រប់វិស័យ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។ ដូចដែលបានបង្ហាញនៅខាងក្រោម ឃើញថាមានការរីកចម្រើនយ៉ាងខ្លាំងទាក់ទងនឹងការអនុវត្តសកម្មភាពកាត់បន្ថយ ប៉ុន្តែគួរមានការធ្វើសមាហរណកម្ម។ សកម្មភាពសំខាន់ៗដែលត្រូវបានកំណត់រួមមាន៖ ១). ការវាយតម្លៃលើសកម្មភាពបច្ចុប្បន្ន ២). កំណត់សកម្មភាពថ្មីៗ ៣).ឧបសគ្គនិងការវាយតម្លៃចាំបាច់ ៤). ការវាយតំលៃគោលនយោបាយ និង ៥). ការសង្ខេបនិងសមាហរណកម្ម។

សេចក្ដីសង្ខេបនៃសកម្មភាពកាត់បន្ថយដែលបានស្នើឡើងនៅក្នុង NDC រួមជាមួយគម្រោង CDM និង JCM ដែលអាចពង្រីកវិសាលភាព និងអាចដាក់បញ្ចូលទៅក្នុងកម្មវិធីប្រចាំប្រទេសសម្រាប់មូលនិធិអាកាសធាតុបៃតង មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី ២ ។ ឧទាហរណ៍នៃសំណើគម្រោងសម្រាប់មូលនិធិ GCF ដែលមានសក្តានុពល មានដូចខាងក្រោមខាងក្រោម៖

**ក. <u>វិស័យគ្រប់គ្រងសំណល់</u>**

- យុទ្ធសាស្ត្រគ្រប់គ្រងសំរាមនិងផែនការសកម្មភាពរបស់រាជធានីភ្នំពេញឆ្នាំ ២០១៨-២០៣៥។ សកម្មភាពដែលរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុរួមមាន៖
  - ការលើកកម្ពស់យុទ្ធសាស្ត្រ ការកាត់បន្ថយ ការប្រើប្រាស់ម្តងទៀត និងការកែច្នៃវត្ថុដែលប្រើរួចដើម្បីប្រើប្រាស់ម្តងទៀត(3Rs)
  - ការផ្លាស់ប្តូរពីការចាក់កាកសំណល់សរីរាង្គនៅទីលានចាក់សំរាម និងការគ្រប់គ្រងការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG / SLCP) នៅទីលានចាក់សំរាម
  - ការបញ្ឈប់ការចាក់សំរាម និងការដុតសំរាម
  - ការលើកកម្ពស់ការគ្រប់គ្រងសំរាមប្រកបដោយចីរភាព

**<u>ខ. វិស័យកសិកម្ម</u>**

- មូលនិធិអាកាសធាតុបៃតង (GCF) និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB)៖ គម្រោងខ្សែចង្វាក់កសិ-ធុរកិច្ចដែលមានមេត្រីភាពអាកាសធាតុ ២០១៩-២០២៧។ គម្រោងនេះត្រូវបានអនុម័តដោយ GCF ដែលបានផ្តល់ជំនួយឥតសំណងចំនួន ៣០ លានដុល្លារអាមេរិក និងប្រាក់កម្ចីសម្បទានចំនួន ១០ លានដុល្លារអាមេរិក ដើម្បីបន្ថែមពីលើកម្ចីពីធនាគារ ADB។
- អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ (UNIDO) / មូលនិធិបរិស្ថានពិភពលោក (GEF) ៖ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់តាមរយៈការជំរុញឡជីវឧស្ម័នពាណិជ្ជកម្មនៅកម្ពុជា (បញ្ចប់ នៅឆ្នាំ ២០១៧) និង
- មូលនិធិបរិស្ថានពិភពលោក (GEF) / មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម(IFAD)៖ ការកសាងសមត្ថភាពបន្សាំតាមរយៈការពង្រីកវិសាលភាពនៃបច្ចេកវិទ្យាថាមពលកកើតឡើងវិញនៅជនបទនៃប្រទេសកម្ពុជា (ឆ្នាំ ២០១៦-២០២០)។

**អាទិភាពនៃការបន្សាំ** ៖ ដើម្បីចៀសវាងការធ្វើការងារជាន់គ្នា គឺត្រូវតែផ្សាភ្ជាប់ការអនុវត្តរវាងផ្នែកបន្សាំនៅក្នុង NDC និងដំណើរការរបស់ NAP ។ ការសិក្សារបស់ Ricardo/GIZ ស្តីពី «តួនាទីរបស់ដំណើរការ NAP

ក្នុងការប្រែក្លាយគោលដៅបន្សាំរបស់ NDC ទៅជាសកម្មភាព៖ ការផ្សារភ្ជាប់រវាងដំណើរការ NAP និង NDCs»[5] បានណែនាំអំពីវិធីធ្វើសមាហរណកម្មរបស់ដំណើរការទាំង២ និងអាចអនុវត្តបានសម្រាប់បរិបទកម្ពុជា (ប្រទេសមួយដែលមានសមាសធាតុបន្សាំស្រាប់ និងកំពុងរីកចម្រើនលើដំណើរការ NAP) ។

- ដំណើរការ NAP អាចអនុវត្តគោលដៅបន្សាំរបស់ NDC តាមរយៈការសម្របសម្រួលសកម្មភាពបន្សាំអន្តរវិស័យ
- ដំណើរការ NAP អាចប្រើប្រាស់ដើម្បីធ្វើបច្ចុប្បន្នភាពគោលដៅនៃការបន្សាំរបស់ NDC បាន
- សហប្រយោជន៍របស់សកម្មភាពកាត់បន្ថយនិងការបន្សាំ អាចកំណត់និងពិចារណាក្នុងដំណើរការ NAP និងដាក់បញ្ចូលនៅក្នុងឯកសារបច្ចុប្បន្នភាព NDC ។
- ការធ្វើការរួមគ្នា អាចធ្វើទៅបានទាក់ទងនឹងការងារអភិបាលកិច្ច ការសម្របសម្រួល ហិរញ្ញវត្ថុ និងតម្លាភាពដោយអនុវត្ត និងអភិវឌ្ឍគោលដៅបន្សាំជាតិ NDC តាមរយៈដំណើរការ NAP ។

**សេចក្តីសង្ខេប៖**

- នៅក្នុងជំពូកនេះបានពន្យល់លម្អិតអំពី ក្របខ័ណ្ឌនៃការធ្វើចូលរួមរបស់ស្ថាប័នសាធារណៈ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល ប្រកបដោយការបើកចំហ យុត្តិធម៌ តម្លាភាព និងបរិយាប័ន្ន ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ សំដៅពង្រីកវិសាលភាពនៃដំណោះស្រាយអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។
- ជំពូកនេះបានបង្ហាញអំពីវិធានការសក្តានុពលសម្រាប់ការបន្សាំ និងការកាត់បន្ថយ ដោយផ្អែកលើផែនទីបង្ហាញផ្លូវ NDC CDM និង JCM ដែលគួរដាក់បញ្ចូលនៅក្នុងកម្មវិធីប្រចាំប្រទេសកម្ពុជាសម្រាប់ GCF។

[5] *Available here:* *http://www.adaptationcommunity.net/wp-content/uploads/2017/10/The-Role-of-the-NAP-Process-in-Translating-NDC-Adaptation-Goals-into-Action.-Linking-NAP-processes-and-NDCs.pdf*

## ជំពូកទី៥៖ ក្របខ័ណ្ឌស្ថាប័ននិងក្របខ័ណ្ឌហិរញ្ញវត្ថុជាតិ ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ

ជំពូកនេះវិភាគអំពីក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌហិរញ្ញវត្ថុបច្ចុប្បន្ន ដើម្បីទទួលនិងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ សំដៅពង្រីកវិសាលភាពដំណោះស្រាយអំពីអាកាសធាតុនៅកម្ពុជា។ លក្ខណៈវិនិច្ឆ័យដើម្បីរៀបចំការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយជាតិ និងវិស័យ ដែលមានយន្តការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុនេះ ត្រូវផ្អែកលើសំណួរដូចខាងក្រោម៖

តើរដ្ឋាភិបាលមានគោលនយោបាយអ្វីខ្លះដើម្បីលើកទឹកចិត្តអង្គភាពជាតិ ដើម្បីទទួលបាននិងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ? តើរដ្ឋាភិបាលបានផ្តល់អាណត្តិការងារអ្វីខ្លះដល់អង្គភាពគ្រប់គ្រងជាតិ? តើរដ្ឋាភិបាលមានយុទ្ធសាស្ត្រសម្របសម្រួល និងទំនាក់ទំនងដូចម្តេចខ្លះ? តើរដ្ឋាភិបាលត្រូវការពង្រឹងសមត្ថភាពដូចម្តេចខ្លះ? តើមានយន្តការគ្រប់គ្រង ត្រួតពិនិត្យ និងអភិបាលកិច្ច ដូចម្តេចខ្លះ? តើមានយុទ្ធសាស្ត្រតាមដាន និងវាយតម្លៃដូចម្តេចខ្លះ?

អនុសាសន៍សម្រាប់រៀបចំក្របខ័ណ្ឌ និងយន្តការដែលមានប្រសិទ្ធភាពបំផុត ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ មានដូចតទៅ៖

- ពិនិត្យឡើងវិញនូវក្របខ័ណ្ឌស្ថាប័នការប្រែប្រួលអាកាសធាតុ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធដែលមានស្រាប់ ដើម្បីកែប្រែចំណុចមួយចំនួនសម្រាប់ប្រតិបត្តិការរបស់ NDA (MOE) និង DCC ក្នុងនាមជាជនបង្គោល ដើម្បីគោរពតាមលក្ខខណ្ឌតម្រូវរបស់ GCF
- ពិនិត្យឡើងវិញ និងកែប្រែសេចក្តីព្រាង តួនាទី និងភារកិច្ចរបស់ NDA និង DCC ដើម្បីធានាបាននូវការចូលរួមប្រកបដោយប្រសិទ្ធភាពរវាង NDA ជាមួយ GCF និងភាគីពាក់ព័ន្ធសំខាន់ៗ
- ពិនិត្យឡើងវិញនូវប្រភេទនៃការគាំទ្រដែល NDA និង DCC នឹងត្រូវការក្នុងការវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា ព្រមទាំងការឧទ្ទេសនាមស្ថាប័នទទួលមូលនិធិដោយផ្ទាល់ (DAE)
- ពិនិត្យឡើងវិញនូវមេរៀនដែលបានពីការវាយតម្លៃគម្រោងយន្តការអភិវឌ្ឍន៍ស្អាត (CDM) ។

### ៥.១ យន្តការនៃការសម្រេចចិត្តដែលមានស្រាប់

#### ក. ក្របខ័ណ្ឌស្ថាប័នស្តីពីការប្រែប្រួលអាកាសធាតុ

**វេទនាសម្ព័ន្ធរបស់** NCSD៖ នៅឆ្នាំ ២០០៦ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិប្រែប្រួលអាកាសធាតុ (NCCC) ដែលជាស្ថាប័នពហុវិស័យ និងពហុជំនាញ ដែលមានអាណត្តិរៀបចំសម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តិ ផែនការនិងកម្មវិធីដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ NCCC បានដំណើរការក្នុងនាមជាយន្តការអន្តរក្រសួងសម្រាប់ការសម្របសម្រួល ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ដោយធ្លាប់ធ្វើវិសោធនកម្មម្តងនៅឆ្នាំ ២០១៤។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) ដែលបានបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ២០១៥ បានបន្តអនុវត្តមុខងាររបស់ NCCC។ ក្រុមប្រឹក្សានេះមាននាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស និងរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន ព្រមទាំងតំណាងជាន់ខ្ពស់ (ថ្នាក់រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ) របស់ក្រសួង ស្ថាប័នរដ្ឋពាក់ព័ន្ធ។ សមាជិក សមាជិការរបស់ក្រុមប្រឹក្សានេះមានការកើនឡើងបើប្រៀបធៀបទៅនឹងចំនួនសមាជិក NCCC ដោយសារគ្របដណ្តប់លើក្រសួង និងទីភ្នាក់ងារជាច្រើនរួមទាំងអភិបាលរាជធានី-ខេត្តផងដែរ (រូបភាព ៧) ។

បច្ចុប្បន្ននេះ NCSD បានខិតខំប្រឹងប្រែងកែលម្អការសម្របសម្រួលសកម្មភាពប្រែប្រួលអាកាសធាតុនៅកម្ពុជា និងលើកកម្ពស់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឱ្យកាន់តែខ្លាំងក្លា ទូលំទូលាយ និងមានប្រសិទ្ធិភាពថែមទៀត។ មិនតែប៉ុណ្ណោះ NCSD បានចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ ២០១៤-២០២៣ ផែនការសកម្មភាពអាកាសធាតុតាមវិស័យ និងក្របខ័ណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុផងដែរ។

ក្រសួងបរិស្ថានដើរតួនាទីសំខាន់ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា៖

- ក្រសួងបរិស្ថាន មាននាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៩[6] ។ នាយកដ្ឋាននេះទទួលខុសត្រូវលើសកម្មភាពជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងដើរតួជាអង្គភាពបង្គោលរបស់ប្រទេសកម្ពុជាសម្រាប់អនុសញ្ញា UNFCCC ក្រុមការងារអន្តររដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) និងពិធីសារក្យូតូ។ លើសពីនេះទៀតនាយកដ្ឋាន DCC ក៏សម្របសម្រួលក្រុមការងារ និងវិស័យផ្សេងៗដែលទាក់ទងនឹងអាកាសធាតុដូចជាវិស័យថាមពល វិស័យព្រៃឈើ សារពើភណ្ឌឧស្ម័នផ្ទះកញ្ចក់ ភាពងាយរងគ្រោះនិងការបន្សុំាជាដើម។ ល។
- នៅខែកក្កដា ឆ្នាំ២០០២ ក្រសួងបរិស្ថានត្រូវបានតែងតាំងជាស្ថាប័នជាតិទទួលបន្ទុក(DNA) សម្រាប់យន្តការអភិវឌ្ឍន៍ស្អាត (CDM) ដែល DCC ដើរតួជាលេខាធិការ DNA។
- ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ (CCTWG) ដែលត្រូវបានបង្កើតឡើងក្នុងខែឧសភា ឆ្នាំ ២០១១ ដើរតួនាទីជាអង្គភាពប្រឹក្សាបច្ចេកទេសដល់ NCSD។ ឧទាហរណ៍ CCTWG បានផ្តល់ការគាំទ្រដល់ក្រសួងពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (CCAP) តាមវិស័យ។

សេចក្តីសង្ខេបនៃ**ស្ថាប័នសំខាន់ៗ**ត្រូវបានបង្ហាញនៅក្នុងតារាងទី ៣ រួមជាមួយនឹងតួនាទី និងភារកិច្ចជាក់លាក់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុរបស់អង្គភាពនីមួយៗ ។

[6] *It replaced the Cambodia Climate Change Office (CCCO), which was established in 2003.*

| តារាងទី ៣៖ សង្ខេបអំពីតួនាទី និងភារកិច្ចរបស់ស្ថាប័នសំខាន់ៗ | |
|---|---|
| **ស្ថាប័ន** | **តួនាទី និងទំនួលខុសត្រូវ** |
| ក្រសួងបរិស្ថាន(ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព) | • ដឹកនាំដំណើរការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការប្រែប្រួលអាកាសធាតុជាតិ<br>• DCC ជាអង្គភាពទំនាក់ទំនងជាមួយ GCF ខណៈឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថានគឺជាតំណាងស្ថាប័នជាតិទទួលបន្ទុក(NDA)<br>• DCC ជាអង្គភាពទំនាក់ទំនងជាមួយ UNFCCC IPCC និង CTCN<br>• សម្របសម្រួលគោលនយោបាយការប្រែប្រួលអាកាសធាតុជាមួយក្រសួង និងភាគីពាក់ព័ន្ធ<br>• ដឹកនាំ និងរៀបចំរបាយការណ៍ជាតិ សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ របាយការណ៍បច្ចុប្បន្នភាពពីរឆ្នាំម្តង ផែនការជាតិបន្សាំនិងការរួមចំណែកជាតិដើម្បីអនុវត្តអនុសញ្ញា UNFCCC (NDC) |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | • ធានាបាននូវលំហូរធនធានហិរញ្ញវត្ថុសម្រាប់គម្រោងការប្រែប្រួលអាកាសធាតុ<br>• តាមដានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជំនួយក្នុងការកៀរគរថវិកា<br>• គាំទ្រមូនិធិសម្រាប់ស្ថាប័នជាក់លាក់ |
| ក្រសួងនីមួយៗ | • ជួយរៀបចំគោលនយោបាយប្រែប្រួលកាសធាតុតាមវិស័យ និងធានាឱ្យបាននូវការបញ្ជ្រាបការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យនីមួយៗ<br>• ប្រមូលទិន្នន័យដែលចាំបាច់សម្រាប់ការធ្វើសារពើភណ្ឌ ឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យនីមួយៗ<br>• រៀបចំឯកសារទស្សនទាន និងអនុវត្តគម្រោងបន្សាំ/ កាត់បន្ថយការប្រែប្រួលអាកាសធាតុ<br>• តាមដាន និងរាយការណ៍<br>• សហប្រតិបត្តិការជាមួយក្រសួងផ្សេងៗ<br>• ផ្តល់ការគាំទ្រដល់សមាជិក NCSD<br>• សម្របសម្រួលជាមួយក្រសួងបរិស្ថាន<br>• ដើរតួជាអង្គភាពប្រតិបត្តិ និងធ្វើការជាមួយNDA/IAE/DAE ដើម្បីទទួលយកនិងប្រើប្រាស់ធនធានរបស់ GCF |

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានអគ្គលេខាធិការដ្ឋាន (GSSD) និងមានការិយាល័យរបស់ខ្លួននៅក្រសួងបរិស្ថាន។ GSSD មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល និងអនុវត្តការងារប្រចាំថ្ងៃដោយអនុលោមតាមសេចក្តីណែនាំ និងសេចក្តីសម្រេចរបស់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បង្កើតកម្មវិធី និងផែនការការងារ ដើម្បីដាក់ឆ្លង ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីពិនិត្យនិងអនុម័ត
- ដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធី និងផែនការការងារ ដែលបានអនុម័តដោយ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- សម្របសម្រួលការរៀបចំលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួល និងគាំទ្រការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព និងធ្វើការតាមដាន និងវាយតម្លៃ និងរាយការណ៍ជាទៀងទាត់
- កៀរគរ និងគ្រប់គ្រងធនធានសម្រាប់ការអនុវត្តលិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- ស្នើសុំការបង្កើតយន្តការដែលចាំបាច់សម្រាប់ បញ្ហាតាមវិស័យដែលទាក់ទងទៅនឹងតួនាទី និងភារកិច្ចរបស់ NCSD និងផ្តល់ការគាំទ្រដល់សកម្មភាពពាក់ព័ន្ធ និងយន្តការប្រតិបត្តិជាទៀងទាត់
- សម្របសម្រួល និងគាំទ្រការពង្រឹងកិច្ចសហប្រតិបត្តិការទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព ជាមួយនឹងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានសិក្សា និងភាគីពាក់ព័ន្ធនានានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងលើពិភពលោក
- ដឹកនាំ និងសម្របសម្រួលការសិក្សាស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល និងការផ្លាស់ប្តូរបច្ចេកវិទ្យាដែលទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព
- គ្រប់គ្រងទិន្នន័យ និងផ្សព្វផ្សាយព័ត៌មានដែលទាក់ទងនឹងការអភិវឌ្ឍដោយចីរភាព និងសកម្មភាពរបស់ NCSD ដល់សាធារណជន
- ពិនិត្យ និងសិក្សាលទ្ធភាពដើម្បីចូលរួមក្នុងកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងការអភិវឌ្ឍដោយចីរភាពសម្រាប់ NCSD
- រៀបចំពង្រាងឯកសារគោលជំហរ និងយុទ្ធសាស្ត្រសម្រាប់ការចូលរួមក្នុងកិច្ចចរចាអន្តរជាតិដែលពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព
- សម្របសម្រួលការរៀបចំរបាយការណ៍ជាតិស្របតាមកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព ដែលកម្ពុជាជារដ្ឋភាគី
- ចូលរួមក្នុងកិច្ចប្រជុំថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិស្តីពីបញ្ហានានាដែលទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព។
- គ្រប់គ្រងហិរញ្ញវត្ថុ និងថវិការបស់ NCSD
- រៀបចំកិច្ចប្រជុំ ធ្វើកំណត់ហេតុ និងធ្វើរបាយការណ៍ជូន NCSD
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូន NCSD
- អនុវត្តមុខងារផ្សេងៗទៀតតាមការចាត់តាំងរបស់ NCSD និងប្រធានគណៈកម្មាធិការប្រតិបត្តិរបស់ NCSD

**ខ. បទពិសោធន៍ទទួលបានពីយន្តការនៃការសម្រេចចិត្តរបស់ស្ថាប័ន ដើម្បីវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា**

**i. ឯកសារទស្សនទាន និងសំណើថវិការបស់ CDM ៖**

- ការយឺតយ៉ាវក្នុងការចេញលិខិតយល់ព្រមពី DNA

- សមត្ថភាពក្នុងការសម្រេចចិត្តរហ័ស និងមានព័ត៌មានគ្រប់គ្រាន់

ii. **ឯកសារទស្សនទាន និងសំណើថវិការបស់ GCF៖**
- ការយឺតយ៉ាវក្នុងការចេញលិខិតយល់ព្រម
- មិនមានការចូលរួមពី វិស័យឯកជន គ្រឹះស្ថានសិក្សា និងអង្គការសង្គមស៊ីវិលក្នុងការវាយតម្លៃឡើយ

iii. **ឯកសារទស្សនទាន និងសំណើថវិការបស់ CCCA៖**
- បង្កើនការចូលរួមយ៉ាងសកម្មពីក្រុមការងារវាយតម្លៃ
- សមត្ថភាពក្នុងការធ្វើការសម្រេចចិត្តយ៉ាងរហ័ស និងមានព័ត៌មានគ្រប់គ្រាន់

**នីតិវិធីបច្ចុប្បន្នដើម្បីវាយតម្លៃឯកសារទស្សនទាន និងសំណើថវិការបស់ GCF ៖** នីតិវិធីបច្ចុប្បន្នដើម្បីវាយតម្លៃ និងអនុម័តឯកសារទស្សនទាន និង សំណើថវិកា GCF ត្រូវបានបង្ហាញនៅក្នុងរូបភាពទី ៨។ ការប្រជុំទ្វេភាគីជាមួយស្ថាប័នរដ្ឋ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិ ក្នុងនាមជា IAE ត្រូវបានធ្វើឡើងដើម្បីស្វែងយល់ និងវាយតម្លៃពីចំណុចខ្លាំង និងចំណុចខ្សោយនៃនីតិវិធីនាពេលបច្ចុប្បន្ន។ ហើយប្រសិនបើមានតម្រូវការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពលើនីតិវិធីដែលមានស្រាប់ដោយផ្អែកលើគោលការណ៍ណែនាំនិងតម្រូវការប្រតិបត្តិរបស់ GCF ។ តើ NDA ត្រូវការការគាំទ្រអ្វីខ្លះ ដើម្បីវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា និងការឧទ្ទេសនាមស្ថាប័នដែលអាចទទួលមូលនិធិដោយផ្ទាល់ (DAE)?




រូបភាពទី ៨៖ នីតិវិធីបច្ចុប្បន្នដើម្បីវាយតម្លៃ និងអនុម័តលើឯកសារទស្សនទាន និងសំណើថវិកា

### គ. ក្របខ័ណ្ឌស្ថាប័ននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន

ការរៀបចំស្ថាប័ន មុខងារ និងសមត្ថភាពរបស់អង្គភាពនានា ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ ដូចជា GCF មានដូចខាងក្រោមៈ

- **ស្ថាប័នថ្នាក់ជាតិៈ** មានក្រសួងបរិស្ថានជា NDA របស់ GCF ហើយមាន DCC ដែលស្ថិតនៅក្រោម GSSD សម្របសម្រួលការងារពាក់ព័ន្ធនឹងហិរញ្ញប្បទានអាកាសធាតុ
- **អង្គភាពអនុវត្តៈ** មានអង្គភាពអន្តរជាតិទទួលសេចក្តីទុកចិត្ត (IAE) ដូចជា UNDP FAO AFD IFAD ជាដើម និងស្ថាប័នជាតិទទួលមូលនិធិដោយផ្ទាល់ ដូចជា NCDD។ និយមន័យនៃពាក្យទាំងនេះមានពន្យល់នៅក្នុងសទ្ទានុក្រម។
- **អង្គភាពប្រតិបត្តិ(EE)៖** មានអង្គភាពសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិលដែលមានបទពិសោធន៍រៀបចំ អនុវត្ត គ្រប់គ្រង តាមដាន វាយតម្លៃ និងផ្តល់លទ្ធផលគម្រោង/កម្មវិធីដែលបានទទួលថវិកាពី GCF ។

ច្រកចូលដែល NDA អង្គភាពអន្តរជាតិទទួលសេចក្តីទុកចិត្ត (IAEs) អង្គភាពទទួលមូលនិធិដោយផ្ទាល់ (DAEs) និងអង្គភាពប្រតិបត្តិ (EEs) ត្រូវដឹងដើម្បីទទួលបាននិងប្រើប្រាស់ធនធាន GCF ត្រូវបានបង្ហាញក្នុងរូបភាពទី៩។ **នេះមានន័យថា ក្របខ័ណ្ឌស្ថាប័នដែលមានស្រាប់បានផ្តល់នូវរចនាសម្ព័ន្ធអភិបាលកិច្ចល្អបំផុតសម្រាប់ស្ថាប័ននានា ដើម្បីបំពេញតួនាទី និងទំនួលខុសត្រូវរបស់អង្គភាពនីមួយៗក្នុងការសម្រេចចិត្ត ដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ។** រហូតមកដល់ពេលនេះមិនមានរចនាសម្ព័ន្ធជាផ្លូវការរបស់NCSDនៅថ្នាក់ខេត្ត/ស្រុកនៅឡើយទេ។យន្តការសម្រាប់ធ្វើសមាហរណកម្ម តួនាទីរបស់NCSDទៅក្នុងអង្គភាពថ្នាក់ក្រោមជាតិដែលមានស្រាប់ត្រូវបានស្នើឡើងនិងពិភាក្សាប៉ុន្តែរហូតមកដល់ពេលនេះមិនទាន់មានអ្វីត្រូវបានអនុម័តនៅឡើយទេ។ លទ្ធផលនៃការពិភាក្សាបានបង្ហាញថាភាគីដែលពាក់ព័ន្ធចង់មានតួនាទី NCSD នៅក្នុងរចនាសម្ព័ន្ធប្រតិបត្តិដែលមានស្រាប់របស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាជាងការបង្កើតស្ថាប័នថ្មីមួយទៀត។

ការងារជាច្រើនត្រូវបានបញ្ចប់ដោយជោគជ័យលើការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏ដូចជាផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ (រហូតដល់កម្រិតឃុំ/សង្កាត់)។ ការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងផែនការរបស់ក្រសួងពាក់ព័ន្ធ។ ក្រសួងពាក់ព័ន្ធទាំងនោះថែមទាំងមានផែនការសកម្មភាពការប្រែប្រួលអាកាសធាតុរបស់អង្គភាពនីមួយៗផងដែរ។ នេះមានន័យថាអង្គភាពពាក់ព័ន្ធនៅថ្នាក់ឃុំ និងស្រុកអាចចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងនាមជា EEs ដើម្បីអនុវត្តគម្រោង/កម្មវិធីដែលបានអនុម័តដោយ GCF ។

ដោយសារ GSSD មានបំណងក្លាយជា DAE ហេតុនេះមូលនិធិជាតិស្តីពីអាកាសធាតុ (NCFF) ដែលបានស្នើ អាចត្រូវបានបញ្ចូលទៅក្នុង GSSD (សូមមើលជំពូក ៧) ដើម្បីផ្តល់មូលនិធិ បន្ថែម ឬជាបន្តបន្ទាប់ដល់សកម្មភាពសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនាពេលអនាគត (រូបភាពទី ១០) ។




**រូបភាពទី ៩៖ ច្រកចូលសម្រាប់ NDA ដើម្បីចូលរួមជាមួយ GCF និងភាគីពាក់ព័ន្ធសំខាន់ៗ**

**(CCTWG, DAE, IAE, និង EE)**

## ៥.២ យន្តការសម្រេចចិត្តក្នុងការទទួល និងប្រើប្រាស់ធនធានរបស់ GCF

### ក. យន្តការសម្រេចចិត្តរបស់ស្ថាប័នក្នុងនីតិវិធីចេញលិខិតគាំទ្រ និងនីតិវិធីឧទ្ទេសនាម DAE៖

- កិច្ចប្រជុំទ្វេភាគី និងសិក្ខាសាលាពិគ្រោះយោបល់ដែលបានធ្វើឡើងនៅខែមេសាឆ្នាំ ២០១៩ និងនៅថ្ងៃទី ២៥ ខែមិថុនាឆ្នាំ ២០១៩ នៅក្នុងប្រទេសកម្ពុជា បានឯកភាពថានឹងបង្កើត ក្រុមការងារវាយតម្លៃ (GCFAP) ដើម្បីគាំទ្រ NDA ក្នុងការវាយតម្លៃឯកសារទស្សនទាន (CN) សំណើថវិកា (FP) និងការឧទ្ទេសនាម DAE។ NDA នឹងជ្រើសរើសអ្នកជំនាញជាសមាជិក ដែលមានសមាសភាពមកអង្គភាពសាធារណៈ វិស័យឯកជន គ្រឹះស្ថានសិក្សា និងអង្គការសង្គមស៊ីវិល ដូចដែលបានបង្ហាញក្នុងតារាងទី ៤។
- GCFAP នឹងពិនិត្យ និងវាយតម្លៃឯកសារទស្សនទាន ព្រមទាំងផ្តល់អនុសាសន៍ដល់ NDA តាមរយៈ DCC ដោយប្រើប្រាស់គំរូវាយតម្លៃ ដែលមាននៅក្នុងផ្នែកទី ១០.៤។

- NDA នឹងពិនិត្យឯកសារទស្សនទាន និងអនុសាសន៍របស់ GCFAP ហើយធ្វើការសម្រេចចិត្តចុងក្រោយ។
- NDA នឹងវាយតម្លៃ និងអនុម័តលើស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងអង្គការសង្គមស៊ីវិល ដែលចង់ក្លាយជាអង្គភាពទទួលមូលនិធិដោយផ្ទាល់ តាមរយៈនីតិវិធីឧទ្ទេសនាម និងវិធីសាស្ត្រផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់ នៅក្នុងផ្នែកទី ៧.២ ។
- សមាជិក GCFAP នឹងត្រូវបានបណ្តុះបណ្តាលអំពីរបៀបវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកាដោយផ្អែកលើគំរូវាយតម្លៃ CN នៅក្នុងផ្នែកទី ១០.៤ និងគំរូវាយតម្លៃឯកសារទស្សនទាននៅកម្ពុជាក្នុងផ្នែក ៩.២ ។




រូបភាពទី 10៖ ក្របខ័ណ្ឌស្ថាប័ន និងហិរញ្ញវត្ថុដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញវត្ថុអាកាសធាតុទ្វេភាគី និងអន្តរជាតិ (ដូចជា *GCF*) ដើម្បីបង្កើនដំណោះស្រាយអាកាសធាតុនៅកម្ពុជាដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ និងគោលដៅអាកាសធាតុ។

## ៥.៣ សមាជិកភាពនិង លក្ខខណ្ឌការងារ (TOR) របស់ GCFAP

### គណៈកម្មការវាយតម្លៃមូលនិធិ GCF ដើម្បីគាំទ្រ NDA៖

ដើម្បីឱ្យសមាជិក GCFAP គាំទ្រ NDA ប្រកបដោយប្រសិទ្ធភាព GCFAP គួរតែ៖

- ទទួលការអនុញ្ញាតពី NDA ដើម្បីដំណើរការប្រកបដោយប្រសិទ្ធភាព
- មានសិទ្ធិស្វែងរកភស្តុតាង និងយោបល់ ពីក្រុមអ្នកជំនាញ ទោះបីអ្នកទាំងនោះមិនមានសិទ្ធិបោះឆ្នោតក៏ដោយ

**រចនាសម្ព័ន្ធ៖** GCFAP គួរមានការចូលរួមរបស់តំណាងស្ថាប័នរដ្ឋ ស្ថាប័នឯកជន និងសង្គមស៊ីវិល ក្នុងនាមជាសមាជិក៖

- GCFAP នឹងត្រូវដឹកនាំដោយអគ្គលេខាធិការនៃ GSSD
- សមាជិករបស់ GCFAP គួរមានការចូលរួមរបស់តំណាងក្រសួងស្ថាប័ន និងទីភ្នាក់ងារដែលពាក់ព័ន្ធ និងមានឋានៈចាប់ពីថ្នាក់កណ្តាលទៅថ្នាក់ខ្ពស់ (ចាប់ពីថ្នាក់ប្រធានការិយាល័យឡើងទៅ)
- GCFAP ចាំបាច់ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង GSSD ហើយគួរតែមានសិទ្ធិចូលជួបប្រធានស្ថាប័ននីមួយៗដោយផ្ទាល់
- សមាជិកដែលបម្រើការនៅ GCFAP នេះគួរតែមានចំណេះដឹង និងជំនាញពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងការប្រែប្រួលអាកាសធាតុ
- GCFAP ក៏គួរតែមានសិទ្ធិស្វែងរកការគាំទ្រពីក្រុមអ្នកជំនាញប្រែប្រួលអាកាសធាតុនៅមូលដ្ឋានផ្សេងទៀត (ដូចជាអ្នកស្រាវជ្រាវ សាស្ត្រាចារ្យ អ្នកតស៊ូមតិ ជាដើម) ហើយគួរតែអាចស្នើសុំឱ្យពួកគេ ចូលរួមបញ្ចេញសមត្ថភាព ដើម្បីប្រឹក្សាយោបល់នៅពេលចាំបាច់។

**របៀបរបបធ្វើការ៖** GCFAP នឹងធ្វើការជាមួយ NDA តាមរយៈ DCC ដើម្បីផ្តល់អនុសាសន៍លើឯកសារទស្សនទាន និងសំណើថវិកា ដែលស្របទៅនឹងគោលដៅអភិវឌ្ឍជាតិ និងគោលដៅប្រែប្រួលអាកាសធាតុរបស់ប្រទេសកម្ពុជា។ GCFAP គួរផ្តល់អនុសាសន៍ទៅ DCC ដើម្បីឱ្យមានវិធានការសមស្រប ហើយសមាជិក GCFAP នឹងត្រូវគោរពតាមសៀវភៅណែនាំ និងក្រមសីលធម៌របស់ NDA ។

**តួនាទីនិងការទទួលខុសត្រូវ៖** តួនាទីដ៏សំខាន់របស់សមាជិក GCFAP គឺគាំទ្រ និងផ្តល់អនុសាសន៍ដល់ NDA ក្នុងការវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា ដោយផ្អែកលើទម្រង់គំរូរបស់កម្ពុជាសម្រាប់វាយតម្លៃ ឯកសារទស្សនទាន (សូមមើលផ្នែកទី ៨.៤) ។

**អាណត្តិស្របច្បាប់៖** សមាជិក និងតួនាទីរបស់ GCFAP នឹងត្រូវបង្កើតឡើងតាមការចាត់តាំងរបស់ GSSD ដែលមានសិទ្ធិបង្កើតគណៈកម្មាធិការ។

**សមាសភាព GCFAP៖** ក្រុមការងារមានទំហំសមល្មម (តិចជាង ១២ នាក់) ដែលជាអ្នកមានជំនាញក្នុងវិស័យរៀងៗខ្លួន និងជាអ្នកជំនាញដែលត្រូវបានអនុញ្ញាតដោយ NDA (តារាងទី ៤)៖

| តារាងទី 4៖ សមាជិក GCFAP ដែលនឹងមានជំនាញស្របតាមវិស័យអាទិភាពទាំង៨ របស់ GCF | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | **អ្នកជំនាញផ្នែកបន្សាំ** | | | | **អ្នកជំនាញផ្នែកកាត់បន្ថយ** | | | |
| **GCFAP** | ១.ការចិញ្ចឹមជីវិតរបស់ប្រជាជននិងសហគមន៍ | ២.សុខភាពសន្តិសុខស្បៀងនិងទឹក | ៣.ហេដ្ឋារចនាសម្ព័ន្ធនិងបរិស្ថាន សង្គម | ៤.សេវាកម្មអេកូឡូស៊ីនិងប្រព័ន្ធអេកូឡូស៊ី | ៥.ការផលិតនិងប្រើប្រាស់ថាមពល | ៦.ការដឹកជញ្ជូន | ៧.អគារ<br>ទីក្រុង<br>ឧស្សាហកម្ម<br>និង<br>ឧបករណ៍ប្រើប្រាស់ | ៨.ព្រៃឈើ<br>និង<br>ការប្រើប្រាស់ដី |
| ក-ស្ថាប័នរដ្ឋ | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MAFF<br>MoWA<br>MRD<br>NCDD<br>MOE (អគ្គនាយកដ្ឋានសហគមន៍ មូលដ្ឋាន) | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MoWA<br>MOH<br>NCDD<br>MAFF<br>MOWRAM | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MPWT<br>MRD<br>MoWA<br>NCDD<br>MOE (GDANCP)<br>CDC | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MAFF<br>MoWA<br>NCDD<br>MOE (GDANCP) | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MME<br>MoWA<br>CDC | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MPWT<br>MoWA<br>CDC | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MME<br>MISTI<br>MPWT<br>MoWA<br>NCDD<br>MLMUPC | NCSD (ប្រធាន)<br>MOE<br>MEF<br>MOP<br>MAFF<br>MoWA<br>NCDD<br>MOE (GDANCP) |
| ខ-វិស័យឯកជន | C Chamber of Commerce (CCC)<br>ABC | CCC<br>ABC | CCC<br>ABC | CCC<br>ABC | CCC<br>EDC<br>ABC | CCC<br>ABC | CCC<br>EDC<br>ABC | CCC<br>ABC |
| គ-គ្រឹះស្ថានសិក្សា | RUPP<br>RUA | RUPP<br>RUA | RUPP<br>Institute of Technology of Cambodia (ITC) | RUPP | RUPP<br>ITC | RUPP | RUPP | RUPP<br>RUA |
| ឃ. CSO/IP | អ្នកជំនាញមកពីសង្គមស៊ីវិល នឹងអញ្ជើញចូលរួមតាមករណីចាំបាច់។ | | | | | | | |

អ្នកជំនាញនីមួយៗគឺជាអ្នកតំណាងឱ្យស្ថាប័នឬអង្គការរៀងៗខ្លួន នៅពេលត្រូវបានជ្រើសរើសឱ្យបម្រើការងារនៅក្នុងក្រុមការងារ GCFAP អាស្រ័យតាមការកំហិតដោយច្បាប់ឬក្រមសីលធម៌។ យ៉ាងណាក៏ដោយ ការទទួលស្គាល់ និងការផ្តល់រង្វាន់លើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ យោងតាមធនធាន និងលិខិតបទដ្ឋានគតិយុត្តិ អាចកើតមាននាពេលអនាគត ដូចជាតាមរយៈយន្តការ មូលនិធិជាតិស្តីពីការប្រែប្រួលអាកាសធាតុជាដើម[7]។ ប្រសិនបើ GCFAP មានចំនួនតិចជាងចំនួនសមាជិកដែល

[7] *Nickleson, K (2014). Analysis and Recommendations for the Cambodia Climate Finance Framework.*

ត្រូវការ នោះ GCFAP នឹងជ្រើសរើសអ្នកជំនួសដែលមានសមត្ថភាពសមរម្យ និងទាន់ពេលវេលា តាមការណែនាំពី GSSD ។

**ការជ្រើសរើស និងលក្ខខណ្ឌសមាជិកភាពរបស់ GCFAP៖** ស្ថាប័ននីមួយៗនឹងធ្វើឧទ្ទេសនាម និងជ្រើសរើសសមាជិករបស់ GCFAP ដោយខ្លួនឯង។ នៅពេលតែងតាំង និងជ្រើសរើសសមាជិក GCFAP ស្ថាប័ននីមួយៗនឹងតែងតាំង និងអនុម័តសមាជិក GCFAP ប្រកបដោយតុល្យភាព និងបរិយាប័ន្ន ជាមួយនឹងភាពចម្រុះនៃបទពិសោធន៍ ចំណេះដឹង យេនឌ័រ និងប្រវត្តិដើម។

**សមាជិក GCFAP បម្រុង៖** សមាជិក GCFAP នីមួយៗអាចជ្រើសរើសសមាជិកបម្រុងពីក្នុងអង្គភាព ឬស្ថាប័នរបស់ខ្លួនបាន។ សមាជិកបម្រុងអាចត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំ **GCFAP** (ក្នុងករណីចាំបាច់មានការបោះឆ្នោត សមាជិកបម្រុងនៃអង្គភាពមួយ អាចបោះឆ្នោតជំនួសបានលុះត្រាតែសមាជិកពេញសិទ្ធិនៃអង្គភាពដដែលនោះ អវត្តមាន ឬមានទំនាស់ផលប្រយោជន៍។ ទោះជាកាលៈទេសៈណាក៏ដោយ សមាជិកពេញសិទ្ធិ និងសមាជិកបម្រុងរបស់ GCFAP ដែលមកពីអង្គភាពតែមួយ មិនអាចចូលរួមបោះឆ្នោតទាំងពីរនាក់បានទេ)។ ស្ថាប័ននីមួយៗនឹងកំណត់វិធីសាស្ត្រជ្រើសរើសសមាជិកបម្រុង GCFAP។ សមាជិកបម្រុង គួរលើកទឹកចិត្តឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់ NDA តាមលទ្ធភាពដែលអាចធ្វើទៅបាន។

**រយៈពេលបម្រើការនៅ GCFAP៖** រយៈពេលបម្រើការរបស់សមាជិក GCFAP គឺ ៣ឆ្នាំ ហើយអាចបន្តតំណែងបានតែមួយអាណត្តិទៀតប៉ុណ្ណោះ។ លក្ខខណ្ឌផ្សេងៗទៀតនឹងបន្តបានអាស្រ័យលើការយល់ព្រមពី NCSD។ សមាជិក GCFAP ដែលបានបំពេញការងារពីរអាណត្តិជាប់ៗគ្នា មានសិទ្ធិបម្រើការងារឱ្យ GCFAP ម្តងទៀតបន្ទាប់ពីសម្រាករយៈពេលមួយឆ្នាំ។ ក្នុងករណីសមាជិកលាលែងពីតំណែង ឬត្រូវបានបញ្ឈប់ សមាជិកមិនអាចបម្រើការងារបានដល់បីឆ្នាំទេ។

សមាជិក CCTWG ដែលបម្រើការនៅ GCFAP ក្នុងនាមជាតំណាងក្រសួង អង្គការក្រៅរដ្ឋាភិបាល ឬគ្រឹះស្ថានសិក្សា ឬតំណាងវិស័យឯកជន ហើយបានបញ្ចប់មុខតំណែងពីស្ថាប័ននោះ ត្រូវលាឈប់ពី GCFAP យ៉ាងយូរបំផុតនៅថ្ងៃចុងក្រោយបង្អស់ នៃកិច្ចសន្យាការងាររបស់ខ្លួន។ ប្រសិនបើសមាជិកខកខានមិនបានចូលរួមកិច្ចប្រជុំ៣ លើកជាប់ៗគ្នាដោយមិនមានហេតុផលដែលអាចទទួលយកបានប្រធាន GCFAP នឹងលើកយកបញ្ហានេះទៅ NDA និងស្នើសុំការតែងតាំងសមាជិកថ្មីក្នុងរយៈពេលពីរសប្តាហ៍។ ប្រសិនបើសមាជិក GCFAP មិនបានបញ្ចប់អាណត្តិរបស់ស្ថាប័នខ្លួនទេ ស្ថាប័ននោះនឹងត្រូវជ្រើសរើសអ្នកជំនួសថ្មី។

**ប្រធាន GCFAP៖** ប្រធាន GCFAP គឺជាអគ្គលេខាធិការនៃ GSSD ដែលស្ថិតនៅក្នុងមុខតំណែង រហូតមានការផ្លាស់ប្តូរអគ្គលេខាធិការថ្មីនៃ GSSD។ ប្រធាន GCFAP មានសិទ្ធិបោះឆ្នោត។

**ការចូលរួមរបស់សមាជិក GCFAP៖** សមាជិករបស់ GCFAP ត្រូវតែចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចប្រជុំ សកម្មភាព ព្រឹត្តិការណ៍ និងការងារនានារបស់ GCFAP ហើយត្រូវផ្សព្វផ្សាយជាទៀងទាត់អំពីគោលបំណង និងគោលដៅរបស់ NDA និងឱកាសរបស់ GCF ជាមួយអ្នកដែលមិនបានចូលរួម។

**សមត្ថភាព៖** សមាជិករបស់ GCFAP ត្រូវតែប្រកាន់ខ្ជាប់នូវបទដ្ឋានវិជ្ជាជីវៈខ្ពស់ និងការសហការដើម្បីបង្ហាញភាពជាអ្នកដឹកនាំ ក្នុងការស្វែងរកសេរីភាពក្នុងការបញ្ចេញមតិ និងឯកជនភាព។

**ចំនួនសមាជិកអង្គប្រជុំ** ៖ នៅពេលដែលមានការប្រជុំចាំបាច់ អង្គប្រជុំត្រូវមានសមាជិក GCFAP យ៉ាងហោចណាស់ ៥០% នៃចំនួនសមាជិកសរុប បូកជាមួយអ្នកតំណាងម្នាក់ ឬអ្នកជំនួសរបស់ពួកគេ (ដោយមានលិខិតផ្ទេរសិទ្ធិពីសមាជិក GCFAP)។ ការចូលរួមប្រជុំតាមរយៈប្រព័ន្ធវីដេអូត្រូវបានចាត់ទុកថាបានចូលរួមក្នុងកិច្ចប្រជុំដូចគ្នា។

**កិច្ចប្រជុំរបស់ GCFAP៖** GCFAP គួរតែមានការប្រជុំយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ[8] ដោយចាត់ទុកថាកិច្ចប្រជុំលើកដំបូងជាកិច្ចប្រជុំប្រចាំឆ្នាំរបស់ GCFAP ។ ប្រធាន GCFAP និង / ឬលេខាធិការក៏អាចកោះប្រជុំបន្ថែមក្នុងពេលចាំបាច់ដោយជូនដំណឹងជាមុនដល់អង្គភាពនីមួយៗ។ លើសពីនេះ GCFAP ក៏អាចប្រជុំផ្ទៃក្នុងនៅពេលណាមានការសម្រេចចិត្ត និងដំណោះស្រាយដែលមានលក្ខណៈរសើបខ្លាំងដូចជាការដោះស្រាយទំនាស់ផលប្រយោជន៍ជាដើម។

**ទំនាស់ផលប្រយោជន៍៖** សមាជិក GCFAP ត្រូវតែមានភាពមិនលំអៀង ភាពឯករាជ្យ និងការយកចិត្តទុកដាក់លើគ្រប់បញ្ហាទាំងអស់ និងតម្រូវអោយមានការប្តេជ្ញាចិត្តគោរពតាមគោលការណ៍ទំនាស់ផលប្រយោជន៍របស់ GCFAP និងក្រមសីលធម៌របស់ NDA ។ ប្រសិនបើសមាជិកណាមួយមានទំនាស់ផលប្រយោជន៍នឹងប្រធានបទដែលត្រូវបានលើកឡើង សមាជិកនោះគួរជូនដំណឹងដល់ GSSD ហើយសមាជិកនោះអាចត្រូវបានដកសិទ្ធមិនឱ្យចូលរួមបោះឆ្នោត ឬបំពេញមុខងារណាមួយបាន។

**កំណត់ហេតុប្រជុំ៖** លេខាធិការនៃ GCFAP ត្រូវធ្វើកំណត់ហេតុនៃកិច្ចប្រជុំរបស់ GCFAP នីមួយៗ និងធ្វើការផ្សព្វផ្សាយ/ចែកចាយកំណត់ហេតុទាំងនោះដល់សមាជិករបស់ GCFAP តាមរយៈអ៊ីម៉ែលបន្ទាប់ពីកិច្ចប្រជុំ។

**សេចក្តីសង្ខេបនៃកិច្ចប្រជុំ៖** សេចក្តីសង្ខេបនៃកិច្ចប្រជុំ GCFAP និងកិច្ចប្រជុំប្រចាំឆ្នាំនឹងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រ របស់ NCSD ឬគេហទំព័ររបស់ NDA បន្ទាប់ពីការអនុម័តកំណត់ហេតុប្រជុំទាំងនេះរួច។ សេចក្តីសង្ខេបទាំងនេះមិនដាក់បញ្ចូលការសន្ទនាសម្ងាត់ឡើយ។

**សេចក្តីសង្ខេប៖**

- ជំពូកនេះរៀបរាប់លម្អិតពីយន្តការសម្រេចចិត្តនៅក្នុងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌហិរញ្ញវត្ថុ ដើម្បីទទួលនិងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ សំដៅពង្រីកវិសាលភាពដំណោះស្រាយអាកាសធាតុនៅប្រទេសកម្ពុជា។
- ជំពូកនេះក៏បានពិពណ៌នាអំពីសមាជិកភាពនិង លក្ខខណ្ឌការងារ(TOR) នៃក្រុមការងារវាយតម្លៃមូលនិធិ GCF។

[8] It is possible to hold additional meetings as needed; the minimum is each 6 months.

## ជំពូកទី៦ ៖ ស្ថាប័នជាតិទទួលបន្ទុក (NDA)

នៅក្នុងជំពូកនេះពន្យល់ប្រាប់អ្នកណាជាស្ថាប័នជាតិទទួលបន្ទុក (NDA) និងអ្វីដែលជាតួនាទី និងទំនួលខុសត្រូវរបស់ពួកគេ ដើម្បីទទួលបាននិងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ ដោយប្រើប្រាស់ GCF ជាឧទាហរណ៍។ ជំពូកនេះពិពណ៌នាអំពីរបៀបបង្កើតលេខាធិការដ្ឋានរបស់ស្ថាប័នជាតិទទួលបន្ទុក (NDA) ដែលអាចដំណើរការបានដោយរលូនប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងមានលក្ខណៈឋិតថេរនាពេលអនាគត។

ស្ថាប័នជាតិទទួលបន្ទុក (NDA) ដើរតួយ៉ាងសំខាន់ដើម្បីធានាបានថាដៃគូពាក់ព័ន្ធសំខាន់ៗរួមមាន វិស័យរដ្ឋ ឯកជន និងសង្គមស៊ីវិលផ្សេងទៀត បានចូលរួមនៅក្នុងដំណើរការមូលនិធិ GCF ដោយផ្អែកលើមូលដ្ឋាននៃតួនាទី និងអាណត្តិរបស់ពួកគេ។ NDA ជានាទូវការរៀបចំកិច្ចប្រជុំថ្នាក់ប្រទេសជាទៀងទាត់ ឬការរៀបចំផែនការជាតិ/ការសន្ទនាថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយនិងចែករំលែកព័ត៌មានដែលទាក់ទងនឹងដំណើរការមូលនិធិ GCF និងលក្ខខណ្ឌតម្រូវសំខាន់ បញ្ហាប្រឈម និងនីតិវិធីប្រតិបត្តិដល់អ្នកពាក់ព័ន្ធ។ NDA ផ្តល់ជាទៀងទាត់នូវទិដ្ឋភាពទូទៅនៃរាល់សំណើថវិកា ដែលទាក់ទងនឹងប្រទេសកម្ពុជា និងបែងចែកព័ត៌មានដែលមានក្នុងគម្រោង/កម្មវិធីតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញពាក់ព័ន្ធឱ្យបានសមស្រប។

យោងតាមអាណត្តិរបស់មូលនិធិអាកាសធាតុបៃតង (GCF) ស្ថាប័នជាតិទទួលបន្ទុក ជំរុញយន្តការសម្របសម្រួលដែលពាក់ព័ន្ធនឹងដំណើរការចូលរួមរបស់ភាគីពាក់ព័ន្ធជាច្រើនតាមភាពចាំបាច់។ ជារួមស្ថាប័នជាតិទទួលបន្ទុក អនុវត្តមុខងារដូចខាងក្រោម៖

i. សម្របសម្រួលជាមួយរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងគ្រឹះស្ថានសិក្សា និងអ្នកពាក់ព័ន្ធ
ii. ជួយសម្រួលការចូលរួមប្រកបដោយអត្ថន័យជាមួយអ្នកពាក់ព័ន្ធក្នុងដំណើរការមូលនិធិ GCF ដើម្បីប្រមូលធាតុចូល នាំមកនូវភាពស៊ីសង្វាក់គ្នា និងបង្កើតភាពជាម្ចាស់លើដំណើរការចូលរួមមូលនិធិ GCF របស់ប្រទេស
iii. សម្របសម្រួលជាមួយមន្ត្រីបង្គោលទទួលបន្ទុកការងារប្រែប្រួលអាកាសធាតុនៅតាមបណ្តាក្រសួង-ស្ថាប័ន សម្រាប់រៀបចំកិច្ចសន្ទនាស្តីពីការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជាតាមរយៈយន្តការនានា ដូចជា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និង ក្រុមការងារបច្ចេកទេសស្តីពីការការប្រែប្រួលអាកាសធាតុ ជាដើម
iv. ផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹងជាទៀងទាត់ អំពីព័ត៌មានថ្មីៗទាក់ទងនឹងការផ្តល់សេចក្តីទុកចិត្ត និងការរៀបចំសំណើថវិកាដល់អ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយ ដូចជាគេហទំព័ររបស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន ជាដើម
v. ជូនដំណឹងដល់អ្នកពាក់ព័ន្ធសំខាន់ៗអំពីការចូលរួម និងតួនាទីរបស់ពួកគេនៅក្នុងដំណើរការមូលនិធិ GCF និងធ្វើបច្ចុប្បន្នភាពដល់ពួកគេអំពីមូលនិធិ GCF/ហិរញ្ញប្បទានអាកាសធាតុ ជាទៀងទាត់ និង
vi. រៀបចំកិច្ចប្រជុំថ្នាក់ជាតិ ការរៀបចំផែនការជាតិ កិច្ចពិភាក្សារវាងភាគីពាក់ព័ន្ធនានា និងរៀបចំសិក្ខាសាលាស្តីពីមូលនិធិ GCF ។

## ៦.១. តួនាទីនិងទំនួលខុសត្រូវសំខាន់ៗរបស់ក្រសួងបរិស្ថានដែលដើរតួជាស្ថាប័នជាតិទទួលបន្ទុក (NDA)

យោងទៅតាមគោលការណ៍ណែនាំរបស់មូលនិធិអាកាសធាតុបៃតង (សេចក្តីសម្រេច លេខ ប.០៤/០៥) តួនាទី និងទំនួលខុសត្រូវសំខាន់ៗរបស់ស្ថាប័នជាតិទទួលបន្ទុក មានបង្ហាញនៅក្នុងតារាងទី៥ ដូចខាងក្រោម។ បញ្ហាចម្បងដែលត្រូវគិតពិចារណានៅក្នុងការវាយតម្លៃភាពខ្វះចន្លោះរវាងជំនាញ ដំណើរការ នីតិវិធី រចនាសម្ព័ន្ធ និងសមត្ថភាពរបស់ស្ថាប័នជាតិទទួលបន្ទុកដែលមានស្រាប់ និងដែលត្រូវការ ក៏ត្រូវបានបញ្ចូលនៅក្នុងតារាងទី៥ផងដែរ។

**តារាងទី 5៖ តួនាទីនិងទំនួលខុសត្រូវរបស់អាជ្ញាធរជាតិ *NDA* ដោយផ្អែកលើសៀវភៅណែនាំរបស់មូលនិធិ *GCF***

| ការទទួលខុសត្រូវរបស់ស្ថាប័នជាតិទទួលបន្ទុក (NDA) | ជំនាញត្រូវការចាំបាច់ | បញ្ហាចម្បងដែលត្រូវពិចារណា៖<br>ដំណើរការ នីតិវិធី រចនាសម្ព័ន្ធ និងសមត្ថភាព (ដែលត្រូវមានក្នុងករណីចាំបាច់) |
|---|---|---|
| **១. ការឧទ្ទេសនាមរបស់ NDA សម្រាប់ការស្នើសុំ ដើម្បីក្លាយជាអង្គភាពទទួលមូលនិធិ ដោយផ្ទាល់)។** | - ក្រសួងបរិស្ថាន(MoE) គឺជាស្ថាប័នជាតិទទួលបន្ទុក(NDA) មូលនិធិ GCF និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD)។<br>អាជ្ញាធរជាតិNDA/ជនបង្គោលគួរតែសម្រួលការទំនាក់ទំនងទៅកាន់លេខាធិការដ្ឋានចំពោះការឧទ្ទេសនាមអង្គភាពដែលស្នើសុំសម្រាប់ក្លាយជាអង្គភាពទទួលមូលនិធិដោយផ្ទាល់។ | **ដំណើរការនិងនីតិវិធី**<br>១. ពិនិត្យ ក) យន្តការរបស់ក្រសួងបរិស្ថានស្តីពីភាពអនុលោមតាម ច្បាប់ជាតិ បទប្បញ្ញត្តិ និងបទដ្ឋានពាក់ព័ន្ធ របស់អង្គភាពស្នើសុំនិង ខ) គោលការណ៍ធានារបស់ GCF (Fiduciary principles) គោលការណ៍សុវត្ថិភាពបរិស្ថាន និងសង្គម (ESS) និង គោលនយោបាយយេនឌ័រ (សូមមើលឧបសម្ព័ន្ធ ទី៥ និង ទី៦) យោងតាមនីតិវិធីផ្តល់ សេចក្តីទុកចិត្តរបស់មូលនិធិ GCF |
| | -សមត្ថភាពក្នុងការវាយតម្លៃនិងអនុម័តលើការឧទ្ទេសនាមអង្គភាព ដែលស្នើសុំសម្រាប់ក្លាយជាអង្គភាពទទួលមូលនិធិដោយផ្ទាល់ដោយផ្អែកលើគោលការណ៍ ធានា និងគោលការណ៍សុវត្ថិភាពបរិស្ថាន និងសង្គម (ESS) របស់មូលនិធិ GCF។ | ២. បណ្តាញទំនាក់ទំនងរវាងក្រសួងបរិស្ថាន (MoE) និង នាយកដ្ឋានប្រែប្រួលអាកាសធាតុ(DCC) ជាមួយមូលនិធិ GCF៖<br>-តើឯកសារស្នើសុំសម្រាប់ឧទ្ទេសនាមគួរតែផ្ញើទៅណា(សូមមើលជំពូកទី៧)?<br>-តើអ្នកណានឹងឆ្លើយតបនិងវាយតម្លៃលើសំណើនោះ? |
| | -បណ្តាញទំនាក់ទំនងជាមួយ មូលនិធិ GCF ទាក់ទងនឹងការឧទ្ទេសនាមអង្គភាព ដែលស្នើសុំសម្រាប់ក្លាយជាអង្គភាពទទួលមូលនិធិដោយផ្ទាល់ | ៣. ដំណើរការទំនាក់ទំនងរវាងក្រសួងបរិស្ថាន (MoE) និងនាយកដ្ឋានប្រែប្រួល អាកាសធាតុ (DCC) ជាមួយអង្គ |

| | | |
|---|---|---|
| | | ភាពដែលអាចទទួលមូលនិធិដោយផ្ទាល់ |
| | -ការជ្រើសរើសអង្គភាពសមស្របសម្រាប់ក្លាយជាអង្គភាពទទួលមូលនិធិដោយផ្ទាល់នឹងត្រូវ អនុវត្តតាមរយៈដំណើរការប្រកួតប្រជែងឬដំណើរការពិគ្រោះយោបល់ដោយNDA/ជនបង្គោល។ ការដាក់សំណើសុំនឹងត្រូវ ពិគ្រោះយោបល់ជាមួយស្ថាប័នជាតិទទួលបន្ទុក (NDA) (សេចក្តីសម្រេចចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៥, មូលនិធិGCF / B.**09 / 05**)។ | **សមត្ថភាព**<br>១) វាយតម្លៃចំណេះដឹងរបស់ក្រសួងបរិស្ថាន(MoE)និងនាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC)ទាក់ទងនឹង គោលការណ៍ ធានា គោលការណ៍សុវត្ថិភាព បរិស្ថាន និងសង្គម និង គោលនយោបាយ យេនឌ័ររបស់មូលនិធិ GCF ។<br>២) តម្រូវការធនធានមនុស្ស<br>៣) ព័ត៌មានលម្អិតអំពីវិធីសាស្ត្រផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់(fit-forpurpose accreditation)<br>សម្រាប់ NDA នៅក្នុងប្រទេសកម្ពុជាត្រូវបានបង្ហាញនៅក្នុងជំពូកទី៧ និង ឧបសម្ព័ន្ធទី២ |
| **២) តាមរយៈនីតីវិធីចេញលិខិតគាំទ្រ** NDA **នឹងផ្តល់អនុសាសន៍ ដល់ក្រុមប្រឹក្សាភិបាល របស់ មូលនិធិ** GCF **ទៅលើសំណើថវិការបស់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិដែលទទួលបានសេចក្តីទុកចិត្ត ដើម្បីធានាថាសំណើនោះ ៖**<br>i. **ស្របតាមលក្ខណៈវិនិច្ឆ័យ ផ្នែកហិរញ្ញវត្ថុនិងការវិនិយោគរបស់មូលនិធិ** GCF<br>ii. **ស្របតាមគោលការណ៍សុវត្ថិភាពបរិស្ថាន និងសង្គម** (ESS) **គោនយោបាយយេនឌ័រ និង ច្បាប់ជាតិពាក់ព័ន្ធ**<br>iii. **ស្របគ្នាជាមួយផែនការនិងយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ផែនការយេនឌ័រ បូករួមទាំងការសម្របសម្រួលរបស់ប្រទេស និងការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើនទៀត** | -ប្រទេសនីមួយៗសម្រេចចិត្តដោយខ្លួនឯងលើដំណើរការ សមស្របរបស់ជាតិសម្រាប់ ការស្នើសុំលិខិតគាំទ្រចំពោះសំណើថវិកា។ គួរផ្អែកលើសមត្ថភាពដំណើរការនិងស្ថាប័នដែលមានស្រាប់នៅក្នុងប្រទេស។ | **ក)ទាក់ទងនឹងសំណើថវិកានិងការចេញលិខិតគាំទ្រៈដំណើរការ និងនីតិវិធី** |
| | - NDA វាយតម្លៃលើសំណើថវិកាដោយពិនិត្យមើលទៅលើបច្ចេកទេសហិរញ្ញវត្ថុ យុទ្ធសាស្ត្រ និងគោលគំនិតនយោបាយរបស់អ្នកស្នើសុំនីមួយៗ រួមទាំងសំណើរបស់វិស័យឯកជនផងដែរ។ | ១)ពិនិត្យនីតិវិធីផ្ទៃក្នុងរបស់ក្រសួងបរិស្ថាន និងថ្នាក់ជាតិ ដែលមានស្រាប់សម្រាប់ពិនិត្យនិងវាយតម្លៃលើសំណើថវិកា (ឧទាហរណ៍៖ ដំណើរការទាំងមូលរបស់គម្រោង ដូចជា ការស្នើសុំឱ្យមានការរៀបចំជាសំណើ លទ្ធកម្ម និងការត្រួត ពិនិត្យនិងវាយតម្លៃ)។ តើ ការគាំទ្រអ្វីដែលនាយកដ្ឋានប្រែប្រួលអាកាសធាតុ ត្រូវការ? (សូមមើលជំពូកទី៥)<br>២) ពិនិត្យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដើម្បីវាយតម្លៃគម្រោងអភិវឌ្ឍន៍ប្រចាំឆ្នាំនិងវដ្តនៃការប្រប្រាស់ថវិកា ODA កម្ចី និងច្បាប់ស្តី |

| | | |
|---|---|---|
| | | ពីការគ្រប់គ្រងមូលនិធិនិងសាធារណៈវិនិយោគ។ |
| | - NDA ស្វែងរកការបញ្ជាក់បន្ថែមលើរាល់សំណើដែលរៀបចំមិនល្អ លួចចម្លង ឬមានអាទិភាពទាប។ | ក) ទាក់ទងនឹងការបន្សុីដំណើរការទាំងនេះជាមួយនឹងលក្ខខណ្ឌតម្រូវរបស់មូលនិធិ GCF សម្រាប់ AE និងប្រភពផ្តល់មូលនិធិផ្សេងទៀត (សូមមើលរូបភាពទី៧ សម្រាប់ការច្របាច់បញ្ចូលគ្នានូវ ធនធានរបស់មូលនិធិGCF។ |
| | - NDA ត្រូវរៀបចំដំណើរការសម្រេចចិត្តដែលមានប្រសិទ្ធភាព យុត្តិធម៌និងមិនលម្អៀង និងអាចប្រតិបត្តិបានទាន់ពេលវេលា និងរហ័ស។ | ខ) ទាក់ទងនឹងការបន្សុីគ្នារវាង AEs ជាមួយនឹងតម្រូវការរបស់កម្ពុជាដែលមានស្រាប់ ទៅលើតម្រូវការជំនួយឥតសំណង ឬប្រាក់កម្ចីសម្បទាន |
| | - NDA ត្រូវបន្តពិនិត្យមើលរាល់សំណើថវិកាដែលកំពុងរៀបចំ ដើម្បីស្វែងរកការបញ្ជាក់បន្ថែម ឬផ្តល់យោបល់លើរាល់សំណើទាំងឡាយណាដែលមិនបានរៀបចំស្របទៅតាមយុទ្ធសាស្ត្រជាតិ។ | ៣) យន្តការដ៏មានប្រសិទ្ធភាពក្នុងការអំពាវនាវដល់ក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD) និងបណ្ដាក្រសួង ឬក្រុមហ៊ុន ម៉ៅការ ដើម្បីផ្តល់បច្ចេកទេស ហិរញ្ញវត្ថុ ឬអ្នកជំនាញផ្នែកនយោបាយនិងជំបូន្មានដែល ចាំបាច់។<br><br>៤) ប្រកទំនាក់ទំនងនិងការផ្តល់យោបល់ផ្សេងៗអាចនឹងធ្វើឡើងទៅវិញទៅមកជាមួយ AEs ដូចជា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (NCDD) |
| | -ដើម្បីធានាបានភាពស៊ីសង្វាក់គ្នាជាមួយអាទិភាព យុទ្ធសាស្ត្រ និងផែនការជាតិ និងដើម្បីជៀសវាងការស្នើសុំត្រួតគ្នា NDA គួរមានសមត្ថភាពក្នុងការទាក់ទងនិងសម្របសម្រួលជាមួយជនបង្គោលនិងស្ថាប័នជាតិទទួលបន្ទុកមូលនិធិផ្សេងទៀត (ឧទាហរណ៍៖មូលនិធិ GEF មូលនិធិបន្សាំ និងមជ្ឈមណ្ឌលCTCN ជាដើម)។ | **សមត្ថភាព**<br><br>៥) សមត្ថភាពក្នុងការអនុវត្តបច្ចេកទេស ហិរញ្ញវត្ថុ បទប្បញ្ញត្តិ យុទ្ធសាស្ត្រនិងការគ្រប់គ្រង ហានិភ័យផ្នែកនយោបាយ ឧទាហរណ៍៖ ការវិភាគផលចំណេញ-ខាត ននិរន្តរភាពហិរញ្ញវត្ថុ EIRR ឬ FIRR ការចំណាយលែស់តិចតួច/ខ្សែកោងផលចំណេញ (សូមមើលជំពូក ៩)។ |

| | | |
|---|---|---|
| | | ៦) ចំណេះដឹងរបស់ NDAទាក់ទងនឹងលក្ខណៈវិនិច្ឆ័យវិនិយោគ របស់មូលនិធិ GCF (សូមមើលជំពូកទី៩)<br>៧) តម្រូវការធនធានមនុស្ស<br>៨) សេចក្តីលម្អិតស្តីពីនីតិវិធីចេញលិខិតគាំទ្រត្រូវបានបង្ហាញនៅក្នុងជំពូកទី១០។ |
| | - NDA/ជនបង្គោលគួរតែអាចត្រួតពិនិត្យនិងបញ្ជាបការចូលរួមរបស់ប្រទេសជាមួយនឹងធនធានទាំងក្នុងនិងក្រៅនៃហិរញ្ញប្បទានអាកាសធាតុ | **ខ) ទាក់ទងនឹងរចនាសម្ព័ន្ធអភិបាលកិច្ចដើម្បីពិនិត្យ លើសំណើថវិកា និងនីតិវិធីចេញលិខិតគាំទ្រ៖**<br>១) នៅក្នុងប្រទេសកម្ពុជា ក្រុមការងារទទួលបន្ទុកប្រឹក្សាយោបល់មូលនិធិGCFនឹងជ្រើសរើសពីអ្នកជំនាញតាមវិស័យនិងសមាជិកក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុ (CCTWG) និងបម្រើជាយន្តការត្រួតពិនិត្យ និងផ្តល់សេវាប្រឹក្សាយោបល់។ អគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. នឹងរាយការណ៍ពីសកម្មភាពហិរញ្ញប្បទានអាកាសធាតុជូន NDA (សូមមើលជំពូក៥)។<br>២) សេចក្តីលម្អិតស្តីពីនីតិវិធីចេញលិខិតគាំទ្រត្រូវបានបង្ហាញនៅក្នុងជំពូកទី១០។ |
| | -ប្រសិនបើចាំបាច់ NDA គួរតែមានជាស្រេចនូវយន្តការសម្របសម្រួលក្នុងការអំពាវនាវស្នើសុំ ការគាំទ្រពីវិស័យឯកជន សង្គមស៊ីវិល និងបណ្តាក្រសួងពាក់ព័ន្ធផ្សេងទៀត ក្នុងដំណើរការវាយតម្លៃសំណើគម្រោង។ | ៣) ក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) នឹងរៀបចំតាមវិស័យ ដើម្បីវាយតម្លៃនិងផ្តល់អនុសាសន៍លើឯកសារទស្សនទាន និងសំណើថវិកា (សូមមើលជំពូកទី៥)។ |
| | -NDA ត្រូវវាយតម្លៃសំណើថវិកាដោយយោងតាមបទដ្ឋានគោលការណ៍សុវត្ថិភាពបរិស្ថាន និងសង្គម (ESS) និងគោលនយោបាយ យេនឌ័ររបស់មូលនិធិGCF | ៤) ព័ត៌មានលម្អិត នៃនីតិវិធីចេញលិខិតគាំទ្រត្រូវបានបង្ហាញនៅក្នុងជំពូកទី១០ ដែលសមាជិកGCFAP នឹងប្រើគំរូវាយតម្លៃរបស់ឯកសារទស្សនទាន ដើម្បីវាយតម្លៃលើឯកសារទស្សនទាននិងសំណើថវិកា។ |
| | -NDA ទទួលខុសត្រូវលើការអនុវត្តជារួមនៃគោលនយោបាយយេនឌ័រ (អង្គ | ៥) សមាជិក GCFAP នឹងប្រើគំរូវាយតម្លៃរបស់ឯកសារទស្សនទាន ដើម្បី |

| | | |
|---|---|---|
| | ភាពដែលទទួលបានសេចក្តីទុកចិត្ត (AEs) និងអង្គភាពប្រតិបត្តិ (EEs) ជាអ្នកទទួលខុសត្រូវចម្បងក្នុងពេលប្រតិបត្តិការគម្រោង | វាយតម្លៃឯកសារទស្សនទាននិងសំណើថវិកានីមួយៗដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការដាក់បញ្ចូលយេនឌ័រ។ គោលនយោបាយ យេនឌ័ររបស់មូលនិធិGCF មានបង្ហាញនៅក្នុងជំពូក ទី៧។ |
| | | **គ) ទាក់ទងនឹងការវាយតម្លៃ សេដ្ឋកិច្ចសង្គម យេនឌ័រ និង សុវត្ថិភាពបរិស្ថាន និងសង្គម (ESS)៖** |
| | | **ដំណើការ និងនីតិវិធី**<br>១) ដំណើរការពិនិត្យលើសំណើគម្រោង ផ្អែកលើច្បាប់ជាតិ បទដ្ឋានគតិយុត្ត និងបទដ្ឋានពាក់ព័ន្ធ ទាក់ទងនឹងការការពារបរិស្ថាន និងសង្គម និងការពិចារណាលើយេនឌ័រ |
| | | ២) បណ្តាញទំនាក់ទំនងជាមួយភាគីសម្របសម្រួល (នៅក្នុងក្រសួងបរិស្ថាននិងស្ថាប័នផ្សេងទៀត) សម្រាប់ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន ការត្រួតពិនិត្យការអនុវត្តតាមច្បាប់អធិការកិច្ច និងការអនុវត្តច្បាប់ក្រោមដែនសមត្ថកិច្ច |
| | | ៣) បណ្តាញទំនាក់ទំនងជាមួយបណ្តាក្រសួងពាក់ព័ន្ធទទួលបន្ទុកពលកម្មនិង បរិយាប័ន្នសង្គមឱ្យស្របតាមយុទ្ធសាស្ត្រជាតិស្តីពីយេនឌ័រ និងសមភាពយុវជន និង បរិយាប័ន្ន |
| | | **សមត្ថភាព**<br>១) ចំណេះដឹង និងការយល់ឃើញពីគោលការណ៍ណែនាំ បរិស្ថាន និងសង្គម និងគោលនយោបាយយេនឌ័រ<br>២) ពិនិត្យលើសំណើគម្រោងផ្អែកលើ i) គោលការណ៍ណែនាំស្តីពីការវាយតម្លៃសេដ្ឋកិច្ចសង្គមនិងយេនឌ័រ និង ii) សុវត្ថិភាព បរិស្ថាន និង សង្គម (ESS)របស់មូលនិធិ GCF |
| | -ទោះបីជាអង្គភាពអន្តរជាតិ(IAEs) អង្គភាពទទួលមូលនិធិផ្ទាល់ (DAEs) | **ឃ) ទាក់ទងនឹងយន្តការពិគ្រោះយោបល់ដើម្បីធានាបានថាសំណើ** |

| | | |
|---|---|---|
| | ទទួលខុសត្រូវក្នុងការសម្របសម្រួល និងសម្រួលដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធក៏ដោយ NDA/ជនបង្គោលត្រូវទទួលបន្ទុកក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការទាំងនេះ ដើម្បីជួយដល់ការសម្របសម្រួលក្នុងប្រទេសនិងការចូលរួមរបស់អ្នកពាក់ព័ន្ធផ្សេងៗទៀត | **គម្រោងត្រូវបានរៀបចំស្របតាមយុទ្ធសាស្ត្រនិងផែនការជាតិ គេគួរផ្ទៀងផ្ទាត់ជាមួយនឹងជម្រើសអនុវត្តល្អៗ ដូចខាងក្រោម៖**<br>**ដំណើរការ នីតិវិធី និងរចនាសម្ព័ន្ធ**<br>១) យន្តការសម្របសម្រួលថ្នាក់ជាតិ យន្តការចូលរួមរបស់អ្នកពាក់ព័ន្ធ ដំណើរការចរចារ និងនីតិវិធីរៀបចំផែនការ (និងយន្តការដទៃទៀត)<br>២) យន្តការក្នុងការបញ្ជ្រាបការចូលរួមរបស់ប្រទេសជាមួយធនធានហិរញ្ញវត្ថុខាងក្នុងនិងក្រៅ |
| | - NDA/ជនបង្គោលត្រូវបានជំរុញឱ្យផ្សព្វផ្សាយពីនីតិវិធីចេញលិខិតគាំទ្រនៅក្នុងប្រទេសរបស់ពួកគេ និងនៅលើគេហទំព័ររបស់ពួកគេ ព្រមទាំងបណ្តាញទំនាក់ទំនងផ្សេងៗ ដោយប្រើប្រាស់ភាសាក្នុងស្រុក | **សមត្ថភាព**<br>១) សមត្ថភាពឬយន្តការក្នុងការពិនិត្យនិងបញ្ជ្រាបការចូលរួមរបស់ប្រទេសជាមួយធនធានហិរញ្ញវត្ថុខាងក្នុងនិងក្រៅ<br>២) សមត្ថភាពឬយន្តការក្នុងការវាយតម្លៃកិច្ចប្រជុំថ្នាក់ប្រទេសជាទៀតទាត់ ឬការរៀបចំផែនការជាតិ/កិច្ចពិភាក្សាដែលមានស្រាប់ (អាចជាយន្តការរបស់ប្រភពមូលនិធិផ្សេងទៀតសម្រាប់គាំទ្រដល់សកម្មភាព ប្រែប្រួលអាកាសធាតុ)<br>៣) សមត្ថភាពឬយន្តការក្នុងការជំរុញក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការរៀបចំ និងអនុវត្តសំណើថវិកា (អាចតម្រូវឱ្យមានការបង្កើតយន្តការសម្របសម្រួលប្រចាំប្រទេសដាច់ដោយឡែកដើម្បីកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់មូលនិធិ GCF) |
| **៣) ដើរតួជាជនបង្គោលសម្រាប់ការទំនាក់ទំនងជាមួយមូលនិធិ GCF** | - NDA/ជនបង្គោលគួរ ក) រក្សាទំនាក់ទំនងជាទៀងទាត់ជាភាសាអង់គ្លេសជាមួយលេខាធិការដ្ឋានតាមប្រព័ន្ធអ៊ីនធើណេត ខ) ជួយសម្រួលដល់ដំណើរទស្សនកិច្ចក្នុងប្រទេស និងកិច្ចប្រជុំជាមួយមន្ត្រីមូលនិធិ និងគ) ផ្តល់ | **ដំណើរការ នីតិវិធី និង រចនាសម្ព័ន្ធ៖**<br>១) បណ្តាញទំនាក់ទំនងរវាងនាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) និងមូលនិធិ GCF<br>២) ការផ្សព្វផ្សាយថ្នាក់ជាតិ និងបណ្តាញផ្សព្វផ្សាយសាធារណៈ |

| | | |
|---|---|---|
| | ទំនាក់ទំនងជាលាយលក្ខណ៍អក្សរតាមការចាំបាច់។<br><br>-ពួកគេគួរផ្សព្វផ្សាយជាភាសាក្នុងស្រុកអំពីនីតិវិធីប្រតិបត្តិសំខាន់របស់មូលនិធិ រួមបញ្ចូលទាំង គោលការណ៍សុវត្ថិភាពបរិស្ថាននិង សង្គម (ESS) និងនីតិវិធីចេញលិខិតគាំទ្រ | (ឧទាហរណ៍៖ គេហទំព័ររបស់នាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) បណ្តាញអ៊ីនធើណេត និងប្រព័ន្ធផ្សព្វផ្សាយ) នៅក្នុងប្រទេស សម្រាប់ការផ្សព្វផ្សាយអំពីនីតិវិធីប្រតិបត្តិនៃមូលនិធិ GCF គោលការណ៍សុវត្ថិភាពបរិស្ថាននិងសង្គម និងនីតិវិធីចេញលិខិតគាំទ្រ ក៏ដូចជាស្ថានភាពនៃសំណើថវិកា និងកម្មវិធី |
| | -NDA/ជនបង្គោលគួររក្សាទុកព័ត៌មានទូទៅអំពីសំណើថវិកាទាំងអស់ដែលទាក់ទាក់ទងនឹងប្រទេសខ្លួន ហើយប្រកាសព័ត៌មានស្តីពីគម្រោងនិងកម្មវិធីតាមរយៈប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសមស្រប ដោយប្រើប្រាស់ភាសាក្នុងស្រុក។<br><br>- NDA/ជនបង្គោលគួរដឹងពីហិរញ្ញវត្ថុពហុភាគី និងអាចទាក់ទងជាមួយអ្នកអនុវត្តក្នុងវិស័យឯកជននៅក្នុងប្រទេស។ | ៣) ក្រុមការងារមួយ ទទួលខុសត្រូវក្នុងការសម្របសម្រួលនិងជំរុញទំនាក់ទំនងជាមួយមូលនិធិGCF និងគ្រប់គ្រងសកម្មភាពប្រតិបត្តិការ។<br><br>៤) តម្រូវការធនធានមនុស្ស |
| **ប្រភព៖ សេចក្តីសម្រេចលេខ *B.04/05* ចុះក្នុងខែមិថុនា ឆ្នាំ២០១៣ និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃមូលនិធិ GCF/B.06/07 ចុះក្នុងខែកុម្ភៈ ឆ្នាំ២០១៤** | | |

## ៦.២. គោលបំណងរបស់ស្ថាប័នជាតិទទួលន្មុក

ដើម្បីអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព ដោយយកប្រជាជនជាចម្បង លេខាធិការដ្ឋានស្ថាប័នជាតិទទួលបន្ទុកមានគោលបំណង៖

- **ប្រសិទ្ធភាព និងប្រសិទ្ធផល៖** បុគ្គលិកមានសមត្ថភាព ធ្វើការដោយប្រសិទ្ធភាពនិងប្រសិទ្ធផល អាចប្រើប្រាស់ឯកសារនានា (ឧទាហរណ៍៖ SOP សៀវភៅណែនាំ ជាដើម) ធ្វើការសម្រេចចិត្តរហ័ស មានតុល្យភាព តម្លាភាព ដោយឈរលើភស្តុតាងទទួលបានពីការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដែលមិនបង្កឱ្យមានការរាំងស្ទះ ឬការខកចិត្តដល់បណ្តាអ្នកពាក់ព័ន្ធនៅក្នុងខ្សែចង្វាក់ហិរញ្ញប្បទានអាកាសធាតុ (ស្ថាប័នរដ្ឋ ឯកជន និងដៃគូសង្គមស៊ីវិល) នៅក្នុងវដ្តរបស់គម្រោង/កម្មវិធី។ បុគ្គលិកនឹងមានជំនាញក្នុងការកំណត់ និងជំនះនូវបញ្ហា និងឧបសគ្គជាអាទិភាព ដើម្បីពង្រឹងការសម្របសម្រួលនិងការទំនាក់ទំនងនៅក្នុងការដាក់ស្នើនូវឯកសារទស្សនទាន ដែលមានគុណភាពខ្ពស់ និងការឧទ្ទេសនាមអង្គភាពដែលស្នើសុំក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់។

- **ដំណើរការ៖** មានយន្តការសម្របសម្រួលនិងទំនាក់ទំនងច្បាស់លាស់ ជាមួយមូលនិធិ GCF និងអ្នកពាក់ព័ន្ធនៅក្នុងខ្សែចង្វាក់ហិរញ្ញប្បទានអាកាសធាតុ ដោយមានការណែនាំ និងគាំទ្រដោយសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) ក្រោមការត្រួតពិនិត្យប្រកបដោយតម្លាភាពនិងហ្មត់ចត់ និងមានរចនាសម្ព័ន្ធគ្រប់គ្រងដែលអនុលោមតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីប្រតិបត្តិរបស់មូលនិធិ GCF ។

- **មានភាពរលូន៖** ការគ្រប់គ្រងនឹងអនុវត្តដោយប្រុងប្រយ័ត្ន សំដៅប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ខណៈដែលការផ្តល់សេវាប្រឹក្សាបច្ចេកទេស ហិរញ្ញវត្ថុ ធុរកិច្ច និងសេវាគាំទ្រអាចផ្តល់ជូនដល់អ្នកពាក់ព័ន្ធ នៅក្នុងខ្សែចង្វាក់ហិរញ្ញប្បទានអាកាសធាតុ។

- **មានលក្ខណៈឌីជីថល៖** ដើម្បីឆ្ពោះទៅការបង្កើតស្ថាប័នជាលេខាធិការដ្ឋានស្ថាប័នជាតិទទួលបន្ទុកនាពេលអនាគត បុគ្គលិកជំនាញព័ត៌មានវិទ្យាត្រូវមានសមត្ថភាពក្នុងការប្រតិបត្តិ គ្រប់គ្រង និងពង្រីក គេហទំព័ររបស់ NDA ចូលរួមកាត់បន្ថយការប្រើប្រាស់ក្រដាស។ ដូច្នេះ អ្នកពាក់ព័ន្ធទាំងអស់អាចចូលទៅកាន់គេហទំព័រដោយមិនប្រកាន់ទីតាំងភូមិសាស្ត្រឬពេលវេលា ដើម្បីដាក់បញ្ចូលឯកសារទស្សនទាននិងសំណើគម្រោងឡើយ។ បន្ទាប់ពីមានការត្រួតពិនិត្យបឋមរួចរាល់ហើយ ឯកសារទស្សនទាន នឹងបញ្ជូនដោយស្វ័យប្រវត្តិទៅកាន់សមាជិកគោលដៅនៃក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) សម្រាប់ត្រួតពិនិត្យ និងផ្តល់យោបល់ (សូមមើលជំពូកទី ១០ ស្តីពីនីតិវិធីចេញលិខិតគាំទ្រ)។

## ៦.៣. ពាក្យសម្បថ និងក្រមប្រតិបត្តិ

ដើម្បីអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងតម្លាភាព លេខាធិការដ្ឋានស្ថាប័នជាតិទទួលបន្ទុកនឹង៖

- គ្រប់គ្រងនិងដោះស្រាយបណ្តឹងតវ៉ា និងមតិត្រឡប់
- ដោះស្រាយទំនាស់ផលប្រយោជន៍-សម្បថ៖
  - ជួយផ្តល់យោបល់និងបញ្ចៀសទំនាស់ផលប្រយោជន៍ដែលអាចកើតមាន
  - ជួយផ្តល់យោបល់លើការរក្សាព័ត៌មានសម្ងាត់
  - ធានាត្រូវមានសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខាដោយសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (សូមមើលក្នុងប្រអប់ទី២)
  - ធានាបានថា ស្ថាប័នជាតិទទួលបន្ទុក និងក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតងបានដឹងពីការទទួលខុសត្រូវរបស់ខ្លួនដែលមាននៅក្នុងលក្ខខណ្ឌយោងការងារ
  - ធានាថាអ្នកអភិវឌ្ឍគម្រោងនិងសាធារណៈជន មានជំនឿទុកចិត្តស្ថាប័នជាតិទទួលបន្ទុក និងសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង ព្រមទាំងការសម្រេចចិត្តរបស់ពួកគេ
  - កត់ត្រានៅក្នុងកំណត់ហេតុអំពីរាល់ចំណាប់អារម្មណ៍ដែលបានលើកឡើងនៅក្នុងប្រជុំ ដោយសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង និងសមាជិកណាមួយដែលត្រូវបានដកសិទ្ធិមិនឱ្យបោះឆ្នោតលើគម្រោងនោះ។

**ប្រអប់ទី២៖ពាក្យសម្បថមុនក្លាយជាសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុ បៃតង (GCFAP)**

ដើម្បីជៀសវាងទំនាស់ផលប្រយោជន៍និងធានាការសម្ងាត់ សមាជិកនីមួយៗ ឬមន្ត្រីទទួលបានសិទ្ធិតំណាងឱ្យសមាជិកនៃក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុ (GCFAP) អាចសរសេរពាក្យសម្បថ ដោយគោរពតាមក្រមប្រតិបត្តិរបស់ស្ថាប័នជាតិទទួលបន្ទុក មុនពេលទទួលភារកិច្ចរបស់ខ្លួន។ រាល់ទំនាស់ដែលបានកើតឡើង ឬប្រុងនឹងកើតឡើង ដែលទាក់ទងនឹងផលប្រយោជន៍ ត្រូវលើកឡើងនៅពេលចាប់ផ្តើមនៃកិច្ចប្រជុំរបស់ NDA និងត្រូវកត់ត្រានៅក្នុងកំណត់ហេតុប្រជុំ។ សមាជិកដែលមានទំនាស់ផលប្រយោជន៍មិនត្រូវចូលរួមក្នុងការបោះឆ្នោតលើការឯកភាពរបស់គម្រោងនោះទេ។

**ពាក្យសម្បថ**

*«ខ្ញុំសូមប្រកាសយ៉ាងឱឡារិកថាខ្ញុំនឹងបំពេញភារកិច្ចរបស់ខ្ញុំជាសមាជិក ឬមន្ត្រីទទួលបានសិទ្ធិតំណាងឱ្យសមាជិកនៃក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុ ដោយស្មោះត្រង់ មិនលំអៀង និងមនសិការ»។*

*«បន្ថែមពីនេះទៀត ខ្ញុំសូមប្រកាសយ៉ាងឱឡារិកនិងសន្យាថា ខ្ញុំនឹងមិនកេងចំណេញផលប្រយោជន៍ហិរញ្ញវត្ថុនៅគម្រោងឬកម្មវិធីណាមួយដែលពិចារណាដោយ NDA ទាំងខ្លួនខ្ញុំផ្ទាល់ សាច់ញាតិ ឬមិត្តភក្តិរបស់ខ្ញុំ ហើយខ្ញុំយល់ព្រមថាខ្ញុំមិនទទួលប្រយោជន៍ពីការអនុវត្តគម្រោងនេះតាមគ្រប់មធ្យោបាយទាំងអស់។ យោងតាមទំនួលខុសត្រូវរបស់ខ្ញុំចំពោះមុខ NDA ខ្ញុំមិនត្រូវបង្ហាញព័ត៌មានអ្វីទាំងអស់ ដែលខ្ញុំទទួលបានក្នុងពេលបំពេញភារកិច្ចរបស់ខ្ញុំជូន NDA សូម្បីតែបន្ទាប់ពីការបញ្ចប់មុខងាររបស់ខ្ញុំក៏ដោយ »។*

*«ខ្ញុំនឹងផ្តល់ដំណឹងជូន NDA អំពីរាល់បញ្ហា ដែលអាចបង្កើតជាទំនាស់ផលប្រយោជន៍ ឬដែលមិនអាចធានាភាពស្មោះត្រង់ និងមិនលំអៀងបាន តាមការរំពឹងទុកពី NDA ហើយខ្ញុំនឹងបដិសេធមិនចូលរួមក្នុងការងាររបស់ NDA ដែលមានបញ្ហាបែបនេះឡើយ»។*

ហត្ថលេខា៖ កាលបរិច្ឆេទ៖

តួនាទី៖

**សេចក្តីសង្ខេប៖**

- ក្រសួងបរិស្ថាននៃប្រទេសកម្ពុជាត្រូវបានប្រគល់សិទ្ធិឱ្យធ្វើជាស្ថាប័នជាតិទទួលបន្ទុកមូលនិធិ GCF ដោយមានការគាំទ្រពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ។
- ជំពូកនេះបានពិពណ៌នាពីមធ្យោបាយនានា ដើម្បីបង្កើតលេខាធិការដ្ឋានស្ថាប័នជាតិទទួលបន្ទុក (NDA) ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល មានដំណើរការរលូន និងមានលក្ខណៈឌីជីថលរួមទាំងតួនាទីនិងទំនួលខុសត្រូវ។
- ជំពូកនេះបានពិពណ៌នាពីក្រមសីលធម៌ផងដែរ។

**ក្រមប្រតិបត្តិ**

១) សមាជិក ឬមន្ត្រីទទួលបានសិទ្ធិតំណាងឱ្យសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) នីមួយៗ នឹង៖

ក) បំពេញភារកិច្ចរបស់ខ្លួនដោយភាពស្មោះត្រង់ សុចរិតភាព និងការទទួលខុសត្រូវចំពោះភារកិច្ចរបស់ខ្លួនក្នុងនាមជាសមាជិក GCFAP។

ខ) រក្សាការសម្ងាត់នៃរាល់ព័ត៌មានសម្ងាត់ទាំងអស់ ដែលខ្លួនទទួលបានក្នុងពេលបំពេញតួនាទីជាសមាជិក GCFAP ហើយមិនត្រូវប្រើប្រាស់ ឬផ្សព្វផ្សាយព័ត៌មានសម្ងាត់ទៅភាគីទីបីឡើយ។

គ) អនុវត្តគោលការណ៍ឯករាជ្យ ត្រឹមត្រូវ គោរព សេចក្តីថ្លៃថ្នូរ និងសុចរិតភាពក្នុងការទាក់ទងជាមួយសមាជិក GCFAP ផ្សេងទៀត លេខាធិការដ្ឋាន NDA និងភាគីពាក់ព័ន្ធរបស់ NDA ។

ឃ) សម្រេចចិត្តផ្ទាល់ខ្លួន ថាតើគាត់នឹងមានទំនាស់ផលប្រយោជន៍ ឬយល់ឃើញថាអាចនឹងមានទំនាស់ ទាក់ទងនឹងបញ្ហាដែលកំពុងពិចារណាដោយ NDA និងចាត់វិធានការសមស្រប ដូចជារក្សាភាពស្ងៀមស្ងាត់ និង/ឬ ចាកចេញពីបន្ទប់កំឡុងពេលពិភាក្សា និង NDA ធ្វើការសម្រេចចិត្ត ព្រមទាំងជម្រាបជូន NDA អំពីទំនាស់ផលប្រយោជន៍ ឬការយល់ឃើញថាអាចនឹងមានទំនាស់ មិនថាផ្ទាល់ ឬប្រយោល ដែលខ្លួនគាត់បានដឹង និងជឿជាក់ថាអាចបង្កហេតុប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬការអនុវត្តរបស់ NDA។

ង) អនុវត្តគោលការណ៍តម្លាភាពក្នុងការរៀបចំ និងការផ្តល់ព័ត៌មានដល់សមាជិក GCFAP និងអ្នកពាក់ព័ន្ធ NDA ផ្សេងទៀត។

ច) ប្តេជ្ញាចិត្តក្នុងការសង្កេត អភិវឌ្ឍ និងអនុវត្តគោលការណ៍នានា ដែលមានចែងក្នុងក្រមនេះដោយមនសិកា សង្គតភាព និងហ្មត់ចត់។

២) «ទំនាស់ផលប្រយោជន៍» សំដៅទៅលើវិជ្ជាជីវៈ ហិរញ្ញវត្ថុ ឬប្រយោជន៍ផ្សេងទៀតនាពេលបច្ចុប្បន្នដែលអាច៖

ក) ធ្វើឱ្យប៉ះពាល់ខ្លាំងដល់ភាពមិនលំអៀងរបស់បុគ្គលក្នុងការបំពេញភារកិច្ច និងទំនួលខុសត្រូវរបស់ខ្លួនចំពោះ GCFAP ឬ

ខ) ផ្តល់អត្ថប្រយោជន៍ដោយអយុត្តិធម៌ដល់បុគ្គលឬស្ថាប័នណាមួយ។ នៅក្នុងការអនុវត្តក្រមនេះ កាលៈទេសៈដែលអាចនាំឱ្យមនុស្សមានហេតុផលម្នាក់សួរនាំពីភាពមិនលំអៀងរបស់បុគ្គលម្នាក់ទៀត ឬបានផ្តល់អត្ថប្រយោជន៍ដោយអយុត្តិធម៌ សុទ្ធតែអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

# ជំពូកទី៧ ៖ និតិវិធីផ្តល់សេចក្តីទុកចិត្ត និងការឧទ្ទេសនាមស្ថាប័នទទួលមូលនិធិផ្ទាល់

ជំពូកនេះនឹងពន្យល់អំពីស្ថាប័នជាតិទទួលមូលនិធិផ្ទាល់ ស្ថាប័នអន្តរជាតិទទួលមូលនិធិ ស្ថាប័នដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាស្ថាប័នខាងលើនេះ តួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នទាំងនោះ ដំណើរការឧទ្ទេសនាមស្ថាប័ន ដំណើរការការផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់របស់មូលនិធិអាកាសធាតុបៃតង ព្រមទាំងស្ថានភាពនៃការស្ថាប័នទទួលសេចក្តីទុកចិត្តនៅក្នុងប្រទេសកម្ពុជា។ មូលនិធិអាកាសធាតុបៃតងកៀរគរហិរញ្ញប្បទានអាកាសធាតុដោយធ្វើការជាមួយបណ្តាស្ថាប័នជាច្រើន។ ស្ថាប័នដែលត្រូវបានគេមើលឃើញថាមានសមត្ថភាពជំនាញក្នុងការជម្រុញសកម្មភាពអាកាសធាតុអាចដាក់សំណើដើម្បីក្លាយជាស្ថាប័ន ដែលទទួលបានសេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតង។ បេក្ខភាពដាក់ស្នើអាចជានីតិបុគ្គលឯកជន សាធារណៈ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ តំបន់ ឬអន្តរជាតិ។ នីតិបុគ្គលទាំងនោះត្រូវតែមានគម្រោង ឬកម្មវិធីប្រែប្រួលអាកាសធាតុដែលច្បាស់លាស់ លម្អិត និងដែលអាចអនុវត្តទៅបាន ដើម្បីបង្ហាញដល់មូលនិធិអាកាសធាតុបៃតង។ នីតិបុគ្គលទាំងអស់នេះក៏ត្រូវតែបំពេញឱ្យបានទៅតាមបទដ្ឋានរបស់មូលនិធិអាកាសធាតុបៃតង ដោយផ្អែកលើបទដ្ឋានហិរញ្ញប្បទាន បទដ្ឋានការពារបរិស្ថាន និងសង្គម ព្រមទាំងយេនឌ័រ។

ស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត រៀបចំសំណើថវិកា សម្រាប់GCFពិចារណា ដោយស្ថាប័ននោះត្រូវត្រួតពិនិត្យ គ្រប់គ្រង ចាត់ចែង និងតាមដានគម្រោង និងកម្មវិធី ដែលត្រូវបានអនុម័តដោយGCF រៀងៗខ្លួន។ ស្ថាប័នដែលទទួលបានសេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតងមានពីរប្រភេទ ដោយផ្អែកលើទម្រង់នៃការទទួលបានមូលនិធិ៖ ស្ថាប័នជាតិទទួលមូលនិធិផ្ទាល់ និងស្ថាប័នអន្តរជាតិទទួលមូលនិធិ។

## ៧.១ តើអ្នកណាខ្លះជាស្ថាប័នអន្តរជាតិទទួលមូលនិធិ ហើយតើស្ថាប័ននោះមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ?

**ស្ថាប័នអន្តរជាតិទទួលមូលនិធិ** រួមមានបណ្តាទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ បណ្តាធនាគារអភិវឌ្ឍន៍ពហុភាគី បណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងបណ្តាស្ថាប័នក្នុងតំបន់។ មូលនិធិអាកាសធាតុបៃតងចាត់ទុកបណ្តាស្ថាប័នទាំងអស់នេះថាមានការស្រាវជ្រាវ និងជំនាញយ៉ាងទូលំទូលាយក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ រួមទាំងបញ្ហាអន្តរវិស័យ និងអន្តរមូលបទ។ ស្ថាប័នអន្តរជាតិទទួលបានមូលនិធិមិនចាំបាច់មានការឧទ្ទេសនាមដោយស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោលរបស់ប្រទេសកំពុងអភិវឌ្ឍន៍ណាមួយឡើយ។

សម្រាប់បណ្តាស្ថាប័នដែលមិនមែនជាស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ក៏អាចចូលរួមជាមួយមូលនិធិអាកាសធាតុបៃតងតាមវិធីផ្សេងៗផងដែរ។ វិធីខ្លះៗមានដូចខាងក្រោម៖

- សហការជាមួយស្ថាប័នទទួលមូលនិធិផ្ទាល់ / ស្ថាប័នអន្តរជាតិទទួលមូលនិធិ ក្នុងការអនុវត្តគម្រោងមូលនិធិអាកាសធាតុបៃតងដែលត្រូវបានអនុម័តរួចហើយ។

- ផ្តល់ហិរញ្ញប្បទានបន្ថែមដល់គម្រោងដែលមានស្រាប់របស់ ស្ថាប័នទទួលមូលនិធិផ្ទាល់ / ស្ថាប័នអន្តរជាតិទទួលមូលនិធិ។
- ដើរតួជាអ្នកអនុវត្តគម្រោងត្រៀម (readiness delivery partner) ក្នុងករណីស្ថាប័ននោះអាចបង្ហាញថាខ្លួនមានជំនាញ បទពិសោធន៍ និងសមត្ថភាពដែលពាក់ព័ន្ធក្នុងការអនុវត្តគម្រោង ។

បណ្តាស្ថាប័នអន្តរជាតិទទួលមូលនិធិ ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា មានបង្ហាញនៅក្នុងតារាងទី៦។ អង្គភាពប្រតិបត្តិគម្រោង អាចសហការជាមួយបណ្តាស្ថាប័នទាំងនេះ ដើម្បីអាចទទួលបានធនធានពីមូលនិធិអាកាសធាតុបៃតង។

**តារាងទី 6៖ ស្ថានភាពរបស់ស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ព្រមទាំងទំនាក់ទំនងជាមួយបណ្តាដៃគូសាធារណៈ ឯកជន និងសង្គមស៊ីវិល**

| ឈ្មោះស្ថាប័ន/ ដៃគូ | អាទិភាពការងារ | ការចូលរួមជាមួយ GCF | កិច្ចខិតខំដើម្បីពង្រឹងការចូលរួមជាមួយ GCF |
|---|---|---|---|
| **ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)** | អភិវឌ្ឍន៍ជនបទ ជាពិសេសលើទឹកស្អាត និងមធ្យោបាយធ្វើដំណើរសាធារណៈ ប្រសិទ្ធភាពថាមពល ថាមពលកកើតឡើងវិញ និរន្តរភាពនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងសេដ្ឋកិច្ចខៀវ | មាន | មាន |
| **អង្គការស្បៀង និងកសិកម្ម (FAO)** | សន្តិសុខស្បៀង កសិកម្ម ជលផលព្រៃឈើ ការវាយតំលៃនិងការឃ្លាំមើលធនធានធម្មជាតិ ការស្តារដី និងការអភិរក្សដី សហគមន៍ធន់នឹងអាកាសធាតុ ថាមពលជីវៈម៉ាស ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ។ | មាន | មាន |
| **ទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)** | ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ នីតិរដ្ឋ អភិបាលកិច្ចល្អ និងសិទ្ធិមនុស្ស ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ទីក្រុង | មាន | អាចមាន |

| | | | |
|---|---|---|---|
| **មូលនិធិអន្តរជាតិសម្រាប់កសិកម្ម (IFAD)** | សន្តិសុខស្បៀង កសិករខ្នាតតូច ការបង្កើតប្រាក់ចំណូល សមត្ថភាពកសិកម្ម ពង្រឹងភាពធន់របស់កសិករមូលដ្ឋាន | មាន | មាន |
| **សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) របស់ធនាគារពិភពលោក** | ជំរុញការចូលរួមរបស់វិស័យឯកជន | មាន | អាចមាន |
| **អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ(IUCN)** | ការអភិវឌ្ឍមនុស្ស និងសេដ្ឋកិច្ច ការអភិរក្សធម្មជាតិ ការគ្រប់គ្រងតំបន់ការពារ ការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ការវាយតម្លៃភាពងាយរងគ្រោះ និងការស្រាវជ្រាវ ការកសាងសមត្ថភាព | មានតិចតួច | អាចមាន |
| **ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KfW)** | ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ទីក្រុង ប្រសិទ្ធភាពថាមពល និងថាមពលកកើតឡើងវិញ | មាន | អាចមាន |
| **កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)** | ការកសាងភាពធន់របស់អ្នកងាយរងគ្រោះ មុខរបរមានភាពធន់ ការបន្សាំដោយផ្អែកលើប្រព័ន្ធអេកូឡូស៊ី ព្រៃឈើ និងរេជបូក ការគ្រប់គ្រងទីជម្រាល ថាមពលកកើតឡើងវិញ ទីក្រុងឆ្លាតវៃនឹងអាកាសធាតុ ការដឹកជញ្ជូនបញ្ចេញឧស្ម័នតិច ការកសាងសមត្ថភាពសម្រាប់ដាក់បញ្ចូលការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងផែនការអភិវឌ្ឍន៍ ការធ្វើផែនការថវិកា និងការអនុវត្តកម្មវិធីត្រៀមហិរញ្ញប្បទានអាកាសធាតុ | មាន | មាន |
| **កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)** | ផែនទីបង្ហាញផ្លូវសម្រាប់បច្ចេកវិទ្យាអាកាសធាតុ និងការវាយតម្លៃស្ថានភាពបរិស្ថាននៅក្នុងប្រទេស | មាន | មាន |

| | | | |
|---|---|---|---|
| **កម្មវិធីស្បៀងអាហារពិភពលោក (WFP)** | ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ នវានុវត្តន៍ភាពធន់ សន្តិសុខស្បៀង អាហារូបត្ថម្ភ ប្រព័ន្ធគាំពារសង្គម និងការឆ្លើយតបនឹងគ្រោះថ្នាក់ | មាន | អាចមាន |

## ៧.២ តើស្ថាប័នទទួលមូលនិធិផ្ទាល់ មានស្ថាប័នណាខ្លះ ហើយតើស្ថាប័ននោះមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ?

**ស្ថាប័នទទួលមូលនិធិផ្ទាល់** គឺជាស្ថាប័នថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ឬថ្នាក់តំបន់ ដែលចាំបាច់ត្រូវមានឧទ្ទេសនាមពីស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោលរបស់ប្រទេសកំពុងអភិវឌ្ឍ។ បណ្តាស្ថាប័នដែលត្រូវបានជ្រើសតាំងឱ្យក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់មានសិទ្ធិទទួលបានការគាំទ្រជាលក្ខណៈគម្រោងត្រៀមពីមូលនិធិអាកាសធាតុបៃតង។ គម្រោងត្រៀមនេះត្រូវបានរៀបចំឡើងដើម្បីជួយស្ថាប័ននានាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការរៀបចំខ្លួនឱ្យក្លាយជាស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ក៏ដូចជាជួយដល់ស្ថាប័នដែលត្រូវបានទទួលបានសេចក្តីទុកចិត្តរួចហើយ ពង្រឹងសមត្ថភាពគ្រប់គ្រងស្ថាប័នរបស់ពួកគេបន្ថែមទៀត។

ស្ថាប័នសក្តានុពល ដែលអាចក្លាយជាស្ថាប័នទទួលសេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតងនៅក្នុងប្រទេសកម្ពុជា រួមមានដូចខាងក្រោម ៖

- វិស័យសាធារណៈ៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ល។
- វិស័យឯកជន៖ ធនាគារដែលមានសក្តានុពលនៅកម្ពុជា ក្នុងការទទួលបានប្រាក់កម្ចីសម្បទាន
- វិស័យសង្គមស៊ីវិល៖ អាចទទួលបានការជ្រើសតាំងនាពេលអនាគត

**លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD-S)**៖ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិជាស្ថាប័នសាធារណៈ ដែលត្រូវបានជ្រើសតាំងដោយរាជរដ្ឋាភិបាលកម្ពុជាជាស្ថាប័នទទួលមូលនិធិផ្ទាល់ដំបូងគេ ដើម្បីទទួលបានមូលនិធិផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង ក្នុងគោលបំណងពង្រីកវិសាលភាពនៃដំណោះស្រាយអាកាសធាតុ ឧទាហរណ៍៖ កម្មវិធីរដ្ឋបាលថ្នាក់ក្រោមជាតិ និងការប្រែប្រួលអាកាសធាតុ (LGCC)[9] ជាដើម។ ដោយមានការគាំទ្រពីកម្មវិធីសម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) និង UNCDF លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានបញ្ជូនឯកសារពាក់ព័ន្ធទាំងអស់ទៅមូលនិធិអាកាសធាតុបៃតង កាលពីខែឧសភា ឆ្នាំ ២០១៩ និងបានប្រកាសជាផ្លូវការថាជាស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់មូលនិធិអាកាសធាតុបៃតង នៅខែវិច្ឆិកា ឆ្នាំ ២០១៩។

**គោលការណ៍ណែនាំរបស់មូលនិធិអាកាសធាតុបៃតងដើម្បីឱ្យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍**

[9] *https://www.uncdf.org/article/3561/stakeholder-presentation-on-proposed-initiatives-for-subnational-climate-change-adaptation-financing-takes-place-in-cambodia*

**ដោយចីរភាពក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់៖** កាលពីថ្ងៃទី ២៨ ខែមីនា ឆ្នាំ ២០១៩ មូលនិធិអាកាសធាតុបៃតងនៅតំបន់អាមេរិកឡាទីន បានផ្តល់ការណែនាំបឋមដោយផ្អែកលើបទពិសោធន៍របស់ពួកគេក្នុងការយល់ព្រមឱ្យស្ថាប័នជាតិទទួលបន្ទុករបស់ប្រទេស Antigua និង Barbuda ក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់ ដូចខាងក្រោម៖

- ដូចអ្វីដែលយើងបានដឹង តួនាទីរបស់ស្ថាប័នជាតិទទួលបន្ទុក និងស្ថាប័នទទួលមូលនិធិផ្ទាល់គឺខុសគ្នាដាច់។ មូលនិធិអាកាសធាតុបៃតង លើកទឹកចិត្តឱ្យមានការញែកភារកិច្ចឱ្យដាច់ពីគ្នាដើម្បីជៀសវាងជម្លោះក្នុងការសម្រេចចិត្ត។ មូលនិធិអាកាសធាតុបៃតង យល់ឃើញ ថាពេលខ្លះ ករណីនេះអាចជាការចង់បានរបស់ប្រទេស ដោយសារហេតុផលផ្សេងៗគ្នា។ ក្នុងករណីបែបនេះ វាចាំបាច់ត្រូវមានការអនុម័តដោយសភា ឬគណៈរដ្ឋមន្ត្រី។ ដើម្បីគាំទ្រដល់ការស្នើសុំ គេត្រូវផ្តល់ព័ត៌មានអំពីរបៀបដែលភារកិច្ចនឹងត្រូវបានញែកដាច់ពីគ្នា និងបង្ហាញយ៉ាងច្បាស់ថាតើនឹងមានទំនាស់ផលប្រយោជន៍ឬអត់។ ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍កើតឡើង គេត្រូវផ្តល់ព័ត៌មាន (រួមទាំងជំហានច្បាស់លាស់) អំពីរបៀបញែកភារកិច្ចឱ្យដាច់ពីគ្នា។
- ក្នុងករណីប្រទេស Antigua និង Barbuda ក្រសួងហិរញ្ញវត្ថុ ដើរតួនាទីជាស្ថាប័នជាតិទទួលបន្ទុកដែលត្រូវសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយមូលនិធិអាកាសធាតុបៃតង។ ពួកគេតម្រូវឱ្យមានសេចក្តីសម្រេចចិត្តពីគណៈរដ្ឋមន្ត្រី និងលិខិតធានាភាពស្របច្បាប់ពីអគ្គមេធាវីលើសេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រី ក្នុងការឧទ្ទេសនាមជាស្ថាប័នទទួលមូលនិធិផ្ទាល់។
- ជំហានច្បាស់លាស់រួមមានដូចខាងក្រោម៖
  - មុនពេលស្នើសុំឱ្យស្ថាប័នជាតិទទួលបន្ទុកក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់ គេត្រូវបង្ហាញថា នៅក្នុងប្រទេសមួយនេះ ពិតជាពុំមានស្ថាប័នចំនួនពីរ ដែលអាចអនុវត្តមុខងារដាច់ដោយឡែកពីគ្នាបាន ពោលគឺ មុខងារជាស្ថាប័នទទួលមូលនិធិផ្ទាល់ និង មុខងារជាស្ថាប័នជាតិទទួលបន្ទុក ។
  - ប្រសិនបើមានការរកឃើញថា នៅក្នុងប្រទេសនោះពិតមិនអាចមានភ្នាក់ងារពីរដាច់ដោយឡែកពីគ្នា នោះគេត្រូវបង្ហាញឯកសារដែលផ្តល់ព័ត៌មានថាតើនឹងមានទំនាស់ផលប្រយោជន៍កើតឡើង ឬអត់ និងព័ត៌មានលំអិតអំពីជំហានសំខាន់ៗដើម្បីបញ្ចៀសទំនាស់ផលប្រយោជន៍ប្រសិនបើកើតមាន ព្រមទាំងព័ត៌មានលំអិតស្តីពីវិធីញែកមុខងារឱ្យនៅដាច់ដោយឡែកពីគ្នា។
  - ធានាថាសេចក្តីសម្រេចចិត្តជ្រើសរើសទីភ្នាក់ងារដែលសាកសម បានមកពីសេចក្តីសម្រេចចិត្តរបស់ស្ថាប័នជាន់ខ្ពស់ ដូចជាសភា ឬគណៈរដ្ឋមន្ត្រី និងត្រូវ បង្ហាញភស្តុតាងដូចជា៖ ១) សេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រី និង ២) ឬលិខិតធានាភាពស្របច្បាប់ពីអគ្គមេធាវី លើសេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រី និង
  - គួរផ្តល់ជូនឯកសារគាំទ្រទៅកាន់មូលនិធិអាកាសធាតុបៃតង ដែលនឹងធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើករណីនីមួយៗ។

- **ករណីសិក្សាសម្រាប់ប្រទេសកម្ពុជា**

  ១. រដ្ឋមន្ត្រីក្រសួងបរិស្ថានគឺជាអ្នកតំណាងស្ថាប័នជាតិទទួលបន្ទុករបស់មូលនិធិអាកាសធាតុបៃតង

  ២. នាយកដ្ឋានប្រែប្រួលអាកាសធាតុដែលស្ថិតនៅក្រោមអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ផ្តល់ការគាំទ្រដល់ក្រសួងបរិស្ថាន ក្នុងការទាក់ទងជាមួយមូលនិធិអាកាសធាតុបៃតង។

  ៣. គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) បានដាក់ពាក្យស្នើសុំទៅមូលនិធិអាកាសធាតុបៃតងដើម្បីក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់ ហើយសំណើនេះត្រូវបានអនុម័តដោយកិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៅខែវិច្ឆិកា ឆ្នាំ ២០១៩ ។

  ៤. ឥឡូវនេះអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD) មានបំណងចង់ក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់ពីមូលនិធិអាកាសធាតុបៃតង ដើម្បីគាំទ្រដល់បណ្តាអង្គភាពប្រតិបត្តិគម្រោង/កម្មវិធីនៅថ្នាក់ជាតិ ខណៈដែល NCDD នឹងគាំទ្របណ្តាអង្គភាពប្រតិបត្តិគម្រោង/កម្មវិធីនៅថ្នាក់ក្រោមជាតិ។

- ដរាបណាក្រសួងបរិស្ថាន និង GSSD មិនមានមុខងារដូចគ្នា និងមិនរំពឹងមានទំនាស់ផលប្រយោជន៍នោះទេ GSSD អាចមានសិទ្ធិក្លាយជាស្ថាប័នទទួលមូលនិធិផ្ទាល់។ គេត្រូវគូសបន្ទាត់បែងចែកមុខងារឱ្យដាច់ពីគ្នា សំដៅទប់ស្កាត់ទំនាស់ផលប្រយោជន៍ដែលអាចកើតមាន។

## ៧.៣ តើនិតិវិធីជ្រើសតាំងរបស់ប្រទេសកម្ពុជាជាអ្វី?

រូបភាពទី ១១ រៀបរាប់ពីនីតិវិធីរបស់ប្រទេសកម្ពុជាក្នុងការឧទ្ទេសនាមស្ថាប័នសាធារណៈ ឯកជន និងសង្គមស៊ីវិលឱ្យក្លាយជាស្ថាប័នដែលទទួលបានសេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតង។ ផ្នែកទី ៧.៤ នឹងរៀបរាប់បន្ថែមពីព័ត៌មានលម្អិត។

### i. ដាក់ស្នើលិខិតឧទ្ទេសនាមទៅស្ថាប័នជាតិទទួលបន្ទុក សម្រាប់ស្នើសុំការផ្តល់សេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតង

### ជំហានទី ១. ស្ថាប័នស្នើសុំនឹងវាយតម្លៃពីភាពសមស្របរបស់ស្ថាប័នខ្លួន

ក. ស្ថាប័នស្នើសុំនឹងវាយតម្លៃពីភាពសមស្របរបស់ស្ថាប័នខ្លួន តាមរយៈការបំពេញកម្រងសំណួរនៅក្នុងប្រព័ន្ធអនឡាញសម្រាប់វាយតម្លៃផ្តល់សេចក្តីទុកចិត្តរបស់មូលនិធិអាកាសធាតុបៃតង (OAS) ដើម្បីទទួលបានរបាយការណ៍វាយតម្លៃខ្លួនឯង។

### ជំហានទី ២ . ស្ថាប័នស្នើសុំ ដាក់ស្នើលិខិតឧទ្ទេសនាមពីស្ថាប័នជាតិទទួលបន្ទុក

ក. ប្រសិនបើរកឃើញថាស្ថាប័នស្នើសុំនោះមានភាពសមស្របពេញលេញហើយស្ថាប័ននោះ ត្រូវស្នើសុំលិខិតឧទ្ទេសនាមពីស្ថាប័នជាតិទទួលបន្ទុក ដោយភ្ជាប់មកជាមួយនូវរាល់ ឯកសារគាំទ្រនានា។

### ជំហានទី ៣. ការវាយតម្លៃ ដើម្បីចេញលិខិតឧទ្ទេសនាម ដោយស្ថាប័នជាតិទទួលបន្ទុក

ក. ក្រុមវាយតម្លៃរបស់ស្ថាប័នជាតិទទួលបន្ទុក ព្រមទទួលពាក្យស្នើសុំ ហើយក្រុមនេះពិនិត្យពាក្យ

ស្នើសុំ និងធ្វើសេចក្តីព្រាងរបាយការណ៍វាយតម្លៃ រួចផ្ញើទៅ GCFAP ដើម្បីពិនិត្យ ថែមទៀត។

ខ. ស្ថាប័នជាតិទទួលបន្ទុក រៀបចំកិច្ចប្រជុំជាមួយ GCFAP ដើម្បីវាយតម្លៃដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងក្រោម និងផ្តល់អនុសាសន៍លើពាក្យស្នើសុំ។

**ជំហានទី ៤. ការអនុម័តលើការឧទ្ទេសនាម**

ក. ប្រសិនបើសំណើសុំត្រូវបានអនុម័ត នោះស្ថាប័នជាតិទទួលបន្ទុកនឹងចេញលិខិតឧទ្ទេសនាម ហើយស្វែងរកលទ្ធភាពក្នុងការដាក់ពាក្យស្នើសុំការគាំទ្រពីគម្រោងត្រៀមរបស់មូលនិធិអាកាសធាតុបៃតង។

**ជំហានទី ៥. ស្ថាប័នស្នើសុំ ផ្ញើជូនទម្រង់ស្នើសុំ០៧[10] ដោយភ្ជាប់ជាមួយលិខិតឧទ្ទេសនាមទៅមូលនិធិអាកាសធាតុបៃតង**

ក. ស្ថាប័នស្នើសុំ ផ្ញើជូនទម្រង់ស្នើសុំ (ទម្រង់០៧)ដោយភ្ជាប់ជាមួយលិខិតឧទ្ទេសនាមទមូលនិធិអាកាសធាតុបៃតង

ខ. មូលនិធិអាកាសធាតុបៃតងនឹងពិនិត្យទម្រង់០៧ ហើយប្រសិនជាមូលនិធិអាកាសធាតុបៃតងបានពិនិត្យច្បាស់លាស់ហើយ នោះស្ថាប័នស្នើសុំ នឹងចូលទៅជំណាក់ទី១ នៃដំណើរការផ្តល់សេចក្តីទុកចិត្ត ហើយត្រូវបំពេញទម្រង់០៥[11]

គ. មូលនិធិអាកាសធាតុបៃតងផ្តល់ ឈ្មោះសម្រាប់ប្រើក្នុងការចុះឈ្មោះអនឡាញ និងលេខសំងាត់ទៅស្ថាប័នស្នើសុំនោះ ដើម្បីអាចឱ្យស្ថាប័ននោះបញ្ចូល ឯកសារទម្រង់០៥របស់ខ្លួន ដោយភ្ជាប់ជាមួយបទពិសោធន៍ និងឯកសារគាំទ្រផ្សេងៗ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអនឡាញ នៃការវាយតម្លៃផ្តល់សេចក្តីទុកចិត្តរបស់GCF។

ឃ. ស្ថាប័នស្នើសុំ ឆ្លើយតបទៅតាមអនុសាសន៍ និងសំណើរបស់មូលនិធិអាកាសធាតុបៃតង។

**ជំហានទី ៦. មូលនិធិអាកាសធាតុបៃតងពិនិត្យពាក្យស្នើសុំ**

ក. មូលនិធិអាកាសធាតុបៃតងពិនិត្យមើលទម្រង់០៥ ពិនិត្យលក្ខណៈគ្រប់ជ្រុងជ្រោយ ពិនិត្យបទពិសោធន៍ និងឯកសារគាំទ្រនានា ហើយផ្តល់អនុសាសន៍ ថាគួរទទួលយក ឬមិនគួរទទួលយកពាក្យស្នើសុំនេះ ទៅក្រុមប្រឹក្សាភិបាលនៃមូលនិធិអាកាសធាតុបៃតង។

**ជំហាន ៧. ការអនុម័តដោយមូលនិធិអាកាសធាតុបៃតង**

ក. ប្រសិនបើសំណើត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនៃមូលនិធិអាកាសធាតុបៃតង នោះលេខាធិការដ្ឋានរបស់មូលនិធិអាកាសធាតុបៃតងនឹងផ្ញើរលិខិតអនុម័តនេះទៅស្ថាប័នស្នើសុំ និងស្ថាប័នជាតិទទួលបន្ទុក។

**ជំហាន ៨. ការចុះហត្ថលេខា និងផ្តល់សុពលភាពលើកិច្ចព្រមព្រៀងផ្តល់សេចក្តីទុកចិត្ត (Accreditation Master Agreement - AMA)**

ក. ចុះហត្ថលេខាលើគ្រប់លិខិតផ្លូវការទាំងអស់ ព្រមទាំងឯកសារផ្សេងៗទៀត

---

[10] *All latest GCF forms are available here: https://www.greenclimate.fund/library/-/docs/list/574044*

[11] *All latest GCF forms are available here: https://www.greenclimate.fund/library/-/docs/list/574044*

ខ. ចុះហត្ថលេខាលើកិច្ចព្រមព្រៀង **AMA** រវាងស្ថាប័នជាតិទទួលបន្ទុក និងលេខាធិការដ្ឋានរបស់មូលនិធិអាកាសធាតុបៃតង




រូបភាពទី 11៖ នីតិវិធីចេញលិខិតឧទ្ទេសនាម និងផ្ដល់សេចក្ដីទុកចិត្តដល់ស្ថាប័នទទួលមូលនិធិផ្ទាល់

## ii. លក្ខណៈវិនិច្ឆ័យដើម្បីវាយតម្លៃលើការជ្រើសតាំង និងទទួលស្គាល់របស់ស្ថាប័នទទួលបានមូលនិធិផ្ទាល់

ដើម្បីវាយតម្លៃលើសំណើសុំនីមួយៗ ស្ថាប័នជាតិទទួលបន្ទុកគួរប្រើប្រាស់លក្ខណៈវិនិច្ឆ័យខាងក្រោម ៖

- តើស្ថាប័នស្នើសុំមានចក្ខុវិស័យច្បាស់លាស់ ក្នុងការប្រើប្រាស់ធនធានរបស់មូលនិធិអាកាសធាតុបៃតងដែរឬទេ ?
- តើស្ថាប័នស្នើសុំអាចចូលរួមបែបណា ដើម្បីសម្រេចគោលបំណងរបស់មូលនិធិអាកាសធាតុបៃតង និងគោលបំណងរបស់ជាតិ ?
- តើមានភ័ស្តុតាង និងបង្ហាញការយល់ដឹងអំពីបទដ្ឋាន និងដំណើរការផ្ដល់សេចក្ដីទុកចិត្តរបស់មូលនិធិអាកាសធាតុបៃតងដែរឬទេ ?
- តើមានភ័ស្តុតាងបញ្ជាក់ពីភាពស្របច្បាប់របស់ស្ថាប័នស្នើសុំដែរឬទេ ?
- តើមានភ័ស្តុតាងបញ្ជាក់ពីការបំពេញបន្ថែមរបស់ស្ថាប័នស្នើសុំ ទៅដល់ស្ថាប័នទទួលមូលនិធិផ្ទាល់ផ្សេងៗទៀតដែរឬទេ និងតើមានភ័ស្តុតាងបញ្ជាក់ពីភាពមិនជាន់គ្នា ឬត្រួតគ្នាដែរឬទេ ?
- តើស្ថាប័នស្នើសុំ មានបទពិសោធន៍ក្នុងការរៀបចំ និងអនុវត្តបទដ្ឋានជានា និងប្រព័ន្ធការពារសុវត្ថិភាពបរិស្ថាន និងសង្គម បទពិសោធន៍រៀបចំសំណើគម្រោងប្រកបដោយភាពច្នៃប្រឌិត និងមានជំនាញគ្រប់គ្រងគម្រោង ( នីតិវិធី MRV ) ដែរឬទេ ?

ស្ថាប័នជាតិទទួលបន្ទុកក៏អាចពិចារណាជាយុទ្ធសាស្ត្រ ទាក់ទងនឹងសមត្ថភាពរបស់ស្ថាប័នស្នើសុំ (ដូចជា គណនេយ្យភាព) រួមមាន៖

- តើថ្នាក់ដឹកនាំកំពូលរបស់ស្ថាប័នស្នើសុំ មានបង្ហាញពីបទពិសោធន៍មិនលើកលែងការលួចបន្លំក្នុងស្ថាប័នរបស់ខ្លួនដែរឬទេ?
- តើស្ថាប័នស្នើសុំអាចបង្ហាញថាបរិយាកាសការងារមិនមានការលួចបន្លំ និងអំពើពុករលួយទាំងផ្ទាល់ និងប្រយោល ដែលប្រព្រឹត្តឡើងដោយបុគ្គលិករបស់ខ្លួន និងភាគីទីបី ដែរឬទេ?
- តើស្ថាប័នមានសមត្ថភាពក្នុងការដោះស្រាយរាល់ការចោទប្រកាន់អំពីការលួចបន្លំ ឬការប្រព្រឹត្តមិនត្រឹមត្រូវនានា ប្រកបដោយតម្លាភាព និងមានការចូលរួមពីអាជ្ញាធរមានសមត្ថកិច្ចដែលសមស្រប ដែរឬទេ?
- តើមានបញ្ហាកេរ្តិ៍ឈ្មោះជាក់ស្តែងណាមួយ ដែលអាចបដិសេធការឧទ្ទេសនាមដែរឬទេ?
- តើបេសកកម្មរបស់ស្ថាប័នស្នើសុំ និងគោលបំណងរបស់មូលនិធិអាកាសធាតុបៃតងមានភាពស៊ីសង្វាក់គ្នាដែរឬទេ?
- តើស្ថាប័នស្នើសុំ បានបង្ហាញពីបទពិសោធន៍ក្នុងការគ្រប់គ្រង និងគណនេយ្យភាពក្នុងមួយវដ្តនៃគម្រោងដែរឬទេ?
- តើស្ថាប័នស្នើសុំ មានបទពិសោធន៍វាយតម្លៃ និងដោះស្រាយទំនាស់ផលប្រយោជន៍ ដែលអាចកើតមានដែរឬទេ?

**iii. ឯកសារនានាដែលត្រូវដាក់ស្នើ**

- លិខិតស្នើសុំឧទ្ទេសនាមសម្រាប់ស្នើសុំសេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតង
- លិខិតបង្ហាញអំពីចក្ខុវិស័យរបស់ស្ថាប័នស្នើសុំ ក្នុងការប្រើប្រាស់មូលនិធិអាកាសធាតុបៃតង និងការលើកកម្ពស់បេសកកម្មរបស់មូលនិធិអាកាសធាតុបៃតង និងគោលដៅរបស់ជាតិ។
- ឯកសារបង្ហាញការយល់ដឹងអំពី ១.) បទដ្ឋាន និងលក្ខខណ្ឌតម្រូវសម្រាប់ទទួលបានសេចក្តីទុកចិត្ត និង ២.) ដំណើរការដាក់ពាក្យស្នើសុំ និង
- ឯកសារបញ្ជាក់ពីភាពស្របច្បាប់របស់ស្ថាប័នស្នើសុំ។

**iv. ការអនុលោមតាមបទដ្ឋានជានា (fiduciary standard) របស់មូលនិធិអាកាសធាតុបៃតង**

ការវាយតំលៃលើស្ថាប័នដែលបានជ្រើសរើសនីមួយៗ អំពីភាពអនុលោមជាមួយបទដ្ឋានជានារបស់ GCF នឹងត្រូវបានពិចារណា យោងទៅតាមលក្ខណៈដើមនៃហានិភ័យ ទំហំនៃសកម្មភាពដែលចង់បាន និងប្រភេទនៃស្ថាប័ន (ដូចបង្ហាញក្នុងរូបភាពទី A៣)។វិធីសាស្ត្រនៃការផ្តល់សេចក្តីទុកចិត្តតាមគោលបំណងជាក់លាក់ (fit-for-purpose accreditation) របស់បណ្តាស្ថាប័នទទួលមូលនិធិផ្ទាល់សម្រាប់ប្រទេសកម្ពុជា ត្រូវបានពិពណ៌នាលម្អិតបន្ថែមទៀតនៅក្នុងឧបសម្ព័ន្ធ៣ ។

## ៧.៤ តើវិធីសាស្រ្តការនៃការផ្តល់សេចក្តីទុកចិត្តតាមគោលបំណងជាក់លាក់ជាអ្វី?[12]

ព័ត៌មានលម្អិតចំពោះវិធីសាស្រ្តនៃការផ្តល់សេចក្តីទុកចិត្តតាមគោលបំណងជាក់លាក់ក៏មានពន្យល់នៅក្នុងឧបសម្ព័ន្ធ៣ ផងដែរ។

**ជំហានដើម្បីក្លាយជាស្ថាប័នទទួលបានសេចក្តីទុកចិត្ត**

**ជំហានទី ១. វាយតម្លៃខ្លួនឯង**

មុនពេលចាប់ផ្តើមដំណើរការដាក់ពាក្យស្នើសុំ ស្ថាប័ននីមួយៗអាចវាយតម្លៃថាតើស្ថាប័នរបស់ពួកគេបំពេញតាមលក្ខខណ្ឌតម្រូវជាមូលដ្ឋាន ដើម្បីក្លាយជាស្ថាប័នទទួលបានសេចក្តីទុកចិត្តដែរឬទេ។ ស្ថាប័នទាំងនោះអាចធ្វើការវាយតម្លៃខ្លួនឯងបាន ដោយពិចារណាលើសំណួរជាច្រើនតាមរយៈឧបករណ៍វាយតម្លៃតាមអ៊ិនធឺណែតរបស់មូលនិធិអាកាសធាតុបៃតង។

កម្រងសំណួរតាមអ៊ីនធឺណែតនេះជួយស្ថាប័ននានាដើម្បីវាយតម្លៃ៖

- ថាតើស្ថាប័នទាំងនោះត្រូវបានចាត់ទុកថាមានសមត្ថភាពស្របច្បាប់ពេញលេញក្នុងការរ៉ាប់រងធ្វើសកម្មភាពដែលទទួលបានពីមូលនិធិពីមូលនិធិអាកាសធាតុបៃតងឬទេ
- តើការរៀបចំស្ថាប័នរបស់ពួកគេមានអ្វីខ្លះ ដោយរាប់បញ្ចូលទាំងប្រព័ន្ធ គោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំនានា និង
- កំណត់ត្រារបស់ពួកគេ អាចចាត់ទុកថាតើប្រព័ន្ធ គោលនយោបាយ នីតិវិធី និងគោលការណ៍ណែនាំនានាត្រូវបានអនុវត្តជាប្រព័ន្ធដែរឬ យ៉ាងណា

ឧបករណ៍វាយតម្លៃខ្លួនឯងជួយស្ថាប័ននានាឱ្យសន្សំសំចៃពេលវេលា និងការចំណាយ ដោយធ្វើការសម្រេចចិត្តនៅដំណាក់កាលដំបូង ថាតើពួកគេបំពេញតាមលក្ខខណ្ឌតម្រូវនៃការផ្តល់សេចក្តីទុកចិត្តរបស់មូលនិធិអាកាសធាតុបៃតងដែរឬទេ។ ឧបករណ៍វាយតម្លៃខ្លួនឯងគ្រាន់តែជាការណែនាំតែប៉ុណ្ណោះ ហើយមិនមានការធានាថាស្ថាប័នដែលបានប្រើប្រាស់វាទទួលបានការទទួលស្គាល់ពីមូលនិធិអាកាសធាតុបៃតងនៅពេលក្រោយឡើយ។ ស្ថាប័នដែលសម្រេចចិត្តដាក់ពាក្យស្នើសុំសេចក្តីទុកចិត្ត មិនចាំបាច់បង់ថ្លៃពាក្យស្នើសុំ នៅដំណាក់កាលនេះទេ។

នៅពេលដែលស្ថាប័នមានទំនុកចិត្តថាខ្លួនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីក្លាយជាស្ថាប័នទទួលសេចក្តីទុកចិត្ត ស្ថាប័ននោះអាចចាប់ផ្តើមដំណើរការដាក់ពាក្យស្នើសុំចំនួនបីដំណាក់កាលបន្តទៀត។ ស្ថាប័នដែលដាក់ពាក្យស្នើសុំសេចក្តីទុកចិត្ត គួរតែជាស្ថាប័នដែលបានដំណើរការយ៉ាងហោចណាស់បីឆ្នាំរួចមកហើយ។

**ជំហានទី ២. រៀបចំពាក្យស្នើសុំ**

[12] https://www.greenclimate.fund/gcf101/getting-accredited/accreditation-process

រាល់ស្ថាប័នទទួលមូលនិធិផ្ទាល់ទាំងអស់ចាំបាច់ត្រូវបានឧទ្ទេសនាមដោយស្ថាប័នជាតិទទួលបន្ទុក /ជនបង្គោលរបស់ប្រទេសកំពុងអភិវឌ្ឍន៍។ ស្ថាប័នទទួលសេចក្តីទុកចិត្តអន្តរជាតិ អាចស្វែងរកការទទួលស្គាល់ពីមូលនិធិអាកាសធាតុបៃតងដោយផ្ទាល់ ដោយមិនចាំបាច់មានការឧទ្ទេសនាមពីស្ថាប័នជាតិទទួលបន្ទុក/ជនបង្គោលរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ណាមួយឡើយ។

ស្ថាប័នជាតិទទួលបន្ទុក/ជនបង្គោលឧទ្ទេសនាមស្ថាប័នទទួលមូលនិធិផ្ទាល់ ដោយបំពេញគំរូនេះ រួចផ្ញើរទៅកាន់មូលនិធិអាកាសធាតុបៃតងតាមអាស័យដ្ឋានអ៊ីមែលនេះ accreditation@gcfund.org

រាល់ស្ថាប័នទាំងអស់ ត្រូវដាក់ពាក្យស្នើសុំចូលរួមប្រព័ន្ធវាយតម្លៃតាមប្រព័ន្ធអ៊ីនធឺណេតរបស់មូលនិធិអាកាសធាតុបៃតង (OAS)។ ពួកគេត្រូវបំពេញឯកសារ។ នៅពេលសំណុំបែបបទត្រូវបានទទួលយកដោយលេខាធិការដ្ឋាន អ្នកដាក់ពាក្យស្នើសុំនឹងទទួលបានសិទ្ធអាចចូលប្រើ ប្រព័ន្ធដាក់ពាក្យស្នើសុំតាមអ៊ីនធឺណែតរបស់មូលនិធិអាកាសធាតុបៃតង។

ស្ថាប័នស្នើសុំទាំងអស់នឹងត្រូវបំពេញទម្រង់ស្នើសុំតាមប្រព័ន្ធ OAS។ នេះគឺជាផ្នែកសំខាន់នៃការដាក់ពាក្យស្នើសុំ។ ពាក្យស្នើសុំមានការណែនាំលំអិតអំពីរបៀបបំពេញព័ត៌មាន។

បណ្តាស្ថាប័នដែលត្រូវបានទទួលស្គាល់រួចមកហើយដោយមូលនិធិបរិស្ថានសកល (GEF) មូលនិធិបន្សាំ និងអគ្គនាយកដ្ឋានអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការជំនួយសហគមន៍អឺរ៉ុប នៃគណៈកម្មការអឺរ៉ុប (DG DEVCO) អាចមានសិទ្ធិដាក់ពាក្យស្នើសុំរហ័ស ប្រសិនបើ ឯកសារតម្រូវឱ្យមានចំនួន ៣ ដំបូងត្រូវបានបំពេញរួចរាល់។

ស្ថាប័ននានាដាក់ពាក្យស្នើសុំរបស់ពួកគេតាមប្រព័ន្ធ OAS បន្ទាប់ពីពួកគេបានបំពេញទម្រង់ពាក្យស្នើសុំអនឡាញ។

ថ្លៃសេវាដាក់ពាក្យស្នើសុំត្រូវបានបង់នៅចំណុចនេះ។ ចំនួនទឹកប្រាក់ដែលត្រូវបង់នេះប្រែប្រួលទៅតាមប្រភេទនៃការផ្តល់សេចក្តីទុកចិត្ត និងទំហំនៃហិរញ្ញប្បទានសម្រាប់គម្រោង ឬកម្មវិធីដែលស្ថាប័នស្នើសុំ ចង់ទទួលបានពីមូលនិធិអាកាសធាតុបៃតង។ ថ្លៃសេវាមួយចំនួននឹងត្រូវលើកលែងសម្រាប់ស្ថាប័នថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ដែលមានមូលដ្ឋាននៅដែនដីរដ្ឋនៃកោះតូចៗ ដែលកំពុងអភិវឌ្ឍន៍ (SIDS) និងប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) សម្រាប់ចំនួនហិរញ្ញប្បទានជាក់លាក់មួយ។

## ដំណាក់កាលទី១៖ ត្រួតពិនិត្យពាក្យស្នើសុំ

នៅពេលទទួលបានថ្លៃសេវាពាក្យស្នើសុំ លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងពិនិត្យពាក្យស្នើសុំ ដើម្បីធានាថាអាណត្តិរបស់ពាក្យស្នើសុំ ស្របនឹងអាណត្តិ និងគោលបំណងរបស់មូលនិធិអាកាសធាតុបៃតង ក្នុងគោលដៅហិរញ្ញប្បទានអាកាសធាតុ និងក្នុងរបៀបដែលអាចរួមចំណែកដល់ការរៀបចំផែនការអាទិភាពរបស់ប្រទេសជាមួយមូលនិធិអាកាសធាតុបៃតង។ មូលនិធិអាកាសធាតុបៃតងបានកំណត់ វិស័យយុទ្ធសាស្ត្រអាទិភាពចំនួន ៨ ដើម្បីលើកស្ទួយសកម្មភាពនៃការកាត់បន្ថយ និងបន្សាំសំខាន់ៗ (សូមមើលគំរូ CN ក្នុងផ្នែក ៩.២)។

លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងក៏ត្រួតពិនិត្យផងដែរថាតើស្ថាប័នស្នើសុំ បានផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីប្រព័ន្ធគ្រប់គ្រង គោលនយោបាយ និតិវិធី និងសេចក្តីណែនាំទាក់ទងទៅនឹងគម្រោង

ការពារសុវត្ថិភាព ពាក់ព័ន្ធនឹងហិរញ្ញវត្ថុ បរិស្ថាន សង្គម និងយេនឌ័រ ហានិភ័យ និងផលប៉ះពាល់ដែរឬទេ។ លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង ក៏នឹងពិនិត្យមើលផងដែរថាតើព័ត៌មានស្ដីពីបទពិសោធន៍នៃការអនុវត្តប្រព័ន្ធ គោលនយោបាយ និតិវិធី និងគោលការណ៍ណែនាំ របស់ស្ថាប័នស្នើសុំ ត្រូវបានផ្ដល់ជូនដែរឬទេ។

លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងអាចសួរសំណួរទៅកាន់ស្ថាប័នស្នើសុំ ក្នុងគោលបំណងបំពេញបន្ថែមទៅលើពាក្យស្នើសុំ ដែលពេលខ្លះ ត្រូវការឆ្លើយឆ្លងគ្នាទៅវិញទៅមករវាងស្ថាប័នស្នើសុំ និងលេខាធិការដ្ឋាន។

នៅឆ្នាំ ២០១៧ ពាក្យស្នើសុំក្នុងដំណាក់កាលទី ១ នឹងត្រួតពិនិត្យដោយលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង ស្របតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃមូលនិធិអាកាសធាតុបៃតងក្នុងការផ្ដល់អាទិភាពដល់ពាក្យស្នើសុំពីៈ

**ស្ថានប័នជាតិទទួលមូលនិធិផ្ទាល់ៈ**

- បណ្ដាស្ថាប័ននានានៅអាស៊ីប៉ាស៊ីហ្វិក និងតំបន់អឺរ៉ុបខាងកើត
- បណ្ដាស្ថាប័នឯកជន ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីស្វែងរកតុល្យភាពស្ថាប័ន ស្របតាមសេចក្ដីសម្រេចចិត្តលេខ B.09/07 កថាខណ្ឌ (g)[13] សេចក្ដីសម្រេចចិត្តលេខ B.10/06 កថាខណ្ឌ (h)[14]
- ស្ថាប័នដែលឆ្លើយតបទៅនឹងសំណើរបស់មូលនិធិអាកាសធាតុបៃតង ដូចជា ជំហានសាកល្បងសម្រាប់ពង្រឹងការទទួលបានមូលនិធិផ្ទាល់ កម្មវិធីសាកល្បងដើម្បីគាំទ្រសហគ្រាសខ្នាតតូចបំផុត តូច និងមធ្យម រួមទាំងកម្មវិធីសាកល្បងដើម្បីកៀរគរធនធានដើម្បីដោះស្រាយការបន្សាំ និងការកាត់បន្ថយ ជាដើម។
- ស្ថាប័នដែលកំពុងតែស្វែងរកការបង្គ្រប់លក្ខខ័ណ្ឌសម្រាប់ទទួលសេចក្ដីទុកចិត្ត និង
- ស្ថាប័នស្នើសុំតម្លើងកម្រិតសេចក្ដីទុកចិត្ត។

**ដំណាក់កាលទី ២ ៖ ពិនិត្យ និងផ្ដល់យោបល់ជូនក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង**

នៅពេលដែលលេខាធិការដ្ឋានរបស់មូលនិធិអាកាសធាតុបៃតងពេញចិត្ត នូវពាក្យស្នើសុំដែលបានបំពេញតាមលក្ខខណ្ឌតម្រូវហើយ មានន័យថាពាក្យស្នើសុំរបស់ស្ថាប័ននោះ ត្រូវដាក់ជូនទៅក្រុមការងារវាយតម្លៃផ្ដល់សេចក្ដីទុកចិត្ត។ ក្រុមការងារនេះមានអ្នកជំនាញចំនួន ៦ រូប ដែលវាយតម្លៃដោយឯករាជ្យលើពាក្យស្នើសុំ ដោយផ្ដោតសំខាន់ថាតើស្ថាប័នស្នើសុំការទទួលស្គាល់ បំពេញទៅតាមស្តង់ដារមូលនិធិអាកាសធាតុបៃតងដែលខ្លួនកំពុងដាក់ពាក្យស្នើដែរឬទេ។

[13] *https://www.greenclimate.fund/documents/20182/24952/GCF_B.10_17_-_Decisions_of_the_Board_-_Tenth_Meeting_of_the_Board__6-9_July_2015.pdf/1238c5ad-8686-4cf9-a401-aa4893818215*

[14] *Also decides that, recalling decision B.06/06 and pursuant to decision B.09/07, paragraph (g), the Secretariat will actively support applications for accreditation received from subnational, national and regional public and private sector entities in order to ensure a balance of diversity, including between entities under the direct access and international access modalities, in the list of entities being considered for accreditation by the Board.*

នៅឆ្នាំ ២០១៧ ពាក្យស្នើសុំក្នុងដំណាក់កាលទី ២ នឹងត្រូវបានត្រួតពិនិត្យដោយគណៈកម្មាធិការទទួលស្គាល់ ដោយស្របទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតងក្នុងការផ្តល់អាទិភាពដល់ពាក្យស្នើសុំណាមួយ (ដូចដែលបានបង្ហាញនៅក្នុងដំណាក់កាលទី ១)។

នៅក្នុងចំណុចនេះគណៈកម្មាធិការទទួលស្គាល់អាចឱ្យស្ថាប័នស្នើសុំផ្តល់ការបំភ្លឺណាមួយ ស្របពេលដែលកំពុងបំពេញការងារជាមួយលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង។

បន្ទាប់មក លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង និងក្រុមការងារវាយតម្លៃផ្តល់សេចក្តីទុកចិត្តបញ្ជូនអនុសាសន៍របស់ពួកគេទៅកាន់ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង។ អនុសាសន៍នេះនឹងរួមបញ្ចូលទាំងការវាយតំលៃរបស់លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងពីការពិនិត្យនៅដំណាក់កាលទី១ និងអនុសាសន៍របស់ក្រុមការងារវាយតម្លៃផ្តល់សេចក្តីទុកចិត្ត អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់សេចក្តីទុកចិត្ត។ ក្រុមការងារវាយតម្លៃផ្តល់សេចក្តីទុកចិត្ត អាចធ្វើការណែនាំបន្ថែមអំពីលក្ខខណ្ឌ ក្នុងករណីដែលរកឃើញថាមានចន្លោះប្រហោងក្នុងការបំពេញឱ្យបានតាមបទដ្ឋានមូលនិធិអាកាសធាតុបៃតង ដែលស្ថាប័នបានដាក់ស្នើ។ ឧទាហរណ៍ លក្ខខណ្ឌនានាអាចត្រូវបានផ្តល់អាទិភាពសម្រាប់ការផ្ទេរប្រាក់លើកទី១ សម្រាប់ការធ្វើវិសោធនកម្ម ឬការបង្កើតនូវគោលនយោបាយ ឬនីតិវិធី ឬលក្ខន្តិកៈដែលកំពុងតែត្រូវបានអនុវត្តចំពោះគម្រោងទាំងអស់ដែលបានមូលនិធិពីមូលនិធិអាកាសធាតុបៃតងទាក់ទងនឹងព័ត៌មានដែលត្រូវផ្តល់ ឬតម្រូវការត្រួតពិនិត្យបន្ថែម។

ប្រសិនបើពាក្យស្នើសុំត្រូវបានបញ្ចប់ ហើយមិនតម្រូវឱ្យបំភ្លឺចំពោះសំណួរបន្ថែម នោះរយៈពេលនៃដំណើរការពិនិត្យដោយលេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង និងក្រុមការងារវាយតម្លៃផ្តល់សេចក្តីទុកចិត្ត អាចមានរយៈពេលតិចបំផុតប្រាំមួយខែ ឬបីខែសម្រាប់ពាក្យស្នើសុំរហ័ស។ (ព័ត៌មានលម្អិតបន្ថែមអំពីរយៈពេលនៃដំណើរការពិនិត្យ មានក្នុងផ្នែកសំណួរចម្លើយ ខាងក្រោម។ )

ជាទូទៅក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតងជួបប្រជុំគ្នាបីដងក្នុងមួយឆ្នាំ ដើម្បីសម្រេចចិត្តចុងក្រោយ ថាតើត្រូវផ្តល់សេចក្តីទុកចិត្តដល់ស្ថាប័នស្នើសុំ។ លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតងនឹងជូនដំណឹងដល់ស្ថាប័នស្នើសុំ អំពីលទ្ធផលនៃការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង។

## ដំណាក់កាលទី ៣: ការរៀបចំក្របខណ្ឌច្បាប់

ស្ថាប័នដែលទទួលបានការអនុម័តក្លាយជាស្ថាប័នទទួលបានសេចក្តីទុកចិត្តនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់សេចក្តីទុកចិត្ត (Accreditation Master Agreement - AMA)[15] ជាមួយមូលនិធិអាកាសធាតុបៃតង។

AMAs គឺជាកិច្ចព្រមព្រៀងស្របច្បាប់ដែលបានកំណត់លក្ខខណ្ឌសម្រាប់ការប្រើប្រាស់ធនធាននៃមូលនិធិអាកាសធាតុ។ កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា ស្ថាប័នត្រូវអនុវត្តគម្រោងដែលបានអនុម័តដោយមូលនិធិអាកាសធាតុបៃតងប្រកបដោយត្រឹមត្រូវ និងមានគណនេយ្យភាព។ សម្រាប់សកម្មភាពដាច់

[15] *https://www.greenclimate.fund/documents/20182/574712/Form_05_-_Accreditation_Master_Agreement.pdf/8c4f6cbf-ae17-4856-81c1-64ac8fbfa506*

ដោយឡែកដែលផ្តល់មូលនិធិដោយមូលនិធិអាកាសធាតុបៃតង និងអនុម័តដោយក្រុមប្រឹក្សាភិបាល ស្ថាប័នទទួលសេចក្តីទុកចិត្ត ត្រូវចុះកិច្ចព្រមព្រៀងអនុវត្តសកម្មភាព (Funded Activity Agreement) សម្រាប់រាល់គម្រោងដែលបានអនុម័ត រួមជាមួយនឹងលក្ខខណ្ឌជាក់លាក់នៃគម្រោងនីមួយៗ។

ស្ថាប័នទទួលបានសេចក្តីទុកចិត្តតម្រូវឱ្យធ្វើការស្វ័យវាយតម្លៃប្រចាំឆ្នាំ ទៅលើដំណើរការការងាររបស់ពួកគេ ដើម្បីដឹងថាតើពួកគេនៅតែបន្តគោរពតាមបទដ្ឋានផ្តល់សេចក្តីទុកចិត្ត ដូចដែលពួកគេបានដាក់ពាក្យកន្លងមកដែរឬទេ។

ស្ថាប័នទទួលបានសេចក្តីទុកចិត្តក៏តម្រូវឱ្យបញ្ជូនរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ អំពីការគ្រប់គ្រងគម្រោង ឬកម្មវិធី ដែលបានអនុម័តដោយមូលនិធិអាកាសធាតុបៃតង។

ស្ថាប័នទទួលបានសេចក្តីទុកចិត្តនឹងត្រូវដាក់ពាក្យស្នើ ដើម្បីរក្សាឋានៈរបស់ខ្លួនរៀងរាល់ ៥ឆ្នាំម្តង។ បច្ចុប្បន្ននេះមូលនិធិអាកាសធាតុបៃតងកំពុងធ្វើការលើនីតិវិធី ដើម្បីណែនាំអំពីដំណើរការនៃការផ្តល់សេចក្តីទុកចិត្តឡើងវិញ។

**សេចក្តីសង្ខេប**

- ជំពូកនេះនឹងពន្យល់អំពីស្ថាប័នជាតិទទួលមូលនិធិផ្ទាល់ ស្ថាប័នអន្តរជាតិទទួលមូលនិធិ ស្ថាប័នដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាស្ថាប័នខាងលើនេះ តួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នទាំងនោះ ដំណើរការឧទ្ទេសនាមស្ថាប័ន ដំណើរការផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់របស់មូលនិធិអាកាសធាតុបៃតង ព្រមទាំងស្ថានភាពនៃស្ថាប័នទទួលសេចក្តីទុកចិត្តនៅក្នុងប្រទេសកម្ពុជា។
- ស្ថាប័នទទួលបានសេចក្តីទុកចិត្ត អាចជានិតិបុគ្គលឯកជន សាធារណៈ មិនមែនរដ្ឋាភិបាល ថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ តំបន់ ឬថ្នាក់អន្តរជាតិ។

## ជំពូកទី៨៖ ស្ថាប័នប្រតិបត្តិ

ជំពូកនេះពន្យល់អំពីស្ថាប័នប្រតិបត្តិ លក្ខណៈសម្បត្តិដើម្បីក្លាយជាស្ថាប័នប្រតិបត្តិ ព្រមទាំងតួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នទាំងនេះ។ មូលនិធិអាកាសធាតុបៃតង កំណត់និយមន័យស្ថាប័នប្រតិបត្តិថាជាស្ថាប័ន ដែលទទួលបានថវិកាពីមូលនិធិអាកាសធាតុបៃតង និង/ឬស្ថាប័នណាដែលប្រតិបត្តិ ឬអនុវត្តសកម្មភាពដែលទទួលបានការគាំទ្រថវិកា។ ស្ថាប័នប្រតិបត្តិធ្វើសកម្មភាពជាច្រើនសំដៅសម្រេចបានភាពជោគជ័យនៃសកម្មភាពនានារបស់គម្រោង។

### ៨.១ តើអ្នកណាជាស្ថាប័នប្រតិបត្តិ ហើយមានតួនាទី និងទំនួលខុសត្រូវអ្វីខ្លះ?

- អង្គភាពប្រតិបត្តិ អាចជាស្ថាប័នណាមួយ មកពីវិស័យសាធារណៈ ឯកជន និងសង្គមស៊ីវិល
- **តួនាទី និងការទទួលខុសត្រូវ៖** បង្កើតឯកសារទស្សនទាន/សំណើគម្រោង អនុវត្ត និងតាមដានគម្រោង / កម្មវិធី និង
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នទទួលមូលនិធិផ្ទាល់ និងស្ថាប័នអន្តរជាតិដែលទទួលបានមូលនិធិ ដើម្បីអនុវត្តសកម្មភាពទាំងអស់ទៅតាមផែនការការងាររបស់គម្រោង ដើម្បីសម្រេចបាននូវលទ្ធផលនានាស្របតាមថវិកា និងពេលវេលាដែលបានស្នើឡើងនៅក្នុងក្របខណ្ឌលទ្ធផល (សូមមើលផ្នែកទី ១១)។

ខុសពីស្ថាប័នទទួលបានសេចក្ដីទុកចិត្ត ស្ថាប័នប្រតិបត្តិមិនទទួលបានមូលនិធិផ្ទាល់ពីមូលនិធិអាកាសធាតុបៃតងទេ។ ស្ថាប័ន ឬបុគ្គលដែលធ្វើសកម្មភាពទាំងអស់នេះគឺជាស្ថាប័នប្រតិបត្តិ ហើយពួកគេអាចមកពីវិស័យឯកជន ឬសាធារណៈ។ ស្ថាប័នប្រតិបត្តិចូលមកដើម្បីធ្វើឱ្យប្រាកដថាទិដ្ឋភាពផ្សេងៗគ្នានៃគម្រោងមូលនិធិអាកាសធាតុបៃតង ត្រូវបានអនុវត្តស្របតាមគោលបំណងរបស់គម្រោង។ ជាពិសេសស្ថាប័នប្រតិបត្តិចូលរួមសកម្មភាពដូចខាងក្រោមក្នុងកំឡុងពេលរៀបចំនិងអនុវត្តគម្រោង៖

- កំណត់គម្រោងដែលមានសក្ដានុពលក្នុងវិស័យអាទិភាពនីមួយៗ។
- ចាត់អាទិភាព និងជ្រើសរើសគម្រោង ដើម្បីឈានទៅមុខ។
- កំណត់ឧបសគ្គ និងដំណោះស្រាយ។
- វាយតម្លៃជម្រើស រៀបចំការធ្វើអន្តរាគមន៍ និងប៉ាន់ប្រមាណអំពីផលប៉ះពាល់។
- រៀបចំផែនការគម្រោង និងចំណាយ។
- បង្កើតឯកសារទស្សនទាន និងសំណើគម្រោង ព្រមទាំងរៀបចំឯកសារគាំទ្រ។
- បញ្ជូនសំណើនានា ទៅស្ថាប័នជាតិទទួលបន្ទុក និងស្ថាប័នទទួលបានសេចក្ដីទុកចិត្ត។
- អនុវត្តសកម្មភាពគម្រោង។
- អភិវឌ្ឍ និងកែលម្អផែនការក្នុងអំឡុងពេលនៃការអនុវត្តគម្រោង។
- តាមដាន និងវាយតម្លៃផលប៉ះពាល់របស់គម្រោង។

### ៨.២ តើស្ថាប័នប្រតិបត្តិមានលក្ខណៈសម្បត្តិដូចម្តេចខ្លះ?

- លក្ខណៈវិនិច្ឆ័យដើម្បីកំណត់ និងជ្រើសរើសស្ថាប័នប្រតិបត្តិ មានដូចខាងក្រោម៖

- មានបទពិសោធន៍អនុវត្ត និងតាមដានគម្រោង/កម្មវិធីអាកាសធាតុ។
- មានប្រព័ន្ធតម្លាភាពសម្រាប់ការគ្រប់គ្រងទិន្នន័យ កត់ត្រាទិន្នន័យ និងរក្សាទុក។
- មានឆន្ទៈក្នុងការអនុវត្ត ធានាភាពជាម្ចាស់ រៀបចំឯកសារទស្សនទានដោយផ្អែកលើតម្រូវការពិតប្រាកដ និងការរៀបចំឯកសារទាំងនេះ។
- មានសមត្ថភាពពេញលេញក្នុងការអនុវត្តការតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់គម្រោង / កម្មវិធី ការពង្រីកវិសាលភាព និងការអនុវត្តដំណោះស្រាយនៅទីតាំងផ្សេង។
- មានភាពប៉ិនប្រសព្វខាងអាជីវកម្ម និងមានស្មារតីជាសហគ្រិន។

- ស្ថាប័នប្រតិបត្តិចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពជំនាញឱ្យបានពេញលេញ ព្រមទាំងមានចំណេះដឹង ដើម្បីអាចទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុ។

**សេចក្តីសង្ខេប**

- ស្ថាប័នប្រតិបត្តិ គឺជាស្ថាប័នមកពីវិស័យសាធារណៈ ឯកជន និងសង្គមស៊ីវិលដែលនឹងអនុវត្តគម្រោង ក្នុងភាពជាដៃគូជាមួយស្ថាប័នទទួលមូលនិធិផ្ទាល់ ឬស្ថាប័នអន្តរជាតិដែលទទួលបានមូលនិធិ ដោយយោងទៅតាមឯកសារគម្រោង។
- ស្ថាប័នប្រតិបត្តិត្រូវការតាមដាន និងផ្តល់របាយការណ៍ប្រចាំឆ្នាំ ទៅស្ថាប័នទទួលមូលនិធិផ្ទាល់ ឬស្ថាប័នអន្តរជាតិ ដែលទទួលបានមូលនិធិ និងស្ថាប័នជាតិទទួលបន្ទុក។

## ជំពូកទី ៩៖ ដំណើរការអនុម័តសំណើគម្រោងរបស់ GCF និងការរៀបចំឯកសារទស្សនទាន និងសំណើថវិកាប្រកបដោយគុណភាពខ្ពស់

ជំពូកនេះ ពិពណ៌នាអំពីដំណើរការអនុម័តគម្រោងសំណើរបស់ GCF និងជំហាននានាដើម្បីរៀបចំឯកសារទស្សនទាន និងសំណើថវិកាប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់សម្រាប់ឆ្លើយតប ទៅនឹងតម្រូវការរបស់ហិរញ្ញប្បទានអាកាសធាតុនានា ដោយប្រើប្រាស់ GCF ជាគំរូ។ ចំណេះដឹង និងជំនាញមូលដ្ឋានក៏នឹងជួយស្ថាប័នប្រតិបត្តិ (EEs) ក្នុងវិស័យសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិល លើការរៀបចំឯកសារទស្សនទានប្រកបដោយគុណភាពខ្ពស់ដើម្បីទទួលបានហិរញ្ញប្បទានអាកាសធាតុជាតិ និងអន្តរជាតិ ពោលគឺមិនមែនសម្រាប់តែ GCF ប៉ុណ្ណោះទេ។

### ៩.១ ដំណើរការអនុម័តសំណើគម្រោងរបស់ GCF

- ដឹងពីភាពខុសគ្នារវាង GCF (សូមមើលរូបភាពទី ១២) និងវដ្តរៀបចំគម្រោងថ្នាក់ជាតិរបស់កម្ពុជា និងការស្វែងយល់ពីចំណុចទាំងនេះ អាចត្រូវបានដាក់បញ្ចូលដើម្បីតាមដាន និងសម្គាល់ហិរញ្ញប្បទានអាកាសធាតុ។
- តើធ្វើដូចម្តេចដើម្បីវាយតម្លៃភាពពាក់ព័ន្ធនៃប្រភពមូលនិធិសាធារណៈ និងឯកជនសម្រាប់បញ្ជីគម្រោងរបស់អ្នក (Project Pipeline)?
- តើអ្វីទៅជាបញ្ជីត្រួតពិនិត្យសម្រាប់សំណើថវិកាដែលទទួលបានជោគជ័យ? តើមានដំណាក់កាលសំខាន់ៗអ្វីខ្លះ ក្នុងការរៀបចំសំណើថវិកាដែលទទួលបានជោគជ័យ?
- តើអ្វីខ្លះជាការត្រួតពិនិត្យនិងវាយតម្លៃ និងក្របខ័ណ្ឌគ្រប់គ្រងលទ្ធផលរបស់ GCF?
- តើធ្វើដូចម្តេចដើម្បីចរចានិងប្រាស្រ័យទាក់ទងរវាងអ្នកដាក់ពាក្យនិង GCF ក្នុងកំឡុងពេលដាក់ស្នើឯកសារទស្សនទាន (ជាមួយការធ្វើវិសោធនកម្មសំណើគម្រោង) រហូតដល់ទទួលបានការអនុម័តចុងក្រោយពីក្រុមប្រឹក្សាភិបាល GCF?




**រូបភាពទី 12៖ ដំណើរការអនុម័តសំណើគម្រោងរបស់ GCF**

**សារសំខាន់ៗ៖**

- ស្ថាប័នប្រតិបត្តិ សហការជាមួយស្ថាប័នទទួលបានមូលនិធិដោយផ្ទាល់ (DAE) / ស្ថាប័នអន្តរជាតិទទួលបានមូលនិធិ (IAE) ត្រូវបានលើកទឹកចិត្តឱ្យរៀបចំឯកសារទស្សនទានប្រកបដោយគុណភាពខ្ពស់ជាចាំបាច់ក្នុងជំហានដំបូង ប្រសើរជាងរៀបចំសំណើគម្រោងលម្អិតដែលអាចចំណាយពេលការខំប្រឹង និងថវិកាច្រើន។
- ស្ថាប័នប្រតិបត្តិ សហការជាមួយស្ថាប័នទទួលបានមូលនិធិដោយផ្ទាល់ (DAE) / ស្ថាប័នអន្តរជាតិទទួលបានមូលនិធិ (IAE) នឹងស្វែងរកកិច្ចពិភាក្សាដំបូងជាមួយស្ថាប័នទទួលបន្ទុកថ្នាក់ជាតិដើម្បីជូនដំណឹងពីឯកសារទស្សនទាន។
- ស្ថាប័នប្រតិបត្តិ សហការជាមួយស្ថាប័នទទួលបានមូលនិធិដោយផ្ទាល់ (DAE) / ស្ថាប័នអន្តរជាតិទទួលបានមូលនិធិ (IAE) នឹងដាក់ពាក្យស្នើសុំលិខិតគាំទ្រ ដោយភ្ជាប់ជាមួយនឹងឯកសារទស្សនទាន ប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់។

## ៩.២ តើធ្វើដូចម្តេចរៀបចំឯកសារទស្សនទាន និងសំណើថវិកាប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់?

ព័ត៌មានខាងក្រោមនឹងពន្យល់អំពីជំហានដើម្បីបំពេញគំរូឯកសារទស្សនទានក្នុងផ្នែក ៩.៣

**ជំហានក្នុងទ្រឹស្តីនៃការផ្លាស់ប្តូរ (Theory of Change Approach)**

ក. តើបញ្ហាឬឧបសគ្គដែលទាក់ទងនឹងអាកាសធាតុអ្វីខ្លះ ដែលអ្នកនឹងព្យាយាមដោះស្រាយ ឬកែលម្អ?

ខ. តើដំណោះស្រាយដែលទាក់ទងនឹងអាកាសធាតុអ្វីខ្លះ ដែលអ្នកនឹងស្នើសុំ?

គ. យល់ដឹងពីទ្រឹស្តីនៃការផ្លាស់ប្តូរ៖

- តើអ្វីទៅជាគោលដៅឬគោលបំណងរួមរបស់អ្នក?
- តើផលប៉ះពាល់រយៈពេលវែងអ្វីខ្លះដែលអ្នកនឹងព្យាយាមធ្វើនិងសម្រេចបាន?
- តើមានសមិទ្ធិផលអ្វីខ្លះ? (លទ្ធផលរយៈពេលមធ្យម)
- តើមានលទ្ធផលអ្វីខ្លះដើម្បីសម្រេចបានលទ្ធផលនីមួយៗ? (លទ្ធផលរយៈពេលខ្លី)
- តើសកម្មភាពអ្វីខ្លះដើម្បីសម្រេចបានលទ្ធផលនីមួយៗ?
- តើមានសូចនាករឆ្លាតវៃ (SMART) អ្វីខ្លះដើម្បីតាមដាននិងវាយតម្លៃលទ្ធផលរបស់អ្នក?

ឃ. ការកំណត់គោលដៅ សមិទ្ធិផល លទ្ធផល និងសកម្មភាព៖

គោលដៅគម្រោងនឹងត្រូវបានសម្រេចតាមរយៈសមិទ្ធិផល លទ្ធផល និងសកម្មភាពដូចខាងក្រោម៖

- សមិទ្ធិផលទី១៖
  - លទ្ធផល ១.១៖
    - សកម្មភាព ១.១.១:
      - ➢ ១.១.១.១សូចនាករ:
    - សកម្មភាព ១.១.២:
    - សកម្មភាព ១.១.៣:
  - លទ្ធផល ១.២៖
    - សកម្មភាព ១.២.១:
    - សកម្មភាព ១.២.២:
    - សកម្មភាព ១.២.៣:

**ង. តើធ្វើដូចម្តេចដើម្បីតាមដាន និងវាយតម្លៃលទ្ធផលរបស់អ្នក? តើមានលទ្ធផលអ្វីខ្លះ នៅក្នុងតារាងក្របខ័ណ្ឌលទ្ធផលគម្រោង (log-frame)?**

| ក្របខ័ណ្ឌលទ្ធផលគម្រោង | | | | | | |
|---|---|---|---|---|---|---|
| សមិទ្ធិផល | លទ្ធផល | សូចនាករឆ្លាតវៃ | ទិន្នន័យដើមគ្រា (Baseline) | ទិសដៅ | ការផ្ទៀងផ្ទាត់ | ការសន្មត |
| សមិទ្ធិផលទី១ | លទ្ធផល ១.១ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | លទ្ធផល ១.២ | | | | | |
| | លទ្ធផល ១.៣ | | | | | |

## ច. តើថវិកាដែលស្នើសុំមានអ្វី?

ថវិកា គឺផ្អែកលើសកម្មភាពដែលត្រូវអនុវត្តនៅក្នុងលទ្ធផលនីមួយៗ។ សហមូលនិធិ ដែលមានសក្តានុពលពីដៃគូសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិលអាចត្រូវបានបន្ថែមជាវិភាគទានសម្ភារៈ ឬសាច់ប្រាក់។ ខុសពីមូលនិធិ GEF មូលនិធិ GCF មិនកំណត់ឱ្យមានសហមូលនិធិក្នុងអត្រាណាមួយឡើយ។

| សំណើថវិកា | | | | | |
|---|---|---|---|---|---|
| សមិទ្ធិផល | លទ្ធផល | តម្លៃឯកតា(USD) | តម្លៃសរុប (USD) | ប្រភពសក្តានុពល /ផែនការ | ពេលវេលា |
| សមិទ្ធិផលទី១ | លទ្ធផល ១.១ | | | | |
| | លទ្ធផល ១.២ | | | | |
| | លទ្ធផល ១.៣ | | | | |
| សរុបរង | | | | | |
| សរុបរួម | | | | | |

## ឆ. តើអ្នកណាជាអ្នកពាក់ព័ន្ធសំខាន់ៗ ហើយតើតួនាទីរបស់ពួកគេមានអ្វីខ្លះ?

| ដៃគូសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិលសំខាន់ៗ និងតួនាទីរបស់ពួកគេនៅក្នុងសកម្មភាពនានា និងប្រសិនបើពួកគេចូលរួមចំណែកដល់គម្រោងនេះ | |
|---|---|
| ដៃគូសំខាន់ៗ | ស្ថានភាព / តួនាទីនៅក្នុងគម្រោង |
| សាធារណៈ | |
| ឯកជន | |
| អង្គការសង្គមស៊ីវិល | |

## ជ. តើមានហានិភ័យអ្វីខ្លះ? ហើយកាត់បន្ថយហានិភ័យទាំងនោះដោយរបៀបណា?

| ការវិភាគហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយ | | |
|---|---|---|
| ប្រភេទនៃហានិភ័យ | កម្រិត (ខ្ពស់ មធ្យម ទាប) | យុទ្ធសាស្ត្រកាត់បន្ថយ |
| គោលនយោបាយ | | |
| បច្ចេកវិទ្យា | | |

| | | |
|---|---|---|
| ហិរញ្ញវត្ថុ | | |
| ធុរកិច្ច | | |
| ចំនេះដឹង/ព័ត៌មាន | | |
| សង្គម/វប្បធម៌ | | |
| ផ្សេងៗ (ឧទា. បញ្ហាប្រឈមក្នុងមុខរបរ ការចេញអាជ្ញាប័ណ្ណនិងលទ្ធភាពទាញយកធនធានមកប្រើប្រាស់ [ដីនិងទឹក]) | | |

**ឈ. តើអ្វីជាយុទ្ធសាស្ត្រក្រោយគម្រោងបញ្ចប់របស់អ្នក? នៅពេលដែលគម្រោងបញ្ចប់ ហើយអស់មូលនិធិ តើនឹងមានអ្វីកើតឡើងចំពោះគម្រោងរបស់អ្នក? កម្រិតនៃនិរន្តរភាពស្ថាប័ន បទប្បញ្ញត្តិ បច្ចេកទេស ហិរញ្ញវត្ថុ និងសង្គម បន្ទាប់ពីគម្រោងនេះ និងការអនុវត្តត្រូវបានបញ្ចប់។**

**តើអ្វីជាលក្ខណៈវិនិច្ឆ័យនៃការវិនិយោគទាំង ៦ របស់ GCF (សូមមើលរូបភាពទី១៣ និងឧបសម្ព័ន្ធទី៤ សម្រាប់ព័ត៌មានលម្អិត)?**

**សក្តានុពលគំរូនៃការផ្លាស់ប្តូរ**

- សក្តានុពលសម្រាប់ពង្រីកវិសាលភាព និងធ្វើឡើងវិញ (ឧទាហរណ៍ កើនឡើងច្រើនដងនៃទំហំពីផលប៉ះពាល់ដំបូង)
- សក្តានុពលសម្រាប់ចំណេះដឹងនិងការរៀនសូត្រ
- ការចូលរួមចំណែកក្នុងការបង្កើតឱ្យមានបរិស្ថានអនុគ្រោះ និង
- ការចូលរួមចំណែកក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនិងគោលនយោបាយ។



## ៩.៣ គំរូឯកសារទស្សនទានកម្ពុជា

ស្ថាប័នប្រតិបត្តិ (EEs) ស្ថាប័នទទួលមូលនិធិដោយផ្ទាល់ (DAEs) និងប្រតិបត្តិករគម្រោងត្រូវបានលើកទឹកចិត្តឱ្យប្រើគំរូឯកសារទស្សនទាន (CN) ដើម្បីរៀបចំសំណើគម្រោងរបស់ពួកគេ។ គំរូ CN នេះត្រូវបានកែសម្រួលពីគំរូ GCFAP និងផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរសម្រាប់រៀបចំសំណើគម្រោង ជាមួយ នឹងយុទ្ធសាស្ត្រដ៏រឹងមាំក្រោយគម្រោងបញ្ចប់ ដើម្បីសម្រេចបានលទ្ធផលរយៈពេលខ្លី ដែលនាំឱ្យមានលទ្ធផល រយៈពេលមធ្យមនិងឈានដល់ផលរយៈពេលវែង។ ការបណ្តុះបណ្តាលតាមកាលកំណត់នឹងត្រូវរៀបចំឡើងដោយ ស្ថាប័នទទួលបន្ទុក (NDA) សម្រាប់ EEs ,DAEs, MOE និងសមាជិក GCFAP[16] អំពីរបៀបប្រើប្រាស់គំរូនេះ។ វាមានសក្តានុពលសម្រាប់ក្រសួងពាក់ព័ន្ធក្នុងការជ្រើសរើស និងប្រើប្រាស់គំរូនេះដើម្បីរៀបចំសំណើគម្រោងសម្រាប់កម្មវិធីអភិវឌ្ឍន៍ប្រចាំឆ្នាំ ក្រោមប្រព័ន្ធថវិកាជាតិ។

**គំរូឯកសារទស្សនទានរបស់កម្ពុជា v1.1** (22 Nov 2018)[17]

**សូមបំពេញ និងប្រគល់នូវឯកសារទស្សនទានរបស់អ្នកទៅស្ថាប័នទទួលបន្ទុកថ្នាក់ជាតិ នៅក្រសួងបរិស្ថាន**

| | |
|---|---|
| ឈ្មោះគម្រោង/កម្មវិធី:[18] | _________________________ |
| ឈ្មោះប្រទេស: | _________________________ |
| ស្ថាប័នទទួលបន្ទុក (NDA): | _________________________ |
| អង្គភាពអនុវត្ត: | _________________________ |
| ស្ថាប័នទទួលបានសេចក្តីទុកចិត្ត (AE): | _________________________ |
| កាលបរិច្ឆេទនៃការស្នើសុំលើកដំបូង/ លេខកំណែឯកសារ: | [ឆ្នាំ-ខែ-ថ្ងៃទី] [V.0] |
| កាលបរិច្ឆេទនៃការស្នើសុំបច្ចុប្បន្ន/ លេខកំណែឯកសារ: | [ឆ្នាំ-ខែ-ថ្ងៃទី] [V.0] |

[16] *First training was conducted on the 5 July 2019 in Phnom Penh, Cambodia*
[17] *This CN template is adapted from the GCF CN template.*
[18] *How you frame your title could also influence the way you design your proposal. Where possible try and frame your title from a business perspective.*

| កំណត់សម្គាល់ |
|---|
| • ចំនួនទំព័រអតិបរមា**មិនគួរលើសពី ១២ ទំព័រ**ដោយមិនរាប់បញ្ចូលឧបសម្ព័ន្ធ។ សំណើគម្រោង ដែលលើសពីចំនួនដែលបានកំនត់នឹងមិនត្រូវបានវាយតម្លៃក្នុងរយៈពេល ៣០ ថ្ងៃ ជាកំហិត។<br>• យោងតាមគោលការណ៍ផ្សព្វផ្សាយព័ត៌មាន ឯកសារទស្សនទាន និងឯកសារពាក់ព័ន្ធផ្សេងៗ ដែលបានផ្តល់ជូនលេខាធិការដ្ឋានអាចត្រូវបានបង្ហាញជាសាធារណៈ លើកលែងករណីមានការជូនដំណឹងដោយស្ថាប័នទទួលសេចក្តីទុកចិត្ត (AE) ឬ NDA ថាជាការសម្ងាត់ ។<br>• NDA ដែលពាក់ព័ន្ធនឹងទទួលបានការជូនដំណឹងពីលេខាធិការដ្ឋាននៅពេលទទួលបានឯកសារទស្សនទាន។<br>• NDA អាចដាក់ស្នើឯកសារទស្សនទានដោយផ្ទាល់ ពោលគឺមិនចាំបាច់កំណត់ ស្ថាប័នទទួលសេចក្តីទុកចិត្ត នៅដំណាក់កាលនេះទេ។ ក្នុងករណីនេះ NDA អាចទុកចំហចោលនូវផ្នែកដែលទាក់ទងនឹង AE។ លេខាធិការដ្ឋាននឹងជូនដំណឹងដល់AE ប្រសិនបើមានការចាត់តាំងពី NDA។<br>• AE និង/ឬ NDA ត្រូវបានលើកទឹកចិត្តឱ្យដាក់ស្នើឯកសារទស្សទាន មុនពេលធ្វើការស្នើសុំការគាំទ្រពីកម្មវិធីគាំទ្រដល់ការរៀបចំគម្រោង (PPF)។<br>• សម្រាប់ព័ត៌មានបន្ថែមពីការរៀបចំឯកសារទស្សនទាន GCF អាចធ្វើការស្វែងរកបាននៅលើគេហទំព័រ Funding Projects Fine Print។ |

| A. សេចក្តីសង្ខេបគម្រោង/កម្មវិធី (អតិបរមា. ១ ទំព័រ) | | | |
|---|---|---|---|
| A.1. គម្រោង/កម្មវិធី | ☐ គម្រោង<br>☐ កម្មវិធី | A.2. វិស័យសាធារណៈ ឬឯកជន | ☐ វិស័យសាធារណៈ<br>☐ វិស័យឯកជន |
| A.3. តើឯកសារទស្សនទានត្រូវបានដាក់ស្នើឆ្លើយតបទៅនឹង RFP? | បាទ/ចាស ☐ ទេ ☐<br>ប្រសិនបើបាទ/ចាស, សូមបញ្ជាក់ពី RFP: ________________ | A.4. ការសម្ងាត់[19] | ☐ សម្ងាត់<br>☐ មិនសម្ងាត់ |
| A.5. បង្ហាញពីតំបន់ដែលគម្រោង / កម្មវិធីផ្តោតលើ | <u>ការកាត់បន្ថយ:</u> កាត់បន្ថយការបញ្ចេញពី:<br>☐ ការប្រើប្រាស់ថាមពល និងការផលិតថាមពល<br>☐ ការដឹកជញ្ជូនដែលបញ្ចេញកាបូនទាប<br>☐ សំណង់ ទីក្រុង និងឧស្សាហកម្ម និងឧបករណ៍ប្រើប្រាស់<br>☐ ព្រៃឈើ និងការប្រើប្រាស់ដី | | |

[19] Concept notes (or sections of) not marked as confidential may be published in accordance with the Information Disclosure Policy (Decision B.12/35) and the Review of the Initial Proposal Approval Process (Decision B.17/18).

| | | | |
|---|---|---|---|
| | ការបន្សុំ: ការកើនឡើងភាពធន់នៃ:<br>☐ មនុស្ស និងសហគមន៍ដែលងាយរងគ្រោះបំផុត<br>☐ សុខភាពនិងសុខុមាលភាព ព្រមទាំងសន្តិសុខស្បៀងនិងទឹក<br>☐ ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថាន<br>☐ ប្រព័ន្ធអេកូឡូស៊ី និងសេវាកម្មអេកូឡូស៊ី | | |
| A.6. ប៉ាន់ស្មានផលពីការកាត់បន្ថយ (tCO2eq លើអាយុកាល) | | A.7. ប៉ាន់ស្មានផលពីការបន្សុំ (តួលេខនៃអ្នកទទួលផលដោយផ្ទាល់ និង ភាគរយ (%) នៃអត្រាប្រជាជន) | |
| A.8. ថវិកាប៉ាន់ស្មានសរុបរបស់គម្រោង (GCF + សហហិរញ្ញប្បទាន) | ចំនួន: ដុល្លារ __________ | A.9. ថវិកាប៉ាន់ស្មានស្នើសុំពី GCF | ចំនួន: ដុល្លារ<br>__________ |
| A.10. ប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលស្នើសុំពីមូលនិធិ GCF | ☐ ជំនួយឥតសំណង ☐ Reimbursable grant ☐ មូលធន ☐ ប្រាក់ធានា ☐ Subordinated loan ☐ Senior loan ☐ ផ្សេងៗ: សូមបញ្ជាក់_____________________ | | |
| A.11. រយៈពេលប៉ាន់ស្មានរបស់គម្រោង/កម្មវិធី: | a) រយៈពេលចំណាយ:<br>b) រយៈពេលសងប្រសិនបើមាន: | A.12. អាយុកាលប៉ាន់ស្មានគម្រោង/កម្មវិធី | នេះសំដៅទៅលើរយៈពេលសរុបដែលការវិនិយោគមានប្រសិទ្ធភាព |
| A.13. តើស្នើសុំមូលនិធិពីកម្មវិធីគាំទ្រដល់ការរៀបចំគម្រោង (PPF) ដែរឬទេ?[20] | បាទ/ចាស ☐ ទេ ☐<br>ទទួលបានការគាំទ្រពីប្រភពផ្សេងទៀត ☐ បើសិនជាមាន, តាមរយៈនរណា: | A.14. ប្រភេទការការពារបរិស្ថាន និងសង្គម (ESS)[21] | ☐ A or I-1<br>☐ B or I-2<br>☐ C or I-3 |
| A.15. តើឯកសារទស្សនទានស្របនឹងបទដ្ឋានសេចក្តីទុកចិត្តរបស់អ្នកដែរឬទេ? | បាទ/ចាស ☐ ទេ ☐ | A.16. តើឯកសារទស្សនទានចែករំលែកជាមួយ NDA ឬនៅ? | បាទ/ចាស ☐<br>ទេ ☐ |

[20] *See here for access to project preparation support request template and guidelines*

[21] *Refer to the Fund's environmental and social safeguards (Decision B.07/02)*

| | | | |
|---|---|---|---|
| A.17. AMA ដែលបានចុះហត្ថលេខា (បើសិនដាក់ស្នើដោយ ស្ថាប័នទទួលបានសេចក្តីទុកចិត្ត (AE)) | បាទ/ចាស ☐ ទេ ☐<br>បើសិនទេ, សូមបញ្ជាក់ពីស្ថានភាពនៃការចរចារ កិច្ចព្រងព្រៀងការទទួលស្គាល់ជាផ្លូវការ (AMA) និងកាលបរិច្ឆេទនៃការចុះហត្ថលេខាដែលបានរំពឹងទុក: | A.18. ឯកសារទស្សនទានត្រូវបានបញ្ចូលក្នុងកម្មវិធីការងារស្ថាប័នដែរឬទេ? | បាទ/ចាស ☐<br>ទេ ☐ |
| A.19. សនិទានគម្រោង/កម្មវិធី គោលបំណង និងវិធីសាស្ត្រនៃកម្មវិធី/គម្រោង (អតិបរមា ១០០ ពាក្យ) | សូមសង្ខេបខ្លីនៃសេចក្តីថ្លែងបញ្ហា សនិទានអាកាសធាតុ និងគោលបំណង ហើយនិងជ្រើសរើសវិធីសាស្ត្រអនុវត្ត រួមទាំងស្ថាប័នអនុវត្ត និងដៃគូអនុវត្តដទៃទៀត។ | | |

## B. ព័ត៌មានគម្រោង/កម្មវិធី (អតិបរមា ៨ ទំព័រ)

### B.1. បរិបទ និងមូលដ្ឋាន (អតិបរមា ២ ទំព័រ)

សូមពិពណ៌នាអំពីភាពងាយរងគ្រោះនិងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ព្រមទាំងតម្រូវការការកាត់បន្ថយ និងការបន្សាំ ដែលចង់ដោះស្រាយ ។

សូមបង្ហាញពីវិធីដែលគម្រោងនេះ មានភាពស្របនឹងអាទិភាពជាតិ និងមានភាពជាម្ចាស់ពេញលេញ។ តើគម្រោង/កម្មវិធីនេះបានចូលរួមចំណែកដោយផ្ទាល់ដល់ *INDC / NDC* របស់ប្រទេស ឬផែនការយុទ្ធសាស្ត្រ ជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឬផែនការផ្សេងៗទៀតដូចជា *NAMAs NAPs* ឬផែនការសមមូល ដែរឬទេ *?* បើមាន សូមពណ៌នាអំពីអាទិភាពណាដែលបានបញ្ជាក់នៅក្នុងឯកសារទាំងនេះ ដែលគម្រោងសំណើនឹងដោះស្រាយ និង/ឬកែលម្អ។

សូមពិពណ៌នាអំពីបុព្វហេតុនិងឧបសគ្គចម្បងៗ (សង្គម យេនឌ័រ សារពើពន្ធ បទប្បញ្ញត្តិ បច្ចេកទេស ហិរញ្ញវត្ថុ អេកូឡូស៊ីនិងស្ថាប័នជាដើម) ដែលចាំបាច់ត្រូវដោះស្រាយ។

ក្នុងករណីពាក់ព័ន្ធ ពិសេសសម្រាប់គម្រោង/កម្មវិធីរបស់វិស័យឯកជន សូមរៀបរាប់អំពីលក្ខណៈ និងឌីណាមិកសំខាន់ៗនៃវិស័យឬទីផ្សារដែលគម្រោង/កម្មវិធីនឹងប្រតិបត្តិ។

**សេចក្តីថ្លែងបញ្ហា៖ តើបញ្ហាទាក់ទងនឹងអាកាសធាតុមានអ្វីខ្លះ?**
**សេចក្តីថ្លែងដំណោះស្រាយ៖ តើដំណោះស្រាយទាក់ទងនឹងអាកាសធាតុមានអ្វីខ្លះ?**
**បន្ទាប់ពីកំណត់បញ្ជីវែងនៃបញ្ហា និងដំណោះស្រាយដែលទាក់ទងនឹងអាកាសធាតុហើយ សូមសាកល្បងរៀបចំវាទៅតាមមូលបទ ដើម្បីរៀបចំសមិទ្ធិផល និងលទ្ធផលដូចបានបង្ហាញក្នុងតារាងខាងក្រោម៖**

| មូលបទ | បញ្ហាទាក់ទងនឹងអាកាសធាតុ | ដំណោះស្រាយទាក់ទងនឹងអាកាសធាតុ |
|---|---|---|

| | | |
|---|---|---|
| i. គោលនយោបាយ / បទប្បញ្ញត្តិ: | | |
| ii. ស្ថាប័ន: | | |
| iii. បច្ចេកវិទ្យា: | | |
| iv. ចំណេះដឹង: | | |
| v. ហិរញ្ញវត្ថុ: | | |
| vi. ធុរកិច្ច: | | |
| vii. សង្គម យេនឌ័រ និងយុវជន: | | |

## B.2. ការពិពណ៌នាគម្រោង/កម្មវិធី (អតិបរមា ៣ទំព័រ)

សូមពិពណ៌នាពីបណ្តុំនៃសមាសភាគ/លទ្ធផល និងសមាសភាគរង/សកម្មភាពនានាដែលរំពឹងទុក ដើម្បីដោះស្រាយឧបសគ្គខាងលើដែលបានកំណត់ ដែលនឹងនាំឱ្យសម្រេចបានលទ្ធផលរំពឹងទុក។

ទាក់ទងនឹងសនិទានភាព សូមពិពណ៌នាពីទ្រឹស្តីនៃការផ្លាស់ប្តូរ និងសូមផ្តល់ព័ត៌មានអំពីវិធីដែលធ្វើឱ្យមានការផ្លាស់ប្តូរមាគ៌ាអភិវឌ្ឍន៍ឆ្ពោះទៅរកការបញ្ចេញកាបូនតិច និង/ឬទិសដៅដែលធន់នឹងអាកាសធាតុស្របតាមគោលដៅ និងគោលបំណងរបស់មូលនិធិ។

សូមពិពណ៌នាពីវិធីដែលសកម្មភាពក្នុងគម្រោងសំណើនេះ ស្របជាមួយនឹងបទប្បញ្ញត្តិ និងក្របខ័ណ្ឌច្បាប់ជាតិប្រសិនបើអនុវត្តបាន។

សូមពិពណ៌នាពីវិធីណាខ្លះដែលស្ថាប័នទទួលសេចក្តីទុកចិត្ត អនុវត្តផែនការសកម្មភាព និងការរៀបចំការអនុវត្តជាមួយអង្គភាពប្រតិបត្តិ និងដៃគូអនុវត្ត។

សូមផ្តល់ទិដ្ឋភាពសង្ខេបនៃហានិភ័យហិរញ្ញវត្ថុ និងប្រតិបត្តិការសំខាន់ៗ និងវិធានការណ៍កាត់បន្ថយដែលបានកំណត់នៅក្នុងដំណាក់កាលនេះ។

**គោលបំណងគម្រោង**:

គោលបំណងគម្រោងអាចនឹងសម្រេចបានតាមរយៈសមិទ្ធិផល និងលទ្ធផលដូចខាងក្រោម (ផ្អែកលើទ្រឹស្តីនៃការផ្លាស់ប្តូរ)៖

- សមិទ្ធិផលទី១៖
    - លទ្ធផល ១.១៖
        - សកម្មភាព ១.១.១:
            - ➢ សូចនាករ ១.១.១.១:
        - សកម្មភាព ១.១.២:
        - សកម្មភាព ១.១.៣:

- លទ្ធផល ១.២៖
  - សកម្មភាព ១.២.១:
  - សកម្មភាព ១.២.២:
- សមិទ្ធិផលទី២៖
  - លទ្ធផល ២.១៖
    - សកម្មភាព ២.១.១:
    - សកម្មភាព ២.១.២:
  - លទ្ធផល ២.២:
    - សកម្មភាព ២.២.១:
    - សកម្មភាព ២.២.២:




ឧទាហរណ៍នៃទ្រឹស្តីនៃការផ្លាស់ប្តូរ

## B.3. លទ្ធផលរំពឹងទុករបស់គម្រោងស្របតាមលក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់ GCF (អតិបរមា ៣ទំព័រ)

GCF មានមហិច្ឆតាចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីសម្រេចគោលដៅដែលបានកំណត់ដោយសហគមន៍អន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការផ្លាស់ប្តូរគំរូឆ្ពោះទៅរកការបញ្ចេញកាបូនទាប និងមាគ៌ាអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុ ដោយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។

សូមផ្តល់ការប៉ាន់ស្មានពីផលប៉ះពាល់ដែលរំពឹងទុកស្របតាមលក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់ GCF ដូចជា៖ សក្តានុពលផលប៉ះពាល់ ការផ្លាស់ប្តូរគំរូ ការអភិវឌ្ឍប្រកបដោយចីរភាព តម្រូវការរបស់អ្នកទទួល ភាពជាម្ចាស់ប្រទេសនិងប្រសិទ្ធផលនិងប្រសិទ្ធភាព។

សូមពិនិត្យឧបសម្ព័ន្ធទី៤ ក្នុងសៀវភៅណែនាំរបស់ NDA ដើម្បីបំពេញផ្នែកនេះ។

ផលប៉ះពាល់រំពឹងទុកគឺត្រូវស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគទាំង៦ របស់ GCF៖

1. **សក្តានុពលផលប៉ះពាល់៖** តើការកាត់បន្ថយរបស់គម្រោង/កម្មវិធីផ្តល់ផលសក្តានុពលអ្វីខ្លះ (បរិមាណប្រចាំឆ្នាំនិងសរុបនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់) ហើយតើការបន្សាំរបស់គម្រោង/កម្មវិធីផ្តល់ផលសក្តានុពលអ្វីខ្លះ (ចំនួនអ្នកទទួលផលផ្ទាល់ និងប្រយោល)?

**2. ការផ្លាស់ប្តូរគំរូ៖**

i. សក្តានុពលសម្រាប់ពង្រីក និងធ្វើឡើងវិញនៅតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជា: តើមានករណីជំនួញសម្រាប់ពង្រីក និងធ្វើឡើងវិញដែរឬទេ?

ii. ចំណេះដឹង និងជំនាញដែលបានរៀនសូត្រ និងដកស្រង់ពីគម្រោង និងពីអ្នកដទៃទៀត អាចផលិតបាននូវចំណេះដឹង និងទំនាក់ទំនង សេវាកម្មនិងវេទិកាសម្រាប់ការរៀនរួមគ្នា និងការផ្លាស់ប្តូរបទពិសោធន៍នៅភាគខាងត្បូង។

iii. បានបង្កើតបរិស្ថានអំណោយផលថ្មី:

iv. បានបង្កើតក្របខ័ណ្ឌបញ្ញត្តិ:

v. បានបង្កើតទីផ្សារថ្មី និងការច្នៃប្រឌិតថ្មី:

**3. ការអភិវឌ្ឍដោយចីរភាព៖ ផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព**

**4. តម្រូវការរបស់អ្នកទទួល៖** តើនេះគឺជាគម្រោងសំណើដែលបានពិភាក្សា និងជំរុញសេចក្តីត្រូវការរបស់ស្ត្រី យុវជន និងក្រុមងាយរងគ្រោះ នៅកន្លែងដែលពួកគេមិនត្រូវបានមើលឃើញថាជាអ្នកទទួលផល តែការចូលរួមយ៉ាងសកម្មរបស់ពួកគេនៅក្នុងខ្សែសង្វាក់តម្លៃគឺជាកម្លាំងចលករមួយដែលមានសារៈសំខាន់ចំពោះជោគជ័យនៃគម្រោងសំណើរនេះ?

**5. ភាពជាម្ចាស់ប្រទេស៖** តើភាពជាម្ចាស់ប្រទេសគឺស្របតាមផែនការយុទ្ធសាស្ត្រ និងសកម្មភាពអភិវឌ្ឍជាតិ និងគោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុដែរឬទេ?

**6. ប្រសិទ្ធភាព និងប្រសិទ្ធផល៖** ទាក់ទងនឹងការចំណាយរួមក្នុងបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងចំនួននៃអ្នកទទួលផលដែលត្រូវបែងចែកទៅតាមទំហំសរុបនៃមូលនិធិ។

## B.4. ការចូលរួមពី NDA AE និង/ឬ អ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងប្រទេស (អតិ. កន្លះទំព័រ)

សូមពិពណ៌នាពីវិធីនៃការចូលរួមរបស់ *NDA AE* និងអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងប្រទេសដែលត្រូវបានដាក់បញ្ចូល និងអំពីអ្វីដែលជាការចូលរួមនាពេលក្រោយដែលនឹងត្រូវបានដាក់បញ្ចូលដូចដែលឯកសារទស្សនទានបានរៀបចំនៅក្នុងគម្រោងសំណើមូលនិធិនេះ។

| អ្នកពាក់ព័ន្ធ | តួនាទីនៅក្នុងគម្រោង |
|---|---|
| A. វិស័យសាធារណៈ | |
| | |
| B. វិស័យឯកជន | |
| | |
| C. ដៃគូអង្គការសង្គមស៊ីវិល | |
| | |
| D. គ្រឹះស្ថានសិក្សា | |

## C. ព័ត៌មានអំពីចំណាយ និងហិរញ្ញវត្ថុប៉ាន់ស្មាន (អតិ. ៣ទំព័រ)

### C.1. ហិរញ្ញវត្ថុទៅតាមសមាសធាតុ (អតិ. កន្លះទំព័រ)

សូមផ្តល់ការប៉ាន់ប្រមាណនៃការចំណាយសរុបក្នុងសមាសធាតុ/លទ្ធផលនីមួយៗ និងសូមបែងចែកទៅតាមប្រភពនៃហិរញ្ញវត្ថុ។

| សមិទ្ធិផល | ឯកតាតម្លៃ (ដុល្លារ) | ហិរញ្ញប្បទាន GCF | | សហហិរញ្ញប្បទាន | | |
|---|---|---|---|---|---|---|
| | | ចំនួន (ដុល្លារ) | ឧបករណ៍ហិរញ្ញវត្ថុ | ចំនួន (ដុល្លារ) | ឧបករណ៍ហិរញ្ញវត្ថុ | ឈ្មោះស្ថាប័ន |
| **សមិទ្ធិផលទី១** | | | | | | |
| លទ្ធផល ១.១ | | | | | | |
| លទ្ធផល ១.២ | | | | | | |
| លទ្ធផល ១.៣ | | | | | | |
| **សមិទ្ធិផលទី២** | | | | | | |
| លទ្ធផល ១.១ | | | | | | |
| លទ្ធផល ១.២ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| លទ្ធផល ១.៣ | | | | | | |
| តម្លៃប៉ាន់ស្មានសរុប (ដុល្លារ) | | | | | | |

សម្រាប់សំណើគម្រោងរបស់វិស័យឯកជន សូមផ្តល់ទិដ្ឋភាព (ដ្យាក្រាម) នៃរចនាសម្ព័ន្ធហិរញ្ញវត្ថុ។ សូមផ្តល់ឧទាហរណ៍នៃគំរូអាជីវកម្មមួយ។




## C.2. ការបញ្ជាក់ពីការស្នើសុំមូលនិធិ GCF (អតិ. ១ទំព័រ)

សូមពន្យល់ពីមូលហេតុដែលគម្រោង/កម្មវិធីស្នើសុំមូលនិធិ *GCF* ។ ឧទាហរណ៍ សូមពន្យល់ពីមូលហេតុអ្វីបានជា គម្រោងសំណើនេះមិនត្រូវបានផ្តល់ហិរញ្ញវត្ថុដោយវិស័យសាធារណៈ និង/ឬវិស័យឯកជននៅក្នុងប្រទេស។

សូមពិពណ៌នាជម្រើសមូលនិធិបំរុងសម្រាប់សកម្មភាពដូចគ្នា ដែលបាននិងកំពុងធ្វើការស្នើសុំនៅក្នុងឯកសារទស្សនទាន ដោយរួមបញ្ចូលនូវការវិភាគពីឧបសគ្គ និងបញ្ហាសម្រាប់អ្នកទទួលផលដែលមានសក្តានុពល ដើម្បីទទួលបានមូលនិធិពីប្រភពសាធារណៈ និងឯកជន។

សូមបញ្ជាក់ពីសនិទាន និងកម្រិតនៃការផ្តល់ឧបករណ៍ហិរញ្ញវត្ថុរបស់ *GCF* ក៏ដូចជាវិធីដែលវាត្រូវបានបញ្ជូនទៅដល់ អ្នកប្រើចុងក្រោយនិងអ្នកទទួលផល។ បញ្ជាក់ពីមូលហេតុអ្វីបានជាមានការទាមទារតិចបំផុត ដើម្បីធ្វើឱ្យការវិនិយោគ មានស្ថិរភាព និងមានប្រសិទ្ធិភាពបំផុតដោយពិចារណាលើការចំណាយបន្ថែម ឬហានិភ័យចម្បងនៃ

គម្រោង/ កម្មវិធី (យោងទៅលើសេចក្តីសំរេច *B.12/17, B.10/03,* និង*B.09/04* សម្រាប់ជាព័ត៌មានលម្អិត)។ ការបញ្ជាក់ពីជំនួយឥតសំណង និងជំនួយជាក់ស្តែងទៅតាមការចំណាយគឺជាភាពចាំបាច់។

ក្នុងករណីសំណើគម្រោងរបស់វិស័យឯកជន លក្ខខណ្ឌនៃការផ្តល់គួរតែត្រូវបានបង្រួម(អប្បបរមា) និងស្របទៅតាម គោលការណ៍ណែនាំដែលត្រូវអនុវត្តចំពោះប្រតិបត្តិការរបស់វិស័យឯកជន (សេចក្តីសម្រេចលេខ *B.05/07*) ។

ហេតុអ្វីបានជាអ្នកត្រូវការមូលនិធិ **GCF** នេះ? តើមានគម្រោងដែលមានស្រាប់ទេ**?** តើមានជាន់គ្នា និងស្ទួនគ្នាជាមួយគម្រោងផ្សេងៗទេ**?**

## C.3. និរន្តរភាពគម្រោង (យុទ្ធសាស្រ្តដែលមានស្រាប់) (អតិ. ១ ទំព័រ)

សូមពន្យល់ពីវិធីដែលគម្រោងនិងកម្មវិធីអាចធានាបាននិរន្តរភាពក្នុងរយៈពេលវែង និងពីវិធីដែលគម្រោងនិងកម្មវិធីនឹងត្រូវបានត្រួតពិនិត្យបន្ទាប់ពីគម្រោង/កម្មវិធីត្រូវបានអនុវត្តដោយមានការគាំទ្រពី *GCF* និងប្រភពផ្សេងៗទៀត។

ក្នុងករណីមិនមែនជាជំនួយឥតសំណង សូមពន្យល់ពីរបៀបដែលដើមទុនដែលបានវិនិយោគនឹងត្រូវបានសងហើយនិងរយៈពេលសង។

**តើអ្វីជាយុទ្ធសាស្រ្តពេលបញ្ចប់គម្រោងរបស់អ្នក?** ឧទា. **នៅពេលគម្រោងបានបញ្ចប់ និងមូលនិធិត្រូវបានផ្អាក នោះតើនឹងមានអ្វីកើតឡើងចំពោះគម្រោងនេះ?**

## D. ឯកសារគាំទ្រដែលបានដាក់ជូន (ប្រសិនបើមាន)

☐ ផែនទីដែលបានបង្ហាញពីទីតាំងនៃគម្រោង/កម្មវិធី

☐ ដ្យាក្រាមនៃទ្រឹស្តីនៃការផ្លាស់ប្តូរ

☐ គំរូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយនឹងការសន្មត និងចំហាក (សេណារីយ៉ូ) ដែលមានសក្តានុពលសំខាន់ៗ

☐ ការសិក្សាសមិទ្ធិលទ្ធភាព

☐ របាយការណ៍វាយតម្លៃគម្រោងពីមុន

☐ លទ្ធផលនៃការពិនិត្យហានិភ័យបរិស្ថាននិងសង្គម

## ស្វ័យរំលឹក

តើអ្នកដឹងទេថាសំណើសុំមូលនិធិពេញលេញ និងឧបសម្ព័ន្ធនឹងត្រូវការឯកសារទាំងនេះ? បាទ/ចាស ☐ ទេ ☐

- ការសិក្សាសមិទ្ធិលទ្ធភាព
- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ឬក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាននិងសង្គម
- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងកម្រិតគម្រោង រួមទាំងជនជាតិដើមភាគតិច ប្រសិនបើពាក់ព័ន្ធ
- ការវាយតម្លៃយេនឌ័រ និងផែនការសកម្មភាព
- ផែនការប្រតិបត្តិការ និងថែទាំ ប្រសិនបើមាន

| |
|---|
| • គោលការណ៍ណែនាំប្រតិបត្តិការកម្ចី ឬជំនួយឥតសំណង ដែលសមស្រប<br>• លិខិតប្តេជ្ញាចិត្តផ្តល់សហហិរញ្ញប្បទាន |
| តើអ្នកដឹងថាសំណើថវិកាពីស្ថាប័នទទួលសេចក្តីទុកចិត្ត ដែលមិនបានចុះហត្ថលេខាកិច្ចព្រមព្រៀងផ្តល់សេចក្តីទុកចិត្តជាផ្លូវការ (AMA) នឹងត្រូវបានពិនិត្យ ប៉ុន្តែមិនបានបញ្ជូនទៅក្រុមប្រឹក្សាភិបាលដើម្បីពិចារណាដែរឬទេ ?<br>បាទ/ចាស ☐ ទេ ☐ |
| |

E. ការតាមដាន និងវាយតម្លៃ

| ក្របខ័ណ្ឌលទ្ធផលគម្រោង | | | | | | |
|---|---|---|---|---|---|---|
| សមិទ្ធិផល | លទ្ធផល | សូចនាករ SMART | ទិន្នន័យដើមគ្រា (Baseline) | គោលដៅ | ការផ្ទៀងផ្ទាត់ | ការសន្មត |
| សមិទ្ធិផលទី១ | លទ្ធផល ១.១ | | | | | |
| | លទ្ធផល ១.២ | | | | | |
| | លទ្ធផល ១.៣ | | | | | |
| | | | | | | |
| សមិទ្ធិផលទី២ | លទ្ធផល ២.១ | | | | | |
| | លទ្ធផល ២.២ | | | | | |
| | លទ្ធផល ២.៣ | | | | | |
| | | | | | | |
| | | | | | | |

F. ការគ្រប់គ្រងហានិភ័យ

| មូលបទ | ហានិភ័យ | ចំណាត់ថ្នាក់ នៃហានិភ័យ (ខ្ពស់ មធ្យម ឬទាប) | វិធីដោះស្រាយ ហានិភ័យទាំងនេះ ? |
|---|---|---|---|

| | | | |
|---|---|---|---|
| i. គោលនយោបាយ /បទប្បញ្ញត្តិ៖ (ការជឿជាក់របស់អ្នកធ្វើគោលនយោបាយ, ស្ថិរភាព, អភិបាលកិច្ច)៖ | | | |
| ii. ស្ថាប័ន៖ (ចំណង់សម្រាប់ការអនុវត្ត, សមត្ថភាពស្រូបយក, ការបាត់បង់ការចងចាំរបស់ស្ថាប័ន) | | | |
| iii. បច្ចេកទេស៖<br>ការអនុវត្តគម្រោង និងហានិភ័យដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ នាពេលអនាគត និងហានិភ័យ MRV | | | |
| iv. ចំណេះដឹង/ព័ត៌មាន៖<br>(ចងក្រងទិន្នន័យដើមគ្រា ទិន្នន័យដែលអាចរកបាន និងមានភាពត្រឹមត្រូវ) | | | |
| v. ហិរញ្ញវត្ថុ៖ (សារពើពន្ធ អត្រាការប្រាក់ អត្រាប្តូរប្រាក់, ការវិភាគហានិភ័យនិងចំណេញ) | | | |
| vi. ធុរកិច្ច៖ (គំរូថេរ - ការផ្គូរផ្គងប្រាក់បង្វិលសង ប្រាក់កម្ចីចាប់ផ្តើមអាជីវកម្ម ការធានាប្រាក់កម្ចីដោយផ្នែក): | | | |
| vii. សង្គម/វប្បធម៌៖ (បម្រាម និងការទទួលស្គាល់សង្គម): | | | |

**សេចក្តីសង្ខេប៖**

- ជំពូកនេះពិពណ៌នាអំពី ដំណើរការអនុម័តសំណើគម្រោងរបស់ GCF និងជំហានដើម្បីរៀបចំឯកសារទស្សនទានប្រកបដោយគុណភាព និងការប្រកួតប្រជែងខ្ពស់ និងសំណើថវិកាសម្រាប់បំពេញតាមតម្រូវការមូលនិធិអាកាសធាតុ ដោយប្រើប្រាស់ GCF ជាឧទាហរណ៍។
- ចំណេះដឹងនិងជំនាញជាមូលដ្ឋានក៏នឹងជួយស្ថាប័នប្រតិបត្តិ (EEs) ក្នុងវិស័យសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិលក្នុងការរៀបចំឯកសារទស្សនទានដែលមានគុណភាពខ្ពស់ជាមួយនឹងយុទ្ធសាស្រ្តបញ្ចប់គម្រោងយ៉ាងរឹងមាំ ដើម្បីទទួលបានហិរញ្ញប្បទានអាកាសធាតុជាតិ និងអន្តរជាតិដទៃទៀត ពោលគឺមិនត្រឹមតែ GCF ទេ។
- ជំពូកនេះពន្យល់អំពីទ្រឹស្តីនៃការផ្លាស់ប្តូរ និងរបៀបបំពេញទំរង់បែបបទឯកសារទស្សនទាន។

# ជំពូកទី ១០: នីតិវិធីចេញលិខិតគាំទ្រក្នុងការវាយតម្លៃនិងអនុម័តឯកសារទស្សនទាន និងសំណើថវិកា

ជំពូកនេះបកស្រាយពីជំហាន និងនីតិវិធីចេញលិខិតគាំទ្រក្នុងការវាយតម្លៃ និងអនុម័តឯកសារទស្សនទាន និងសំណើថវិកា ដើម្បីទទួលបាន និងប្រើប្រាស់មូលនិធិអាកាសធាតុ ដោយផ្អែកលើបទពិសោធន៍អន្តរជាតិល្អៗ និងដោយយោងទៅតាមគោលការណ៍ណែនាំរបស់ GCF។ នីតិវិធីនេះ គឺផ្អែកលើការពិគ្រោះយោបល់ កាលពីខែមេសា និងខែមិថុនា/កក្កដា ឆ្នាំ២០១៩ ជាមួយសមាជិកសំខាន់ៗនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (GSSD) និងក្រុមការងារ GCFAP[22] ដែលបានដើរតួយ៉ាងសកម្មក្នុងដំណើការសម្រេចចិត្តដើម្បីទទួលបាន និងប្រើប្រាស់ហិរញ្ញប្បទានអាកាសធាតុនៅក្នុងប្រទេសកម្ពុជា។ សមាជិកផ្សេងៗទៀត វិស័យឯកជន និងអ្នកពាក់ព័ន្ធអង្គការសង្គមស៊ីវិល ក៏ត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចពិភាក្សាដើម្បីផ្តល់ទស្សនវិស័យដែលមានតុល្យភាពលើការអភិវឌ្ឍក្នុងប្រទេសកម្ពុជា។

## ១០.១ នីតិវិធីចេញលិខិតគាំទ្រតាមគោលការណ៍ណែនាំរបស់ GCF

### I. គោលបំណង

គោលបំណងនៃនីតិវិធីចេញលិខិតគាំទ្រ គឺដើម្បីធានាបាននូវសង្គតិភាពជាមួយរបៀបវារៈនៃការអភិវឌ្ឍជាតិ ក៏ដូចជាយុទ្ធសាស្ត្រទាក់ទងនឹងអាកាសធាតុ ផែនការនិងវិធីសាស្ត្រដឹកនាំប្រទេស និងដើម្បីផ្តល់ហិរញ្ញប្បទានដល់វិស័យសាធារណៈ និងឯកជនប្រកបដោយប្រសិទ្ធភាព (ទាំងផ្ទាល់ និងដោយប្រយោល) ដោយ GCF។ ការមិនជំទាស់គឺជាលក្ខខ័ណ្ឌសម្រាប់ការអនុម័តលើរាល់សំណើថវិកានានាដែលបានដាក់ស្នើសុំមូលនិធិ។ វាគួរតែត្រូវបានផ្តល់ជូនទៅ GCF ដោយភ្ជាប់ជាមួយនឹងការដាក់ជូននៃសំណើថវិកាមួយដែលកំពុងស្វែងរកមូលនិធិ GCF ។ នៅក្នុងករណីមានការដាក់ពាក្យសុំសេចក្តីទុកចិត្តពីស្ថាប័នថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ និងអន្តរការី NDA/ជនបង្គោលនឹងជួយសម្រួលដល់ការទាក់ទងដើម្បីដាក់ពាក្យស្នើសុំទាំងនេះទៅ GCF ។

### II. របៀបទាក់ទងដើម្បីទទួលបានការគាំទ្រលើសំណើថវិកា

មុនពេលជូនដំណឹងអំពីគាំទ្ររបស់ពួកគេ ប្រទេសនីមួយៗនឹងធ្វើការសម្រេចចិត្តលើដំណើរការសមស្របរបស់ជាតិមួយ សម្រាប់បញ្ជាក់ពីគោលជំហរគាំទ្រលើសំណើថវិកានានា ដោយយោងទៅតាមកាលៈទេសៈរបស់ប្រទេស សមត្ថភាព ព្រមទាំងដំណើរការ និងស្ថាប័នដែលមានស្រាប់។ ដើម្បីលើកកម្ពស់តម្លាភាពសង្គតិភាព និងអភិបាលកិច្ចល្អ រាល់សំណើគម្រោងនីមួយៗរបស់ស្ថាប័នប្រតិបត្តិ (EE) ស្ថាប័នជាតិទទួលមូលនិធិផ្ទាល់ (DAE) ឬ ស្ថាប័នអន្តរជាតិទទួលមូលនិធិ (IAE) ត្រូវផ្តល់ការពិពណ៌នាយ៉ាងពេញលេញអំពីរបៀបដែលភាពជាម្ចាស់ប្រទេសត្រូវបានអនុវត្ត ប្រសិនបើមិនពេញចិត្ត ក្រុមប្រឹក្សាភិបាលអាចបដិសេធបាន។

NDA/ជនបង្គោល នឹងជូនដំណឹងពីការគាំទ្ររបស់ពួកគេទៅកាន់លេខាធិការដ្ឋាន GCF ដោយភ្ជាប់ជាមួយ រាល់សំណើថវិកាដែលបានដាក់ស្នើដោយ EE, DAE ឬ IAE ។ លិខិតគាំទ្រ នឹងត្រូវចុះហត្ថលេខា

[22] *First training was conducted on the 5 July 2019 in Phnom Penh, Cambodia*

ដោយអ្នកតំណាងផ្លូវការនៃ NDA/ជនបង្គោលដែលបានចុះបញ្ជីជាមួយលេខាធិការដ្ឋាន (ពោលគឺ MOE)។ លេខាធិការដ្ឋាននឹងបញ្ជាក់ពីការទទួលបានជាផ្លូវការនូវលិខិតគាំទ្រទៅកាន់ NDA/ជនបង្គោល និង IE ឬ អន្តរការីនីមួយៗ។

ក្នុងករណីដែលសំណើថវិកាត្រូវបានដាក់ដោយមិនមានលិខិតគាំទ្រ លេខាធិការដ្ឋាននឹងជូនដំណឹងដល់ NDA/ជនបង្គោលថា សំណើគម្រោងនេះនឹងមិនត្រូវបានដាក់ជូនទៅក្រុមប្រឹក្សាភិបាលសម្រាប់ធ្វើការពិចារណាទេ លុះត្រា NDA/ជនបង្គោលបានផ្តល់លិខិតគាំទ្រ។ NDA/ជនបង្គោលនឹងលិខិតគាំទ្ររបស់ខ្លួនក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទទួលបានព័ត៌មាននេះ។ បន្ទាប់ពីរយៈពេល ៣០ ថ្ងៃ សំណើគម្រោងនឹងត្រូវផ្អាក ហើយលេខាធិការដ្ឋាននឹងជូនដំណឹងដល់ EE, DAE ឬ IAE ។

ការជូនដំណឹងអំពីការគាំទ្ររបស់ NDA/ជនបង្គោល ដែលស្របតាមបទប្បញ្ញត្តិនៃនីតិវិធីនេះ មានសេចក្តីដូចខាងក្រោម៖

ក) រដ្ឋាភិបាលមិនមានការជំទាស់នឹងសំណើថវិកា

ខ) សំណើថវិកាដែលបានដាក់ស្នើគឺអនុលោមតាមអាទិភាព យុទ្ធសាស្ត្រ និងផែនការជាតិរបស់ប្រទេស ហើយសង្គតិភាពត្រូវបានបញ្ជាក់ និង

គ) សំណើថវិកាដែលបានដាក់ស្នើគឺអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាតិ ដែលស្របតាមគោលការណ៍ការពារបរិស្ថាននិងសង្គមរបស់ GCF ។

ដើម្បីលើកកម្ពស់តម្លាភាព រាល់លិខិតគាំទ្រនឹងត្រូវផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់GCF។ NDAs/ជនបង្គោលត្រូវបានលើកទឹកចិត្ត ឱ្យផ្សព្វផ្សាយជាសាធារណៈនូវលិខិតគាំទ្ររបស់ពួកគេភ្លាមៗតាមដែលអាចអនុវត្តបាន បន្ទាប់ពីត្រូវបានចេញផ្សាយ (អាចដាក់នៅលើគេហទំព័ររបស់ DCC)។

ក្នុងករណីសំណើថវិការៀបចំសម្រាប់កម្មវិធីមួយ ពេលទទួលបានលិខិតគាំទ្រ បានន័យថាការគាំទ្រនេះនឹងគ្របដណ្តប់លើរាល់គម្រោងឬសកម្មភាព ដែលត្រូវអនុវត្តទាំងក្នុងក្របខ័ណ្ឌនៃកម្មវិធីនោះ ។

### III. ការផ្សព្វផ្សាយអំពីនីតិវិធីចេញលិខិតគាំទ្រ

លេខាធិការដ្ឋាន GCF នឹងផ្សព្វផ្សាយនីតិវិធីចេញលិខិតគាំទ្រនៅលើគេហទំព័ររបស់ GCF និងបោះពុម្ព រួមជាមួយការពន្យល់ ដែលងាយស្រួល។ ការបកប្រែទៅជាភាសាដទៃទៀតនឹងត្រូវធ្វើឡើងនៅពេលសមស្រប។

ប្រសិនបើមានការស្នើសុំ លេខាធិការដ្ឋាននឹងជួយ NDA/ជនបង្គោលក្នុងការលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីចេញលិខិតគាំទ្រ។

NDAs/ជនបង្គោលត្រូវបានលើកទឹកចិត្តឱ្យផ្សព្វផ្សាយនីតិវិធីនេះនៅក្នុងប្រទេសរបស់ពួកគេតាមភាពសមស្រប និងតាមរយៈគេហទំព័រនិងបណ្តាញទំនាក់ទំនងផ្ទាល់ខ្លួនជាពិសេសជាភាសាក្នុងស្រុករបស់ពួកគេ។

### IV. ការពិនិត្យ និងកែសម្រួលនីតិវិធីចេញលិខិតគាំទ្រ

នីតិវិធីចេញលិខិតគាំទ្រនេះអាចត្រូវបានពិនិត្យ និងកែសម្រួល ដោយផ្អែកលើតម្រូវការ និង បទពិសោធន៍ ដែលទទួលបានពីការអនុវត្ត។

## ១០.២ នីតិវិធីចេញលិខិតគាំទ្ររបស់កម្ពុជា

នីតិវិធីចេញលិខិតគាំទ្រក្នុងការវាយតំលៃនិងអនុម័តឯកសារទស្សនទាន (CN) និងសំណើថវិកា (FP) ត្រូវបានបង្ហាញនៅក្នុងរូបភាពទី១៤ និងទី១៥។ ដំណាក់កាលសម្រាប់នីតិវិធីចេញលិខិតគាំទ្រ (NOL) ត្រូវបានពន្យល់លម្អិតនៅក្នុងតារាងទី ៧ ហើយត្រូវបានសង្ខេបនៅក្នុងរូបភាពទី ១៦ ដើម្បីឆ្លុះបញ្ចាំងពីវដ្តគម្រោងរបស់ GCF។ សូមពិនិត្យរូបភាពទី ៩ ស្តីពីក្របខ័ណ្ឌស្ថាប័ននិងហិរញ្ញវត្ថុទូទៅដើម្បីទទួលបាន និងប្រើប្រាស់ធនធានរបស់ GCF ។

### A. នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការវាយតម្លៃនិងការអនុម័តលើឯកសារទស្សនទាននិងសំណើថវិកាតាមរយៈនីតិវិធីចេញលិខិតគាំទ្រនៅកម្ពុជា

នីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការវាយតម្លៃនិងការអនុម័តកំណត់ឯកសារទស្សនទាន និង សំណើថវិកានៅកម្ពុជាគឺផ្អែកលើដំណាក់កាលដូចខាងក្រោម៖

**ដំណាក់កាលចាប់ផ្តើម ៖ បង្កើនការយល់ដឹងអំពីឱកាសរបស់ GCF**

- NDA ធ្វើយុទ្ធនាការដើម្បីលើកកម្ពស់ការយល់ដឹងដល់ដៃគូសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិល អំពីឱកាសរបស់ GCF តាមរយៈគេហទំព័រ NDA សិក្ខាសាលា ព្រឹត្តិការណ៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។
- EE, DAE ឬប្រតិបត្តិករគម្រោងត្រូវបានលើកទឹកចិត្តឱ្យពិភាក្សាជាមួយ NDA នូវគំនិតគម្រោងដំបូងដែលពួកគេអាចមាន។
- ប្រសិនបើគំនិតទាំងនោះត្រូវបានគេចាត់ទុកថា "មានសក្តានុពលហើយមិនជាន់គ្នា" នោះ NDA នឹងលើកទឹកចិត្តដល់អ្នកគាំទ្រគម្រោង ដើម្បីរៀបចំឯកសារទស្សនទានដោយប្រើគំរូ CN របស់កម្ពុជាដូចដែលបានបង្ហាញនៅក្នុងផ្នែកទី ៨.២ ។
- DAE, IAE និង EE ចាំបាច់ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ NDA មុនពេលចេញលិខិតគាំទ្រដើម្បីយល់ស្របថា: i) ត្រូវជូនដំណឹងដល់ NDA តាមរយៈនាយកដ្ឋានប្រែប្រួលអាកាសធាតុ (DCC) នូវរាល់ការកែតម្រូវជាបន្តបន្ទាប់ នៃឯកសារទស្សនទាន និងសំណើថវិកា ។ ii) មន្ត្រីរបស់ DCC នឹងចាត់ជាតំណាងនៅក្នុងគណៈកម្មាធិការដឹកនាំគម្រោង GCF ។ (iii) រាល់របាយការណ៍វឌ្ឍនភាពទាំងអស់ត្រូវតែដាក់ជូនទៅ NDA តាមរយៈ DCC ។

**ដំណាក់កាលទី១៖ ការរៀបចំ និងការដាក់ស្នើឯកសារទស្សនទាន**

- ១.១ EE ឬប្រតិបត្តិករគម្រោងរៀបចំឯកសារទស្សនទានគម្រោង[23] ហើយបញ្ជូនទៅ NDA តាមរយៈ នាយកដ្ឋានប្រែប្រួលអាកាសធាតុ(DCC) ដោយអ៊ីម៉ែល ឬគេហទំព័រផ្ទុកព័ត៌មានអន

[23] *EEs and project proponents will be trained on how to complete the CN template on the 25 June 2019 in Cambodia.*

ឡាញ (Online Portal) របស់ DCC (នឹងរៀបចំបង្កើតនាពេលខាងមុខ)។ នេះរួមបញ្ចូលនូវការកំណត់អត្តសញ្ញាណដៃគូស្ថាប័នអន្តរជាតិទទួលមូលនិធិ (IAE) នៅក្នុងគម្រោង/កម្មវិធី។ នេះគឺជាជំហាន ចាំបាច់ដែល NDA ចង់បានយ៉ាងខ្លាំង។ EE ត្រូវបានលើកទឹកចិត្តឱ្យពិភាក្សាឯកសារទស្សនទាន (CN) ជាមួយក្រសួងពាក់ព័ន្ធ និងទទួលបានលិខិតគាំទ្រ ដើម្បីធានាថាក្រសួងពាក់ព័ន្ធនេះដឹងអំពី CN និងផ្តល់ការគាំទ្រ។

- ១.២ NDA ទទួល CN ពី EE, DAE ឬ IAE
- ១.៣ NDA អនុញ្ញាតឱ្យ DCC នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព (GSSD) ឱ្យបញ្ជាក់ពីការទទួលបានឯកសារទស្សនទាន (CN) ប្រគល់លេខកូដ និងពិនិត្យ CN។
- ១.៤ ក្រុមវាយតំលៃនៅ DCC នឹងពិនិត្យពីភាពពេញលេញនៃឯកសារទស្សនទាន ដើម្បីធ្វើឱ្យប្រាកដថាផ្នែកទាំងអស់ត្រូវបានបំពេញយ៉ាងត្រឹមត្រូវ ហើយព័ត៌មានដែលបានផ្តល់គឺច្បាស់លាស់។ ១.៤.១ ប្រសិនបើ CN មិនទាន់ពេញលេញ CN នោះនឹងត្រូវបានប្រគល់ទៅ EE, DAE ឬ IAE ដើម្បីស្នើសុំការកែតម្រូវ។
- ១.៥ ប្រសិនបើ CN មានភាពពេញលេញហើយនោះ DCC នឹងស្នើសុំឱ្យសមាជិកក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) ធ្វើការវាយតំលៃ CN ដោយប្រើទម្រង់គំរូវាយតម្លៃនៅក្នុងផ្នែក ១០.៤ ។ នៅពេលដែលគេហទំព័រផ្ទុកព័ត៌មានអនឡាញដំណើរការ DCC នឹងបញ្ជូន CN ទៅប្រអប់សាររបស់អ្នកជំនាញតាមផ្នែកពាក់ព័ន្ធ ដែលជាសមាជិក GCFAP[24] និងផ្តល់ពេល ៣០ថ្ងៃ ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍
- ១.៦ GCFAP ផ្តល់អនុសាសន៍មក NDA តាម DCC តាមរយៈអ៊ីម៉ែលឬ ប្រព័ន្ធគេហទំព័រផ្ទុកព័ត៌មានអនឡាញ
- ១.៧ NDA ពិនិត្យ CN និងអនុសាសន៍របស់ GCFAP ។ ១.៧.១ ប្រសិនបើ CN មិនទាន់ពេញលេញឬមិនទាន់បានអនុម័ត នោះNDA នឹងជូនដំណឹងដល់ EE / DAE ហើយ EE អាចសម្រេចថាតើត្រូវដាក់ស្នើម្តងទៀត ឬបោះបង់ CN។ CN នីមួយៗអនុញ្ញាតឱ្យដាក់ស្នើចំនួន ២ ដងតែប៉ុណ្ណោះ ដោយការពិនិត្យម្តងៗមានរយៈពេល ១ ខែ។ ១.៧.២ ប្រសិនបើ CN ត្រូវបានអនុម័ត នោះNDA នឹងផ្តល់លិខិតគាំទ្រទៅ EE ឬប្រតិបត្តិករគម្រោង
- ១.៨ EE ដោយមានការគាំទ្រពី DCC នឹងកំណត់អត្តសញ្ញាណ DAE / IAE ជាដៃគូអនុវត្ត ដើម្បីធ្វើការជាមួយ ក្នុងករណីមិនទាន់បានកំណត់ពីមុនមក
- ១.៩ DAE / IAE សហការជាមួយ EE នឹងបញ្ជូន CN ទៅលេខាធិការដ្ឋាន GCF ដើម្បីទទួលបាននូវមតិយោបល់ដំបូងលើ CN ដោយមានការជូនដំណឹងទៅ NDA ផងដែរ
- ១.១០ NDA ធ្វើបច្ចុប្បន្នភាព និងបង្ហាញលិខិតគាំទ្រ នៅក្នុងគេហទំព័រផ្ទុកព័ត៌មានរបស់ DCC (នាពេលអនាគត) និង
- ១.១១ ប្រសិនបើ CN ទទួលបានការពេញចិត្តពី GCF បន្ទាប់មក GCF នឹងលើកទឹកចិត្តឱ្យ DAE/IAE រៀបចំសំណើថវិកាពេញលេញរបស់ GCF ដែលជាផ្នែកមួយនៃដំណាក់កាលទី២

[24] *GCFAP members have been trained on how to design high quality CN and on how to appraise the CN template on the 5 July 2019 in Phnom Penh, Cambodia.*

ដោយប្រើគំរូរបស់ GCF នៅលើគេហទំព័ររបស់ GCF ។ DAE មានជម្រើសក្នុងការដាក់ពាក្យស្នើសុំថវិកាពីកម្មវិធីគាំទ្រដល់ការរៀបចំគម្រោង (PPF) ដែលមានទឹកប្រាក់ចំនួន ១.៥ លានដុល្លារក្នុងមួយគម្រោង (អនុវត្តសម្រាប់តែ DAE ប៉ុណ្ណោះ)។




**រូបភាពទី 14:** និតិវិធីចេញលិខិតគាំទ្រលើការវាយតម្លៃ និងអនុម័តឯកសារទស្សនទាន

## ដំណាក់កាលទី២៖ ការរៀបចំសំណើថវិកា និងការដាក់ស្នើ

- ២.១ DAE/IAE សហការជាមួយ EE រៀបចំសំណើថវិកា GCF ពេញលេញ ហើយ DAE/IAE បញ្ជូនសំណើថវិកាមក NDA
- ២.២ NDA ទទួលសំណើថវិកាពី DAE/IAE
- ២.៣ NDA អនុញ្ញាតឱ្យ DCC នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍដោយចីរភាព (GSSD) ឱ្យបញ្ជាក់ពីការទទួលបានសំណើថវិកា ប្រគល់លេខកូដ និងពិនិត្យសំណើថវិកា។
- ២.៤ ក្រុមវាយតំលៃនៅ DCC នឹងពិនិត្យពីភាពពេញលេញនៃសំណើថវិកា ដើម្បីធ្វើឱ្យប្រាកដថាផ្នែកទាំងអស់ត្រូវបានបំពេញយ៉ាងត្រឹមត្រូវ ហើយព័ត៌មានដែលបានផ្តល់គឺច្បាស់លាស់។ ២.៤.១ ប្រសិនបើសំណើថវិកា មិនទាន់ពេញលេញ សំណើថវិកានោះនឹងត្រូវប្រគល់ទៅ EE, DAE ឬ IAE ដើម្បីស្នើសុំការកែតម្រូវ។
- ២.៥ ប្រសិនបើសំណើថវិកាមានភាពពេញលេញហើយនោះ DCC នឹងស្នើសុំឱ្យសមាជិកក្រុមការងារ វាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) ធ្វើការវាយតំលៃសំណើថវិកា
- ២.៦ GCFAP ផ្តល់អនុសាសន៍មក NDA តាមរយៈ DCC
- ២.៧ NDA ពិនិត្យសំណើថវិកា និងអនុសាសន៍របស់ GCFAP

- ២.៧.១ ប្រសិនបើ FP មិនទាន់ពេញលេញឬមិនទាន់បានអនុម័ត នោះNDA នឹងជូនដំណឹងដល់ DAE/IEA ហើយពួកគេអាចសម្រេចថាតើត្រូវដាក់ស្នើឡើងវិញ ឬបោះបង់សំណើថវិកា (កំណត់ត្រឹម ២ ជុំនៃការពិនិត្យឡើងវិញ ១ ខែក្នុងមួយជុំ
- ២.៧.២ ប្រសិនបើសំណើថវិកាត្រូវបានអនុម័ត នោះNDA នឹងផ្តល់លិខិតគាំទ្រទៅ DAE/IAE

- ២.៨ DAE/IAE បញ្ជូនសំណើថវិកា ជាមួយលិខិតគាំទ្រ និងឯកសារពាក់ព័ន្ធទាំងអស់ទៅ GCF
- ២.៩ NDA ធ្វើបច្ចុប្បន្នភាព និងបង្ហាញលិខិតគាំទ្រលើសំណើថវិកា នៅក្នុងគេហទំព័រផ្ទុកព័ត៌មានរបស់ DCC (អាចមាននាពេលអនាគត)។

**ដំណាក់កាលទី៣៖ ការអនុម័តរបស់ GCF**

- ៣.១ លេខាធិការដ្ឋាន GCF វាយតម្លៃសំណើថវិកា ដោយមានការគាំទ្រពីក្រុមប្រឹក្សាវាយតម្លៃបច្ចេកទេសឯករាជ្យ (ITAP)
- ៣.២ លេខាធិការដ្ឋាន GCF ផ្តល់អនុសាសន៍លើសំណើថវិកា ទៅក្រុមប្រឹក្សាភិបាលរបស់ GCF
- ៣.៣ ក្រុមប្រឹក្សាភិបាល GCF វាយតម្លៃសំណើថវិកា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល និងធ្វើការសម្រេចចិត្ត
- ៣.៤ ក្រុមប្រឹក្សាភិបាល GCF អនុម័តទាំងស្រុង អនុម័តតែមានលក្ខខណ្ឌត្រូវកែតម្រូវ ឬការបដិសេធលើសំណើថវិកាទាំងស្រុង។
- ៣.៥ លេខាធិការដ្ឋាន GCF ជូនដំណឹងដល់ DAE/IAE និង NDA អំពីការសម្រេចចិត្ត។

**ដំណាក់កាលទី៤៖ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តល់សេចក្តីទុកចិត្ត (AMA -Accreditation Master Agreement)**

- ៤.១ ប្រសិនបើសំណើថវិកាត្រូវបានអនុម័តនោះ លេខាធិការដ្ឋាន GCF នឹងធ្វើការជាមួយ NDA ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀង AMA។

**ដំណាក់កាលទី៥៖ អនុវត្ត តាមដាន និងវាយតម្លៃគម្រោង GCF**

- ៥.១ EE នឹងអនុវត្ត និងតាមដានគម្រោងដោយផ្អែកលើក្របខ័ណ្ឌលទ្ធផលគម្រោង និងវាយតម្លៃពាក់កណ្តាលគម្រោងនិងចុងបញ្ចប់គម្រោង ដោយយោងតាមផែនការ M&E ដូចដែលបានស្នើឡើងនៅក្នុងសំណើថវិកា និងក្នុងជំពូកទី ១១
- ៥.២ EE បញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅ IAE/DAE ដើម្បីឱ្យIAE/DAE រៀបចំរបាយការណ៍ប្រចាំឆ្នាំជូន NDA និងលេខាធិការដ្ឋាន GCF។

**ដំណាក់ទី៦៖ ការធ្វើសវនកម្ម និងការបិទគម្រោង**

- ៦.១ នៅពេលគម្រោងត្រូវបានបញ្ចប់ EE និង DAE/IAE នឹងធ្វើការវាយតម្លៃបញ្ចប់គម្រោង និងបិទគម្រោងបន្ទាប់ពីគម្រោងត្រូវបានធ្វើសវនកម្ម។
- ៦.២ ផលិតផល និងសេវាកម្មចំណេះដឹង និងទំនាក់ទំនង ព្រមទាំងវេទិកានឹងត្រូវបានបង្កើតសម្រាប់ជាយុទ្ធសាស្ត្រពេលបញ្ចប់គម្រោង ដោយផ្អែកលើបទពិសោធន៍ និងការអនុវត្តល្អៗសម្រាប់ការចែករំលែកចំណេះដឹង និងការរៀនសូត្រពីគ្នាទៅវិញទៅមក។




រូបភាពទី 15៖ និតិវិធីចេញលិខិតគាំទ្រសម្រាប់ការវាយតម្លៃ និងអនុម័តសំណើថវិកា

| តារាងទី 7៖ និតិវិធីចេញលិខិតគាំទ្រ សម្រាប់ការវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកា។ ដំណាក់កាលនីមួយៗត្រូវបានបង្ហាញនៅក្នុងរូបភាពទី ១៤ និង ១៥ ។ | | | |
|---|---|---|---|
| ដំណាក់កាល | សកម្មភាព | ទំនួលខុសត្រូវ | គំរូ ឬឯកសារផ្សេងៗ |
| ដំណាក់កាលចាប់ផ្តើម៖ NDA តាមរយៈ DCC បង្កើនការយល់ដឹងស្តីពីឱកាសរបស់ GCF តាមរយៈគេហទំព័រ សិក្ខាសាលា ព្រឹត្តិការណ៍នានា និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ | NDA តាមរយៈ DCC ធ្វើយុទ្ធនាការដើម្បីលើកកម្ពស់ការយល់ដឹងសម្រាប់ដៃគូសាធារណៈ ឯកជន និងអង្គការសង្គមស៊ីវិលស្តីពីឱកាសរបស់ GCF តាមរយៈគេហទំព័រ សិក្ខាសាលា ព្រឹត្តិការណ៍នានា និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ | NDA/DCC អាចប្រើប្រធានបទនៅក្នុងសៀវភៅណែនាំប្រតិបត្តិការនេះ ដើម្បីបង្កើតខិតប័ណ្ណផ្សព្វផ្សាយ | ខិតប័ណ្ណផ្សព្វផ្សាយ ស្តីពីឱកាសរបស់ GCF |
| ការពិភាក្សាបឋមជាមួយNDAអំពីគំនិតផ្តួចផ្តើមគម្រោង និង ឯកសារទស្សនទាន | EEs ឬ ប្រតិបត្តិករគម្រោង ត្រូវបានលើកទឹកចិត្តពិភាក្សាជាមួយ NDA/DCC គំនិតនានាដែលមានសក្តានុពលមកលើគម្រោងដែលពួកគេមាន។ | | |
| ដំណាក់កាលទី ១៖ ការរៀបចំឯកសារទស្សនទានដើម្បីដឹងថាតើគម្រោងនេះសាកសមនឹងបន្តវឌ្ឍន | ១.១ ការបញ្ចប់ និងការដាក់ឯកសារទស្សនទានគម្រោងទៅ NDA ជាមួយការបែងចែកតួនាទីរបស់ DAE/IAE | EE និងប្រតិបត្តិករគម្រោង | គំរូឯកសារទស្សនទានក្នុងផ្នែក៩.២ |

| | | | |
|---|---|---|---|
| ភាពនិងសមស្របទៅនឹងតម្រូវការជាតិនិង GCF (ជាគម្រោងមានភាពចាំបាច់ និងគាំទ្រដោយ NDA) ។ សូមពិនិត្យ រូបភាពទី ១៤ ។ | ១.២ NDA បញ្ជាក់ពីការទទួលបានឯកសារទស្សនទាន និងប្រគល់លេខកូដសម្រាប់ CN | NDA | |
| | ១.៣ NDA ស្នើមក DCC ដើម្បីពិនិត្យ CN | NDA តាមរយៈDCC | |
| | ១.៣.១ ក្រុមវាយតម្លៃនៅ DCC ធ្វើការត្រួតពិនិត្យភាពពេញលេញ<br>- CN ប្រគល់មក EE បើសិន CN មិនមានភាពពេញលេញ<br>- បើសិនពេញលេញ DCC ស្នើសុំក្រុមប្រឹក្សាវាយតម្លៃមូលនិធិអាកាសធាតុបៃតង(GCFAP) ឱ្យវាយតម្លៃ CN | DCC | តារាងត្រួតពិនិត្យពេញលេញនិងគំរូវាយតម្លៃក្នុងផ្នែកទី ១០.៤ |
| | ១.៤ GCFAP ផ្តល់អនុសាសន៍ទៅ NDA តាមរយៈ DCC | GCFAP | |
| | ១.៥ NDA ពិនិត្យ CN និងធ្វើការផ្តល់អនុសាសន៍<br>- បើសិនមិនបានអនុម័ត CN ត្រូវបានប្រគល់មក EE ហើយ EE អាចសម្រេចចិត្តធ្វើការដាក់ស្នើឡើងវិញ ឬ បោះបង់ CN<br>- បើសិនបានអនុម័ត នោះ NDA ចេញលិខិតគាំទ្រ (NOL) ទៅ EE | NDA | |
| | ១.៦ EE កំណត់អត្តសញ្ញាណ DAE/IAE ឱ្យធ្វើការជាមួយ បើសិនជាមិនទាន់បានកំណត់អត្តសញ្ញាណពីមុនមកទេ | EE | |
| | ១.៧ DAE/IAE បញ្ជូន CN ទៅ GCF ដើម្បីទទួលបានមតិយោបល់ដំបូងជាមួយការជូនដំណឹងមក NDA | EE, IAE, DAE | |
| | ១.៨ NDA ធ្វើបច្ចុប្បន្នភាព និងបង្ហាញលិខិតមិនជំទាស់ នៅលើគេហទំព័រផ្ទុកព័ត៌មានរបស់DCC | DCC | |
| | ១.៩ ប្រសិនបើ GCF អនុម័ត CN នោះ DAE អាចស្វែងរកថវិកាពីកម្មវិធីគាំទ្រការរៀបចំគម្រោង (PPF) និងប្រតិបត្តិកិច្ចការនេះ។ | GCF and DAE | |

| | | | |
|---|---|---|---|
| ដំណាក់កាលទី ២៖ ការរៀបចំសំណើថវិកាដើម្បីកំណត់ថាតើការរចនាគម្រោងបានចប់សព្វគ្រប់រឺអត់ហើយទំនងជាអាចទទួលបានជោគជ័យ - បច្ចេកទេសនិងហិរញ្ញវត្ថុ ដោយសារតែមានការព្យាយាម (ចាំបាច់)។ សូមមើលលើរូបភាពទី ១៥ ។ | ២.១ សំណើថវិកា ត្រូវបានបញ្ជូនទៅ NDA តាមរយៈ DAE/IAE | DAE/IAE | គំរូសំណើថវិកាអាចស្វែងរកបាននៅគេហទំព័រ GCF |
| | ២.២ NDA ទទួលសំណើថវិកា ពី DAE/IAE | NDA | |
| | ២.៣ NDA ស្នើសុំ DCC ទទួលស្គាល់នូវការទទួលបានឯកសារ FP ប្រគល់លេខកូដ និងពិនិត្យ FP | NDA via DCC | |
| | ២.៣.១ ក្រុមវាយតម្លៃនៅ DCC ធ្វើការត្រួតពិនិត្យភាពពេញលេញ | DCC | |
| | ២.៣.២ FP ប្រគល់ទៅ DAE/IAE បើសិន FP គឺមិនមានភាពពេញលេញ | DCC | |
| | ២.៤ DCC ស្នើសុំ ក្រុមប្រឹក្សាវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) ឱ្យវាយតម្លៃ FP | DCC and GCFAP | |
| | 2.5 GCFAP បានផ្តល់អនុសាសន៍មក NDA តាមរយៈ DCC | GCFAP | លិខិតយល់ព្រម |
| | ២.៦ NDA ពិនិត្យ FP និង អនុសាសន៍របស់ GCFAP | NDA | |
| | ២.៧.១ NDA មិនអនុម័ត និងប្រគល់ FP ទៅ DAE/IAE វិញ និងអាចសម្រេចចិត្តថាតើគួរដាក់ស្នើFPឡើងវិញ ឬបោះបង់ | NDA និង DAE/IAE | |
| | ២.៧.២ NDA អនុម័ត FP និងចេញលិខិតគាំទ្រឱ្យ DAE/IAE | NDA | លិខិតមិនជំទាស់ |
| | ២.៨ DAE/IAE បញ្ជូន FP ទៅ GCF ជាមួយឯកសារគាំទ្រទាំងអស់ | DAE/IAE | |
| | ២.៩ NDA/DCC ធ្វើបច្ចុប្បន្នភាព និងបង្ហាញលិខិតគាំទ្រលើ FP នៅក្នុងគេហទំព័រផ្ទុកព័ត៌មានរបស់ DCC | NDA | |
| **ដំណាក់កាលទី៣៖ ការអនុម័ត GCF** | ៣.១ លេខាធិការដ្ឋាន GCF វាយតម្លៃ FP ដោយមានការគាំទ្រពី ក្រុមប្រឹក្សាវាយតម្លៃបច្ចេកទេសឯករាជ្យ (ITAP) | GCF and ITAP | |
| **ដំណាក់កាលទី៤៖ ការចុះហត្ថលេខាកិច្ចព្រមព្រៀងការទទួលស្គាល់ជាផ្លូវការ** (AMA) | ៤.១ NDA ចុះហត្ថលេខាលើ AMA ជាមួយ GCF | NDA and GCF | |

| | | | |
|---|---|---|---|
| **ដំណាក់កាលទី៥៖ ការអនុវត្ត និង<br>ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ក្រោយការបញ្ជូនសំណើថវិកា** | ៥.១ EE អនុវត្តគម្រោង និង IAE/DAE តាមដានគម្រោង និងធ្វើការវាយតម្លៃពាក់កណ្តាលគម្រោង និងចុងបញ្ចប់គម្រោងដោយយោងទៅតាមផែនការ M&E | | |
| | ៦.១ EE និង IAE/DAE បិទគម្រោងបន្ទាប់ពីគម្រោងត្រូវបានធ្វើសវនកម្មរួច | | |
| **ដំណាក់កាលទី៦៖ សវនកម្ម និងបិទគម្រោង** | ៦.២ DAE រៀបចំសេវាកម្ម និងផលិតចំណេះដឹង និងទំនាក់ទំនង និងវេទិកាដែលជាយុទ្ធសាស្រ្តពេលបញ្ចប់គម្រោងដោយផ្អែកលើបទពិសោធន៍ និងការអនុវត្តល្អៗ | | |




រូបភាពទី 16: សេចក្តីសង្ខេបនៃនីតិវិធីចេញលិខិតគាំទ្រ និងវដ្តគម្រោង GCF សម្រាប់ប្រទេសកម្ពុជាជាមួយនឹងរយៈពេលដែលត្រូវស្នើសុំ

## ១០.៣ ឧបករណ៍ធ្វើសេចក្តីសម្រេចចិត្តដើម្បីផ្តល់អាទិភាពដល់ឯកសារទស្សនទាន និងសំណើថវិកា

ការជូនដំណឹង និងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើភស្តុតាងដើម្បីផ្តល់អាទិភាពដល់សំណើគម្រោងអាចផ្អែកលើវិធីសាស្រ្តដូចខាងក្រោម៖

### A. ការវិភាគអត្ថប្រយោជន៍ និងចំណាយ (CBA)៖

- ការវាយតម្លៃលើការចំណាយ និងអត្ថប្រយោជន៍ បានបង្ហាញជាតម្លៃរូបិយវត្ថុដែលមានគោលបំណងសំខាន់មួយ ពោលគឺប្រសិទ្ធភាពហិរញ្ញវត្ថុ។ ឧទាហរណ៍ អត្រាចំណេញនៃហិរញ្ញវត្ថុ (FIRR) អាចត្រូវបានប្រើជាសូចនាករដើម្បីប្រៀបធៀបជម្រើសផ្សេងៗនៅទូទាំងវិស័យ។

**B. ការវិភាគប្រសិទ្ធភាពចំណាយ (CEA)៖**

- ការចំណាយត្រូវបានអោយតម្លៃជារូបិយវត្ថុ និងអត្ថប្រយោជន៍ដែលគិតជាឯកតារូបវន្ត។
- សម្រាប់អ្នកវិនិយោគដែលផ្តោតលើអត្ថប្រយោជន៍ចំពោះសង្គម អត្រាចំណេញនៃសេដ្ឋកិច្ច (EIRR) អាចត្រូវបានប្រើ ដូចជា ចំនួនការងារបៃតងត្រូវបានបង្កើត ការកែលំអសុខភាព និងការអប់រំ។
- ចាត់ថ្នាក់នៃជម្រើសផ្សេងគ្នាផ្អែកលើការចំណាយដែលសម្រេចបាននូវគោលបំណងដូចគ្នា។
- អនុញ្ញាតសម្រាប់ករណីជាពហុគោលបំណង ឬលក្ខណៈវិនិច្ឆ័យ លុះត្រាតែអាចគណនាចេញជាបរិមាណបាន។

**C. ការវិភាគពហុលក្ខណៈវិនិច្ឆ័យ (MCA)៖**

- ចាត់ថ្នាក់នៃជម្រើសផ្សេងៗដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យអាទិភាពមួយចំនួន (តារាងទី ៨) ក្នុងករណីអត្ថប្រយោជន៍សំខាន់ៗ មិនអាចគណនាចេញជាបរិមាណបាន ដូចជា ការអភិរក្សជីវៈចម្រុះ។
- អនុញ្ញាតឱ្យបញ្ចូលគ្នានូវលក្ខណៈវិនិច្ឆ័យហិរញ្ញវត្ថុ/សេដ្ឋកិច្ចជាមួយបច្ចេកទេស បរិស្ថាន និងសង្គម។ ការវិភាគពហុលក្ខណៈវិនិច្ឆ័យ (MCA) អាចបំពេញបន្ថែមលើ ការវិភាគអត្ថប្រយោជន៍ និងចំណាយ (CBA) ឬការវិភាគប្រសិទ្ធភាពចំណាយ (CEA) ។
- ទិន្នន័យដែលអាចរកបាន គឺជាកត្តាចម្បងដែលនឹងកំណត់ថាគួរើសយកវិធីសាស្ត្រណាមួយមកប្រើប្រាស់។ ក្នុងការអនុវត្តជាក់ស្តែង ការសម្រេចចិត្តនយោបាយប្រហែលជានឹងកំណត់ការជ្រើសរើស និងអាទិភាព។

| តារាងទី ៨៖លក្ខណៈវិនិច្ឆ័យសក្តានុពលសម្រាប់ជ្រើសរើសសំណើគម្រោង | |
|---|---|
| **អាទិភាពនានារបស់ប្រទេស** | **អាទិភាពនានារបស់អ្នកផ្តល់មូលនិធិ** |
| • បរិបទទៅតាមតំបន់ជាក់លាក់ (ឧទា. ភាពបន្ទាន់ ការទទួលយកពីសង្គម)<br>• ការគាំទ្រនយោបាយកម្រិតខ្ពស់និង / ឬអាទិភាពក្នុងតំបន់<br>• គោលបំណងដែលត្រូវបានកំណត់សម្រាប់ផែនការការកាត់បន្ថយ ឬការបន្សាំ (ឧទាហរណ៍ការកាត់បន្ថយភាពក្រីក្រ ឬការកាត់បន្ថយការបញ្ចេញ)<br>• <u>សក្តានុពលសម្រាប់ការផ្លាស់ប្តូរជាទូទៅ ពោលគឺមិនត្រឹមតែគម្រោងតែមួយ</u><br>• អាទិភាព និងអត្ថប្រយោជន៍នានានៃការអភិវឌ្ឍន៍ | • ប្រព័ន្ធ វាស់វែង រាយការណ៍ ផ្ទៀងផ្ទាត់ (MRV) ឬតាមដាន និងវាយតម្លៃ (M&E) រឹងមាំ<br>• សក្តានុពលសម្រាប់ការផ្លាស់ប្តូរជាទូទៅ<br>• បានបញ្ជ្រាបនៅក្នុងគោលនយោបាយជាតិ<br>• មានការចូលរួមពីថវិការបស់ជាតិ<br>• មានការគាំទ្រពីវិស័យឯកជន |

| | |
|---|---|
| • ប្រសិទ្ធភាពចំណាយ<br>• ផលប៉ះពាល់សង្គម<br>• ភាពងាយស្រួលនៃការអនុវត្ត<br>• ការគាំទ្ររបស់អ្នកពាក់ព័ន្ធ<br>• ភាពទាក់ទាញដល់អ្នកផ្តល់មូលនិធិនានា | • សមត្ថភាពស្ថាប័ន និងតម្រូវការសម្រាប់ការអនុវត្តនៃស្ថាប័នអនុវត្ត<br>• ភាពអាចពង្រីកវិសាលភាពបាន និងភាពអនុវត្តបាននៅទីកន្លែងផ្សេង<br>• កម្រិតនៃភាពច្នៃប្រឌិត |

## ១០.៤ គំរូវាយតម្លៃឯកសារទស្សនទាន និងសំណើថវិកាដោយសមាជិក ក្រុមប្រឹក្សាវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP)

សមាជិក GCFAP នឹងប្រើគំរូនេះដើម្បីវាយតម្លៃឯកសារទស្សនទានដែលត្រូវបានដាក់ស្នើដោយ EEs ឬនិងប្រតិបត្តិករគម្រោងដោយផ្អែកលើគំរូ CN ដែលបង្ហាញនៅក្នុងផ្នែក ៩.២ ខាងលើ។ NDA នឹងរៀបចំវគ្គបណ្តុះបណ្តាលជាទៀងទាត់ស្តីពីវិធីប្រើប្រាស់គំរូវាយតម្លៃនេះ សម្រាប់អ្នកជំនាញការមកពី DCC, GSSD និង GCFAP[25] ។

---

**ក្រុមការងារវាយតម្លៃ GCF**

**ទម្រង់វាយតម្លៃសំណើគម្រោង**

| |
|---|
| គម្រោង NDA លេខ៖ *[បំពេញដោយ NDA]* |
| កូដ / គម្រោងអភិវឌ្ឍន៍ជាតិលេខ៖<br>*[ស្រង់ចេញពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ]* |
| ឯកសារម្ចាស់ជំនួយ/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ៖ *[ស្រង់ចេញពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ]* |

| | |
|---|---|
| **ចំណងជើងគម្រោង** | |
| **ប្រតិបត្តិករគម្រោង** | |

[25] *First training was conducted on the 5 July 2019 in Phnom Penh, Cambodia*

| | | | | |
|---|---|---|---|---|
| ស្ថាប័នទទួលបានមូលនិធិដោយផ្ទាល់(DAE) | | | | |
| ស្ថាប័នអន្តរជាតិទទួលបានសេចក្តីទុកចិត្ត (IAE) | | | | |
| កាលបរិច្ឆេទនៃការដាក់ស្នើ | | | | |
| ការបញ្ជាក់ពីការទទួលឯកសារទស្សនទាន | | | | |
| **លក្ខណៈវិនិច្ឆ័យ** | **សំណួរណែនាំ** | **យោងតាមគំរូ CN របស់ GCF** | **ចម្លើយ** | **មតិយោបល់** |
| **១. សនិទានគម្រោង** | ១.១ តើគម្រោងនេះមានសនិទានសមហេតុផលដែរឬទេ? | A.19 ការពិពណ៌នាគម្រោង<br>និង B.1. សនិទានគម្រោង<br>– បញ្ហា និងដំណោះស្រាយ | បាទ/ចាស ☐ទេ ☐ | |
| | ១.២ តើបញ្ហានិងតម្រូវការសំខាន់របស់គម្រោងត្រូវបានកំណត់ និងរកឃើញហើយឬនៅ? | | បាទ/ចាស ☐ទេ ☐ | |
| | ១.៣ តើមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រគម្រោងនេះទេ ឧទា. ការស្ទង់មតិ និងរបាយការណ៍? | | បាទ/ចាស ☐ទេ ☐ | |
| **២. គោលបំណងគម្រោងធៀបនឹងទិន្នន័យដើមគ្រា** | ២.១ តើគោលបំណងគម្រោងត្រូវបានកំណត់ច្បាស់ហើយឬនៅ?<br>២.២ ចំពោះគម្រោងប្រែប្រួលអាកាសធាតុ តើសេណារីយ៉ូមូលដ្ឋានគ្រឹះនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់/ភាពងាយរងគ្រោះត្រូវបានកំណត់ហើយឬនៅ?<br>២.៣ តើគម្រោងនេះទំនងជាធ្វើឱ្យប្រសើរឡើងនូវសេណារីយ៉ូមូលដ្ឋានដែរឬទេ? | B.2. គោលបំណងគម្រោងធៀបនឹងទិន្នន័យដើមគ្រា<br><br>ការពិចារណាលើការបញ្ចូលបញ្ហាយេនឌ័រ និងសង្គម | បាទ/ចាស ☐ទេ ☐ | |
| **៣. ទំនាក់ទំនងគោលនយោបាយនិងការស្របតាម (អាទិភាពថ្នាក់ជាតិ, ភាពជាម្ចាស់ប្រទេស, ការគាំទ្រជាតិ)** | ៣.១ តើគម្រោងនេះស្របជាមួយ និង/ឬភ្ជាប់សកម្មភាពដោយផ្ទាល់ទៅនឹងអាទិភាពយុទ្ធសាស្ត្រ និង/ឬគោលដៅគោល | B.3 លក្ខណៈវិនិច្ឆ័យវិនិយោគ GCF: 5. ភាពជាម្ចាស់ប្រទេស ឧទា. ទំនាក់ទំនងគោល | បាទ/ចាស ☐ទេ ☐ | |

| | | | | |
|---|---|---|---|---|
| | នយោបាយ ដូចជា គោលនយោបាយអភិវឌ្ឍន៍ជាតិ គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុ និង/ឬ គោលនយោបាយផែនការ និងយុទ្ធសាស្ត្រផ្សេងៗទៀត ដូចជា ផែនការតាមវិស័យ ផែនការរួម ឬផែនការថ្នាក់ក្រោមជាតិ?<br>៣.២ តើវាស្របជាមួយ NDC, NAMA ឬ NAP ដែរឬទេ? តើគម្រោងនេះជួយដល់គោលដៅនៃការកាត់បន្ថយ និង/ឬការបន្ស៊ាំដែរឬទេ?<br>៣.៣ តើការគាំទ្រជាតិមានភស្តុតាងគ្រប់គ្រាន់ដែរឬទេ? ឧទា. លិខិតគាំទ្រពីសមភាគីជាតិ (ឧទា. សមភាគីក្រសួងពាក់ព័ន្ធ និងមន្ទីរខេត្ត និង/ឬស្ថាប័នសហគមន៍ផ្សេងទៀត) | នយោបាយនិងការស្របតាម | | |
| **៤. សាវតាស្ថាប័នអនុវត្ត/ស្ថាប័នប្រតិបត្តិ** | ៤.១ តើស្ថាប័នអនុវត្តនិងស្ថាប័នប្រតិបត្តិមានសមត្ថភាព / ជំនាញគ្រប់គ្រាន់/សមស្រប និងមានជំនាញបច្ចេកទេសទាក់ទងនឹងវិសាលភាព និងសមាសធាតុរបស់គម្រោងដែរឬទេ?<br>៤.២ តើពួកគេមានបទពិសោធន៍/ភាពជឿជាក់នៅក្នុងការងារស្រដៀងគ្នាដែរឬទេ? តើពួកគេបានផ្តល់ហេតុផលត្រឹមត្រូវគ្រប់គ្រាន់ហើយឬនៅ?<br>៤.៣ តើពួកគេមានចំណេះដឹង ជំនាញ និងបុគ្គលិកគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងទេ? | ទំព័រមុខនៃគំរូ<br><br>សាវតាស្ថាប័នអនុវត្ត/ស្ថាប័នប្រតិបត្តិ | បាទ/ចាស ☐ទេ ☐ | |

| | | | | |
|---|---|---|---|---|
| **៥. យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ** | ៥.១ តើហានិភ័យ និងវិធីសាស្ត្រដោះស្រាយហានិភ័យទាំងនេះត្រូវបានកំណត់អត្តសញ្ញាណ និងផ្តល់ហេតុផលត្រឹមត្រូវហើយឬនៅ? ឧទា. ហានិភ័យហិរញ្ញវត្ថុ បច្ចេកទេស និងប្រតិបត្តិការ បរិស្ថាននិងសង្គម គោលនយោបាយ និងហានិភ័យផ្សេងៗទៀត។ សូមមើលការវាយតម្លៃហានិភ័យរបស់គម្រោង។ | F. ការគ្រប់គ្រងហានិភ័យ និង ឧបសម្ព័ន្ធទី១ នៃគំរូ CN របស់GCF<br><br>កត្តាហានិភ័យ គម្រោង<br>វិធានការកាត់បន្ថយនិងឧបករណ៍វាយតម្លៃ | បាទ/ចាស ☐ទេ ☐ | |
| **៦. ការពិគ្រោះយោបល់ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ** | ៦.១ តើគម្រោងនេះមានការពិគ្រោះយោបល់គ្រប់គ្រាន់ដោយគិតពិចារណា និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ (រួមទាំងម្ចាស់ជំនួយ វិស័យឯកជន ថ្នាក់ខេត្ត សហគមន៍មូលដ្ឋាន និងសង្គមស៊ីវិល) ដែរឬទេ? | C.4 ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការពិគ្រោះយោបល់ | បាទ/ចាស ☐ទេ ☐ | |
| **៧. ការជាន់/ស្ទួនដែលអាចមាន និងត្រូវដោះស្រាយ (និងទីតាំងសមស្រប)** | ៧.១ តើគម្រោងនេះជាន់លើការងារដែលមានស្រាប់ដែរឬទេ?<br>៧.២ តើមានគម្រោងដែលកំពុងអនុវត្តនៅក្នុងតំបន់មួយ ដោយមានការជួយគាំទ្រពីគម្រោងផ្សេងដែលមានសកម្មភាពដូចគ្នា/ស្រដៀងគ្នាដែរឬទេ? | C.2 ការពន្យល់ហេតុផល | បាទ/ចាស ☐ទេ ☐ | |
| **៨. សមិទ្ធិលទ្ធភាព/ការវាយតម្លៃបច្ចេកទេស** | ៨.១ តើគម្រោងនេះអាចអនុវត្តបានទេផ្អែកលើទិដ្ឋភាពបច្ចេកទេស? តើធាតុចូល (ឧទាហរណ៍ កម្លាំងពលកម្ម សំភារៈ ដឹកជញ្ជូន។ ល។ ) ចំពោះសកម្មភាពគម្រោងអាចនឹងបង្កើតបានលទ្ធផលគម្រោងដែរឺទេ?<br>៨.២ ប្រសិនបើគម្រោងស្នើដំណោះស្រាយបច្ចេកទេសណាមួយ តើវាបានបញ្ជាក់ | B.1 កំណត់បញ្ហានិងដំណោះស្រាយ<br><br>B.3 និង C.3 ស្តីពីនិរន្តរភាពបច្ចេកទេស<br>C.5 ស្តីពីកត្តាហានិភ័យ, វិធានការកាត់បន្ថយ និងឧបករណ៍វាយតម្លៃ | បាទ/ចាស ☐ទេ ☐ | |

| | | | | |
|---|---|---|---|---|
| | ត្រឹមត្រូវថាហេតុអ្វីបានជាបច្ចេកទេសនោះសមស្របបំផុតសម្រាប់គម្រោងនេះដែរឬទេ? | | | |
| **៩. លទ្ធភាពជោគជ័យខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | ៩.១ តើគម្រោងនេះត្រូវបានចាត់ទុកថាមានលទ្ធភាពជោគជ័យផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែរឬទេ? តើមានថវិកាគ្រប់គ្រាន់សម្រាប់រាល់ធាតុចូល/សមាសភាគ និងសកម្មភាពគម្រោងដែរឬទេ?<br>៩.២ តើមានការវិភាគសេដ្ឋកិច្ច និង/ឬការវិភាគហិរញ្ញវត្ថុហើយឬនៅ? | C.5 លក្ខណៈវិនិច្ឆ័យនៃការវិនិយោគ GCF និង C.1 ថវិកាសង្ខេបរបស់គម្រោង និង<br>ការចំណាយទៅតាមសមាសភាគនៃគម្រោង | បាទ/ចាស □ទេ □ | |
| **១០. ការគិតគូរពីបរិស្ថាន និងសង្គម** | ១០.១ តើហានិភ័យសក្តានុពលមកលើបរិស្ថានត្រូវបានគេពិចារណាហើយឬនៅ? តើនឹងមានការការពារបរិស្ថានគ្រប់គ្រាន់ទេ?<br>១០.២ តើហានិភ័យដែលមានសក្តានុពលដល់សង្គមត្រូវបានគេពិចារណាហើយឬនៅ? តើនឹងមានការការពារសង្គមគ្រប់គ្រាន់ទេ? | ឧបសម្ព័ន្ធទី១នៃឯកសារទស្សនទាន GCF: ការការពារបរិស្ថាននិងសង្គម - ការគិតគូរពីបរិស្ថាន និងសង្គម<br>ឧបសម្ព័ន្ធទី១នៃឯកសារទស្សនទាន GCF: កត្តាហានិភ័យគម្រោង វិធានការកាត់បន្ថយ និងឧបករណ៍វាយតម្លៃ | បាទ/ចាស □ទេ □ | |
| **១១. ការគិតគូរពីការបញ្ចូលយេនឌ័រ និងសង្គម** | ១១.១ តើយេនឌ័រ ពិការភាព ការព្រួយបារម្ភរបស់ជនជាតិដើមភាគតិច ស្ត្រី យុវជន កុមារ និងក្រុមងាយរងគ្រោះត្រូវបានគិតគូរគ្រប់គ្រាន់នៅក្នុងគម្រោងនេះហើយឬនៅ? | C.5 ស្តីពីផលប៉ះពាល់ដែលមានសក្តានុពល និងតម្រូវការរបស់អ្នកទទួល<br>ដូចជា ចំនួនប្រជាជនដែលរងផលប៉ះពាល់/ឥទ្ធិពលអាក្រក់<br>ការគិតគូរពីការបញ្ចូលយេនឌ័រនិងសង្គម | បាទ/ចាស □ទេ □ | |
| **១២. ការតាមដាន ការរាយការណ៍ និងការវាយតម្លៃ** | ១២.១ តើដំណើរការតាមដាន រាយការណ៍ និងវាយតម្លៃត្រូវបានបញ្ជាក់គ្រប់គ្រាន់ដែរឬទេ? | D. ការតាមដាន រាយការណ៍ និងវាយតម្លៃ និងក្របខ័ណ្ឌលទ្ធផលគម្រោងជាមួយសូចនាករSMART | បាទ/ចាស □ទេ □ | |

| | | | | |
|---|---|---|---|---|
| | ១២.២ តើមានក្របខ័ណ្ឌលទ្ធផលគម្រោង/ទ្រឹស្តីនៃការផ្លាស់ប្តូរគួរឱ្យពេញចិត្តដែរឬទេ? | | | |
| **១៣. វិធានការដើម្បីនិរន្តរភាព** | ១៣.១ តើមានយុទ្ធសាស្ត្រពេលបញ្ចប់គម្រោង និងភស្តុតាងដែលបង្ហាញថាសកម្មភាពគម្រោងអាចត្រូវបានបន្ត បន្ទាប់ពីការផ្តល់មូលនិធិដល់គម្រោងលែងមាន ដែរឬទេ?<br>១៣.៣ តើការថែទាំ និងការចំណាយសម្រាប់រដ្ឋាភិបាលត្រូវបានបញ្ជាក់គ្រប់គ្រាន់ឬទេ? | B.3 សក្តានុពលនៃការផ្លាស់ប្តូរគំរូ និង C.3 យុទ្ធសាស្ត្រពេលបញ្ចប់គម្រោង វិធានការពង្រីកវិសាលភាព ចម្លងសកម្មភាព និងនិរន្តរភាព | បាទ/ចាស □ទេ □ | |
| **១៤. ផលប៉ះពាល់ដែលមានសក្តានុពល *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៤.១ ការកាត់បន្ថយ៖ តើគម្រោងបានរួមចំណែកដល់ការផ្លាស់ប្តូរទៅរកមាគ៌ាអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការបញ្ចេញកាបូនទាប ឧទាហរណ៍ ឧស្ម័នកាបូនិចត្រូវបានកាត់បន្ថយដោយសារតែគម្រោង និង/ឬប្រសិទ្ធភាពចំណាយពោលគឺចំណាយលើគម្រោងសរុបបើប្រៀបធៀបទៅនឹងការកាត់បន្ថយឧស្ម័នកាបូនិច<br><br>១៤.២ ការបន្ស៊ាំ៖ ការចូលរួមចំណែកក្នុងការបង្កើនការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងធន់នឹងអាកាសធាតុ ឧទា. ចំនួនអ្នកទទួលផលដោយផ្ទាល់/ប្រយោល និង/ឬអ្នកទទួលផលទាក់ទងនឹងចំនួនប្រជាជនសរុប និងតំបន់ទទួលបានអត្ថប្រយោជន៍សរុប។ | B.3 ផលប៉ះពាល់ដែលមានសក្តានុពល<br>- ការអនុវត្តធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |
| **១៥. សក្តានុពលនៃការផ្លាស់ប្តូរគំរូ *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៥.១ តើគម្រោងនេះមានសក្តានុពលជះឥទ្ធិពលក្នុងរយៈពេលវែង និងលើសពី | B.3 ការផ្លាស់ប្តូរគំរូ - ការអនុវត្តរំពឹងទុកធៀប | បាទ/ចាស □ទេ □ | |

| | | | | |
|---|---|---|---|---|
| | វិសាលភាពរបស់សំណើគម្រោង (សក្តានុពលសម្រាប់ការពង្រីកវិសាលភាព និងចម្លងសកម្មភាពរបស់គម្រោង, ចំណេះដឹងនិងការរៀនសូត្រ, ការចូលរួមចំណែកក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងផែនការសាធារណៈ, ការប្រមូលផ្តុំតួអង្គផ្សេងៗ ការអភិវឌ្ឍទីផ្សារ និងការផ្លាស់ប្តូរទីផ្សារ)? | នឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | | |
| **១៦. សក្តានុពលនៃការអភិវឌ្ឍដោយចីរភាព *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៦.១ តើគម្រោងនេះមានបរិបទជាក់លាក់ដែលផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងយេនឌ័រដែរឬទេ? (ឧទាហរណ៍៖ រួមមានសុខភាពសាធារណៈប្រសើរឡើង សន្តិសុខថាមពល និងប្រព័ន្ធអេកូឡូស៊ីព្រៃឈើប្រសើរឡើង) | B.3 ការអនុវត្តរំពឹងទុកធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |
| **១៧. តម្រូវការរបស់អ្នកទទួល *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៧.១ តើគម្រោងកាត់បន្ថយកម្រិតនៃការប្រឈមនឹងហានិភ័យអាកាសធាតុ និងកម្រិតនៃភាពងាយរងគ្រោះ និងដោះស្រាយតម្រូវការ និងភាពងាយរងគ្រោះរបស់អ្នកទទួលផលដែរឬទេ? តើការវាយតម្លៃភាពងាយរងគ្រោះត្រូវបានធ្វើឡើងហើយឬនៅ? | B.3 ការអនុវត្តរំពឹងទុកធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |
| **១៨. ភាពជាម្ចាស់ ប្រទេស *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៨.១ តើមានភស្តុតាងបញ្ជាក់ពីភាពជាម្ចាស់ប្រទេស ស្របតាមគោលនយោបាយដែលមានស្រាប់ សមត្ថភាពក្នុងការអនុវត្តគម្រោង និងការចូលរួមជាមួយអ្នកពាក់ព័ន្ធនានាដែរឬទេ? | B. 3 ការអនុវត្តរំពឹងទុកធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |

| | | | | |
|---|---|---|---|---|
| **១៩. ប្រសិទ្ធផល និងប្រសិទ្ធភាព *[សម្រាប់គម្រោង GCF តែប៉ុណ្ណោះ]*** | ១៩.១ តើគម្រោងនេះមានលទ្ធភាពជោគជ័យខាងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយពិចារណាលើថវិកាស្នើសុំសរុប ថវិកាដែលរំពឹងឬច្បាស់ថានឹងទទួលបានចំណូល និងការចូលរួមវិភាគទានផ្សេងៗដែលអាចមានដែរឬទេ? | B.3 ការអនុវត្តរំពឹងទុកធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |
| **២០. ស្ថានភាពនៃការវិភាជន៍ថវិកា [សម្រាប់តែគម្រោងត្រៀម (Readiness) របស់ GCF ប៉ុណ្ណោះ សូមមើលទំព័របន្ទាប់]** | ២០.១ តើស្ថានភាពនៃការវិភាជន៍ថវិការបស់កម្ពុជាមានអ្វីខ្លះ? តើមានមូលនិធិគ្រប់គ្រាន់ទេដល់គម្រោងត្រៀមសម្រាប់ឆ្នាំដែលគម្រោងកំពុងស្វែងរកការអនុវត្ត? យោងតាមកម្មវិធីប្រចាំប្រទេសកម្ពុជាសម្រាប់ GCF | A. ពិនិត្យជាមួយ NDA, ការអនុវត្តរំពឹងទុកធៀបនឹងលក្ខណៈវិនិច្ឆ័យនៃការវិនិយោគ | បាទ/ចាស □ទេ □ | |
| **២១. សេចក្តីសន្និដ្ឋាន /មតិយោបល់** | | | | |
| **២២. សមាជិកនៃក្រុមការងារវាយតម្លៃ GCF** | គួរយល់ព្រម □ គួរយល់ព្រមតែស្នើឱ្យកែសម្រួល□<br>មិនគួរយល់ព្រម □<br>ឈ្មោះ: ហត្ថលេខា<br>កាលបរិច្ឆេទ | | | |

**សេចក្តីសង្ខេប**

- ដើម្បីទទួលបានភាពជាម្ចាស់ និងការគាំទ្រខ្លាំង ភាគីពាក់ព័ន្ធសំខាន់ៗដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ក្នុងខែមេសាឆ្នាំ ២០១៩ បានចូលរួមចំណែកក្នុងការរៀបរៀងនីតិវិធីប្រតិបត្តិការស្តង់ដារ (SOP) សម្រាប់នីតិវិធីចេញលិខិតគាំទ្រក្នុងការវាយតម្លៃ និងអនុម័ត ឯកសារទស្សនទាន (CN) និង សំណើថវិកា (FP) ដូចដែលបានពិពណ៌នានៅក្នុងរូបភាពទី ១៤ ១៥ និង១៦ ព្រមទាំងតារាងទី ៦ ។
- ដោយមានការគាំទ្រពីក្រុមការងារវាយតម្លៃមូលនិធិអាកាសធាតុបៃតង (GCFAP) តាមរយៈ DCC នីតិវិធីចេញលិខិតគាំទ្រនឹងអនុញ្ញាតឱ្យ NDA ធានាថា រាល់ CN និងFP មានភាពអនុលោមតាមផែនការអភិវឌ្ឍជាតិ គោលដៅអាកាសធាតុ និងអាទិភាពរបស់ប្រទេសកម្ពុជា។
- EEs, DAEs និងប្រតិបត្តិករគម្រោងនឹងតម្រូវឱ្យប្រើប្រាស់គំរូ CN កម្ពុជា ដែលបានកែសម្រួលពីគំរូ CN របស់ GCF ដើម្បីដាក់ស្នើ CN របស់ពួកគេដូចដែលបានបង្ហាញនៅក្នុងផ្នែកទី ៩.២ ។
- សមាជិក GCFAP នឹងប្រើប្រាស់គំរូវាយតម្លៃ CN នៅក្នុងផ្នែកទី ១០.៤ ដើម្បីវាយតម្លៃ CN និងផ្តល់អនុសាសន៍ដល់ NDA តាមរយៈ DCC ។

## ជំពូកទី ១១៖ ការតាមដាន និងការវាយតំលៃការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានអាកាសធាតុ

ជំពូកនេះពិពណ៌នាអំពីវិធីដែលគម្រោង/កម្មវិធីដែលផ្តល់មូលនិធិដោយ GCF នឹងត្រូវបានតាមដាននិងវាយតម្លៃស្របតាមផែនការ M&E ដែលបានស្នើនៅក្នុងសំណើគម្រោង GCF។ EE និង DAE/IAE នឹងធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីធានាថារាល់សកម្មភាពទាំងអស់ត្រូវបានអនុវត្តស្របតាមផែនការការងារ ពេលវេលា និងថវិកា ដើម្បីផ្តល់នូវលទ្ធផលទាំងអស់ដូចដែលបានស្នើឡើងនៅក្នុងក្របខណ្ឌលទ្ធផលគម្រោងដូចដែលបានបង្ហាញនៅក្នុងតារាងទី៩។ ការគ្រប់គ្រងបែបកែសម្រួលនឹងត្រូវអនុវត្ត ដើម្បីធានាថារាល់សកម្មភាពត្រូវបានធ្វើឡើងដើម្បីដោះស្រាយ និងជំនះនូវហានិភ័យនិងបញ្ហាដែលបានជួបប្រទះក្នុងការអនុវត្តគម្រោង/កម្មវិធី។ ការវិភាគហានិភ័យ និងយុទ្ធសាស្ត្រកាត់បន្ថយដែលបានស្នើឡើងនៅក្នុងឯកសារគម្រោងនឹងយកមកប្រើប្រាស់ជាគោលសម្រាប់នាំផ្លូវ។ ដូចមានចែងក្នុងផ្នែកទី ១០.១ DAE និង IAE ចាំបាច់ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ NDA មុនពេលចេញលិខិតគាំទ្រដើម្បីធានាថា៖ ១) មន្ត្រីរបស់ DCC នឹងក្លាយជាតំណាងនៅក្នុងគណៈកម្មាធិការដឹកនាំគម្រោង GCF និង ii) រាល់របាយការណ៍វឌ្ឍនភាពទាំងអស់នឹងត្រូវបញ្ជូនទៅ NDA តាមរយៈ DCC ។

**ការត្រួតពិនិត្យពាក់កណ្តាលគម្រោង៖** ការត្រួតពិនិត្យពាក់កណ្តាលគម្រោងឯករាជ្យនឹងត្រូវធ្វើឡើងនៅពេលគម្រោងអនុវត្តបានពាក់កណ្តាល។ ការត្រួតពិនិត្យពាក់កណ្តាលគម្រោងនឹងក្លាយជាព្រឹត្តិការណ៍សំខាន់ មួយនៃគម្រោង ហើយនឹងត្រូវឈរលើលក្ខណៈវិនិច្ឆ័យវាយតម្លៃរបស់ GCF ស្តីពីភាពពាក់ព័ន្ធ សុពលភាពនៃការរៀបចំ ការអនុវត្ត (ប្រសិទ្ធភាព ប្រសិទ្ធផល និងទាន់ពេលវេលា) ប្រសិទ្ធផល និរន្តរភាព និងការតម្រង់ទិស ផលប៉ះពាល់ (រូបភាពទី១៧)។ ការត្រួតពិនិត្យនេះនឹងលើកឡើងពីបញ្ហាដែលទាមទារឱ្យមានការសម្រេចចិត្ត និងមានសកម្មភាព ការកែសម្រួលសេចក្តីត្រូវការ និងបទពិសោធន៍លើការរៀបចំគម្រោង ការអនុវត្ត និងការគ្រប់គ្រង។ ការរកឃើញ និងអនុសាសន៍ពីការត្រួតពិនិត្យពាក់កណ្តាលគម្រោង (MTR) នឹងត្រូវផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ។ លើសពីនេះទៀត លិខិតឆ្លើយតបរបស់អ្នកគ្រប់គ្រងគម្រោងចំពោះអនុសាសន៍ ដែលទទួលបានពីការត្រួតពិនិត្យពាក់កណ្តាលគម្រោង រួមជាមួយផែនការសម្រាប់កែតម្រូវ នឹងត្រូវរៀបចំ ហើយស្ថានភាពនៃការអនុវត្តនឹងត្រូវតាមដាន។ លក្ខខណ្ឌការងារយោងសម្រាប់ MTR នឹងត្រូវរៀបចំដោយ DAE ឬIAE ដោយពិគ្រោះយោបល់ជាមួយស្ថាប័នប្រតិបត្តិ និងស្ថាប័នផ្តល់មូលនិធិ (GCF)។ ការជ្រើសរើស ទីប្រឹក្សាដើម្បីអនុវត្ត MTR នឹងត្រូវអនុលោមតាម គោលនយោបាយ/បទប្បញ្ញត្តិលទ្ធកម្ម របស់DAE ឬ IAE ។

**ការវាយតំលៃបញ្ចប់គម្រោង៖** ការការវាយតម្លៃបញ្ចប់គម្រោងដោយឯករាជ្យនឹងត្រូវធ្វើឡើងក្នុងរយៈពេល ៣ខែ មុនកាលបរិច្ឆេទបញ្ចប់គម្រោង។ ការវាយតម្លៃនេះនឹងផ្តោតលើបញ្ហាដូចគ្នានឹងការត្រួតពិនិត្យពាក់កណ្តាលគម្រោង។ ទោះយ៉ាងណាក៏ដោយ ការវាយតម្លៃបញ្ចប់នេះនឹងពិនិត្យមើលសូចនាករនៃផលប៉ះពាល់ និងលទ្ធផលនៃនិរន្តរភាព រួមទាំងការចូលរួមចំណែកក្នុងការសម្រេចបាននូវគោលដៅគម្រោងទាំងមូល។ បន្ថែមលើបទពិសោធន៍ដែលទទួលបាន ការវាយតំលៃបញ្ចប់គម្រោងនឹងផ្តល់ជាអនុសាសន៍សម្រាប់ តាមដានសកម្មភាព និងការគ្រប់គ្រងពាក់ព័ន្ធផ្សេងៗ សកម្មភាពយុទ្ធសាស្ត្រ និង/ឬសកម្មភាពគោលនយោបាយនានា។ ការឆ្លើយតបការគ្រប់គ្រងចំពោះបញ្ហាដែលបានលើកឡើងនៅចុងបញ្ចប់នៃការវាយតម្លៃគម្រោង

នឹងត្រូវរៀបចំឡើងដោយប្រធានគម្រោងនៃ EE ។ ការត្រួតពិនិត្យគុណភាពនៃរបាយការណ៍វាយតម្លៃនឹងត្រូវធ្វើឡើងដោយអង្គភាពគ្រប់គ្រងគម្រោង (PMU) ដោយពិគ្រោះយោបល់ជាមួយស្ថាប័នអនុវត្តន៍ និងប្រតិបត្តិ។ បន្ទាប់មក របាយការណ៍នេះនឹងត្រូវបញ្ជូនទៅគណៈកម្មាធិការដឹកនាំគម្រោងដើម្បីពិនិត្យនិងផ្តល់យោបល់បន្ថែម។ របាយការណ៍ចុងក្រោយនឹងត្រូវបញ្ជូនទៅ GCF ។ បទពិសោធន៍ដែលទទួលបាននឹងត្រូវកត់ត្រា និងបង្កើតទៅជាផលិតផលនិងសេវាកម្មចំណេះដឹង និងការទំនាក់ទំនងដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក និងផ្លាស់ប្តូរបទពិសោធន៍រវាងប្រទេសកំពុងអភិវឌ្ឍន៍មួយនិងប្រទេសកំពុងអភិវឌ្ឍន៍មួយទៀត។

| តារាងទី ១៖ ក្របខ័ណ្ឌលទ្ធផលគម្រោង | | | | | | |
|---|---|---|---|---|---|---|
| សមិទ្ធិផល | លទ្ធផល | សូចនាករ SMART | ទិន្នន័យដើមគ្រា(Baseline) | ទិសដៅ | ការផ្ទៀងផ្ទាត់ | ការសន្មត |
| សមិទ្ធិផលទី១ | លទ្ធផល ១.១ | | | | | |
| | លទ្ធផល ១.២ | | | | | |
| | លទ្ធផល ១.៣ | | | | | |
| | | | | | | |
| សមិទ្ធិផលទី២ | លទ្ធផល ២.១ | | | | | |
| | លទ្ធផល ២.២ | | | | | |
| | លទ្ធផល ២.៣ | | | | | |
| | | | | | | |
| | | | | | | |




រូបភាពទី 17: ក្របខ័ណ្ឌសម្រាប់ធ្វើការត្រួតពិនិត្យពាក់កណ្តាលគម្រោង និងបញ្ចប់គម្រោង

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ សទ្ទានុក្រម[26]

**ការផ្តល់សេចក្តីទុកចិត្ត (Accreditation)៖** គឺជាដំណើរការដែលស្ថាប័ននានាត្រូវបង្ហាញពីសមត្ថភាពក្នុងការគ្រប់គ្រងធនធានរបស់ GCF យោងទៅតាមបទដ្ឋាន និងលក្ខខណ្ឌដែលបានកំណត់ដោយ GCF និងមានចែងនៅក្នុងពាក្យស្នើសុំសេចក្តីទុកចិត្ត។

**ស្ថាប័នទទួលបានសេចក្តីទុកចិត្ត (Accredited Entities - AE)៖** គឺជាស្ថាប័នដែលក្រុមប្រឹក្សាភិបាល GCF បានផ្តល់សេចក្តីទុកចិត្ត ដើម្បីអាចទទួលបានមូលនិធិពី GCF។ ស្ថាប័នទាំងនេះ នឹងឆ្លងកាត់ដំណើរការនៃការវាយតម្លៃផ្តល់សេចក្តីទុកចិត្ត ដើម្បីពិនិត្យថា ស្ថាប័នទាំងនេះពិតជាមានសមត្ថភាពរឹងមាំក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងការពារគម្រោងនិងកម្មវិធី កុំឱ្យមានហេតុប៉ះពាល់ដល់បរិស្ថាន ឬសង្គម។ ស្ថាប័នទទួលបានសេចក្តីទុកចិត្ត អាចជាស្ថាប័នថ្នាក់ជាតិ ថ្នាក់តំបន់ ឬពហុភាគី ព្រមទាំងអាចជាស្ថាប័នរដ្ឋាភិបាល ស្ថាប័នមិនមែនរដ្ឋាភិបាល និងស្ថាប័នឯកជន។

**ការបន្សាំ (Adaptation) ៖** សំដៅលើការសម្របរបស់ប្រព័ន្ធអេកូឡូស៊ី សង្គម និងសេដ្ឋកិច្ច តាមរយៈការបង្កើតភាពធន់របស់សហគមន៍មនុស្ស និងប្រព័ន្ធអេកូឡូស៊ីនៃធម្មជាតិ ដើម្បីសម្រួល ឬកាត់បន្ថយការខូចខាត ឬអត្ថប្រយោជន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

**ការរៀបចំផែនការបន្សាំ (Adaptation Planning) ៖** ជាការកំណត់អាទិភាពបន្សាំ និងការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់ដោះស្រាយអាទិភាពបន្សាំជាបន្តបន្ទាប់ ប្រកបដោយភាពរស់រវើក និងការកែលម្អជាប្រចាំ។ GCF ផ្តល់ការគាំទ្រលើដំណើរការរៀបចំផែនការបន្សាំ សម្រាប់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិង/ឬតាមវិស័យ និងអាចចូលរួមចំណែកក្នុងការសម្រេចបានទស្សនវិស័យជាតិរួមមួយសម្រាប់កសាងភាពធន់នឹងអាកាសធាតុ។

**ការប្រែប្រួលអាកាសធាតុ (Climate Change) ៖** ជាការប្រែប្រួលតួលេខមធ្យមនៃស្ថានភាពធាតុអាកាស និងការប្រែប្រួលអាកាសធាតុជាធម្មជាតិ ដែលបានអង្កេតមើលក្នុងរយៈពេលវែង ជាទូទៅក្នុងរយៈពេល ៣០ឆ្នាំ ដោយសារសកម្មភាពរបស់មនុស្ស ទោះផ្ទាល់ឬប្រយោលក្តី ដែលបានផ្លាស់ប្តូរសមាសភាពបរិយាកាសសកល។

**ហិរញ្ញប្បទានអាកាសធាតុ (Climate Finance) ៖** សំដៅលើលំហូរមូលនិធិពីបណ្តាប្រទេសអភិវឌ្ឍន៍ទៅប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ដោះស្រាយការប្រែប្រួលអាកាសធាតុ រួមមាន ការទទួលបាន ការស្រូបយក និងការគ្រប់គ្រងថវិកាសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈយន្តការពហុភាគីទ្វេភាគី វិស័យឯកជន ប្រាក់កំចីសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ជំនួយឥតសំណង និងសហហិរញ្ញប្បទាន។

**កម្មវិធីប្រចាំប្រទេស (Country Programme) ៖** កម្មវិធីប្រចាំប្រទេសសម្រាប់ GCF គឺជាឯកសាររស់ ដែលបង្ហាញពីបញ្ជីគម្រោង/កម្មវិធីកំពុងរៀបចំរបស់ប្រទេសមួយសម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

[26] *Partly extracted from the guidelines for NDAs or focal points available at Annex XIII of GCF/B.08/45.*

ហើយដែលត្រូវការការគាំទ្រពីGCF។ ឯកសារនេះបង្ហាញពីផែនការសកម្មភាព ដែលរៀបរាប់លម្អិតពីវិធីដែលគម្រោងនិងកម្មវិធីនឹងត្រូវបង្កើត អង្គភាពដៃគូ តម្រូវការមូលនិធិត្រៀម និងតម្រូវការការគាំទ្រដល់ការរៀបចំគម្រោង។

**ដៃគូអនុវត្តគម្រោង (Delivery Partners)** ៖ ជាស្ថាប័នដែលបានជ្រើសរើសដោយស្ថាប័នជាតិទទួលបន្ទុក (National Designated Authority) ឬជនបង្គោលសម្រាប់អនុវត្តសកម្មភាពគម្រោងត្រៀម និងសកម្មភាពគាំទ្រដល់ការរៀបចំគម្រោង (Readiness and Preparatory Support Programme)។ ដៃគូអនុវត្តគម្រោងមានតួនាទីបង្កើតសំណើគម្រោងត្រៀម អនុវត្តនិងតាមដានគម្រោង គ្រប់គ្រងការធានាទំនុកចិត្ត រាយការណ៍ពីវឌ្ឍនភាព និងការវាយតម្លៃបញ្ចប់គម្រោង។ ដៃគូអនុវត្តគម្រោងអាចជាស្ថាប័នទទួលបានសេចក្តីទុកចិត្ត (Accredited Entity) ឬជាស្ថាប័នដែលបានពិនិត្យឃើញថាមានសមត្ថភាព គ្រប់គ្រាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ តាមលក្ខខណ្ឌតម្រូវរបស់ GCF ។

**ការទទួលមូលនិធិដោយផ្ទាល់ (Direct Access)** ៖ សំដៅដល់ការទទួលបានធនធានដោយផ្ទាល់ពី GCF តាមរយៈស្ថាប័នទទួលបានសេចក្តីទុកចិត្ត ថ្នាក់ជាតិ ឬថ្នាក់តំបន់ ដើម្បីយកមកអនុវត្តគម្រោង/កម្មវិធីដោយមិនចាំបាច់ឆ្លងកាត់អន្តរការីទ្វេភាគី និងពហុភាគីឡើយ។

**ស្ថាប័នទទួលមូលនិធិដោយផ្ទាល់ (Direct Access Entities – DAE)** ៖ សំដៅដល់ស្ថាប័ននានាដែលបានដាក់ពាក្យស្នើសុំសេចក្តីទុកចិត្ត ដូចជា ស្ថាប័នថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យបញ្ជូនលិខិតឧទ្ទេសនាមពីស្ថាប័នជាតិទទួលបន្ទុក (NDA) ឬជនបង្គោល ដោយភ្ជាប់ជាមួយនឹងឯកសារស្នើសុំរបស់ពួកគេ។ ស្ថាប័នដែលបានទទួលសេចក្តីទុកចិត្ត ឬចង់ស្នើសុំក្លាយជាស្ថាប័នទទួលបានសេចក្តីទុកចិត្ត មានសិទ្ធិទទួលបានការគាំទ្រលើកម្មវិធីត្រៀម តាមការស្នើសុំរបស់ស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោល។

**ស្ថាប័នប្រតិបត្តិ (Executive Entity – EE)** ៖ សំដៅដល់ស្ថាប័នមានបទពិសោធ៍ (ដូចជា ស្ថាប័នសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល) ដែលនឹងទទួលបានមូលនិធិសម្រាប់អនុវត្ត និងតាមដានគម្រោង ឬកម្មវិធី។

**អង្គភាពប្រតិបត្តិគម្រោង(Executing Entity)** ៖ សំដៅដល់អង្គភាពទទួលខុសត្រូវលើការប្រតិបត្តិគម្រោង ឬកម្មវិធី ដែលទទួលបានមូលនិធិពី GCF។

**ការបញ្ជាក់ចំណាប់អារម្មណ៍ (Expression of Interest)**៖ ជាលិខិតដែលចេញដោយស្ថាប័នជាតិទទួលបន្ទុក ដល់ស្ថាប័នដែលទទួលបានសេចក្តីទុកចិត្ត ដើម្បីឱ្យមានការរៀបចំឯកសារទស្សនទានគម្រោងសម្រាប់ GCF (ជាជម្រើសមួយដែលស្ថាប័នជាតិទទួលបន្ទុក(NDA) អាចអនុវត្ត)។

**សុវត្ថិភាពបរិស្ថាន និងសង្គម (Environmental and Social Safeguards – ESS)** ៖ ជាសំណុំលក្ខខណ្ឌ ដែលមានគោលបំណងដោះស្រាយហានិភ័យបរិស្ថាន និងសង្គមសំខាន់ៗ នៅក្នុងការអនុវត្តសម្មភាពដែលបានផ្តល់មូលនិធិដោយ GCF។ GCF បានអនុវត្តប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គមអន្តរកាល ខណៈពេលដែលប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមពេញលេញ (ESMS) កំពុងរៀបចំ។ ជាវិធានការអនុវត្តដើម្បីការពារនិងកាត់បន្ថយគ្រោះថ្នាក់ចំពោះមនុស្សនិងបរិស្ថាន ដែលអាចកើតមានដោយសារគម្រោង/កម្មវិធី ដែលទទួលបានមូលនិធិពី GCF។

**បទដ្ឋានជានា (Fiduciary Standards)៖** សំដៅលើលក្ខខណ្ឌតម្រូវមូលដ្ឋាន និងលក្ខខណ្ឌតម្រូវពិសេសរបស់ GCF ដែលស្ថាប័នទទួលបានសេចក្តីទុកចិត្តនានា និងដៃគូអនុវត្តគម្រោងត្រៀម ត្រូវប្រតិបត្តិ អាស្រ័យតាមប្រភេទនៃសកម្មភាព ដែលផ្តល់មូលនិធិដោយ GCF។ បទដ្ឋានជានាបឋមរបស់ GCF មាននៅក្នុងឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចលេខ GCF/B.07/11។

**វិធីសាស្ត្រផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់ (Fit-for-Purpose Accreditation Approach)៖** ជាវិធីសាស្ត្រផ្សេងៗពីគ្នាក្នុងការផ្តល់សេចក្តីទុកចិត្ត អាស្រ័យទៅតាមទំហំ និងប្រភេទ នៃសកម្មភាព និងសមត្ថភាពរបស់ស្ថាប័នប្រតិបត្តិ ដែលអាចចូលរួមចំណែកសម្រេចបានគោលបំណងរបស់ GCF។ វិធីសាស្ត្រវាយតម្លៃលើ ប្រភេទ វិសាលភាព និងហានិភ័យរបស់សកម្មភាពដែលបានគ្រោងទុក ធៀបទៅនឹងបទដ្ឋានជានា និងប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គម។

**សំណើថវិកា (Funding Proposal – FP)៖** សំដៅដល់សំណើគម្រោងដែលស្ថាប័នទទួលសេចក្តីទុកចិត្តរៀបចំ ដើម្បីស្នើសុំថវិកាពី GCF យកមកអនុវត្តគម្រោង/កម្មវិធី។

**គោលនយោបាយយេនឌ័រ (Gender Policy)៖** គោលនយោបាយយេនឌ័ររបស់ GCF ( សូមអានឧបសម្ព័ន្ធទី៥) មានគោលបំណងជានាប្រសិទ្ធិភាពក្នុងការប្រើប្រាស់មូលនិធិរបស់ GCF ដើម្បីលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងឈានទៅដល់ការសម្រេចបានលទ្ធផលកាន់តែប្រសើរឡើងក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព។ គោលនយោបាយយេនឌ័រត្រូវបានអនុវត្តចំពោះរាល់សកម្មភាពទាំងឡាយ ដែលអនុវត្តដោយស្ថាប័នថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ ស្ថាប័នសាធារណៈ ឬឯកជន ឬស្ថាប័ននានាដែលប្រើប្រាស់ធនធានរបស់មូលនិធិអាកាសធាតុបៃតង។

**មូលនិធិអាកាសធាតុបៃតង (Green Climate Fund – GCF)៖** គឺជាយន្តការហិរញ្ញវត្ថុ ដែលបង្កើតឡើងដោយអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ សម្រាប់គាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ លើការផ្លាស់ប្តូរទៅរកការអនុវត្តមាគ៌ាអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងបង្កើនភាពធន់នឹងអាកាសធាតុ។ មូលនិធិអាកាសធាតុបៃតងបានផ្តល់ការគាំទ្រដល់គម្រោង កម្មវិធី គោលនយោបាយ និងសកម្មភាពផ្សេងៗ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក UNFCCC។

**លក្ខខណ្ឌវិនិយោគ (Investment criteria)៖** ជាបណ្តុំលក្ខខណ្ឌដែលប្រើប្រាស់ដោយ GCF សម្រាប់វាយតម្លៃសំណើថវិកាដែលស្ថាប័នទទួលសេចក្តីទុកចិត្តបានដាក់ជូន។

**ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (Mitigation)៖** សំដៅដល់ការខិតខំប្រឹងប្រែងកាត់បន្ថយ ឬបញ្ចៀសការបំភាយឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។

**ស្ថាប័នអន្តរជាតិទទួលសេចក្តីទុកចិត្ត ឬស្ថាប័នអន្តរជាតិទទួលមូលនិធិ (International Accredited Entity – IAE)៖** ជាស្ថាប័នដែលទទួលសេចក្តីទុកចិត្តពី GCF ហើយអាចកៀរគរ និងគ្រប់គ្រងថវិការបស់ GCF ក្នុងកម្រិតសកលលោកបាន ដូចជា ទីភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិ ធនាគារអភិវឌ្ឍន៍ពហុភាគី និងស្ថាប័នអន្តរជាតិដទៃទៀត។

**សកម្មភាពជាតិកាត់បន្ថយសមស្រប (Nationally Appropriate Mitigation Action – NAMA)៖** UNFCCC បានបង្កើតដំណើរការរៀបចំសកម្មភាពជាតិកាត់បន្ថយសមស្រប ដើម្បីសម្របសម្រួលការរៀបចំផែនការ

កាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត។

**ផែនការជាតិបន្សាំ (National Adaptation Plan – NAP) ៖** UNFCCC បានបង្កើតដំណើរការរៀបចំផែនការជាតិបន្សាំ ដើម្បីសម្របសម្រួលការរៀបចំផែនការបន្សាំនៅក្នុងប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងអភិវឌ្ឍន៍ផ្សេងៗទៀត។

**ស្ថាប័នជាតិទទួលបន្ទុក (National Designated Authorities – NDAs) ឬជនបង្គោល (Focal Points)៖** NDAs គឺជាស្ថាប័នរដ្ឋាភិបាលដែលសម្របសម្រួលរាល់ទំនាក់ទំនងរវាងប្រទេសនីមួយៗ និង GCF ។ NDAs មានតួនាទីផ្តល់ដំបូន្មានជាយុទ្ធសាស្ត្រដល់រាល់សកម្មភាពទាំងឡាយរបស់ GCF នៅក្នុងប្រទេសរបស់ខ្លួន ព្រមទាំងផ្តល់ព័ត៌មានអំពីអាទិភាពរបស់ប្រទេស ដែលគាំទ្រដល់ការអភិវឌ្ឍដែលធន់នឹងអាកាសធាតុ និងបញ្ចេញកាបូនតិច។

**ការចូលរួមចំណែករបស់ជាតិ (Nationally Determined Contributions – NDCs) ៖** NDCs គឺជាមធ្យោបាយចម្បងរបស់រដ្ឋាភិបាលក្នុងការប្រាស្រ័យទាក់ទងជាមួយអន្តរជាតិ អំពីជំហានដែលពួកគេនឹងអនុវត្តដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅក្នុងប្រទេសរបស់ពួកគេ។ NDCs ឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ប្រទេសនីមួយៗ ក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ ដោយគិតគូរពីសមត្ថភាព និងបរិបទរបស់ជាតិ។ ប្រទេសមួយចំនួន ក៏បង្ហាញពីវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការគាំទ្រដែលពួកគេត្រូវការ ឬពួកគេនឹងផ្តល់ជូនដល់ប្រទេសដទៃទៀត សម្រាប់ឈានទៅរកមាគ៌ាអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច និងបង្កើនភាពធន់នឹងអាកាសធាតុ។

**លិខិតឧទ្ទេសនាម (Nomination letter) ៖** ជាលិខិតដែលចេញដោយស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោល ទៅឱ្យស្ថាប័នដែលមានបំណងស្នើសុំសេចក្តីទុកចិត្តពី GCF។ ស្ថាប័នដែលដាក់ពាក្យស្នើសុំសេចក្តីទុកចិត្ត ត្រូវភ្ជាប់លិខិតឧទ្ទេសនាម ជាមួយនឹងពាក្យស្នើសុំ។

**លិខិតគាំទ្រ (No Objection Letter – NOL) ៖** ជាលិខិតដែលចេញដោយស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោល ដែលបញ្ជាក់ពីការគាំទ្រដល់សំណើថវិកា ដែលដាក់ជូនដោយស្ថាប័នទទួលបានសេចក្តីទុកចិត្ត ក្នុងនាមប្រទេសរបស់ខ្លួន។

**កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ (Paris Agreement) ៖** កិច្ចព្រមព្រៀងទីក្រុងប៉ារីស គឺជាកិច្ចព្រមព្រៀងអន្តរជាតិ ដែលបានអនុម័តនៅក្នុងសម័យប្រជុំលើកទី២១ នៃសន្និសីទបណ្តាភាគី (COP២១) នៃអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានប្រព្រឹត្តទៅកាលពីខែវិច្ឆិកាឆ្នាំ ២០១៥ នៅទីក្រុងប៉ារីស៍ ប្រទេសបារាំង។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ មានគោលបំណងលើកស្ទួយការឆ្លើយតបជាសកលចំពោះការគំរាមកំហែងនៃការប្រែប្រួលអាកាសធាតុដោយរក្សាការកើនឡើងនៃសីតុណ្ហភាពពិភពលោកឱ្យនៅទាបជាង ២ អង្សាសេ លើកម្រិតមុនសម័យឧស្សាហកម្ម គិតត្រឹមសតវត្សរ៍នេះ និងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការកើនឡើងសីតុណ្ហភាពបន្ថែមទៀតឱ្យទាបជាង ១,៥ អង្សាសេ។ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍បានចូលជាធរមាននៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៦។ ប្រទេសកម្ពុជាបានចុះហត្ថលេខា និងផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦។

**អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change – UNFCCC)** ៖ ជាក្របខណ្ឌសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ដែលបានចរចានៅក្នុងកិច្ចប្រជុំកំពូលផែនដីនៅទីក្រុងរីយ៉ូដឺហ្សាណេរ៉ូ (Rio de Janeiro) កាលពីខែមិថុនា ឆ្នាំ១៩៩២ និងបានចាប់ផ្តើមអនុវត្តកាលពីខែមីនា ឆ្នាំ១៩៩៤។

## ឧបសម្ព័ន្ធ ២ ៖ វិធានការមានសក្តានុពលសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើផែនទីបង្ហាញផ្លូវ NDC, ព្រមទាំងគម្រោង CDM និង JCM

**អាទិភាពលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (Mitigation priorities)៖** NCSD នឹងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធនានាលើការរៀបចំសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅតាមវិស័យនីមួយៗ។ ដូចបានបង្ហាញខាងក្រោម ការអនុវត្តសកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ មានវឌ្ឍនភាពជាច្រើន ប៉ុន្តែសកម្មភាពទាំងនេះចាំបាច់ត្រូវច្របាច់បញ្ចូលគ្នា។ សកម្មភាពសំខាន់ៗដែលបានកំណត់មានដូចជា ការវាយតម្លៃសកម្មភាពបច្ចុប្បន្ន ការកំណត់សកម្មភាពថ្មីៗ បញ្ញាប្រឈមនានា ការវាយតម្លៃតម្រូវការ ការវាយតម្លៃគោលនយោបាយ ការសង្ខេប និងការធ្វើសមាហរណកម្ម។

**ការវាយតម្លៃ (Assessment)៖** ជាការកំណត់តួលេខជាក់ស្តែង ឬតួលេខរំពឹងទុកនៃផលប៉ះពាល់របស់សកម្មភាពដែលកំពុងមានស្រាប់ (ដូចជា គម្រោង និងយន្តការ ជាដើម)។ ក្នុងករណីមិនមានប្រព័ន្ធវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV) ដូចពេលបច្ចុប្បន្ន សកម្មភាព ផែនការ គោលនយោបាយ និងគម្រោងនានា បានត្រឹមតែរាយការណ៍ និងដាក់បញ្ចូលទៅក្នុងឯកសារ NDC និង BUR។ ការងារមួយចំនួនទៀតរំពឹងថានឹងត្រូវអនុវត្តនៅពេលដែលប្រព័ន្ធ MRV បានដាក់ដំណើរការឱ្យទាន់យ៉ាងហោចណាស់មុនពេលដែលត្រូវរៀបចំ និងបញ្ជូនឯកសារខាងលើនៅវគ្គក្រោយទៀត។

សេចក្តីសង្ខេបអំពីសកម្មភាពនានានៅក្នុងNDC ក្តីរំពឹងទុកក្នុងការកាត់បន្ថយគិតជា Gg CO2eq និងគិតជាភាគរយនៅក្នុងឆ្នាំ២០៣០ ធៀបជាមួយទិន្នន័យដើមគ្រា ការបន្សុីជាមួយសកម្មភាពនានារបស់ CCAP និងភស្តុតាងនៃការរីកចម្រើន ត្រូវបានបង្ហាញដូចខាងក្រោម។

**តារាងទី 10៖សក្តានុពលនៃការកាត់បន្ថយ ស្របជាមួយនឹងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ (CCAPs) និងវឌ្ឍនភាពការងារ**

| វិស័យ | សកម្មភាពអាទិភាព | GHG Red[27] | ផែនការសកម្មភាពប្រែប្រួលអាកាសធាតុ និងក្រសួង | ភស្តុតាងនៃវឌ្ឍនភាពការងារ |
|---|---|---|---|---|
| វិស័យថាមពល | តភ្ជាប់បណ្តាញអគ្គិសនីថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ វារីអគ្គិសនី ជីវម៉ាស និងជីវឧស្ម័ន) និងតភ្ជាប់ថាមពលកកើតឡើងវិញវិមជ្ឈការទៅនឹងបណ្តាញជាតិ | ១,៨០០ (១៦%) | ក្រសួងរ៉ែ និងថាមពល<br>• ការអភិវឌ្ឍនូវសមាសធាតុបច្ចេកវិទ្យានៃថាមពលកកើតឡើងវិញសម្រាប់វិស័យឧស្សាហកម្ម<br>• ការលើកកម្ពស់ការបង្កើតថាមពលកកើតឡើងវិញនៅនឹងកន្លែង និងរួមគ្នាសម្រាប់វិស័យឧស្សាហកម្មក៏ដូចជាតំបន់សេដ្ឋកិច្ចពិសេស | • បទប្បញ្ញត្តិស្តីពីលក្ខខណ្ឌទូទៅសម្រាប់ភ្ជាប់ប្រភពផលិតថាមពលព្រះអាទិត្យ PV ទៅនឹងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៃបណ្តាញអគ្គិសនីជាតិ (២០១៨)<br>• សួនឧទ្យានថាមពលព្រះអាទិត្យ ១០ មេហ្គាវ៉ាត់បានដំណើរការពេញលេញ ៦០ មេហ្គាវ៉ាត់កំពុងដំណើរការសាងសង់ និង១៨០ មេហ្គាវ៉ាត់កំពុងគ្រោងនឹងរៀបចំដំណើរការ។<br>• គម្រោងយន្តការអភិវឌ្ឍន៍ស្អាត និងឥទានកាបូនរួមគ្នា |

[27] Gg CO2eq and % in the year 2030 compared to the baseline.

| | | | | |
|---|---|---|---|---|
| | | | • សាកល្បង និងរៀបចំឯកសារយុទ្ធសាស្ត្រសម្រាប់បំលែងកាកសំណល់ឧស្សាហកម្មទៅជាថាមពល<br>• វាយតម្លៃសក្តានុពលនៃការប្រើប្រាស់ថាមពលកកើតឡើងវិញនៅក្នុងវិស័យឧស្សាហកម្ម។ | |
| | បណ្តាញអគ្គិសនីល្អបំផុតមានដូចជាប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ប្រព័ន្ធវារីអគ្គិសនី (pico, mini and macro) | | | • ផ្សងប្រកបដោយនិន្នភោព សកម្មភាពជាតិកាត់បន្ថយសមស្រប(NAMA)(2015-17) |
| | ការលើកកម្ពស់ប្រសិទ្ធភាពថាមពលពីអ្នកប្រើប្រាស់បង្ហស់ចុងក្រោយ។ | | | • គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ (២០១៩) |
| វិស័យផលិតកម្ម | លើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញ និងប្រើប្រាស់ប្រសិទ្ធភាពថាមពលសម្រាប់រោងចក្រកាត់ដេរ រោងម៉ាស៊ីនកិនស្រូវ និងឡូឥដ្ឋ។ | ៧២៧ (៧%) | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>• អនុវត្តការវាយតម្លៃតម្រូវការបច្ចេកវិទ្យាសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យថាមពល | • ប្រសិទ្ធភាពថាមពល NAMA ក្នុងឧស្សាហកម្មកាត់ដេរ<br>• គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥ ២០២៥ (២០១៨) -<br>• សេណារីយ៉ូឧស្សាហកម្មបៃតងសម្រាប់ប្រទេសកម្ពុជា -វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល (២០១៨)<br>• ការអភិវឌ្ឍការបញ្ចេញកាបូនតិចសម្រាប់ផលិតភាពដោយមូនិធិបរិស្ថានសកល |
| វិស័យដឹកជញ្ជូន | លើកកម្ពស់ការដឹកជញ្ជូនសាធារណៈ | ៣៩០ (៣%) | | |
| | ជំរុញនូវប្រតិបត្តិការនិងថែទាំយានយន្តតាមរយៈការត្រួតពិនិត្យយានយន្តនិងការបើកបរសន្សំសំចៃនិង បង្កើនការប្រើប្រាស់ថេយន្តអគ្គិសនីនិងកង់។ | | ក្រសួងសាធារណការ និងដឹកជញ្ជូន<br>• បង្កើនការថែទាំ និងត្រួតពិនិត្យយានយន្ត | ផ្សេងៗ |
| ផ្សេងៗ | ការលើកកម្ពស់ប្រសិទ្ធភាពថាមពលសម្រាប់អាគារ និងចង្ក្រានឲ្យមានប្រសិទ្ធិភាពជាងមុន | ១៥៥ (១%) | ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>• ការអភិវឌ្ឍការអនុវត្តធនធាននិងថាមពលឲ្យល្អបំផុតសម្រាប់ឧស្សាហកម្មនិងសហគ្រាសធុនតូចនិងមធ្យម | • គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ (២០១៩) |
| | កាត់បន្ថយការបញ្ចេញឧស្ម័នពីកាកសំណល់តាមរយៈការប្រើប្រាស់ | | | គម្រោងយន្តការអភិវឌ្ឍន៍ស្អាត |

| | | | | |
|---|---|---|---|---|
| | ឡជីវឧស្ម័ននិងផុងចម្រោះទឹក | | | |
| | ការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ប្រព័ន្ធធារាសាស្ត្រនិងអំពូលសូឡា | | | |
| ការសន្សំសរុប | | ៣,១០០ (២៧%) | | |
| ស្របតាមកម្មវិធីព្រៃឈើជាតិ(ឆ្នាំ ២០១០-២០២៩) ប្រទេសកម្ពុជាខិតខំពង្រីក និងថែរក្សាគម្របព្រៃឈើឱ្យបាន៦០ ភាគរយនៃផ្ទៃដីសរុប ពេលគឺកើនពីអត្រា៥៧ ភាគរយក្នុងឆ្នាំ ២០១០ | | ៤.៧ tco2eq ក្នុង១ឆ្នាំសម្រាប់ចាប់ពី៥លានហិចតា | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• បង្កើតនិងអនុវត្តបទបញ្ញានិងយន្តការស្តីពីរេដបូក | • យុទ្ធសាស្ត្ររេដបូកជាតិ(២០១៧)<br>• កំរិតយោងព្រៃឈើដែលបានដាក់ជូនក្នុងឆ្នាំ ២០១៦ និងត្រូវបានវាយតម្លៃដោយ UNFCCC នៅឆ្នាំ ២០១៧<br>• NFMS / MRV ជាមួយទិន្នន័យសកម្មភាព ប្រើប្រាស់ដី (ឆ្នាំ២០០៦ ដល់ឆ្នាំ២០១៨) និងកត្តាបំភាយឧស្ម័នសម្រាប់វិស័យព្រៃឈើ<br>• គម្រោង<br>- គម្រោងរេដបូកក្នុងជួរភ្នំក្រវាញខាងត្បូង<br>- គ្រោងរេដបូកទំរីង<br>- គម្រោងរេដនៅក្នុងដែនជម្រកសត្វព្រៃកែវសីម៉ា<br>- គម្រោងរេដនៅក្នុងសហគមន៍ព្រៃឈើខេត្តឧត្តរមានជ័យនៃប្រទេសកម្ពុជា(ផ្អាកសកម្មភាព) |

ប្រភព៖ ការវិភាគរបស់ក្រុមការងារ NDC

ទន្ទឹមនឹងនេះ ប្រទេសកម្ពុជាបានរៀបចំគម្រោងមួយចំនួននៅក្រោមយន្តការអភិវឌ្ឍន៍ស្អាត (CDM) រួមមានដូចខាងក្រោម៖

តារាងទី 11៖ បញ្ជីគម្រោង CDM នៅក្នុងប្រទេសកម្ពុជា

| ឈ្មោះរបស់សកម្មភាពគម្រោងយន្តការអភិវឌ្ឍន៍ស្អាត | ប្រភេទនៃគម្រោង | ព័ត៌មានអំពីបច្ចេកវិទ្យា | កាលបរិច្ឆេទ | ការប៉ាន់ស្មានការកាត់បន្ថយការបញ្ចេញឧស្ម័នប្រចាំឆ្នាំ )tCO2 / ឆ្នាំ( | ការកាត់បន្ថយការបញ្ចេញឧស្ម័នសុពលភាពប្រចាំឆ្នាំ )tCO2 / ឆ្នាំ( |
|---|---|---|---|---|---|
| គំរោងវារីអគ្គិសនីកំចាយ | វារីអគ្គិសនី | អាងស្តុកទឹកថ្មី | ០៨/១០/២០១៣ | ២៨១,៣៤៨ | ៣៧០,៤៩៦ |
| គម្រោងវារីអគ្គិសនីកម្ពុជាស្ទឹងអាតៃ | វារីអគ្គិសនី | អាងស្តុកទឹកថ្មី | ១៩/១២/២០១២ | ២៦៦,៤៧២ | ២៦៦,៤៧២ |
| គម្រោងវារីអគ្គិសនីស្ទឹងតាតៃ | វារីអគ្គិសនី | អាងស្តុកទឹកថ្មី | ១៤/១២/២០១២ | ៥៦៣,០៧៤ | ៥៦៣,០៧៤ |
| គម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម | វារីអគ្គិសនី | អាងស្តុកទឹកថ្មី | ២១/០៨/២០១២ | ៧០១,១៩៩ | ៧០១,១៩៩ |
| គម្រោងជីវឧស្ម័ននៅ MH Bio-Ethanol Distillery ប្រទេសកម្ពុជា | ជីវឧស្ម័ន | កាក់សំណល់កសិកម្ម | ១៦/០២/២០១២ | ៥៨,១៤៦ | ៥២,៨៣១ |

| ឈ្មោះរបស់សកម្មភាពគម្រោងយន្តការអភិវឌ្ឍន៍ស្អាត | ប្រភេទនៃគម្រោង | ព័ត៌មានអំពីបច្ចេកវិទ្យា | កាលបរិច្ឆេទ | ការប៉ាន់ស្មានការកាត់បន្ថយការបញ្ចេញឧស្ម័នប្រចាំឆ្នាំ )tCO2 / ឆ្នាំ( | ការកាត់បន្ថយការបញ្ចេញឧស្ម័នសុពលភាពប្រចាំឆ្នាំ )tCO2 / ឆ្នាំ( |
|---|---|---|---|---|---|
| **គម្រោងជីវឧស្ម័ន W2E Siang Phong នៅកម្ពុជា** | ជីវឧស្ម័ន | កាក់សំណល់កសិកម្ម | ០៧/០៤/២០១២ | ២៦,៥៩២ | ២៧,១២១ |
| **គម្រោងផលិតថាមពលកំដៅស៊ីម៉ងត៍កំពត (KCC-WHG)** | ថាមពលកំដៅដែលចេញពីកាកសំណល់/ការប្រើប្រាស់ហ្គាស | ខ្សែសង្វាក់ផលិតកម្មស៊ីម៉ងត៍ | ១៧/០៤/២០០៩ | ១៧,១០៧ | ១៧,២៤៩ |
| **រោងចក្រផលិតថាមពលជីវដោយថាមពលមេតាននៅរោងម៉ាស៊ីនចិញ្ចឹមសត្វសំរោងធំនៃប្រទេសកម្ពុជា** | ជីវឧស្ម័ន | កាកសំណស់ចេញពីសត្វ | ០៣/១២/២០០៨ | ៥,៥៩៣ | ៦,៧៩២ |
| **គម្រោងឡជីវឧស្ម័ន TTY នៅប្រទេសកម្ពុជា** | ជីវឧស្ម័ន | កាក់សំណល់កសិកម្ម | ០៣/០៩/២០០៨ | ៥០,០៣៦ | ៦៦.៤០២ |
| **គម្រោងថាមពលអង្កាមAngkor Bio Cogen** | ជីវឧស្ម័ន | អង្កាម | ១០/០៨/២០០៦ | ៥១,៦២០ | ៣៩,៩៨១ |
| **ការបំលែងកាកសំណល់ POA ទៅជាថាមពលដោយប្រើប្រាស់ឧស្ម័នជីវម៉ាស់នូវសកម្មភាពក្នុងកម្មវិធីអាស៊ីអាគ្នេយ៍LDCs នៅប្រទេសកម្ពុជា** | ជីវឧស្ម័ន | ការបញ្ចេញឧស្ម័នពីកាកសំណល់ | ១៤/០៣/២០១៦ | ៥៤៩ | ៦០១ |
| **PoA Water Kiosks in Cambodia – CPA 4** | ស្ថានីយ៍ប្រព្រឹត្តិកម្មទឹកខ្នាតតូច | ការបន្សុទ្ធទឹក | ០៥/១២/២០១៦ | ៧,៣២១ | |

ប្រភព៖ **BUR** (2020)

លើសពីនេះ ប្រទេសកម្ពុជាបានចុះកិច្ចព្រមព្រៀងសហការជាមួយប្រទេសជប៉ុនក្នុងក្របខណ្ឌគម្រោងឥណទានកាបូនរួមគ្នា (JCM) ដែលមានគម្រោងមួយចំនួនដូចខាងក្រោម។ គួរកត់សម្គាល់ថា បរិមាណកាត់បន្ថយឧស្ម័នដែលបានផ្ទៀងផ្ទាត់របស់គម្រោងនៅក្រោមយន្តការ JCM នេះ រួមទាំងវិស័យព្រៃឈើ អាចយកទៅប្រើប្រាស់ជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ប្រទេសជប៉ុនក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅលើឆាកអន្តរជាតិ និងជាផ្នែកមួយនៃសកម្មភាពជាតិកាត់បន្ថយសមស្របរបស់ប្រទេសកម្ពុជាផងដែរ។

តារាងទី 12៖បញ្ជីគម្រោងឥណទានកាបូនរួមគ្នា

| សកម្មភាពកាត់បន្ថយ | ស្ថាប័នអនុវត្ត | ស្ថានភាពគម្រោង | រយៈពេល | វិស័យ | បរិមាណកាត់បន្ថយឧស្ម័នរំពឹងទុកប្រចាំឆ្នាំ ($tCO_2$) | ប្រភេទឧស្ម័ន |
|---|---|---|---|---|---|---|
| ការប្រើប្រាស់អំពូល LED ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងការប្រើប្រាស់បណ្តាញឥតខ្សែ | ក្រុមហ៊ុនមីណេបៀ ខូអិលធីឌី OCIC សាលាខេត្តសៀមរាប អាជ្ញាធរអប្សរា | បានបញ្ចប់ | ខែមករា ឆ្នាំ ២០១៦ដល់ខែធ្នូ ២០១៨ | វិស័យថាមពល | ៣,៥៩០ | កាបូនឌីអុកស៊ីត ($CO_2$) |
| ការប្រើប្រាស់បន្ទះសូឡាដែលមានទំងន់ស្រាលបំផុតសម្រាប់បង្កើតថាមពលនៅគម្រោងសាលាអន្តរជាតិ | សាជីវកម្ម Asian Gateway<br>សាលាអន្តរជាតិភ្នំពេញ | បានបញ្ចប់ | ខែកុម្ភៈ ឆ្នាំ ២០១៦ ដល់ខែកញ្ញា ឆ្នាំ ២០១៦ | វិស័យថាមពល | ១៤៩ | កាបូនឌីអុកស៊ីត ($(CO)_2$) |
| ការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យអានុភាព១មេកា វ៉ាត់ (1MW) និងម៉ាស៊ីនបង្កក មានប្រសិទ្ធិភាពខ្ពស់នៅក្នុងផ្សារទំនើបធំៗ | អ៊ីអនម៉លខូអិលធីឌី ក្រុមហ៊ុនអ៊ីអនម៉ល (ខេមបូឌា) ខូអិលធីឌី។ | បានបញ្ចប់ | ខែវិច្ឆិកា ឆ្នាំ ២០១៦ ដល់ ខែឧសភាឆ្នាំ ២០១៨ | វិស័យថាមពល | ១,៦៨៨ | កាបូនឌីអុកស៊ីត ($CO_2$) |
| ការសន្សំសំចៃអគ្គិសនីដោយប្រើ Inverter នៅក្នុងម៉ាស៊ីនចែកចាយទឹកនៅក្នុងរោងចក្រផលិតទឹកស្អាត | Metawater Co., Ltd. រដ្ឋាករទឹកស្វយ័តភ្នំពេញ | បានបញ្ចប់ | ខែមេសា ឆ្នាំ ២០១៦ ដល់ខែឧសភា ឆ្នាំ ២០១៨ | វិស័យថាមពល | ៤០៧ | មេតាន ($CH_4$) |
| គម្រោងផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យខេត្ត | ធនាគារអភិវឌ្ឍន៍អាស៊ី | មិនទាន់បានចាប់ផ្តើម | គម្រោងនឹងចាប់ផ្តើមនៅខែ កក្កដា ឆ្នាំ ២០១៩ ដល់ខែមិថុនា ឆ្នាំ ២០២១ | វិស័យថាមពល | ៦,៣៧១ | កាបូនឌីអុកស៊ីត $CO_2$ |

| | | | | | | |
|---|---|---|---|---|---|---|
| គម្រោងថាមពលពន្លឺព្រះអាទិត្យ ១.៥ មេកាវ៉ាត់ នៅខេត្តកំពង់ធំ | ក្រុមហ៊ុន Asian Gateway Corporation<br><br>ក្រុមហ៊ុន SOMA Energy Co., Ltd | មិនទាន់បានចាប់ផ្តើម | មិនទាន់បានកំណត់ | វិស័យថាមពល | ៨៣១ | កាបូនឌីអុកស៊ីត $CO_2$ |

ប្រភព៖ BUR ( 2020 )

## ឧបសម្ព័ន្ធ ៣ ៖ គោលការណ៍ណែនាំរបស់ GCF ស្តីពីវិធីសាស្ត្រវាយតម្លៃផ្តល់សេចក្តីទុកចិត្តសម្រាប់គោលបំណងជាក់លាក់ (Fit-For-Purpose Accreditation Approach)

### ក. គោលបំណង និងវិសាលភាពនៃវិធីសាស្ត្រវាយតម្លៃផ្តល់សេចក្តីទុកចិត្តសម្រាប់គោលបំណងជាក់លាក់

គោលការណ៍ណែនាំដំបូងស្តីពីដំណើរការវាយតម្លៃផ្តល់សេចក្តីទុកចិត្តត្រូវបានអនុម័តដោយសេចក្តីសម្រេច លេខ B.07/02 ដែលបានបង្កើតឡើង ដើម្បីសិក្សាថា ស្ថាប័នស្នើសុំ ៖ ក. អាចឆ្លើយតបទៅនឹងបទដ្ឋានជានាមូលដ្ឋាន និងបទដ្ឋានជានាពិសេសដែលសមស្រប របស់ GCF និង ខ.អាចមានសមត្ថភាពគ្រប់គ្រងហានិភ័យសុវត្ថិភាពបរិស្ថាន និងសង្គម ស្របតាមគោលការណ៍ ESS របស់ GCF និងវិធីសាស្ត្រផ្អែកលើហានិភ័យ។ ជាជាងប្រើប្រាស់វិធីសាស្ត្រតែមួយសម្រាប់រាល់សំណើទាំងអស់ គោលការណ៍ណែនាំស្តីពីដំណើរការវាយតម្លៃផ្តល់សេចក្តីទុកចិត្ត សម្រាប់គោលបំណងជាក់លាក់ (យោងសេចក្តីសម្រេចលេខ GCG/B.08/02) ពន្យល់អំពីវិធីវាយតម្លៃបទដ្ឋានជានា និងគោលការណ៍ ESS របស់ GCF ព្រមទាំងរៀបរាប់អំពីលក្ខណៈវិនិច្ឆ័យដែលស្ថាប័ននៃប្រទេសកម្ពុជាចាំបាច់ត្រូវគោរពតាម ដើម្បីទទួលបានសេចក្តីទុកចិត្តពី GCF។

គោលបំណងរបស់វិធីសាស្ត្រវាយតម្លៃផ្តល់សេចក្តីទុកចិត្តសម្រាប់គោលបំណងជាក់លាក់ ដែលតម្រូវទៅតាមប្រភេទ វិសាលភាព និងហានិភ័យនានា នៃសកម្មភាពដែលបានស្នើឡើង មានដូចខាងក្រោម៖

ក) បង្កលក្ខណៈឱ្យ GCF សម្រេចគោលបំណងរបស់ខ្លួន តាមរយៈការចូលរួមរបស់ស្ថាប័នចម្រុះ ដូចជា ស្ថាប័នអន្តរជាតិ តំបន់ ជាតិ ក្រោមជាតិ និងស្ថាប័នឯកជន ជាដើម។

ខ) ទទួលស្គាល់ថាស្ថាប័ននីមួយៗមានការរៀបចំ និងដំណើរការខុសៗគ្នា (ឧទាហរណ៍ ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ជាដើម) និងត្រូវគោរពតាមលក្ខខណ្ឌផ្សេងៗគ្នា ស្របទៅតាមវិសាលភាពរំពឹងទុក នៃសកម្មភាពរបស់ស្ថាប័ន ដែលបានដាក់សំណើសុំប្រើប្រាស់ធនធានរបស់ GCF

គ) ជៀសវាងបង្កើតដំណើរវាយតម្លៃផ្តល់សេចក្តីទុកចិត្ត ដែលស្មុំញ៉ាំ វែងឆ្ងាយ និងមិនចាំបាច់សម្រាប់ស្ថាប័ននានា ដែលនឹងមានតិចតួច ឬគ្មានហានិភ័យហិរញ្ញវត្ថុ បរិស្ថាន និងសង្គម។

ដំណើរការផ្តល់សេចក្តីទុកចិត្ត នឹងពិចារណាលើវិសាលភាព និងប្រភេទ (ពោលគឺ ឧបករណ៍ហិរញ្ញវត្ថុ) នៃហិរញ្ញវត្ថុដែលស្ថាប័នចង់ស្នើសុំប្រើប្រាស់ ក៏ដូចជាប្រភេទនៃសកម្មភាពគ្រោងទុកផងដែរ។ វិធីសាស្ត្រនេះនឹងធានាថា សមត្ថភាពអនុលោមតាមបទដ្ឋានជានា និងសមត្ថភាពពាក់ព័ន្ធនឹងការគ្រប់គ្រង ESS របស់ស្ថាប័នស្នើសុំនៅប្រទេសកម្ពុជា គឺសមស្របជាមួយកម្រិតជានា និងកម្រិតហានិភ័យមិនមែនហិរញ្ញវត្ថុ (ពោលគឺបរិស្ថាន និងសង្គម) ដែល GCF នឹងត្រូវជួបប្រទះដោយសារសកម្មភាពរបស់ស្ថាប័នទទួលសេចក្តីទុកចិត្ត និងអន្តរការីនានា។

ការវាយតម្លៃផ្តល់សេចក្តីទុកចិត្តសម្រាប់គោលបំណងជាក់លាក់ ត្រូវអនុវត្តនៅពេលទទួលបានសំណើសុំ និងព័ត៌មានគាំទ្រ ដូចជា បទពិសោធន៍ ជាដើម ដែលស្ថាប័នស្នើសុំ ត្រូវផ្តល់ជូនក្នុងកំឡុងពេល

នៃការដាក់ពាក្យស្នើសុំ។ បន្ទាប់ពីស្ថាប័នទាំងនោះបានទទួលសេចក្ដីទុកចិត្ត រាល់បទពិសោធន៍របស់ស្ថាប័ននេះដែលរួមចំណែកដល់ការសម្រេចបានគោលបំណងរបស់ GCF អាចត្រូវបានពិចារណា នៅពេលមានការពិនិត្យឡើងវិញអំពីស្ថានភាពទទួលបានសេចក្ដីទុកចិត្តរបស់ស្ថាប័ននេះ។




រូបភាព A3៖ វិធីសាស្ត្រវាយតម្លៃផ្ដល់សេចក្ដីទុកចិត្តសម្រាប់គោលបំណងជាក់លាក់នៅប្រទេសកម្ពុជា

## ខ. ការអនុលោមតាមបទដ្ឋានធានាដោយស្ថាប័ននៅក្នុងប្រទេសកម្ពុជា

ការវាយតម្លៃទៅលើស្ថាប័នកម្ពុជាធៀបនឹងបទដ្ឋានធានារបស់GCFនឹងត្រូវពិចារណាយោងទៅតាមប្រភេទនៃហានិភ័យធានា វិសាលភាពនៃសកម្មភាពគ្រោងទុក និងប្រភេទស្ថាប័ន (សូមមើលក្នុងរូបភាព A2)។

**i. ប្រភេទនៃហានិភ័យធានា៖** បទដ្ឋានធានារបស់ GCF (ដែលមានចែងនៅក្នុងសេចក្ដីសម្រេច B.07/02) បានបែងចែករវាងប្រភេទផ្សេងៗគ្នានៃហានិភ័យធានា អាស្រ័យលើប្រភេទនៃសកម្មភាព និងប្រភេទឧបករណ៍ហិរញ្ញវត្ថុនីមួយៗ ដែលស្ថាប័នកម្ពុជាចង់ស្នើសុំ។ រាល់ស្ថាប័នទាំងអស់ត្រូវវាយតម្លៃធៀបនឹងបទដ្ឋានធានាមូលដ្ឋាន ចំណែកបទដ្ឋានធានាពិសេស នឹងអនុវត្តចំពោះតែស្ថាប័ន ដែលនឹងអនុវត្តសកម្មភាពពាក់ព័ន្ធដូចខាងក្រោម៖

a) **ការគ្រប់គ្រងគម្រោង៖** ក្នុងករណីស្ថាប័នកម្ពុជាដែលនឹងអនុវត្តគម្រោងនានា ការវាយតម្លៃនឹងត្រូវពិនិត្យលើសមត្ថភាពគ្រប់គ្រងគម្រោងរបស់ស្ថាប័ននោះ។ ក្នុងករណីស្ថាប័នដែលនឹងបន្តចាត់ចែងមូលនិធិ ក្នុងទម្រង់ជាជំនួយឥតសំណង ប្រាក់កម្ចី ឬចម្រុះគ្នា ការវាយតម្លៃនឹងពិនិត្យមើលសមត្ថភាពសមស្របរបស់ស្ថាប័នកម្ពុជាក្នុងការត្រួតពិនិត្យសកម្មភាព ពង្រឹងអភិបាលកិច្ច និងមានតម្លាភាពធៀបនឹងលក្ខខណ្ឌតម្រូវចំពោះបទដ្ឋានធានានៅក្នុងប្រភេទនេះ។

b) **ការផ្តល់ជំនួយឥតសំណង និង/ឬការវិភាជមូលនិធិ៖** សំណុំលក្ខណៈវិនិច្ឆ័យនេះ នឹងត្រូវអនុវត្ត ចំពោះស្ថាប័នកម្ពុជាណាដែលនឹងបន្តចាត់ចែងមូលនិធិ ក្នុងទម្រង់ជាជំនួយឥតសំណង តាមរយៈ យន្តការផ្តល់ជំនួយ ឬការវិភាជមូលនិធិ។

c) **ការផ្តល់ប្រាក់កម្ចី និង/ឬចម្រុះគ្នា៖** សំណុំលក្ខណៈវិនិច្ឆ័យនេះ នឹងអនុវត្តចំពោះស្ថាប័នហិរញ្ញវត្ថុ កម្ពុជា ឬស្ថាប័នផ្សេងទៀតដែលនឹងបន្តចាត់ចែងមូលនិធិ ក្នុងទម្រង់ជាប្រាក់កម្ចីតាមរយៈការផ្តល់ ប្រាក់កម្ចី ឬចម្រុះគ្នា (ដូចជា ការប្រៀបចប់បញ្ចូលធនធាន និងការរៀបចំធនធានជាដំណាក់កាល បន្តបន្ទាប់) រួមជាមួយនឹងធនធានពីប្រភពផ្សេងទៀត។

ii. **វិសាលភាពនៃសកម្មភាពគ្រោងទុក៖** ស្ថាប័នទាំងអស់តម្រូវឱ្យបំពេញតាមបទដ្ឋានជានាមូលដ្ឋានរបស់ GCF និងបទដ្ឋានជានាពិសេសផ្សេងៗ ដើម្បីទទួលបានសេចក្តីទុកចិត្ត ដោយមិនគិតពីទំហំសកម្មភាព ដែលនឹងទទួលបានធនធានពី GCF ឡើយ ។ ស្ថាប័នកម្ពុជាអាចទទួលបានមូលនិធិក្នុងកម្រិតមួយ ដែល សមស្របនឹងសមត្ថភាពគ្រប់គ្រងរបស់ខ្លួន ផ្អែកលើបទដ្ឋានជានារបស់ GCF។ គណៈកម្មការវាយតម្លៃ នឹងប្រើប្រាស់ការវិនិច្ឆ័យរបស់ខ្លួន ដើម្បីពិនិត្យសមត្ថភាពរបស់ស្ថាប័ននោះ ថាអាចឆ្លើយតបនឹងបទដ្ឋាន ជានានីមួយៗ។ ហេតុនេះ ស្ថាប័នស្នើសុំត្រូវតែបង្ហាញពីសមត្ថភាពរបស់ខ្លួន ថាខ្លួនមានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ ដើម្បីបញ្ចុះបញ្ចូលគណៈកម្មការឱ្យធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ គណៈកម្មការអាចផ្តល់ យោបល់ដល់ក្រុមប្រឹក្សាភិបាល ថាស្ថាប័នរបស់កម្ពុជាអាចទទួលបានសេចក្តីទុកចិត្តតាមប្រភេទនីមួយៗ យោងតាមបទពិសោធន៍ និងសមត្ថភាពរបស់ខ្លួន ដូចខាងក្រោម ៖

a) កម្រិតតូចបំផុត (ពាក្យស្នើសុំមូលនិធិរហូតដល់ទឹកប្រាក់ចំនួន១លានដុល្លារអាមេរិក សម្រាប់ ឧបករណ៍ហិរញ្ញវត្ថុណាមួយ ចំពោះគម្រោង ឬសកម្មភាពនីមួយៗ)

b) កម្រិតតូច (ពាក្យស្នើសុំមូលនិធិចាប់ពី១លានដុល្លារអាមេរិករហូតដល់ទឹកប្រាក់ចំនួន១០លាន ដុល្លារអាមេរិក សម្រាប់ឧបករណ៍ហិរញ្ញវត្ថុណាមួយ ចំពោះគម្រោង ឬសកម្មភាពនីមួយៗ)

c) កម្រិតមធ្យម (ពាក្យស្នើសុំមូលនិធិចាប់ពី១០លានដុល្លារអាមេរិករហូតដល់ទឹកប្រាក់ចំនួន៥០ លានដុល្លារអាមេរិក សម្រាប់ឧបករណ៍ហិរញ្ញវត្ថុណាមួយ ចំពោះគម្រោង ឬសកម្មភាពនីមួយៗ)

d) កម្រិតធំ (ពាក្យស្នើសុំមូលនិធិលើសពី៥០លានដុល្លារអាមេរិក សម្រាប់ឧបករណ៍ហិរញ្ញវត្ថុណាមួយ ចំពោះគម្រោង ឬសកម្មភាពនីមួយៗ)

នៅក្នុងដំណើរការជ្រើសរើស ស្ថាប័នសក្តានុពលនីមួយៗរបស់កម្ពុជា នឹងត្រូវបានត្រួតពិនិត្យអំពី បទពិសោធន៍កន្លងមករបស់ពួកគេក្នុងការធ្វើពង្រីកវិសាលភាពគម្រោង/កម្មវិធីបន្សាំ និងកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ។

iii. **ប្រភេទស្ថាប័ន៖** ដូចមានចែងក្នុងយន្តការគ្រប់គ្រង IEs និងអន្តរការីនីមួយៗនៃមូលនិធិ អាចជាស្ថាប័ន អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ សាធារណៈ ឬឯកជន។ ស្ថាប័នគ្រប់ប្រភេទតម្រូវឱ្យ បំពេញតាម បទដ្ឋានជានាមូលដ្ឋានរបស់ GCF (និងបទដ្ឋានជានាពិសេសដែលពាក់ព័ន្ធ) ចំណែកឯកសារ

ដែលត្រូវភ្ជាប់មក មានបែងចែងទៅតាមប្រភេទស្ថាប័ននីមួយៗ។

### គ. ការអភិវឌ្ឍសមត្ថភាពសម្រាប់អនុលោមទៅតាមប្រព័ន្ធ ESS របស់ GCF

ប្រព័ន្ធ ESS របស់ GCF (ដែលមានចែងក្នុងឧបសម្ព័ន្ធ ១ និង ៣ នៃសេចក្តីសម្រេច B.០៧/០២) ពិព៌ណនាពីបទដ្ឋានអនុវត្តការងារទាំងប្រាំបី ដែលត្រូវបានអនុវត្តតាមរយៈវិធីសាស្ត្រផ្អែកលើហានិភ័យ ចំពោះសកម្មភាពនានាដែល GCF ផ្តល់មូលនិធិ។ ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ឧទាហរណ៍ បទដ្ឋានអនុវត្តទី១: ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់បរិស្ថាន និងសង្គម) សមត្ថភាពស្ថាប័នរបស់កម្ពុជា ក្នុងការអនុលោមតាម ប្រព័ន្ធ ESS របស់ GCF នឹងត្រូវវាយតម្លៃនៅក្នុងដំណើរការផ្តល់សេចក្តីទុកចិត្ត។ ដំណាក់កាលដំបូងនៃការត្រួតពិនិត្យសំណើគម្រោង នឹងផ្ទៀងផ្ទាត់ថា គម្រោងឬកម្មវិធីនោះ មានសង្គតភាពជាមួយ ESS ឬអត់។

ស្ថាប័នកម្ពុជានីមួយៗនឹងត្រូវបានវាយតម្លៃលើ ១)សមត្ថភាពស្ថាប័ន ២)ប្រព័ន្ធគ្រប់គ្រងសម្រាប់ពិនិត្យសំណើថវិកា ដើម្បីកំណត់ពីហានិភ័យ ឬ/និងហេតុប៉ះពាល់បរិស្ថាន និងសង្គម និង ៣) សមត្ថភាពរបស់ខ្លួនក្នុងការអនុវត្ត ESS ក្នុងកម្រិតមួយដែលសមស្របទៅនឹងវិសាលភាព និងប្រភេទនៃហានិភ័យ និងហេតុប៉ះពាល់។

i. **ចំណាត់ថ្នាក់ហានិភ័យបរិស្ថាន និងសង្គម៖** ស្ថាប័នកម្ពុជានីមួយៗ នឹងត្រូវបានវាយតម្លៃទៅលើបទពិសោធន៍ និងសមត្ថភាពរបស់ពួកគេ ដើម្បីជម្នះលើឧបសគ្គបទប្បញ្ញត្តិ បច្ចេកទេស ហិរញ្ញវត្ថុ និងសង្គម ក្នុងការគ្រប់គ្រងគម្រោង ឬកម្មវិធីទៅតាមចំណាត់ថ្នាក់ហានិភ័យនីមួយៗ។ គណៈកម្មការវាយតម្លៃអាចផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ថាស្ថាប័នកម្ពុជាអាចទទួលបានសេចក្តីទុកចិត្ត ក្នុងកម្រិតហានិភ័យមួយដែលស្ថាប័ននោះអាចគ្រប់គ្រងបាន យោងតាមចំណាត់ថ្នាក់ហានិភ័យ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ នៃសេចក្តីសម្រេច B.០៧/០២ បទពិសោធន៍ និងសមត្ថភាពរបស់ស្ថាប័នកម្ពុជា។

បន្ទាប់ពីការពិនិត្យមើលពាក្យសុំ គណៈកម្មការវាយតម្លៃនឹងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ថាតើស្ថាប័នស្នើសុំ គួរទទួលបានសេចក្តីទុកចិត្តឬអត់ និងគួរទទួលបានចំណាត់ថ្នាក់ហានិភ័យក្នុងកម្រិតណាមួយ។ នៅពេលដែលស្ថាប័ននោះ បានទទួលសេចក្តីទុកចិត្តហើយ ស្ថាប័ននោះអាចដាក់សំណើថវិកាសម្រាប់គម្រោង ឬកម្មវិធីនានា តាមរយៈដំណើរការត្រួតពិនិត្យដំបូង រហូតដល់ដំណាក់កាលដែលពាក់ព័ន្ធទៅតាមចំណាត់ថ្នាក់ហានិភ័យដែលស្ថាប័ននោះបានទទួល។

### ឃ. ការពិចារណាបន្ថែមសម្រាប់ស្ថាប័នដែលមានបទពិសោធន៍តិចតួច

i. **លក្ខខណ្ឌតម្រូវបន្ថែមសម្រាប់ស្ថាប័នដែលមានបទពិសោធន៍តិចតួច៖** ប្រសិនបើស្ថាប័នមួយបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យផ្តល់សេចក្តីទុកចិត្ត ប៉ុន្តែមានបទពិសោធន៍តិចតួចក្នុងការគ្រប់គ្រងគម្រោង ឬមូលនិធិ ១) តាមប្រភេទ ២) តាមវិសាលភាព និង/ឬ ៣) នៅកម្រិតហានិភ័យដែលស្ថាប័នចង់យកមកអនុវត្តនោះ គណៈកម្មការអាចពិចារណាផ្តល់អនុសាសន៍ទៅក្រុមប្រឹក្សាភិបាលថាស្ថាប័ននោះ អាចទទួល

បានសេចក្តីទុកចិត្ត ដោយតម្រូវឱ្យរាយការណ៍ញឹកញាប់ ហើយអាចនឹងត្រូវលើកលែងវិញបន្ទាប់ពីរយៈពេលពីរឆ្នាំដំបូង នៃការទទួលបានសេចក្តីទុកចិត្ត ផ្អែកលើការបំពេញលក្ខខណ្ឌបានល្អ។ គណៈកម្មការក៏អាចពិចារណាផ្តល់អនុសាសន៍ឱ្យអនុវត្តការផ្ទេរមូលនិធិម្តងបន្តិចៗ តែញឹកញាប់ ហើយនឹងត្រួតពិនិត្យម្តងទៀតបន្ទាប់ពីទទួលបានសេចក្តីទុកចិត្តពីរឆ្នាំ។ គណៈកម្មការអាចផ្តល់អនុសាសន៍ដោយផ្អែកលើករណីជាក់ស្តែងនីមួយៗ ប្រសិនបើស្ថាប័ននោះមានបទពិសោធន៍តិចតួច។

ii. **ការផ្តល់សេចក្តីទុកចិត្តលើសមត្ថភាពបន្ថែម៖** នៅក្នុងករណីដែលស្ថាប័នទទួលបានសេចក្តីទុកចិត្ត ចង់អនុវត្តសកម្មភាពបន្ថែម ប៉ុន្តែលើសពីសមត្ថភាពរបស់ខ្លួនដែល GCF ទទួលស្គាល់ ស្ថាប័ននោះត្រូវដាក់ពាក្យម្តងទៀតដើម្បីទទួលបានសេចក្តីទុកចិត្តបន្ថែមលើសកម្មភាពទាំងអស់នោះ។ ស្ថាប័នស្នើសុំនឹងឆ្លងទៅដំណាក់កាលទី២ នៃដំណើរការផ្តល់សេចក្តីទុកចិត្ត ដោយស្វ័យប្រវត្តិ ហើយការវាយតម្លៃនឹងពិនិត្យតែលើសមត្ថភាពបន្ថែមទាំងនោះតែប៉ុណ្ណោះ ពោលគឺមិនពិនិត្យចំណុចដែលបានវាយតម្លៃរួចហើយទេ លើកលែងតែក្នុងករណីស្ថាប័នស្នើសុំនោះចង់ចាប់ផ្តើមពីដំណាក់កាលទី១ ក្នុងគោលបំណងចង់បានការគាំទ្រ តាមរយៈគម្រោងត្រៀមរបស់ GCF ដើម្បីទទួលបានសេចក្តីទុកចិត្តលើសមត្ថភាពបន្ថែមនោះ។

iii. **ការត្រួតពិនិត្យឡើងវិញអំពីសេចក្តីទុកចិត្ត៖** ការទទួលសេចក្តីទុកចិត្ត ត្រូវបានពិនិត្យជារៀងរាល់៥ឆ្នាំ ម្តងតាមរយៈវិធាន ដែលនឹងបង្កើតឡើង ដើម្បីពិចារណាលើការអនុវត្ត និងភាពអនុលោមរបស់ IE ឬអន្តរការីតាមបទដ្ឋានជានា និងប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គម របស់ GCF។ លេខាធិការដ្ឋាន ឬគណៈកម្មការផ្តល់សេចក្តីទុកចិត្ត អាចពិចារណាផ្តល់យោបល់ឱ្យពិនិត្យឡើងវិញចំណុចជាក់លាក់មួយចំនួន ដែលមាននៅក្នុងវិធីសាស្ត្រផ្តល់សេចក្តីទុកចិត្តតាមគោលបំណងជាក់លាក់។

## សំណួរដែលធ្លាប់សួរញឹកញាប់

### ១. ហេតុអ្វីបានជា GCF ប្រើប្រាស់ស្ថាប័នទទួលបានសេចក្តីទុកចិត្ត?

GCF ទទួលស្គាល់ថាស្ថាប័ននីមួយៗ មានជំនាញឯកទេស និងបទពិសោធន៍ច្បាស់លាស់ ដែលអាចកៀរគរ និងប្រើប្រាស់ហិរញ្ញវត្ថុអាកាសធាតុបានល្អបំផុតនៅតាមទីតាំងគោលដៅ។ នេះជាមូលហេតុដែល GCF ធ្វើការយ៉ាងទូលំទូលាយជាមួយស្ថាប័នទទួលសេចក្តីទុកចិត្តនានា ដើម្បីបញ្ជូនធនធានហិរញ្ញវត្ថុរបស់ខ្លួនឱ្យដល់គម្រោង និងកម្មវិធីដែលដោះស្រាយការប្រែប្រួលអាកាសធាតុ។ ស្ថាប័នទទួលសេចក្តីទុកចិត្ត អាចជាស្ថាប័នឯកជន ស្ថាប័នសាធារណៈ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ ការប្រើប្រាស់ស្ថាប័នទទួលសេចក្តីទុកចិត្តទាំងនេះ ត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ GCF ដែលជាឯកសារគោលណែនាំដល់រាល់សកម្មភាពរបស់ GCF ទាំងអស់។

### ២. តើស្ថាប័នទទួលបានសេចក្តីទុកចិត្ត អាចជា NDA/ជនបង្គោលដែរឬទេ?

NDA/ជនបង្គោល នៃប្រទេសកំពុងអភិវឌ្ឍន៍ មានតួនាទីខុសគ្នាពីស្ថាប័នទទួលបានសេចក្ដីទុកចិត្ត។ NDA/ជនបង្គោល ដើរតួជាអ្នកសម្របសម្រួលរវាងប្រទេសកំពុងអភិវឌ្ឍន៍ និងGCF។ NDA/ជនបង្គោល មានតួនាទីផ្ដល់ជំបូន្មានជាយុទ្ធសាស្ត្រដល់រាល់សកម្មភាពទាំងឡាយរបស់ GCF នៅក្នុងប្រទេសរបស់ខ្លួន ព្រមទាំងធានាថារាល់ការវិនិយោគឆ្លើយតបនឹងសេចក្ដីត្រូវការ និងផែនការរបស់ប្រទេស។

ស្ថាប័នទទួលបានសេចក្ដីទុកចិត្ត ទទួលខុសត្រូវលើការបញ្ជូនធនធាន GCF ទៅឱ្យគម្រោង និងកម្មវិធីនានា។ GCF ផ្ដល់សេចក្ដីទុកចិត្តដល់ស្ថាប័នទទួលមូលនិធិផ្ទាល់ ដែលធ្វើការងារនៅថ្នាក់ក្រោមជាតិ ឬថ្នាក់ជាតិ ក៏ដូចជាស្ថាប័នថ្នាក់តំបន់ និងអន្តរជាតិ។ ស្ថាប័នទទួលសេចក្ដីទុកចិត្ត អាចជាស្ថាប័នរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ស្ថាប័នឯកជន ឬសាធារណៈ។

ជាទូទៅ តួនាទីរបស់ NDA និងស្ថាប័នទទួលសេចក្ដីទុកចិត្ត មានភាពខុសគ្នា និងចែកដាច់ពីគ្នា។ យ៉ាងណាក៏ដោយ ក្នុងករណីខ្លះ NDA អាចស្នើសុំដើម្បីក្លាយទៅជាស្ថាប័នទទួលសេចក្ដីទុកចិត្តពី GCF។ លេខាធិការដ្ឋាន GCF អាចផ្ដល់ជាយោបល់ដែលសមស្រប សម្រាប់ករណីនេះ។

**៣. តើស្ថាប័ននានាចាំបាច់ត្រូវមានសំណើថវិកាទាក់ទងនឹងបញ្ហាអាកាសធាតុ ដើម្បីដាក់ជូន GCF ពិចារណា មុនពេលស្ថាប័ននោះ ស្នើសុំសេចក្ដីទុកចិត្តពី GCF ដែរឬទេ?**

មិនចាំបាច់ទេ។

**៤ .តើស្ថាប័នស្នើសុំ ត្រូវបានវាយតម្លៃយ៉ាងដូចម្ដេច ដើម្បីទទួលបានសេចក្ដីទុកចិត្ត?**

ការវាយតម្លៃផ្ដល់សេចក្ដីទុកចិត្តនឹងពិនិត្យលើសមត្ថភាពគ្រប់គ្រងថវិកា និងមានប្រព័ន្ធធានាសុវត្ថិភាពបរិស្ថាន និងសង្គមរឹងមាំរបស់ស្ថាប័នស្នើសុំ។

ស្ថាប័នជាច្រើនអាចក្លាយទៅជាស្ថាប័នទទួលបានសេចក្ដីទុកចិត្ត។ នេះជាមូលហេតុដែល GCF បានដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រផ្ដល់សេចក្ដីទុកចិត្តតាមគោលបំណងជាក់លាក់ ដើម្បីវាយតម្លៃស្ថាប័នទាំងនោះ ខុសៗគ្នា ទៅតាមសមត្ថភាពរបស់ពួកគេ និងទៅតាមរបៀបធ្វើការងាររបស់ពួកគេ ដើម្បីឆ្លើយតបនឹងសេចក្ដីត្រូវការហិរញ្ញប្បទានអាកាសធាតុរបស់ប្រទេសផ្សេងៗគ្នា។

នៅពេលដែលវិសាលភាពនៃការទទួលសេចក្ដីទុកចិត្តមានលក្ខណៈខុសៗគ្នានោះ ស្ថាប័នទាំងអស់ត្រូវបំពេញតាមបទដ្ឋានមូលដ្ឋាន ដែលផ្អែកទៅលើគោលការណ៍ដូចខាងក្រោម៖

- បទដ្ឋានធានាមូលដ្ឋាន
- សុវត្ថិភាពបរិស្ថាន និងសង្គម
- ការគិតគូរដល់បញ្ហាយេនឌ័រ។

បទដ្ឋានជានាមូលដ្ឋានជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុឱ្យបានសមស្រប រួមមានការបង្ហាញថារាល់ជាតុចូល និងជាតុចេញផ្នែកហិរញ្ញវត្ថុត្រូវបានកត់ត្រា វាយការណ៍ និងគ្រប់គ្រងដោយត្រឹមត្រូវនិងមានតម្លាភាព ស្របតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ និងប្រកបដោយគណនេយ្យភាព។ ព័ត៌មានអំពីផ្នែករដ្ឋបាលទូទៅ និងការគ្រប់គ្រងត្រូវតែអាចរកបាន មានសង្គតភាព អាចជឿទុកចិត្តបានពេញលេញ និងពាក់ព័ន្ធ។ ស្ថាប័នស្នើសុំត្រូវបង្ហាញពីបទពិសោធន៍ស្តីពីការសម្រេចបានប្រសិទ្ធភាព និងប្រសិទ្ធផលផងដែរ។

ព័ត៌មានបន្ថែមស្តីពីលក្ខខណ្ឌតម្រូវបទដ្ឋានជានាមូលដ្ឋានមាននៅទីនេះ។

បទដ្ឋានសុវត្ថិភាពបរិស្ថាន និងសង្គមបណ្តោះអាសន្នរបស់ GCF ត្រូវបានដកស្រង់ចេញពីបទដ្ឋានអនុវត្តន៍របស់ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដែលជាស្ថាប័នអន្តរជាតិកំពុងធ្វើការលើវិស័យឯកជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ បទដ្ឋានអនុវត្តន៍ទាំង៨នោះរួមមានៈ

i. ការវាយតម្លៃ និងការគ្រប់គ្រងលើហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គម
ii. លក្ខខណ្ឌពលកម្ម និងការងារ
iii. ប្រសិទ្ធភាពធនធាន និងការពារការបំពុល
iv. សុខមាលភាព សុវត្ថិភាព និងសន្តិសុខសហគមន៍
v. កម្មសិទ្ធិដីធ្លី និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំ
vi. ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព
vii. ជនជាតិដើមភាគតិច និង
viii. បេតិកភណ្ឌវប្បធម៌

ដំណើរការផ្តល់សេចក្តីទុកចិត្ត ពិនិត្យលើសមត្ថភាព និងឆន្ទៈរបស់ស្ថាប័នស្នើសុំ ក្នុងការអនុវត្តប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គមនៅក្នុងកម្រិតសមស្របរបស់ស្ថាប័ននោះ (បទដ្ឋានអនុវត្តន៍ទី១)។ បន្ទាប់មក ក្នុងកំឡុងពេលពិនិត្យសំណើថវិការបស់ស្ថាប័នទទួលបានសេចក្តីទុកចិត្ត លេខាធិការដ្ឋាន GCF នឹងត្រួតពិនិត្យអំពីរបៀបស្ថាប័ននោះអនុវត្តការងាររបស់ខ្លួនទាក់ទងនឹងបទដ្ឋានអនុវត្តន៍ទី២ ដល់ទី៨ ដើម្បីឱ្យស្របតាមប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គម។

ឯកសារនេះពន្យល់លម្អិតអំពីរបៀបដែលស្ថាប័នត្រូវអនុវត្ត ដើម្បីបំពេញតាមប្រព័ន្ធសុវត្ថិភាពបរិស្ថាន និងសង្គមជាអប្បបរមា។

គោលនយោបាយ និងផែនការសកម្មភាពយេនឌ័ររបស់ GCF គឺផ្អែកទៅលើការណែនាំរបស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលគាំទ្រលើសមភាព និងសមធម៌

យេនឌ័រ ។ ព័ត៌មានបន្ថែមអំពីអភិក្រមរបស់ GCF លើយេនឌ័រ និងការប្រែប្រួលអាកាសធាតុគឺអាចរកបាននៅទីនេះ។

ការវាយតម្លៃផ្តល់សេចក្តីទុកចិត្តនឹងពិនិត្យលើសមត្ថភាពរបស់ស្ថាប័នស្នើសុំ ក្នុងការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងកម្រិតស្ថាប័ន និងកម្រិតគម្រោង/កម្មវិធី

នៅក្នុងពេលពិនិត្យសំណើថវិកាដែលបានដាក់ជូនដោយស្ថាប័នទទួលសេចក្តីទុកចិត្ត លេខាធិការដ្ឋាន GCF នឹង៖

i. ពិនិត្យថាបានដាក់បញ្ចូលការគិតគូរបញ្ហាយេនឌ័រទៅក្នុងសកម្មភាពជាក់លាក់ សម្រាប់ឆ្លើយតបនឹងបទដ្ឋានយេនឌ័រ ដែលបានកំណត់នៅក្នុងដំណើរការផ្តល់សេចក្តីទុកចិត្តឬអត់ និង

ii. ពិនិត្យថាគម្រោង/កម្មវិធីដែលបានដាក់ជូនដោយស្ថាប័នទទួលសេចក្តីទុកចិត្ត មានសង្គតភាពជាមួយនឹងអភិក្រមដែលមានចែងនៅក្នុងគោលនយោបាយ និងផែនការសកម្មភាពយេនឌ័ររបស់ GCF ឬអត់។

## ៥. តើការផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់របស់មូលនិធិអាកាសធាតុបៃតងគឺជាអ្វី?

វិធីសាស្ត្រវាយតម្លៃផ្តល់សេចក្តីទុកចិត្តស្របទៅតាមគោលបំណងជាក់លាក់ ដែលជាការបង្កើតថ្មីរបស់មូលនិធិអាកាសធាតុបៃតង ដើម្បីវាយតម្លៃស្ថាប័ន ទទួលស្គាល់អំពីសកម្មភាព និងសមត្ថភាពយ៉ាងទូលំទូលាយរបស់ស្ថាប័នស្នើសុំ។ ស្ថាប័នផ្សេងៗគ្នាមកពីរដ្ឋាភិបាលតូចៗ និងអង្គការមិនមែនរដ្ឋាភិបាលដែលគ្រប់គ្រងរាល់សកម្មភាពដែលមានទឹកប្រាក់ពីរទៅបីលានដុល្លា ឬតិចជាងនេះ រហូតដល់កម្រិតធនាគារអភិវឌ្ឍន៍ពហុភាគីធំៗដែលផ្តល់មូលនិធិសម្រាប់សកម្មភាពតម្លៃរាប់រយលានដុល្លារ។

ការផ្តល់សេចក្តីទុកចិត្តស្របទៅតាមគោលបំណងជាក់លាក់ ចាត់ថ្នាក់ស្ថាប័នស្នើសុំ ដោយផ្អែកលើប្រភេទនៃស្ថាប័នរបស់ពួកគេ ព្រមទាំងវិសាលភាព ប្រភេទ និងហានិភ័យនៃសកម្មភាពអាកាសធាតុដែលបានដាក់ស្នើ។

ដូច្នេះ ស្ថាប័នស្នើសុំសេចក្តីទុកចិត្ត សម្រាប់អនុវត្ត ឬជាអន្តរការីគម្រោង និងកម្មវិធីដែលមានហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គមតិចតួចមិនចាំបាច់មានប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គមដូចគ្នាទៅនឹងស្ថាប័នដែលគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមខ្ពស់នោះទេ។

ការផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់ផ្អែកលើ៖ ១) ទំហំនៃសកម្មភាពរបស់គម្រោង និងកម្មវិធីដែលបានដាក់ស្នើ ២) បទដ្ឋានធានា និង ៣) ប្រភេទហានិភ័យសង្គម និងបរិស្ថាន។

ទំហំនៃសកម្មភាពរបស់គម្រោង និងកម្មវិធី ដែលបានស្នើត្រូវបានបែងចែកជា ៤ ប្រភេទ។

- ខ្នាតតូចបំផុត៖ ការឧបត្ថម្ភរបស់មូលនិធិអាកាសធាតុបៃតងអតិបរមារហូតដល់ស្មើនឹង១០ លានដុល្លារអាមេរិក។

- ខ្នាតតូច៖ ការឧបត្ថម្ភរបស់មូលនិធិអាកាសធាតុបៃតងអតិបរិមាលើសពី ១០ លានដុល្លារអាមេរិក និងរហូតដល់ស្មើនឹង ៥០ លានដុល្លារអាមេរិក។
- ខ្នាតមធ្យម៖ ការឧបត្ថម្ភរបស់មូលនិធិអាកាសធាតុបៃតងអតិបរិមាលើសពី ១០ លានដុល្លារអាមេរិក និងរហូតដល់ស្មើនឹង ២៥០ លានដុល្លារអាមេរិក និង
- ខ្នាតធំ៖ ការឧបត្ថម្ភរបស់មូលនិធិអាកាសធាតុបៃតងច្រើនជាង ២៥០ លានដុល្លារអាមេរិក។

ស្ថាប័នទទួលបានសេចក្តីទុកចិត្តសម្រាប់ប្រភេទទំហំជាក់លាក់មួយ អាចដាក់ស្នើសំណើថវិកាសម្រាប់ការពិចារណារបស់មូលនិធិអាកាសធាតុបៃតង ដែលតម្លៃសរុបសម្រាប់គម្រោងស្ថិតនៅក្នុងប្រភេទទំហំអតិបរមា។ (ឧទាហរណ៍ ស្ថាប័នទទួលបានសេចក្តីទុកចិត្តសម្រាប់កម្រិតមធ្យម អាចដាក់សំណើថវិកាដែលស្ថិតនៅក្នុងប្រភេទមីក្រូ តូច ឬមធ្យម ប៉ុន្តែមិនអាចដាក់ស្នើថវិកាកម្រិតធំបានទេ)។

បទដ្ឋានជានាពិសេសមានបីប្រភេទ ដែលអនុញ្ញាតឱ្យស្ថាប័នទទួលបានសេចក្តីទុកចិត្ត អនុវត្តសកម្មភាព ស្របតាមមុខងារពិសេស ដូចខាងក្រោម៖

- ការគ្រប់គ្រងគម្រោង៖ វាយតម្លៃសមត្ថភាពរបស់ស្ថាប័នដាក់ពាក្យក្នុងការគ្រប់គ្រង ផ្តល់យោបល់ និងត្រួតពិនិត្យគម្រោង ឬកម្មវិធីទាំងមូល តាមរយៈអង្គភាពប្រតិបត្តិ ដោយផ្ទាល់ ឬដោយប្រយោល ។
- ការផ្តល់ជំនួយឥតសំណង និង/ឬការរិភាជមូលនិធិ៖ វាយតម្លៃពីសមត្ថភាពរបស់ស្ថាប័នដាក់ពាក្យក្នុងការប្រើប្រាស់មូលនិធិអាកាសធាតុបៃតងក្នុងនាមជាអន្តរការី តាមរយៈដំណើរការផ្តល់ជំនួយឥតសំណងប្រកបដោយការប្រកួតប្រជែង និងតម្លាភាព។
- ការផ្តល់ប្រាក់កម្ចី និង/ឬថវិកាចម្រុះគ្នា៖ វាយតំលៃសមត្ថភាពរបស់ស្ថាប័នដាក់ពាក្យក្នុងការគ្រប់គ្រងថវិកាទំហំមធ្យម ក្នុងទម្រង់ជាប្រាក់កម្ចី ឬការច្របាច់បញ្ចូលគ្នានូវបរិធាន និងធនធានផ្សេងៗគ្នាផ្តល់ជាដើមទុនវិនិយោគ ឬផ្តល់ការធានា។

ស្ថាប័នដាក់ពាក្យក៏ត្រូវបានវាយតម្លៃ អំពីសមត្ថភាពគ្រប់គ្រងហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គម ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ។ ចំណាត់ថ្នាក់ត្រូវបានបែងចែកទៅជា គ្មានហានិភ័យ ឬហានិភ័យតិចតួច ហានិភ័យមធ្យម និងហានិភ័យខ្ពស់។ ចំណាត់ថ្នាក់ទាំងនេះក៏បានគិតគូរផងដែរ ថាតើស្ថាប័នដាក់ពាក្យនឹងគ្រប់គ្រងគម្រោង ឬចាត់ចែងធនធានបន្តក្នុងនាមជាអន្តរការី របស់មូលនិធិអាកាសធាតុបៃតង តាមរយៈការផ្តល់ជំនួយឥតសំណង ការផ្តល់ប្រាក់កម្ចី ការផ្តល់ថវិកាចម្រុះ ការផ្តល់ដើមទុន វិនិយោគ ឬការធានា ដែរឬទេ។

សម្រាប់គម្រោងដែលគ្រប់គ្រងដោយស្ថាប័នទទួលបានសេចក្តីទុកចិត្ត កម្រិតហានិភ័យបរិស្ថាន និងសង្គមអាចជា:

- ប្រភេទ ក៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់ឬហានិភ័យអវិជ្ជមានខ្លាំងដល់បរិស្ថាន និង/ឬសង្គម និង/ឬ ហេតុប៉ះពាល់ដែលចម្រុះ ដែលមិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុន

- ប្រភេទ ខ៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់ឬហានិភ័យមធ្យមដល់បរិស្ថាន និង / ឬ សង្គម និង/ឬហេតុប៉ះពាល់ដែលមានតិចតួច ជាទូទៅស្ថិតនៅក្នុងទីតាំងជាក់លាក់ ដែលអាចស្តារឡើងវិញបានភាគច្រើន និងងាយស្រួលដោះស្រាយតាមរយៈវិធានការកាត់បន្ថយ
- ប្រភេទ គ៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់អវិជ្ជមានតិចតួច ឬគ្មានហេតុប៉ះពាល់និង/ឬ ហានិភ័យដល់បរិស្ថាន និងសង្គម

គម្រោងវិនិយោគតាមរយៈអន្តរការីហិរញ្ញវត្ថុ (ការផ្តល់ជំនួយឥតសំណង ឬការផ្តល់ប្រាក់កម្ចី/ ថវិកាចម្រុះគ្នា) ឬតាមរយៈយន្តការចែកចាយ របស់អន្តរការីហិរញ្ញវត្ថុ គួរអនុវត្តតាមកម្រិតហានិភ័យបរិស្ថាន និងសង្គមដូចខាងក្រោម៖

- អន្តរការីកម្រិតខ្ពស់ (អន្តរការីកម្រិត១, I-1)៖ ប្រសិនបើសកម្មភាពរបស់អន្តរការីហិរញ្ញវត្ថុ អាចមានហេតុប៉ះពាល់ឬហានិភ័យអវិជ្ជមានខ្លាំងដល់បរិស្ថាន និង/ឬ សង្គម និង/ឬ ហេតុប៉ះពាល់ដែលចម្រុះ ដែលមិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុន
- អន្តរការីកម្រិតមធ្យម (I-2): ប្រសិនបើសកម្មភាពរបស់អន្តរការីហិរញ្ញវត្ថុ អាចមានហេតុប៉ះពាល់អវិជ្ជមានឬហានិភ័យដល់បរិស្ថាន និង / ឬ សង្គម តិចតួច ជាទូទៅស្ថិតនៅក្នុងទីតាំងជាក់លាក់ ដែលអាចស្តារឡើងវិញបានភាគច្រើន និងងាយស្រួលដោះស្រាយតាមរយៈវិធានការកាត់បន្ថយ ឬអាចមានសកម្មភាពតិចតួចដែលអាចមានហេតុប៉ះពាល់ឬហានិភ័យបរិស្ថាន ឬសង្គម ដែលចម្រុះ មិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុន
- អន្តរការីកម្រិតទាប(I-3)៖ ប្រសិនបើសកម្មភាពភាគច្រើនរបស់អន្តរការីហិរញ្ញវត្ថុ អាចមានហេតុប៉ះពាល់អវិជ្ជមានឬហានិភ័យដល់បរិស្ថាន និង / ឬ សង្គម តិចតួច ឬគ្មានតែម្តង។

ព័ត៌មានបន្ថែមអំពីវិធីសាស្រ្តផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់របស់មូលនិធិអាកាសធាតុបៃតងមាននៅទីនេះ។

## ៦. តើស្ថាប័នទទួលបានសេចក្តីទុកចិត្តអាចតម្លើងប្រភេទនៃការផ្តល់សេចក្តីទុកចិត្តរបស់ស្ថាប័នពួកគេបានដែរឬទេ?

ស្ថាប័នទទួលបានសេចក្តីទុកចិត្ត អាចកែលម្អប្រភេទនៃការផ្តល់សេចក្តីទុកចិត្តរបស់ស្ថាប័នពួកគេបាន។ ស្ថាប័នទទួលបានសេចក្តីទុកចិត្តអាចស្នើសុំបញ្ចូលសមត្ថភាពបន្ថែមណាមួយ ដែលសកម្មភាពទាំងនោះបានអភិវឌ្ឍន៍ស្ថាប័នរបស់ពួកគេឱ្យកាន់តែល្អឡើង។ នេះមានន័យថាស្ថាប័ននេះតម្លើងប្រភេទនៃការផ្តល់សេចក្តីទុកចិត្តទៅតាមគោលបំណងជាក់លាក់របស់ខ្លួន។ ហើយវាធ្វើឱ្យស្ថាប័ននេះអាចស្វែងរកមូលនិធិ ពីមូលនិធិអាកាសធាតុបៃតងសម្រាប់គម្រោង និងកម្មវិធីនៅកម្រិតហិរញ្ញវត្ថុខ្ពស់ជាងចំណាត់ថ្នាក់ហិរញ្ញវត្ថុដែលអាចទទួលបាននាពេលបច្ចុប្បន្ន។ ស្ថាប័នទទួលបានសេចក្តីទុកចិត្ត អាចដាក់ពាក្យស្នើសុំតាមប្រព័ន្ធ OAS ដោយបង្កើតពាក្យសុំថ្មីដើម្បីសុំធ្វើការអភិវឌ្ឍអោយមុខងារដែលពាក់ព័ន្ធកាន់តែប្រសើរ។

## ៧. តើស្ថាប័នអាចទទួលបានសេចក្តីទុកចិត្តក្នុងរយៈពេលប៉ុន្មាន?

ស្ថាប័ននីមួយៗអាចត្រូវបានផ្តល់សេចក្តីទុកចិត្តក្នុងរយៈពេលប្រាំឆ្នាំ។ បច្ចុប្បន្ននេះ មូលនិធិអាកាសធាតុបៃតងកំពុងធ្វើការលើវិធីដើម្បីវាយតម្លៃលើស្ថាប័នដែលបានទទួលស្គាល់រួចហើយ សម្រាប់ការទទួលស្គាល់ឡើងវិញ។

## ៨.តើការផ្តល់សេចក្តីទុកចិត្តត្រូវប្រើរយៈពេលប៉ុន្មាន?

លេខាធិការដ្ឋានមូលនិធិអាកាសធាតុ និងគណៈកម្មាធិការវាយតម្លៃផ្តល់សេចក្តីទុកចិត្ត ព្យាយាមធ្វើការសម្រេចចិត្តក្នុង**រយៈពេលប្រាំមួយខែ** បន្ទាប់ពីទទួលបានឯកសារចាំបាច់ និងពេញលេញ ថាតើត្រូវផ្តល់យោបល់លើពាក្យស្នើសុំទៅក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុដែរឬយ៉ាងណា។ ប្រសិនបើស្ថាប័នទាំងនោះបានដាក់ពាក្យស្នើសុំការគាំទ្រពីគម្រោងត្រៀមនោះដំណើរការនេះអាចចំណាយពេលយូរជាងនេះ។

លេខាធិការដ្ឋានមូលនិធិអាកាសធាតុបៃតង និងគណៈកម្មាធិការវាយតម្លៃផ្តល់សេចក្តីទុកចិត្ត ព្យាយាមធ្វើការសម្រេចចិត្តក្នុងរយៈពេលបីខែសម្រាប់ស្ថាប័នដែលបំពេញគ្រប់តាមតម្រូវការ។ ស្ថាប័នទាំងនេះគឺជាស្ថាប័នដែលត្រូវបានទទួលស្គាល់រួចហើយដោយមូលនិធិបរិស្ថានសកល (GEF) មូលនិធិបន្សាំ និង អគ្គនាយកដ្ឋានអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ- ជំនួយអឺរ៉ុប នៃគណៈកម្មការអឺរ៉ុប (DG DEVCO) ។

## ៩. តើការផ្តល់សេចក្តីទុកចិត្តត្រូវចំណាយទឹកប្រាក់អស់ប៉ុន្មាន?

ស្ថាប័នដាក់ពាក្យសុំដែលជាស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងរដ្ឋកោះតូចៗកំពុងអភិវឌ្ឍន៍ (SIDS) និងបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច អាចទទួលបានការលើកលែងចំពោះការបង់ថ្លៃមួយចំនួន ដើម្បីទទួលបានការផ្តល់សេចក្តីទុកចិត្ត នៅពេលដែលស្ថាប័នទាំងនេះស្វែងរកការផ្តល់សេចក្តីទុកចិត្តសម្រាប់ប្រភេទគម្រោងខ្នាតតូចបំផុត និង គម្រោងខ្នាតតូច ។

ថ្លៃឈ្នួលសម្រាប់ការផ្តល់សេចក្តីទុកចិត្តគឺផ្អែកលើគម្រោងចំណាយសរុបនៃគម្រោង ឬសកម្មភាពហិរញ្ញប្បទានអាកាសធាតុដែលបានស្នើឡើងក្នុងកម្មវិធីនៅពេលដាក់ពាក្យ។ គេបានកំណត់ថ្លៃឈ្នួលសម្រាប់ការផ្តល់សេចក្តីទុកចិត្ត ចំនួនបួនប្រភេទ ដោយយោងទៅលើគម្រោងចំណាយសរុបរបស់សកម្មភាព ដោយមិនគិតពីចំណែកដែលត្រូវបានផ្តល់មូលនិធិដោយមូលនិធិអាកាសធាតុបៃតងឡើយ។

- កម្រិតមីក្រូះ មានទំហំក្រោមនិងស្មើ១០លានដុល្លារអាមេរិកសំរាប់គម្រោង រឺសកម្មភាពនីមួយៗ។ កម្រិតថ្លៃឈ្នួលសំរាប់កម្រិតនេះគឺ ១ ០០០ ដុល្លារអាមេរិកសំរាប់កម្រិតបទដ្ឋានជានាមូលដ្ឋាន និង ៥០០ ដុល្លារអាមេរិកសំរាប់បទដ្ឋានជានាពិសេស នីមួយៗ។
- កម្រិតតូចះ មានទំហំលើសពី ១០ លានដុល្លារអាមេរិក រហូតដល់ស្មើ៥០ លានដុល្លារសម្រាប់គម្រោងនីមួយៗ។ កម្រិតថ្លៃឈ្នួលចាប់ពីកំរិតនេះគឺ ៥,០០០ ដុល្លារអាមេរិកសម្រាប់កម្រិតបទដ្ឋានជានាមូលដ្ឋាន និង១ ០០០ដុល្លារអាមេរិកសម្រាប់កម្រិតបទដ្ឋានជានាពិសេសនីមួយៗ។

- កម្រិតមធ្យមៈ មានទំហំលើសពី ៥០ លានដុល្លារអាមេរិក រហូតដល់ស្មើ ២៥០ លានដុល្លារអាមេរិក សម្រាប់គម្រោង ឬសកម្មភាពនីមួយៗ។ កម្រិតថ្លៃឈ្នួលចាប់ពីកម្រិតនេះគឺ ១០,០០០ ដុល្លារអាមេរិកកម្រិតបទដ្ឋានជានាមូលដ្ឋាន និង៣ ០០០ ដុល្លារអាមេរិកសម្រាប់កម្រិតបទដ្ឋានជានាពិសេសនីមួយៗ។
- កម្រិតធំៈ លើសពី ២៥០ លានដុល្លារអាមេរិកសម្រាប់គម្រោង ឬសកម្មភាពនីមួយៗ។ កម្រិតថ្លៃឈ្នួលចាប់ពីកម្រិតនេះគឺ ២៥,០០០ ដុល្លារអាមេរិកកម្រិតបទដ្ឋានជានាមូលដ្ឋាន និង ៧ ០០០ ដុល្លារអាមេរិកសម្រាប់កម្រិតបទដ្ឋានជានាពិសេសនីមួយៗ។

ព័ត៌មានលម្អិតបន្ថែមអំពីថ្លៃឈ្នួលសម្រាប់ការផ្តល់សេចក្តីទុកចិត្តគឺមាននៅទីនេះ។

## ១០. តើមានស្ថាប័នណាដែលត្រូវបានផ្តល់អាទិភាពសម្រាប់ការផ្តល់សេចក្តីទុកចិត្តដែរឬទេ ?

ពិតណាស់ មានស្ថាប័នដែលត្រូវបានផ្តល់អាទិភាពសម្រាប់ការទទួលសេចក្តីទុកចិត្ត។ នៅឆ្នាំ ២០១៧ ពាក្យសុំក្នុងដំណាក់កាលទី ១ នឹងត្រូវបានពិនិត្យដោយលេខាធិការដ្ឋាននៃមូលនិធិអាកាសធាតុបៃតង ដោយស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលមូលនិធិអាកាសធាតុបៃតង ក្នុងការផ្តល់អាទិភាពដល់ពាក្យសុំដែលដាក់ស្នើមកពីៈ

- ស្ថាប័នជាតិទទួលមូលនិធិដោយផ្ទាល់
- ស្ថាប័ននានានៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់អឺរ៉ុបខាងកើត
- ស្ថាប័នឯកជន ជាពិសេសស្ថាប័ននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីស្វែងរកតុល្យភាពនៃស្ថាប័នចម្រុះស្របតាមសេចក្តីសម្រេចលេខ B០៩ / ០៧ កថាខណ្ឌ (g) និងសេចក្តីសម្រេចលេខ ១០ / ០៦ កថាខណ្ឌ (h)
- ស្ថាប័នដែលដាក់សំណើគម្រោង តាមការប្រកាសរបស់មូលនិធិអាកាសធាតុបៃតង ឧទាហរណ៍មានដូចជា ដំណាក់កាលសាកល្បងសម្រាប់ការបង្កើនការទទួលបានមូលនិធិដោយផ្ទាល់ កម្មវិធីសាកល្បងដើម្បីគាំទ្រសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម និងកម្មវិធីសាកល្បងដើម្បីកៀរគរធនធានដើម្បីដោះស្រាយការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ
- ស្ថាប័នដែលស្វែងរកការបំពេញលក្ខខណ្ឌសម្រាប់ការផ្តល់សេចក្តីទុកចិត្ត និង
- ស្ថាប័នស្នើសុំតម្លើងប្រភេទនៃការផ្តល់សេចក្តីទុកចិត្ត។

## ១១.តើគណៈកម្មាធិការផ្តល់សេចក្តីទុកចិត្តគឺជាអ្វី ?

គណៈកម្មាធិការផ្តល់សេចក្តីទុកចិត្តផ្តល់នូវដំបូន្មានឯករាជ្យដល់ក្រុមប្រឹក្សាភិបាលរបស់មូលនិធិអាកាសធាតុបៃតង អំពីការដាក់ពាក្យស្នើសុំការផ្តល់សេចក្តីទុកចិត្ត ។ គណៈកម្មាធិការនេះមានអ្នកជំនាញជាន់ខ្ពស់ចំនួន ៦ រូប ដែលជានិច្ចកាល មានតុល្យភាពស្មើគ្នារវាងអ្នកតំណាងមកពីប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ សមាជិកនៃគណៈកម្មាធិការផ្តល់សេចក្តីទុកចិត្តបំពេញករណីយកិច្ចរយៈពេល ៣ ឆ្នាំ។

សមាជិកនៃគណៈកម្មាធិការផ្តល់សេចក្តីទុកចិត្តផ្តល់នូវចំណេះដឹងឯកទេសលើបញ្ហាជាច្រើន ដែលទាក់ទងទៅនឹងការសម្រេចចិត្តចំពោះការផ្តល់សេចក្តីទុកចិត្ត ដែលរួមទាំងការអនុវត្តល្អៗនៅក្នុង គោលការណ៍ និងបទដ្ឋានជានា សុវត្ថិភាពបរិស្ថាន និងសង្គម ព្រមទាំងទទួលស្គាល់ការអនុវត្តល្អៗនៅក្នុង នីតិវិធីនៃការផ្តល់សេចក្តីទុកចិត្ត។ ពួកគេក៏អាចពិគ្រោះយោបល់ជាមួយអ្នកជំនាញពាក់ព័ន្ធផ្សេងទៀតនៅ ពេលចាំបាច់។

**១២.តើខ្ញុំអាចទាក់ទងទៅមូលនិធិអាកាសធាតុបៃតង ដើម្បីស្វែងយល់បន្ថែមអំពីការផ្តល់សេចក្តីទុកចិត្ត បានដោយរបៀបណា?**

សូមសាកសួរដោយផ្ទាល់ទៅកាន់៖ accreditation@gcfund.org

## ឧបសម្ព័ន្ធទី ៤៖ លក្ខណៈវិនិច្ឆ័យ និងសូចនាករសម្រាប់កម្មវិធី / គម្រោងដែលត្រូវបានផ្តល់មូលនិធិ និងលក្ខណៈវិនិច្ឆ័យនៃការសម្រេចចិត្តសកម្មភាពជាក់លាក់របស់មូលនិធិ

ស្ថាប័នទទួលបានសេចក្តីទុកចិត្តនឹងរៀបចំនូវសំណើថវិការបស់ខ្លួនដោយពិចារណាលើលក្ខណៈវិនិច្ឆ័យនៃការវិនិយោគរបស់មូលនិធិអាកាសធាតុបៃតងចំនួន ៦ (GCF 6) និងលក្ខណៈវិនិច្ឆ័យរងនៃសកម្មភាពជាក់លាក់ ព្រមទាំងកត្តាវាយតម្លៃ ដែលពាក់ព័ន្ធ និងអាចអនុវត្តបាន។ នៅក្នុងការរៀបចំសំណើគម្រោង ស្ថាប័នទទួលបានសេចក្តីទុកចិត្តត្រូវបានគេរំពឹងថានឹងឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យទាំងប្រាំមួយនៃការវិនិយោគ ប៉ុន្តែមានតែលក្ខណៈវិនិច្ឆ័យរង និងកត្តាវាយតម្លៃ ដែលពាក់ព័ន្ធ និងអាចអនុវត្តបានប៉ុណ្ណោះ។ លក្ខណៈវិនិច្ឆ័យរងនៃសកម្មភាពជាក់លាក់ និងកត្តាវាយតម្លៃទាំងអស់មិនមែនសុទ្ធតែអាចអនុវត្តបាន ឬពាក់ព័ន្ធសម្រាប់រាល់គ្រប់សំណើសុំទាំងអស់នោះទេ។

**តារាង ក៤.១ លក្ខណៈវិនិច្ឆ័យរងនៃសកម្មភាពជាក់លាក់ និងកត្តាវាយតម្លៃចង្អុលបង្ហាញ**

| លក្ខណៈវិនិច្ឆ័យ | និយមន័យ | វិស័យគ្របដណ្តប់ | លក្ខណៈវិនិច្ឆ័យរងនៃសកម្មភាពជាក់លាក់ | កត្តាវាយតម្លៃ (រួមបញ្ចូលទាំង សូចនាករ) |
|---|---|---|---|---|
| ផលប៉ះពាល់ដែលអាចកើតមាន | សក្តានុពលនៃកម្មវិធី/គម្រោងដើម្បីរួមចំណែកសម្រេចគោលបំណងរបស់GCF និងវិស័យអាទិភាព | ផលប៉ះពាល់លើការកាត់បន្ថយ | រួមចំណែកនៅក្នុងការផ្លាស់ប្តូរទៅរកមាគ៌ាអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការបំភាយឧស្ម័នតិច | បរិមាណកាបូនឌីអុកស៊ីតសមតុល្យរំពឹងទុក (t CO2 eq) ត្រូវបានកាត់បន្ថយ ឬបញ្ចៀស (PMF-M Core 1)<br><br>កម្រិតដែលសកម្មភាពបញ្ចៀសការបំភាយឧស្ម័នខ្លាំង ថេរ និងរយៈពេលវែង<br><br>រំពឹងទុកថា ចំនួនគ្រួសារដែលប្រើប្រាស់ថាមពលមានការបំភាយឧស្ម័នទាប មានចំនួនកើនឡើង<br><br>រំពឹងទុកថាមានការកើនឡើងនូវចំនួនអ្នកផ្គត់ផ្គង់ថាមពលខ្នាតតូច មធ្យម និងធំ ដែលមានការបំភាយទាប (PMF-M 6,0 and related indicator(s)), សមត្ថភាពមានប្រសិទ្ធភាព<br><br>រំពឹងទុកថា ការប្រើប្រាស់អគ្គីសនីតាមអគារ ទីក្រុង ឧស្សាហកម្ម និងឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ មានការថយចុះ (PMF-M 7,0 and related indicator(s));<br><br>រំពឹងទុកថា មធ្យោបាយដឹកជញ្ជូនបំភាយឧស្ម័នទាបមានការកើនឡើង (PMF-M 8,0 and related indicator(s));<br><br>រំពឹងទុកថា ការគ្រប់គ្រងដី និងតំបន់ព្រៃដែលរួមចំណែកដល់ការកាត់បន្ថយការបំភាយឧស្ម័ន ត្រូវបានគ្រប់គ្រងឱ្យបានកាន់តែល្អប្រសើរ(PMF-M 9,0 |

| | | | | |
|---|---|---|---|---|
| | | | | and related indicator(s));<br><br>រំពឹងទុកថា សមត្ថភាពបន្សាំត្រូវបានពង្រឹងឱ្យកាន់តែប្រសើរឡើង និងកាត់បន្ថយហានិភ័យអាកាសធាតុ(PMF-A and related indicator(s));<br><br>រំពឹងទុកថាការយល់ដឹងពីគ្រោះថ្នាក់អាកាសធាតុ និងដំណើរការកាត់បន្ថយហានីភ័យ ត្រូវបានពង្រឹងឱ្យកាន់តែប្រសើរឡើង(PMF-A 8,0 and related indicator(s)); and/or<br><br>កត្តាវាយតម្លៃផ្សេងៗទៀត ដោយគិតគូរពីគោលបំណងរបស់GCF  អាទិភាព និងវិស័យអាទិភាពដែលសមស្របសម្រាប់ករណីជាក់លាក់នីមួយៗ |
| ការផ្លាស់ប្តូរជាគំរូដែលអាចកើតមាន | កម្រិតដែលសកម្មភាពស្នើឡើងអាចជម្រុញឱ្យមានលទ្ធផលលើសពីគម្រោងវិនិយោគតែមួយនេះ | សកម្មភាពអាចពង្រីកវិសាលភាព និងអនុវត្តនៅទីកន្លែងដទៃបាន ហើយវារួមចំណែកទៅនឹងមាគ៌ាអភិវឌ្ឍន៍ដែលបញ្ចេញកាបូនទាបជាសាកលដែលស្របគ្នាទៅនឹងការកំណត់ឱ្យសីតុណ្ហភាពកើនឡើងតិចជាង២ អង្សារសេសែលស្យុស។ | មានសក្តានុពលអាចពង្រីកវិសាលភាពនៃលទ្ធផលរបស់គម្រោង ដោយមិនចាំបាច់បង្កើនចំណាយ( scalability ).<br><br>មានសក្តានុពលអាចប្រើប្រាស់សមាសធាតុនៃសំណើគម្រោងនេះ នៅក្នុងសំណើគម្រោងនៃវិស័យ តំបន់ ឬប្រទេសដទៃ ( replicability)<br><br>កម្រិតនៃការរួមចំណែកទៅក្នុងមាគ៌ានៃការអភិវឌ្ឍន៍ឆ្ពោះទៅរកការបញ្ចេញកាបូនទាបសកល ដែលដើរស្របទៅនឹងការកំណត់កំណើនសីតុណ្ហភាព មិនឱ្យកើនលើស២ អង្សារសេសែលស្យុស ដោយឈរលើសក្តានុពលនៃការពង្រីកសកម្មភាព ( scalability ) និងការអនុវត្តសកម្មភាពដូចគ្នានៅទីកន្លែងដទៃ ( replicability ) រួមទាំង | ការបង្ហាញទ្រឹស្តីនៃការផ្លាស់ប្តូរដ៏រឹងមាំ និងគួរឱ្យជឿជាក់សម្រាប់ការអនុវត្តសកម្មភាពដូចគ្នានៅទីកន្លែងដទៃ និងការពង្រីកវិសាលភាព។<br><br>ឱកាសសម្រាប់ពង្រីកវិសាលភាព និងលទ្ធផលរបស់គម្រោង / កម្មវិធីដែលបានគ្រោងទុកដោយមិនចាំបាច់បង្កើនចំណាយសរុបនៃការអនុវត្ត។<br><br>ឱកាសដែលរំពឹងទុក និងផលប៉ះពាល់ត្រូវគ្នាដែលអាចកើតមាន សម្រាប់ការអនុវត្តសកម្មភាពដូចគ្នានៅទីកន្លែងដទៃ ( replication ) នៃសកម្មភាពដែលបានស្នើឡើងនៅក្នុងគម្រោង / កម្មវិធី នៅក្នុងវិស័យស្ថាប័ន ទីតាំងភូមិសាស្ត្រ ឬតំបន់ សហគមន៍ ឬប្រទេសផ្សេងៗ។<br><br>ពិពណ៌នាអំពីរបៀបដែលគម្រោង ឬកម្មវិធីរួមចំណែកនៅក្នុងមាគ៌ាភិវឌ្ឍន៍ឆ្ពោះទៅរកការបញ្ចេញកាបូនទាបសកល និងរបៀបដែលគម្រោង ឬកម្មវិធីនេះ ដើរស្របទៅនឹងការកំណត់កំណើនសីតុណ្ហភាព មិនឱ្យកើនលើស២ អង្សារសេសែលស្យុស នៅក្នុងលក្ខខណ្ឌវឌ្ឍនភាពផ្នែកបច្ចេកវិទ្យា ការកាត់បន្ថយថ្លៃបច្ចេកវិទ្យា និង នវានុវត្តន៍គំរូធុរះកិច្ច។ |

| | | | | |
|---|---|---|---|---|
| | | | ថ្លៃចំណាយលើបច្ចេកវិទ្យា | |
| | | សក្តានុពលសម្រាប់បង្កើនចំណេះដឹងនិងការសិក្សា | រំពឹងទុកថាបានចូលរួមចំណែកនៅក្នុងការបង្កើត ឬពង្រឹងចំណេះដឹង ការប្រមូលផ្តុំដំណើរការនៃការរៀនសូត្រ ឬស្ថាប័ន | ទស្សនៈវិស័យក្នុងការសម្រាប់គោលបំណងរយៈពេលវែង និងសូចនាករដែលអាចវាស់វែងបាន ដើម្បីឈានទៅរកភាពជោគជ័យ<br><br>ការកំណត់តួអង្គសំខាន់ៗ ទិសដៅលទ្ធផល និងឱកាសសម្រាប់ការបង្កើតចំណេះដឹង។<br><br>រំពឹងទុកថាមានការកែលម្អក្នុងការគ្រប់គ្រងសំណល់ដែលរួមចំណែកក្នុងការកាត់បន្ថយការបំភាយឧស្ម័ន (ឧ. ការប្រែប្រួលនៃអត្រាសំណល់ ដែលគ្រប់គ្រងដោយប្រើប្រាស់យុទ្ធសាស្ត្របញ្ចៀញកាបូនទាប និង/ឬការប្រែប្រួលនៃអត្រាសំណល់ ដែលត្រូវបានកែច្នៃ និងធ្វើជី)<br><br>កត្តាវាយតម្លៃផ្សេងៗទៀត ដោយគិតគូរពីគោលបំណងរបស់GCF អាទិភាព និងវិស័យអាទិភាពដែលសមស្របសម្រាប់ករណីជាក់លាក់នីមួយៗ |
| | | ផលប៉ះពាល់លើការបន្សាំ | រួមចំណែកបង្កើននូវការអភិវឌ្ឍន៍ធន់នឹងអាកាសធាតុដោយចីរភាព | អ្នកទទួលបានផលទាំងផ្ទាល់ និង ប្រយោល រំពឹងទុក(កាត់បន្ថយភាពងាយរងគ្រោះ ឬ បង្កើតភាពធន់)។ ចំនួននៃអ្នកទទួលបានផល ធៀបនឹងចំនួនប្រជាជនសរុប(PMF- A Core1);<br><br>កម្រិតដែលសកម្មភាពបញ្ចៀសការបំភាយឧស្ម័នខ្លាំង ថេរ និងរយៈពេលវែង;<br><br>រំពឹងថាមានការកាត់បន្ថយភាពងាយរងគ្រោះតាមរយៈការបង្កើនសមត្ថភាពបន្សាំ និងភាពធន់ សម្រាប់ប្រជាជនដែលទទួលរងផលប៉ះពាល់ ដោយសកម្មភាពស្នើឡើង ផ្តោតសំខាន់លើក្រុមងាយរងគ្រោះបំផុត ហើយគិតគូរពីបញ្ហាយេនឌ័រ<br><br>ចំនួនមនុស្សដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលទាក់ទងទៅនឹងគ្រោះមហន្តរាយធម្មជាតិ (រាប់បញ្ចូលទាំងអ្នកស្លាប់) |

| | | | | |
|---|---|---|---|---|
| | | | | ចំនួន និងប្រភេទនៃស្ថាប័នប្រើប្រាស់នូវព័ត៌មានអាកាសធាតុ ដើម្បីគាំទ្រដល់ការបង្កើតគោលនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត<br><br>រំពឹងទុកថានឹងពង្រឹងប្រព័ន្ធស្ថាប័ននិងបទប្បញ្ញត្តិសម្រាប់ការរៀបចំផែនការ និងការអភិវឌ្ឍដែលឆ្លើយតបនឹងអាកាសធាតុ(PMF-A 5.0 and related indicators(s));<br><br>រំពឹងទុកថា មានការកើនឡើងនូវ ការបង្កើត និងប្រើប្រាស់ព័ត៌មានអាកាសធាតុនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត(PMF-A 6.0 and related indicator(s)); |
| | | រួមចំណែកនៅក្នុងការបង្កើតនូវបរិយាកាសអនុគ្រោះ | នវានុវត្តន៍<br><br>និរន្តរភាពនៃសមិទ្ធិផល និងលទ្ធផល បន្ទាប់ពីសកម្មភាពបានបញ្ចប់<br><br>ការគៀរគរអ្នកពាក់ព័ន្ធសំខាន់ៗ<br><br>ការអភិវឌ្ឍ និងផ្លាស់ប្តូរទីផ្សារ | ឱកាសសម្រាប់បង្កើតដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ចំណែកទីផ្សារថ្មី ការអភិវឌ្ឍ ឬ ការទទួលយកបច្ចេកវិទ្យាថ្មី គំរូធុរកិច្ច ការផ្លាស់ប្តូរគំរូ និង/ឬ ដំណើរការ។<br><br>ការរៀបចំសម្រាប់បន្តភាពយូរអង្វែងនៃសមិទ្ធិផល និងសកម្មភាពសំខាន់ៗដែលពាក់ព័ន្ធ របស់គម្រោង / កម្មវិធី។<br><br>រំពឹងទុកថានឹងមានសក្តានុពលដើម្បីគៀរគរអ្នកពាក់ព័ន្ធក្នុងវិស័យសាធារណៈ ឯកជន និងអ្នកពាក់ព័ន្ធដ៏ទៃទៀត នៅក្នុងកម្រិតមូលដ្ឋាន និង/ឬកម្រិតជាតិ ដែលមានគំនិតដើម្បីពង្រឹងភាពជោគជ័យក្នុងរយៈពេលវែងរបស់គម្រោង/កម្មវិធីដែលបានដាក់ស្នើ។<br><br>មានវិសាលភាពរហូតដល់ការបង្កើតទីផ្សារថ្មី និងសកម្មភាពធុរៈកិច្ចរបស់គម្រោង/កម្មវិធីនៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ<br><br>កម្រិតនៃការផ្លាស់ប្តូរការលើកទឹកចិត្ត ឱ្យមានការចូលរួមក្នុងទីផ្សារ ដោយកាត់បន្ថយថ្លៃដើម និងហានិភ័យ ព្រមទាំងលុបបំបាត់ឧបសគ្គនានានៅក្នុងដំណោះស្រាយបញ្ចេញកាបូនទាប។ |

| | | | | |
|---|---|---|---|---|
| | | ការចូលរួមចំណែកក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនិងគោលនយោបាយ។ | សក្តានុពលសម្រាប់ពង្រឹងក្របខណ្ឌគតិយុត្តិនិងគោលនយោបាយដើម្បីជំរុញការវិនិយោគលើបច្ចេកវិទ្យា និងសកម្មភាពបំភាយឧស្ម័នទាប ជំរុញការអភិវឌ្ឍគោលនយោបាយបំភាយឧស្ម័នទាបផ្សេងៗទៀត និង / ឬកែលម្អការធ្វើផែនការ និងការអភិវឌ្ឍដែលការឆ្លើយតបទៅនឹងអាកាសធាតុ។ | រំពឹងថាមានការផ្លាស់ប្តូរក្របខ័ណ្ឌបទប្បញ្ញត្តិឬច្បាប់ក្នុងកម្រិតជាតិ/មូលដ្ឋាន ដើម្បីដោះស្រាយការវិនិយោគក្នុងបច្ចេកវិទ្យាបំភាយឧស្ម័នទាប និងសកម្មភាពជាប្រព័ន្ធ ការអភិវឌ្ឍគោលនយោបាយបំភាយឧស្ម័នទាប និងការធ្វើឱ្យប្រសើរឡើងនូវផែនការ និងការអភិវឌ្ឍការបំភាយឧស្ម័នទាប។<br><br>កម្រិតនៃការផ្លាស់ប្តូរការលើកទឹកចិត្ត ឬជំរុញការបញ្ជ្រាបសកម្មភាពនៃការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងក្របខ័ណ្ឌបទប្បញ្ញត្តិ ព្រមទាំងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន រួមទាំងការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យឯកជនផងដែរ។ |
| | | ការរួមចំណែកជារួមទៅនឹងមាគ៌ាអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុដែលស្របតាមយុទ្ធសាស្រ្តនិងផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេស។ | មានសក្តានុពលអាចពង្រីកវិសាលភាពនៃលទ្ធផលរបស់គម្រោង ដោយមិនចាំបាច់បង្កើនចំណាយ(scalability).<br><br>មានសក្តានុពលអាចប្រើប្រាស់សមាសធាតុនៃសំណើគម្រោងនេះ នៅក្នុងសំណើគម្រោងនៃវិស័យ តំបន់ ឬប្រទេសដទៃ (replicability) | ឱកាសសម្រាប់ពង្រីកវិសាលភាព និងលទ្ធផលរបស់គម្រោង / កម្មវិធីដែលបានគ្រោងទុកដោយមិនចាំបាច់បង្កើនចំណាយសរុបនៃការអនុវត្ត។<br><br>ឱកាសដែលរំពឹងទុក និងផលប៉ះពាល់ត្រូវគ្នាដែលអាចកើតមាន សម្រាប់ការអនុវត្តសកម្មភាពដូចគ្នានៅទីកន្លែងដទៃ (replication) នៃសកម្មភាពដែលបានស្នើឡើងនៅក្នុងគម្រោង / កម្មវិធី នៅក្នុងវិស័យស្ថាប័ន ទីតាំងភូមិសាស្រ្ត ឬតំបន់ សហគមន៍ ឬប្រទេសផ្សេងៗ។ |
| សក្តានុពលអភិវឌ្ឍន៍ប្រកបដោយចីរភាព | អត្ថប្រយោជន៍និងអាទិភាពកាន់តែទូលំទូលាយ | ផលប្រយោជន៍រួមសម្រាប់បរិស្ថាន | រំពឹងថាមានផលវិជ្ជមានដល់បរិស្ថាន និងវិស័យអាទិភាពGCF ផ្សេងទៀត និង / ឬស្របតាមអាទិភាពដែលបានកំណត់នៅថ្នាក់ជាតិថ្នាក់មូលដ្ឋាន ឬតាមវិស័យ | រំពឹងថាមានផលវិជ្ជមានដល់តម្លៃបរិស្ថានដែលមិនបានប៉ះប៉ូវ (externalities) តាមរយៈការអនុវត្តសំណើគម្រោង ដូចជា គុណភាពខ្យល់ ការអភិរក្សជីវៈចម្រុះ -ល-ជាដើម។ |

| | | | | |
|---|---|---|---|---|
| | | ផល ប្រយោជន៍រួមសម្រាប់សង្គម | រំពឹងថាមានផលវិជ្ជមានផ្នែកសង្គម និងសុខភាព និងវិស័យអាទិភាពGCF ផ្សេងទៀត និង / ឬស្រប តាមអាទិភាពដែលបាន កំណត់នៅថ្នាក់ជាតិថ្នាក់ មូលដ្ឋាន ឬតាមវិស័យ | រំពឹងថាមានការកែលម្អ សម្រាប់ស្ត្រី និងបុរសដែលពាក់ព័ន្ធនៅក្នុងវិស័យដូចជាសុខភាព និងសុវត្ថិភាពក្រុមងាយរងគ្រោះទទួលបានថាមពលដែលមានការបំភាយឧស្ម័នទាប ទទួលបានការអប់រំ ការកែលម្អបទបញ្ញត្តិនិង / ឬការអភិរក្សវប្បធម៌។ អត្ថប្រយោជន៍រួមទាំងនេះក៏អាចទាញយកពីយន្តការដែលត្រូវបានប្រើក្នុងការអនុវត្តសំណើ និងការផ្លាស់ប្តូរសង្គម និងនយោបាយដែលចាំបាច់ត្រូវអនុវត្ត ដូចជាការបញ្ជាក់អំពីសិទ្ធិកាន់កាប់ដីធ្លី និងពង្រឹងការចូលរួមក្នុងការសម្រេចចិត្ត។ |
| | | ផល ប្រយោជន៍រួមសម្រាប់សេដ្ឋកិច្ច | រំពឹងថាមានផលវិជ្ជមានដល់សេដ្ឋកិច្ច និងវិស័យអាទិភាពGCF ផ្សេងទៀត និង / ឬស្របតាមអាទិភាពដែលបានកំណត់នៅថ្នាក់ជាតិថ្នាក់មូលដ្ឋាន ឬតាមវិស័យ | រំពឹងថាធ្វើឱ្យកាន់តែល្អប្រសើរនៅក្នុងវិស័យនានាដូចជាការពង្រីក និងពង្រឹងទីផ្សារការងារ ការបង្កើតការងារសំរាប់ស្ត្រី និងបុរស (ដោយផ្ទាល់ និងដោយប្រយោលនៅក្នុងវិស័យបច្ចេកវិទ្យា គ្រប់គ្រង និងហិរញ្ញវត្ថុ) ការកើនឡើងនៃការចូលរួមពីឧស្សាហកម្មក្នុងស្រុក។ បង្កើនកិច្ចសហការរវាងឧស្សាហកម្ម និងគ្រឹះស្ថានអប់រំ កំណើនមូលនិធិឯកជន ចូលរួមចំណែកដល់ការបង្កើនផលិតភាព និងសមត្ថភាពប្រកួតប្រជែង។ ធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពក្នុងការរកប្រាក់ចំណូលតាមវិស័យ រួមចំណែកដល់ការកើនឡើងនៃសន្តិសុខថាមពល។ ការផ្លាស់ប្តូរការផ្គត់ផ្គង់ទឹក និងផលិតភាពកសិកម្មនៅក្នុងតំបន់គោលដៅ-ល-។ |
| | | ការអភិវឌ្ឍគិតគូរពីយេនឌ័រ | សក្តានុពលសម្រាប់កាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និង / ឬការចូលរួមដោយស្មើគ្នាពីក្រុមយេនឌ័រក្នុងការរួមចំណែកដល់លទ្ធផលរំពឹងទុក | ការពន្យល់ពីរបៀបដែលសកម្មភាពរបស់គម្រោងនឹងដោះស្រាយសេចក្តីត្រូវការរបស់ស្ត្រី និងបុរសដើម្បីកែតម្រូវវិសមភាពទូទៅនៅក្នុងភាពងាយរងគ្រោះ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ។ |
| តម្រូវការរបស់អ្នកទទួល | ភាពងាយរងគ្រោះនិងតម្រូវការហិរញ្ញប្បទានរបស់ប្រទេសនិងប្រជាជនដែលជាអ្នកទទួលបាន | ភាពងាយរងគ្រោះនៃប្រទេស | កម្រិតនៃការប្រឈមរបស់ប្រជាជន និង / ឬទ្រព្យសម្បត្តិសង្គមនិងសេដ្ឋកិច្ចឬ ដើមទុនទៅនឹងហានិភ័យដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ | កម្រិតនៃការប្រឈមនឹងហានិភ័យអាកាសធាតុ និងកម្រិតនៃភាពងាយរងគ្រោះ (ឧទាហរណ៍ ប្រទេសងាយរងគ្រោះ រួមទាំងប្រទេសអភិវឌ្ឍន៍តិចតួច រដ្ឋកោះតូចៗកំពុងអភិវឌ្ឍន៍នៃ និងរដ្ឋនៅក្នុងតំបន់អាហ្វ្រិក) |
| | | ក្រុមងាយរងគ្រោះនិង | ភាពងាយរងគ្រោះខ្ពស់នៃក្រុមអ្នកទទួលផល។ | គម្រោង / កម្មវិធីដែលបានដាក់ស្នើគាំទ្រដល់ក្រុមដែលត្រូវបានកំណត់ថាងាយរងគ្រោះ នៅក្នុងយុទ្ធ |

| | | | | |
|---|---|---|---|---|
| | ផល ប្រយោជន៍ | ទិដ្ឋភាពយេនឌ័រ | | សាស្ត្រអាកាសធាតុជាតិ ឬយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដែលមានការបែងចែកទៅតាមភេទ ។ |
| | | កម្រិតអភិវឌ្ឍន៍ សេដ្ឋកិច្ច និងសង្គម របស់ ប្រទេសនិង ប្រជាជន ដែលរងផលប៉ះពាល់ | ក្រុមងាយរងគ្រោះជាក់លាក់ (ជនជាតិភាគតិច ជនពិការ ចាស់ជរា កុមារ ស្ត្រីមេគ្រួសារ ជនជាតិដើម-ល-។ ) ត្រូវបាន យកមកដោះស្រាយ | កម្រិតនៃការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រជាជនគោលដៅ បើប្រៀបធៀបនឹងមធ្យមភាគនៃ ប្រទេស |
| | | អវត្តមាននៃ ជម្រើស ហិរញ្ញប្បទានដទៃ | ឱកាសសម្រាប់ជំនះ ឧបសគ្គជាក់លាក់ចំពោះ ហិរញ្ញប្បទាន | ការពន្យល់អំពីឧបសគ្គដែលមានស្រាប់ដែលរារាំង មិនឱ្យមានជម្រើសហិរញ្ញវត្ថុផ្សេងទៀត |
| | | តម្រូវការ សម្រាប់ ពង្រឹងស្ថាប័ន និង សមត្ថភាព អនុវត្ត | ឱកាសដើម្បីដោះស្រាយ បញ្ហាកង្វះសមត្ថភាពស្ថាប័ន និងសមត្ថភាពអនុវត្ត នៅក្នុងស្ថាប័នសំខាន់ៗ ឬស្ថាប័នពាក់ព័ន្ធក្នុងបរិបទនៃការអនុវត្តសំណើគម្រោង។ | ការពិពណ៌នាអំពីផែនការជាក់លាក់សម្រាប់វិធីដែល សមត្ថភាព ក្នុងការរៀបចំស្ថាប័ន និងអនុវត្ត ត្រូវបាន ពង្រឹងនៅក្នុងស្ថាប័នសំខាន់ៗ ឬស្ថាប័នពាក់ព័ន្ធ |
| ភាពជា ម្ចាស់ របស់ ប្រទេស | មានភាពជា ម្ចាស់ ប្រទេស និងសមត្ថ ភាពក្នុងការ អនុវត្ត កម្មវិធី/ គម្រោង ដែលទទួល បានមូលនិ | អត្ថិភាពនៃ យុទ្ធសាស្ត្រ អាកាស ធាតុជាតិ | ប្រទេសមានយុទ្ធសាស្ត្រ ឬផែនការអាកាសធាតុ ជាតិ ដែលថ្មី និងមាន ប្រសិទ្ធិភាព ដូចជា សកម្មភាពជាតិកាត់ បន្ថយសមស្រប (NAMA) ផែនការបន្សាំ ជាតិ (NAP) ឬ ផែនការ/ យុទ្ធសាស្ត្រដែលមាន តម្លៃស្មើ | សំណើគម្រោងដោះស្រាយអាទិភាពអាកាសធាតុ របស់ប្រទេសដែលមានស្រាប់ ផែនការជាតិ ផែនការថ្នាក់មូលដ្ឋាន ឬតាមវិស័យហើយទាក់ទាញ ការគាំទ្រផ្នែកនយោបាយកម្រិតខ្ពស់ប្រកបដោយ និរន្តរភាពនៅក្នុងប្រទេសកំពុងអនុវត្ត។ |

| | | | | |
|---|---|---|---|---|
| | ធិ (គោលនយោបាយ យុទ្ធសាស្ត្រ អាកាសធាតុ និងស្ថាប័ន) | ពាក់ព័ន្ធជាមួយនឹងគោលនយោបាយដែលមានស្រាប់ | សំណើនេះមិនត្រូវបានជំទាស់ដោយស្ថាប័នជាតិទទួលបន្ទុក (NDA) ឬជនបង្គោល។<br><br>គោលបំណងគឺស្របតាមអាទិភាពនៅក្នុងយុទ្ធសាស្ត្រអាកាសធាតុជាតិរបស់ប្រទេស។ | សំណើគម្រោងទទួលបានការគាំទ្រ ពីស្ថាប័នជាតិទទួលបន្ទុក ឬជនបង្គោលដោយអនុលោមតាមនីតិវិធីគាំទ្ររបស់មូលនិធិ<br><br>សំណើគម្រោង បង្ហាញពីភាពជាប់ទាក់ទង និងស្របគ្នាជាមួយវិស័យអាទិភាពមួយ ឬច្រើនដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រអាកាសធាតុជាតិរបស់ប្រទេស រួមទាំង NAMAs ឬ ផែនការបន្សាំជាតិដែលសមស្រប និងអាចអនុវត្តបាន។<br><br>កម្រិតសកម្មភាពដែលត្រូវបានគាំទ្រដោយគោលនយោបាយ និងក្របខ័ណ្ឌស្ថាប័នដែលអាចធ្វើទៅបានរបស់ប្រទេស ឬរួមបញ្ចូលទាំងការផ្លាស់ប្តូរគោលនយោបាយ ឬស្ថាប័ន។<br><br>អ្នកឧបត្ថម្ភគម្រោង / កម្មវិធីត្រូវបានកំណត់ថាជាអ្នកដឹកនាំដែលគួរអោយទុកចិត្ត។ |
| | | សមត្ថភាពរបស់ស្ថាប័នទទួលបានសេចក្តីទុកចិត្ត ឬអង្គភាពប្រតិបត្តិ | បទពិសោធន៍ និងបទពិសោធន៍របស់ស្ថាប័នទទួលបានសេចក្តីទុកចិត្ត ឬ អង្គភាពប្រតិបត្តិ ជាធាតុផ្សំសំខាន់ៗនៃសកម្មភាពដែលបានស្នើសុំ | ម្ចាស់សំណើគម្រោងបង្ហាញបទពិសោធន៍ជាក់លាក់ និងជំនាញពាក់ព័ន្ធក្នុងកាលៈទេសៈស្រដៀងគ្នា ឬពាក់ព័ន្ធដូចដែលបានពិពណ៌នានៅក្នុងគម្រោង / កម្មវិធីដែលបានដាក់ស្នើ (ឧ. វិស័យ ប្រភេទនៃអន្តរាគមន៍ បច្ចេកវិទ្យា-ល-។ ) |
| | | ការចូលរួមជាមួយអង្គការសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធដទៃទៀត | ការពិគ្រោះយោបល់និងការចូលរួមរបស់ភាគីពាក់ព័ន្ធ | សំណើត្រូវបានបង្កើតឡើងដោយពិគ្រោះយោបល់ជាមួយក្រុមសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀតដោយយកចិត្តទុកដាក់ជាពិសេសចំពោះសមភាពយេនឌ័រ និងផ្តល់នូវយន្តការជាក់លាក់មួយ សម្រាប់ការចូលរួមនាពេលអនាគតរបស់ពួកគេ ស្របតាមគោលការណ៍សុវត្ថិភាពបរិស្ថាន និងសង្គម (ESS) របស់មូលនិធិ និងគោលការណ៍ណែនាំពិគ្រោះយោបល់របស់ភាគីពាក់ព័ន្ធ។ សំណើនេះដាក់ការទទួលខុសត្រូវក្នុងការសម្រេចចិត្តជាមួយស្ថាប័ននានានៅក្នុងប្រទេស និងប្រើប្រាស់ប្រព័ន្ធជាតិដើម្បីធានានូវគណនេយ្យភាព។ |

| | | | | |
|---|---|---|---|---|
| ប្រសិទ្ធិផល និងប្រសិទ្ធភាព | ភាពអាចជោគជ័យខាងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់កម្មវិធី/គម្រោង | ប្រសិទ្ធភាពនិងប្រសិទ្ធផលចំពោះចំណាយទាក់ទងនឹងទិដ្ឋភាពហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ។ | ភាពគ្រប់គ្រាន់ផ្នែកហិរញ្ញវត្ថុ និងភាពសមស្របនៃសម្បទាន។<br><br>ប្រសិទ្ធិភាពចំណាយ (សម្រាប់សកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ) | ការបង្ហាញថារចនាសម្ព័ន្ធហិរញ្ញវត្ថុដែលបានស្នើ (ចំនួនថវិកា ឧបករណ៍ហិរញ្ញវត្ថុ និងលក្ខន្តិកៈ) គឺគ្រប់គ្រាន់ និងសមហេតុផលដើម្បីសម្រេចគោលបំណងរបស់សំណើ រួមទាំងការដោះស្រាយភាពទាល់ច្រក និង / ឬឧបសគ្គនានា ដែលមានស្រាប់។<br><br>តម្លៃប៉ាន់ស្មានសម្រាប់កាបូនឌីអុកស៊ីតសមមូលមួយតោន (ចំណាយវិនិយោគសរុប / ការកាត់បន្ថយការបំភាយតាមអាយុកាលដែលរំពឹងទុក)(PMF-M Core 2)<br><br>អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងអត្ថប្រយោជន៍រួមដែលពាក់ព័ន្ធទៅនឹងចំណាយគម្រោង។ |
| | | ចំនួនទឹកប្រាក់នៃសហហិរញ្ញប្បទាន | សក្តានុពលក្នុងការជំរុញ និង / ឬគ្រប់គ្រងការវិនិយោគ (សម្រាប់សកម្មភាពកាត់បន្ថយការប្រែប្រួលអាកាសធាតុ) | បរិមាណហិរញ្ញវត្ថុដែលរំពឹងទុកនឹងត្រូវបានប្រើប្រាស់ដោយគម្រោង / កម្មវិធីដែលបានស្នើ ហើយជាលទ្ធផលនៃការផ្តល់ហិរញ្ញប្បទានរបស់មូលនិធិដែលបែងចែកដោយប្រភពសាធារណៈ និងឯកជន (PMF-M ស្នូល ៣)<br><br>អត្រាសហហិរញ្ញប្បទាន(ចំនួនសរុបនៃសហហិរញ្ញប្បទាន ចែកនឹងការវិនិយោគរបស់GCFក្នុងគម្រោង / កម្មវិធី)<br><br>មានសក្តានុពលក្នុងការជំរុញការវិនិយោគពីវិស័យឯកជន និងវិស័យសាធារណៈ ដែលត្រូវបានវាយតម្លៃនៅក្នុងបរិបទនៃការអនុវត្ត លើការអនុវត្តល្អបំផុតក្នុងឧស្សាហកម្ម។<br><br>រំពឹងទុកថា ការវិនិយោគលើការបំភាយឧស្ម័នទាបដោយប្រយោល/ក្នុងរយៈពេលវែង ត្រូវបានគៀរគរដែលជាលទ្ធផលនៃការអនុវត្តសកម្មភាព។ |
| | | លទ្ធភាពជោគជ័យខាងផ្នែកហិរញ្ញវត្ថុរបស់កម្មវិធី / គម្រោង និងសូចនាករហិរញ្ញវត្ថុផ្សេងៗទៀត | អត្រាចំណេញសេដ្ឋកិច្ច និងហិរញ្ញវត្ថុរំពឹងទុក<br><br>លទ្ធភាពជោគជ័យខាងផ្នែកហិរញ្ញវត្ថុក្នុងរយៈពេលវែង។ | អត្រាចំណេញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមាននិងដោយគ្មានការគាំទ្រពីមូលនិធិ (អត្រាចំណេញផ្សេងៗទៀត)<br><br>ការពិពណ៌នាអំពីលទ្ធភាពជោគជ័យក្នុងរយៈពេលវែង (បន្ទាប់ពីអន្តរាគមន៍របស់មូលនិធិបានបញ្ចប់) |

| | | | | |
|---|---|---|---|---|
| | | ការអនុវត្តល្អបំផុតរបស់ឧស្សាហកម្ម | ការប្រើប្រាស់ការអនុវត្តល្អៗ និង កម្រិតនៃនវានុវត្តន៍ | ការពន្យល់អំពីវិធីដែលបច្ចេកវិទ្យា និង / ឬការអនុវត្តល្អបំផុតដែលអាចមាន ដូចជារបស់ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានជាដើម ត្រូវបានពិចារណា និងអនុវត្ត។<br><br>ប្រសិនបើអាចអនុវត្តបាន សំណើនេះគួរបញ្ជាក់ពីការច្នៃប្រឌិត ឬការកែប្រែ / ការកែសម្រួលដែលធ្វើឡើងដោយផ្អែកលើការអនុវត្តល្អបំផុតក្នុងឧស្សាហកម្ម។ |

## ឧបសម្ព័ន្ធទី ៥៖ សុវត្ថិភាពបរិស្ថាន និងសង្គមរបស់មូលនិធិអាកាសធាតុបៃតង និងគម្រោងការយេនឌ័រ

### សុវត្ថិភាពបរិស្ថាន និងសង្គមបណ្តោះអាសន្នរបស់មូលនិធិអាកាសធាតុបៃតង (ESS)

មូលនិធិអាកាសធាតុនឹងអនុវត្តតាមបទដ្ឋាននៃការបំពេញមុខងារបរិស្ថាន និងសង្គម របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាបណ្តោះអាសន្ន ។

IEs និងអន្តរការីដែលទទួលបានសេចក្តីទុកចិត្តពីមូលនិធិ ចាំបាច់ត្រូវមានសមត្ថភាព និងប្រព័ន្ធសម្រាប់ពិនិត្យសំណើថវិកា ដើម្បីកំណត់ហានិភ័យ ឬហេតុប៉ះពាល់ដែលអាចមានចំពោះបរិស្ថាន និងសង្គម និងដើម្បីកំណត់ថាតើមានភាពមិនស៊ីចង្វាក់គ្នាដែលអាចកើតមានជាមួយ ESS បណ្តោះអាសន្នរបស់មូលនិធិ ដែលមិនអាចជម្នះបាន និង / ឬមិនអាចគ្រប់គ្រងក្នុងរយៈពេលមួយសមស្របដែលឬយ៉ាងណា។

IEs និងអន្តរការីដែលទទួលបានសេចក្តីទុកចិត្តពីមូលនិធិ ត្រូវការបង្ហាញសមត្ថភាពរបស់ពួកគេដើម្បីវាយតម្លៃ និងគ្រប់គ្រងហានិភ័យ និងហេតុប៉ះពាល់ចំពោះបរិស្ថាន និងសង្គម។ ស្ថាប័នដាក់ពាក្យត្រូវមានសមត្ថភាពដើម្បីអភិវឌ្ឍឡើងនូវប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដើម្បីអនុវត្តបទដ្ឋាននៃការអនុវត្តជាប្រចាំ ដូចបានរៀបរាប់លម្អិតនៅក្នុងតារាងខាងក្រោម។ ESMS គួរតែមានបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោមៈ

- គោលនយោបាយ
- ដំណើរការដើម្បីកំណត់អត្តសញ្ញាណហានិភ័យ និងហេតុប៉ះពាល់ស្របតាមបទដ្ឋាននៃការបំពេញមុខងារ
- កម្មវិធីគ្រប់គ្រងវិធានការកាត់បន្ថយ និងសកម្មភាពដែលបណ្តាលមកពីហានិភ័យ និងហេតុប៉ះពាល់ទាំងនោះ។ កម្មវិធីនេះគួរតែរួមបញ្ចូលទាំងដំណើរការកំណត់អត្តសញ្ញាណ ស្របតាមបទដ្ឋាននៃការបំពេញមុខងារ
- សមត្ថភាពរៀបចំស្ថាប័ន និងសមត្ថភាពប្រកួតប្រជែងដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទដ្ឋាននៃការបំពេញមុខងារ
- កម្មវិធីតាមដាន និងត្រួតពិនិត្យ ដើម្បីធានាបាននូវការបញ្ចប់សកម្មភាពកាត់បន្ថយ។ កម្មវិធីនេះគួរតែជួយសម្របសម្រួលដល់ការរៀនសូត្រ និងរួមបញ្ចូលការរាយការណ៍អំពីប្រសិទ្ធភាពរបស់ESMS
- បណ្តាញព័ត៌មានខាងក្រៅដែលជួយសម្របសម្រួលដល់ការទទួល និងការឆ្លើយតបចំពោះសំណួរពីមជ្ឈដ្ឋានខាងក្រៅ។

សំណើថវិកាគួរតែស្របគ្នានឹងប្រភេទណាមួយក្នុងចំណោមប្រភេទដូចខាងក្រោម៖

- ប្រភេទក៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់ឬហានិភ័យអវិជ្ជមានខ្លាំងដល់បរិស្ថាន និង ឬ/ /សង្គម និងហេតុប៉ះពាល់ដែលចម្រុះ ដែលមិនអាចកែប្រែបាន ឬមិនធ្លាប់មានពីមុន
- ប្រភេទខ៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់ឬហានិភ័យមធ្យមដល់បរិស្ថាន និង / ឬ សង្គម និងឬ/ហេតុប៉ះពាល់ដែលមានតិចតួច ជាទូទៅស្ថិតនៅក្នុងទីតាំងជាក់លាក់ ដែលអាចស្តារឡើងវិញបានភាគច្រើន និងងាយស្រួលដោះស្រាយតាមរយៈវិធានការកាត់បន្ថយ

- ប្រភេទគ ៖ សកម្មភាពដែលអាចមានហេតុប៉ះពាល់អវិជ្ជមានតិចតួច ឬគ្មានហេតុប៉ះពាល់និង ឬ/ហានិភ័យដល់បរិស្ថាននិងសង្គម

| សុវត្ថិភាពបរិស្ថាន និងសង្គម |
|---|
| **PS1: ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និងហេតុប៉ះពាល់បរិស្ថាននិងសង្គម**<br>(ក) កំណត់អត្តសញ្ញាណហានិភ័យ និងហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសំណើថវិកា<br>(ខ) អនុវត្តតាមឋានានុក្រមនៃការកាត់បន្ថយ៖ គ្រោងទុកជាមុន បញ្ចៀស កាត់បន្ថយ ទូទាត់សង និងតុល្យភាព<br>(គ) ធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត តាមរយៈប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម និង<br>(ឃ) ការចូលរួមជាមួយសហគមន៍ដែលរងផលប៉ះពាល់ ឬអ្នកពាក់ព័ន្ធដទៃទៀតក្នុងកំឡុងពេលនៃវដ្តរបស់ការស្នើថវិកា។ នេះរាប់បញ្ចូលទាំងការទំនាក់ទំនង និងយន្តការបណ្តឹងសារទុក្ខ។ |
| **PS2: កំលាំងពលកម្ម និងលក្ខខណ្ឌការងារ**<br>(ក) ការប្រព្រឹត្តដោយយុត្តិធម៌ ការមិនរើសអើង និងឱកាសស្មើគ្នា<br>(ខ) មានទំនាក់ទំនងល្អក្នុងការគ្រប់គ្រងកម្មករ<br>(គ) អនុលោមតាមច្បាប់ស្តីពីការងារជាតិ<br>(ឃ) ការពារកម្មករជាពិសេសអ្នកដែលស្ថិតក្នុងប្រភេទងាយរងគ្រោះ<br>(ង) លើកកម្ពស់សុវត្ថិភាព និងសុខភាព ព្រមទាំង<br>(ច) បញ្ចៀសការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ ឬពលកម្មកុមារ។ |
| PS3: **ប្រសិទ្ធភាពធនធាន និងការការពារការបំពុល**<br>(ក) ដើម្បីបញ្ចៀស ឬកាត់បន្ថយការបំពុលបរិស្ថានដែលទាក់ទងនឹងគម្រោង<br>(ខ) ការប្រើប្រាស់ធនធានឱ្យកាន់តែមាននិរន្តរភាព រួមទាំងថាមពល និងទឹក ព្រមទាំង<br>(គ) កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលទាក់ទងនឹងគម្រោង។ |
| **PS4: សុខភាពសហគមន៍ សុវត្ថិភាព និងសន្តិសុខ**<br>(ក) ដើម្បីរៀបចំគ្រោងទុកជាមុន និងបញ្ចៀសហេតុប៉ះពាល់អវិជ្ជមានដល់សុខភាព និងសុវត្ថិភាពរបស់សហគមន៍ដែលរងផលប៉ះពាល់ និង<br>(ខ) ដើម្បីការពារសុវត្ថិភាពបុគ្គល និងទ្រព្យសម្បត្តិស្របតាមគោលការណ៍សិទ្ធិមនុស្សដែលពាក់ព័ន្ធ។ |
| **PS5: ការទទួលបានដី និងការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត**<br>(ក) បញ្ចៀស / កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានខាងផ្នែកសង្គម និងសេដ្ឋកិច្ចពីការទទួលបានដី ឬការរឹតត្បិតលើការប្រើប្រាស់ដីធ្លី<br>(១) បញ្ចៀស / កាត់បន្ថយការផ្លាស់ទីលំនៅ<br>(២) ផ្តល់ជម្រើសផ្សេងនៃការរចនាគម្រោង<br>(៣) បញ្ចៀសការបណ្តេញចេញដោយបង្ខំ<br>(ខ) កែលម្អ ឬស្តារជីវភាព និងបទដ្ឋាននៃការរស់នៅ<br>(គ) ធ្វើឱ្យប្រសើរឡើងនូវលក្ខខ័ណ្ឌនៃការរស់នៅក្នុងចំណោមអ្នកដែលផ្លាស់ទីលំនៅដោយផ្តល់នូវ៖ |

| |
|---|
| (១) លំនៅដ្ឋានសមរម្យ និង<br>(២) សុវត្ថិភាពនៃសិទ្ធិកាន់កាប់។ |
| **PS6: ការអភិរក្សជីវៈចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយនិរន្តរភាព**<br>(ក) ការការពារ និងអភិរក្សជីវចម្រុះ<br>(ខ) ការថែរក្សាអត្ថប្រយោជន៍ពីសេវាកម្មអេកូឡូស៊ី<br>(គ) លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព និង<br>(ឃ) ការធ្វើសមាហរណកម្មតម្រូវការអភិរក្ស និងអាទិភាពក្នុងការអភិវឌ្ឍន៍។ |
| **PS7: ជនជាតិដើម**<br>(ក) ធានានូវការគោរពយ៉ាងពេញលេញចំពោះជនជាតិដើមភាគតិច<br>(១) សិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ បំណងប្រាថ្នា<br>(២) ជីវភាពរស់នៅ<br>(ខ) ជៀសវាង / កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន<br>(គ) អត្ថប្រយោជន៍ និងឱកាសអភិវឌ្ឍន៍សមស្របតាមវប្បធម៌ និងប្រកបដោយចីរភាព<br>(ឃ) ការយល់ព្រមដោយសេរីជាមុន និងទទួលបានព័ត៌មាននៅក្នុងកាលៈទេសៈជាក់លាក់។ |
| **PS8: បេតិកភណ្ឌវប្បធម៌**<br>(ក) ការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌ និង<br>(ខ) ការលើកកម្ពស់ការចែករំលែកអត្ថប្រយោជន៍បេតិកភណ្ឌវប្បធម៌ប្រកបដោយសមធម៌។ |

## ឧបសម្ព័ន្ធ ៦៖ គោលនយោបាយយេនឌ័ររបស់មូលនិធិអាកាសធាតុបៃតង

### ការបញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងមូលនិធិអាកាសធាតុបៃតង

គោលនយោបាយយេនឌ័ររបស់មូលនិធិអាកាសធាតុបៃតង ក្នុងចំណោមខ្សែបណ្តាយនៃមូលនិធិ និង ឧបករណ៍ហិរញ្ញវត្ថុអាកាសធាតុដទៃទៀត ឃើញថាមូលនិធិអាកាសធាតុបៃតងមានភាពលេចធ្លោទាក់ទងនឹងការបញ្ជ្រាបយេនឌ័រ ហើយដែលត្រូវបានគេចាត់ទុកថាជាស្ថាប័នដំបូងគេដែលធ្វើសមាហរណកម្មទិដ្ឋភាពយេនឌ័រចាប់តាំងពីប្រតិបត្តិការមូលនិធិដំបូង។ ការបញ្ជ្រាបយេនឌ័រគឺជាចំណុចស្នូលនៃគោលបំណង និងគោលការណ៍ណែនាំរបស់មូលនិធិអាកាសធាតុ ហើយវិធីសាស្ត្រគិតគូរពីយេនឌ័រ ត្រូវបានដាក់បញ្ចូលទៅក្នុងបរិធានគ្រប់គ្រងរបស់មូលនិធិអាកាសធាតុ និងគោលនយោបាយពាក់ព័ន្ធ ដែលត្រូវបានអនុវត្តចាប់តាំងពីចាប់ផ្តើមដំណើរការដំបូងរបស់មូលនិធិ។ ក្រុមប្រឹក្សារបស់មូលនិធិអាកាសធាតុបៃតងបានអនុវត្តគោលនយោបាយ និងផែនការសកម្មភាពយេនឌ័រ នៅខែមីនា ឆ្នាំ ២០១៥ (GCF / B.09 / 10) ។ សនិទានភាពរបស់វាត្រូវបានចាក់ឫសនៅក្នុងអាណត្តិរបស់មូលនិធិអាកាសធាតុបៃតង ដើម្បីលើកទឹកចិត្តដល់ការផ្លាស់ប្តូរជាគំរូ ឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍ ដែលបំភាយឧស្ម័នទាប និងមានភាពធន់នឹងអាកាសធាតុ។ វិធីសាស្ត្រឆ្លើយតបនឹងយេនឌ័រ គឺចាំបាច់សម្រាប់បញ្ហានេះ រួមទាំងការសម្រេចចិត្ត និងសកម្មភាពរបស់ស្ត្រី និងបុរស។ គោលនយោបាយបានចែងថា៖

i. ស្ត្រីក៏ដូចជាបុរសចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ ការផ្លាស់ប្តូរជាគំរូឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍ ដែលបំភាយឧស្ម័នទាប និងមានភាពធន់នឹងអាកាសធាតុ ដែលជាអាណត្តិរបស់មូលនិធិ ត្រូវការការសម្រេចចិត្តជាលក្ខណៈបុគ្គល និងសមូហភាពដោយស្ត្រី និងបុរសក្នុងចំនួនយ៉ាងច្រើន។ ហើយវិធីសាស្ត្រគិតគូរពីយេនឌ័រជាផ្នែកមួយនៃការផ្លាស់ប្តូរជាគំរូនេះ។

ii. ការប្រែប្រួលអាកាសធាតុជះឥទ្ធិពលខុសៗគ្នាទៅលើស្ត្រី និងបុរស។ ចំពោះការប៉ះពាល់ដល់ស្ត្រី រួមទាំងវិសមភាពយេនឌ័រដែលកំពុងតែកើតមាន ទំនងជាកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុ។

iii. វិសមភាពយេនឌ័រដែលកាន់តែធ្ងន់ធ្ងរដោយសារការប្រែប្រួលអាកាសធាតុមានទំនាក់ទំនងគ្នាទៅនឹងភាពងាយរងគ្រោះ និងហានិភ័យដូចជាការអភិវឌ្ឍន៍ដទៃទៀតដែរ។ ភាពងាយរងគ្រោះយ៉ាងធ្ងន់ធ្ងររបស់ស្ត្រីចំពោះការប្រែប្រួលអាកាសធាតុគឺបណ្តាលមកពីក្រឹត្យក្រម និងការរើសអើងភេទ ដែលបណ្តាលឱ្យមានការបែងចែកដោយលម្អៀងលើកម្លាំងពលកម្ម កម្រិតប្រាក់ចំណូលទាប និងឱកាសលើកកម្ពស់ជីវភាពទាប សិទ្ធិក្នុងការប្រើប្រាស់ និងការគ្រប់គ្រងលើដីធ្លី ព្រមទាំងទ្រព្យសម្បត្តិដែលមានផលិតភាពផ្សេងទៀតមានកម្រិតទាប សិទ្ធិស្របច្បាប់តិចជាងមុន មិនសូវមានការចល័ត ហើយមានតំណាងផ្នែកនយោបាយ និងវិជ្ជាជីវៈតិចជាង។

តាមរយៈការអនុវត្តនូវវិធីសាស្ត្រឆ្លើយតបទៅនឹងយេនឌ័ររបស់មូលនិធិអាកាសធាតុនឹងចូលរួមចំណែកប្រកបដោយប្រសិទ្ធភាពដល់សមភាពយេនឌ័រ និងការទទួលបានឱកាស ព្រមទាំង៖

- សម្រេចបាននូវសមិទ្ធិផលកាន់តែធំ និងមានប្រសិទ្ធភាពជាងមុន ព្រមទាំងលទ្ធផលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុដែលប្រកបដោយនិរន្តរភាព និងសមភាព។

- កសាងភាពធន់ និងសមត្ថភាពក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុរបស់ស្ត្រី និងបុរស ដោយសមភាព ព្រមទាំងធានាថាស្ត្រី និងបុរសនឹងចូលរួមចំណែក ហើយទទួលបានអត្ថប្រយោជន៍ ពីសកម្មភាពរបស់មូលនិធិដោយសមភាព។
- ដោះស្រាយ និងកាត់បន្ថយហានិភ័យគម្រោងដែលអាចកើតមានចំពោះស្ត្រី និងបុរសតាមរយៈសកម្មភាពបន្សាំ និងកាត់បន្ថយដែលទទួលបានមូលនិធិ និង
- ចូលរួមចំណែកកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងភាពងាយរងគ្រោះផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានដែលកាន់តែធ្ងន់ធ្ងរឡើង។

តាមរយៈគោលនយោបាយយេនឌ័ររបស់ខ្លួន មូលនិធិអាកាសធាតុប្ដេជ្ញាថា៖

- ធ្វើឱ្យមានសមភាព និងសមធម៌យេនឌ័រ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ និងរដ្ឋធម្មនុញ្ញជាតិ ព្រមទាំងកិច្ចព្រមព្រៀងសិទ្ធិមនុស្សដទៃទៀត។
- មានបរិយាប័ន្នក្នុងរាល់សកម្មភាពទាំងអស់
- ធ្វើឱ្យមានគណនេយ្យភាពចំពោះយេនឌ័រ ព្រមទាំងចំពោះលទ្ធផលនៃការប្រែប្រួលអាកាសធាតុ និងហេតុប៉ះពាល់
- ភាពជាម្ចាស់របស់ប្រទេសតាមរយៈភាពស្របគ្នាទៅនឹងគោលនយោបាយ និងអាទិភាពជាតិនិងការចូលរួមរបស់ភាគីពាក់ព័ន្ធដោយបរិយាប័ន្ន
- មានសមត្ថភាពខ្ពស់ទូទាំងក្របខ័ណ្ឌស្ថាប័នរបស់មូលនិធិ
- ការបែងចែកធនធានប្រកបដោយសមធម៌ ដូច្នេះស្ត្រី និងបុរសទទួលបានអត្ថប្រយោជន៍ពីសកម្មភាពបន្សាំ និងការកាត់បន្ថយរបស់មូលនិធិដោយសមធម៌។

ការផ្លាស់ប្តូរជាគំរូប្រកបដោយមហិច្ឆតារបស់មូលនិធិអាកាសធាតុត្រូវបានចាក់ឫសគល់នៅក្នុងការទទួលស្គាល់តួនាទីសំខាន់ និងការចូលរួមចំណែករបស់ស្ត្រីក្នុងការឆ្លើយតបទៅនឹងអាកាសធាតុ ថាជាភ្នាក់ងារនៃការផ្លាស់ប្តូរ និងជាការចែករំលែកផលប្រយោជន៍។

ដូច្នោះ វាមានសារៈសំខាន់ណាស់ដើម្បីធានាឱ្យបាននូវការឆ្លើយតបទៅនឹងយេនឌ័ររបស់ហិរញ្ញប្បទាន មូលនិធិអាកាសធាតុ លើសពីការប្រកបការងារតាមបែបធម្មតា ដែលចាត់ទុកយេនឌ័រជាបញ្ហាចម្បងនៅក្នុងបរិបទសុវត្ថិភាពសង្គម និងបរិស្ថាន។ ការបញ្ជ្រាបយេនឌ័រត្រូវតែមានគោលបំណងដើម្បីសម្រួចការផ្តួចផ្តើមគំនិត និងការវិនិយោគអាកាសធាតុឱ្យកាន់តែស៊ីជម្រៅ។

*ប្រភព:*https://www.greenclimate.fund/documents/20182/194568/Guidelines_-_GCF_Toolkit_Mainstreaming_Gender.pdf/860d1d03-877d-4c64-9a49-c0160c794ca7

# ឧបសម្ព័ន្ធ ៧៖ ឯកសារយោង និងតំណភ្ជាប់សំខាន់ៗ

សៀវភៅណែនាំពីមូលនិធិអាកាសធាតុបៃតង(ខែមេសា ឆ្នាំ២០១៨)[28]។ សេចក្ដីសម្រេច, គោលនយោបាយ និងក្របខ័ណ្ឌនានា។

*https://www.greenclimate.fund/documents/20182/296788/GCF_Handbook__Decisions__Policies_and_Frameworks__updated_April_2018_.pdf/25fd22ec-4f81-44ee-b5d1-20bceb2c9264*

http://www4.unfccc.int/ndcregistry/Pages/All.aspx

All NDCs

www4.unfccc.int

http://www4.unfccc.int/ndcregistry/PublishedDocuments/State%20of%20Cambodia%20First/State%20of%20Cambodia%20First%20NDC.pdf

STATE OF CAMBODIA NATIONALLY DETERMINED CONTRIBUTIONS/www4.unfccc.int

http://unfccc.int/national_reports/non-annex_i_natcom/submitted_natcom/items/653.php

Submitted National Communications from non-Annex I Parties/unfccc.int

http://www4.unfccc.int/nap/Pages/national-adaptation-plans.aspx

National adaptation plans - Climate change/www4.unfccc.int

## ស្ថាប័នជាតិទទួលបន្ទុក និងជនបង្គោល

http://www.gcfund.org/operations/readiness/designations.html/http://www.erd.gov.bd/

## ការផ្ដល់សេចក្ដីទុកចិត្ត

http://www.gcfund.org/operations/accreditation.html

## សំណើថវិកា

ទម្រង់ និងគំរូដែលទាក់ទងនឹងមូលនិធិអាកាសធាតុថ្មីៗ អាចរកបាននៅទីនេះ

: https://www.greenclimate.fund/library/-/docs/list/574044

ឯកសារទស្សនទាន: http://www.gcfund.org/fileadmin/00_customer/documents/Operations/4.5_Concept_Note.docx

សំណើថវិកាពេញលេញ: http://www.gcfund.org/fileadmin/00_customer/documents/Operations/GCF_Funding_Proposal_Template_BETA.docx

## គម្រោង/កម្មវិធីដែលត្រូវបានអនុម័តដោយមូលនិធិអាកាសធាតុបៃតង

https://unfccc.int/climatefinance/gcf/gcf_data

## សៀវភៅឧបទេសប្រតិបត្តិការ

http://www.gcfund.org/operations/resource-guide.html

[28]*https://www.greenclimate.fund/documents/20182/296788/GCF_Handbook__Decisions__Policies_and_Frameworks__updated_April_2018_.pdf/25fd22ec-4f81-44ee-b5d1-20bceb2c9264*

សម្រាប់ព័ត៌មានបន្ថែមទាក់ទងទៅនឹងអាជ្ញាធរជាតិទទួលបន្ទុក និងជនបង្គោល សូមទាក់ទង ទៅ:countries@gcfund.org

**សម្រាប់ការផ្តល់សេចក្តីទុកចិត្តពីមូលនិធិអាកាសធាតុបៃតង សូមទាក់ទងតាម៖**

accreditation@gcfund.org

សៀវភៅណែនាំពីមូលនិធិអាកាសធាតុបៃតង (២០១៧)។ Accessing the GCF Readiness and Preparatory Support Programme. An introduction and how-to guide.25 September 2017. https://www.greenclimate.fund/documents/20182/574766/Guidelines_-_Readiness_and_Preparatory_Support_Guidebook.pdf/9eea580f-a109-4d90-b281-c54695114772




បោះពុម្ពដោយ
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន ព្រះរាជាណាចក្រកម្ពុជា



រក្សាសិទ្ធិគ្រប់យ៉ាងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន ព្រះរាជាណាចក្រកម្ពុជា។
គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានផលិតម្តងទៀត ឬកែប្រែទោះក្នុងទម្រង់ណា ឬតាមមធ្យោបាយណាក៏ដោយ ដោយពុំមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិឡើយ។



ព័ត៌មានសម្រាប់ទំនាក់ទំនង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព/ក្រសួងបរិស្ថាន
អគារមរតកតេជោ (ផ្លូវលេខ ៥០៣) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
maohakccd.se@gmail.com | https://ncsd.moe.gov.kh